# ការឃ្លាំមើលសេរីភាពមូលដ្ឋាន នៅកម្ពុជា

## របាយការណ៍ប្រចាំឆ្នាំទី៤

ខែមេសា ឆ្នាំ២០១៩
ដល់ខែមីនា ឆ្នាំ២០២០



គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

សមាគមអាដហុក
ADHOC

SOLIDARITY CENTER
AFL-CIO

ឧបត្ថម្ភដោយ

ICNL
INTERNATIONAL CENTER
FOR NOT-FOR-PROFIT LAW

# មាតិកា


មូលន័យសង្ខេប ........................................................................................................................1

១.សេចក្តីផ្តើម........................................................................................................................9

២.ចំណុចគន្លឹះទី១៖ តើក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានស្របតាមបទដ្ឋានអន្តរជាតិដែរឬទេ?. 11

២.១ ការធ្វើវិសោធនកម្មច្បាប់ស្តីពីសហជីព ....................................................................12

២.២ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិក្នុងភាពអាសន្ន ................................................... 20

៣. ចំណុចគន្លឹះទីពីរ៖ តើក្របខ័ណ្ឌច្បាប់សម្រាប់សេរីភាពមូលដ្ឋានត្រូវបានអនុវត្ត និងពង្រឹងការអនុវត្តបានត្រឹមត្រូវដែរឬទេ?....................................................................................................... 23

៣.១ សិទ្ធិសេរីភាពមូលដ្ឋានត្រូវបានរឹតត្បិត និងរំលោភបំពានដែលជាហេតុនាំឱ្យលំហសង្គមស៊ីវិលរួមតូច23

៣.២ ការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលកម្ពុជាមកលើសិទ្ធិសេរីភាពខាងសមាគម..............................28

៣.៣ សហជីពនៅតែជួបបញ្ហាប្រឈមក្នុងដំណើរការចុះបញ្ជី ................................................... 33

៣.៤ បុគ្គលដែលត្រូវបានកំណត់ជាមុខសញ្ញាដោយសារតែពួកគេមាន ឬត្រូវបានសន្មតថាមានសម្ព័ន្ធភាពជាមួយគណបក្សសង្គ្រោះជាតិ ............................................................................................ 34

៣.៥ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិមិនទទួលបានការការពារគ្រប់គ្រាន់ ........................................ 37

៣.៦ រដ្ឋាភិបាលឃ្លាំមើលការប្រាស្រ័យទាក់ទងឯកជនដោយពុំមានការអនុញ្ញាតតាមប្រព័ន្ធតុលាការ...... 40

៣.៧ ឥទ្ធិពលនៃជំងឺកូវីដ ១៩ មកលើសេរីភាពខាងការបញ្ចេញមតិ ...........................................41

៣.៨ សេរីភាពខាងការជួបប្រជុំត្រូវបានលើកកម្ពស់ភាគច្រើនប៉ុន្តែមានការរឹតត្បិតម្តងម្កាល.................. 45

៣.៩ ១១នៃការជួបប្រជុំទាំងអស់ធ្លាប់ទទួលរងការជ្រៀតជ្រែកហួសហេតុពីអាជ្ញាធរ %........................47

៣.១០ ជាងពាក់កណ្តាលនៃការជួបប្រជុំទាំងអស់ដែលកើតឡើងគឺទាក់ទងនឹងសិទ្ធិដីធ្លី.......................49

៣.១១ ការកើនឡើងចំនួនការជួបប្រជុំដើម្បីសិទ្ធិកម្មករនិយោជិត................................................ 50

ចំណុចគន្លឹះទី៣៖ តើបុគ្គលម្នាក់ៗមានការយល់ដឹងពីសេរីភាពមូលដ្ឋាន ហើយយល់ថាខ្លួនមានសេរីភាពក្នុងការអនុវត្តសិទ្ធិទាំងនេះដែរឬទេ?.........................................................................................51

៤.១ ការយល់ដឹងរបស់សាធារណជនអំពីសេរីភាពមូលដ្ឋាននៅតែបន្តធ្លាក់ចុះ .....................................51

៤.២ កម្រិតយល់ដឹងរបស់សាធារណជនអំពីច្បាប់ជាតិដែលគ្របដណ្តប់លើសេរីភាពមូលដ្ឋាននៅតែមានកម្រិតទាប ................................................................................................................ 52

៤.៣ ពលរដ្ឋខ្មែរភាគច្រើនមិនយល់ថាមានសេរីភាពក្នុងការអនុវត្តសិទ្ធិសេរីភាពមូលដ្ឋានទេ................. 55

៤.៤ ការមានទំនុកចិត្តនៅមានកម្រិតនៅក្នុងការដោះស្រាយបញ្ហារំលោភសិទ្ធិមនុស្ស ......................... 60

៥. ចំណុចគន្លឹះទី ៤៖ តើអង្គការសង្គមស៊ីវិល និងសហជីព ត្រូវបានទទួលស្គាល់ និងអាចធ្វើការក្នុងភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា ដែរឬទេ? ....62
៥.១ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពជឿជាក់ថាពួកគេត្រូវបានរាជរដ្ឋាភិបាលទទួលស្គាល់ថាមានភាពស្របច្បាប់ ប៉ុន្តែមិនមានសមត្ថភាព ....62
៥.២ កិច្ចសហការជាផ្លូវការជាមួយរាជរដ្ឋាភិបាលកម្ពុជាកំពុងមានការថយចុះ ....63
៥.៣ ឱកាសសម្រាប់ការផ្តល់ហិរញ្ញប្បទានសាធារណៈ និងការចូលរួមក្នុងក្រុមប្រឹក្សា និងគណៈកម្មាធិការរាជរដ្ឋាភិបាលកម្ពុជាត្រូវបានយល់ថាមិនមានភាពច្បាស់លាស់បើកចំហ និងមានតម្លាភាព....64
សេចក្តីសន្និដ្ឋាន ....66
ឧបសម្ព័ន្ធទី១ ៖ វិធីសាស្ត្រ និងការប្រមូលទិន្នន័យ ....68
ឧបសម្ព័ន្ធទី ២ ៖ តារាងលទ្ធផលនៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន.... 72
ឧបសម្ព័ន្ធទី៣ ៖ ការស្ទង់មតិជាសាធារណៈនៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ៖សំណួរ និងលទ្ធផល ..107
ឧបសម្ព័ន្ធទី៤ ៖ សំណួរនិងលទ្ធផលនៃការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព.... 116

# មូលន័យសង្ខេប

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានពិនិត្យទៅលើស្ថានភាពសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ តាមរយៈការប្រើប្រាស់នូវឧបករណ៍តាមដានការឃ្លាំមើលមួយចំនួន គម្រោងបានផ្តល់នូវទិដ្ឋភាពបែបសត្យានុម័ត ថាតើសេរីភាពមូលដ្ឋានទាំងនេះមានចែងក្នុងច្បាប់យ៉ាងដូចម្តេច និងត្រូវបានការពារ និងអនុវត្តដោយរបៀបណានៅទូទាំងប្រទេស។

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន គឺជាការផ្តួចផ្តើមរួមគ្នារបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា ("អាដហុក") និងមជ្ឈមណ្ឌលសាមគ្គីភាព ដោយមានការសហការជាមួយពីមជ្ឈមណ្ឌលអន្តរជាតិដើម្បីច្បាប់ដោយមិនយកកម្រៃ ("អាយ.ស៊ី.អិន.អិល")។

របាយការណ៍នេះបានបង្ហាញពីចំណុចសំខាន់ៗដែលរកឃើញក្នុងឆ្នាំទី៤ ដែលចាប់ផ្តើមពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩ ដល់ថ្ងៃ៣១ ខែមីនា ឆ្នាំ២០២០ (ឆ្នាំទី៤)។[1] ព័ត៌មានដែលមាននៅក្នុងរបាយការណ៍នេះ ត្រូវបានចងក្រងឡើងដោយប្រើប្រាស់ទិន្នន័យ ដែលបានកត់ត្រាជាលក្ខណៈប្រព័ន្ធទៅលើប្រភពទិន្នន័យទាំងបរិមាណ និងគុណភាព (សូមមើលឧបសម្ព័ន្ធ១ វិធីសាស្ត្រ)។ នៅឆ្នាំទី៤នេះ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានវិភាគលើអត្ថបទនៃសារព័ត៌មានសរុបចំនួន ១១៩៤ និងការរាយការណ៍ពីហេតុការណ៍ចំនួន ១១៩ បានធ្វើការស្ទង់មតិសាធារណៈ (ទទួលបានអ្នកឆ្លើយតបសរុបចំនួន ៧៧៩ នាក់) បានធ្វើការស្ទង់មតិជាមួយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព (ទទួលបានអ្នកឆ្លើយតបសរុបចំនួន ១៤២ នាក់) ព្រមទាំងធ្វើការវិភាគលើក្របខ័ណ្ឌច្បាប់កម្ពុជាដែលទាក់ទិននឹងសេរីភាពមូលដ្ឋាន។

លំហក្នុងការអនុវត្តសេរីភាពមូលដ្ឋាននៅតែបន្តរងការរឹតត្បិត។ ការវិវឌ្ឍសំខាន់ៗនៅក្នុងឆ្នាំទី៤នេះរួមមាន(ក) ការបន្តបង្ក្រាបលើអ្នកមានទស្សនៈនយោបាយផ្ទុយ (ខ) បំបិតនូវការបញ្ចេញមតិដែលធ្វើឱ្យបរិយាកាសនៃការបញ្ចេញមតិនេះមានការរឹតត្បិតលើខ្លួនឯង (គ) ការអនុវត្តក្រមព្រហ្មទណ្ឌតាមទំនើងចិត្តពោលគឺបទបរិហារកេរ្តិ៍ បទរួមគំនិតក្បត់ បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ និងបទក្លែងបន្លំព័ត៌មាន និង (ឃ) ការថយចុះការយល់ដឹងរបស់សាធារណជនចំពោះសេរីភាពមូលដ្ឋាន។

[1] ឆ្នាំទី៣នៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានចាប់ផ្តើមពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៩។ ឆ្នាំទី២ ចាប់ផ្តើមពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨។ ឆ្នាំទី១ ចាប់ផ្តើមពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែ មេសា ឆ្នាំ២០១៧។ របាយការណ៍ប្រចាំឆ្នាំមុនៗមាននៅលើគេហទំព័រ៖ https://cchrcambodia.org ។

**តារាងតួលេខទី១ ៖ ចំនួនហេតុការណ៍សរុបរាប់ទាំងហេតុការណ៍នៃការរឹតត្បិត និងហេតុការណ៍នៃការរំលោភបំពាននានានៅក្នុងឆ្នាំទី៤**




នៅចន្លោះថ្ងៃទី១ ខែមេសាឆ្នាំ ២០១៩ ដល់ថ្ងៃទី ៣១ ខែមីនាឆ្នាំ២០២០ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានកត់ត្រានូវហេតុការណ៍សរុបចំនួន ៦៥៦ ដែលទាក់ទងទៅនឹងការអនុវត្តសេរីភាពមូលដ្ឋាន។ ២/៣ នៃហេតុការណ៍ទាំងអស់ដែលត្រូវបានកត់ត្រាដោយគម្រោង រួមមានការរឹតត្បិតមួយ ឬច្រើន ឬការរំលោភលើសេរីភាពមូលដ្ឋាន។[2] ក្នុងចំណោមហេតុការណ៍ចំនួន ៦៥៦ ដែលបានកត់ត្រា មានហេតុការណ៍ចំនួន ៤៤០ ពាក់ព័ន្ធនឹងការរឹតត្បិតសេរីភាពមូលដ្ឋាន ហើយ ២៤៦ ពាក់ព័ន្ធនឹងការរំលោភបំពាន។ នៅក្នុងឆ្នាំទី ៤ នេះ គម្រោងបានកត់ត្រាការរឹតត្បិតចំពោះសេរីភាពមូលដ្ឋាននៅគ្រប់ខេត្តក្រុងទាំងអស់ជាមួយនឹងការរឹតត្បិតនៅក្នុងរាជធានីភ្នំពេញ និងនៅភូមិភាគពាយព្យ។

**តារាងតួលេខទី ២៖ ផែនទីភូមិសាស្ត្រនៃហេតុការណ៍នៃការរឹតត្បិតសេរីភាពមូលដ្ឋាន**




ចំនួននៃការរឹតត្បិតដែលបានកើតឡើងនៅក្នុងរាជធានីបានថយចុះបើធៀបឆ្នាំមុនៗ (២៨៨ ឆ្នាំទី ២, ២៤៦ ឆ្នាំទី ៣ និង ១៦៥ នៅឆ្នាំទី៤)។ ចំនួននៃការរឹតត្បិតដែលកើតឡើងនៅខេត្តបន្ទាយមានជ័យដែលជាច្រកឆ្លងកាត់ព្រំដែនកម្ពុជា - ថៃកំពុងមានការកើនឡើងជាលំដាប់ក៏ដូចជាការរឹតត្បិតកំពុងកើតមាននៅក្នុងខេត្តព្រះសីហនុ ដែលមានលំហូរចូលនៃការវិនិយោគ និងការអភិវឌ្ឍន៍របស់ចិនក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ។

[2] ភាពខុសគ្នារវាងការរឹតត្បិត និងការរំលោភលើសិទ្ធិគឺថាការរឹតត្បិតអាចត្រូវបានអនុញ្ញាតដោយស្របច្បាប់ក្រោមកាលៈទេសៈជាក់លាក់ខណៈដែលការរំលោភបំពាន គឺផ្ទុយនឹងបទដ្ឋានច្បាប់អន្តរជាតិ។ ឧទាហរណ៍ដើម្បីកំណត់ថាតើការរឹតត្បិតលើការបញ្ចេញមតិបង្កើតជាការរំលោភបំពានឬអត់ ដូច្នោះគម្រោងពិនិត្យថាតើការរឹតត្បិតនោះមិនបានបំពេញតាមលក្ខខណ្ឌកំណត់ទាំង ៣ចំណុច ដែលមានចែងក្នុងមាត្រា ១៩ នៃ កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែរឬទេ។ ប្រសិនបើការរឹតត្បិតមិនបានបំពេញតាមលក្ខខណ្ឌកំណត់នេះទេ នោះវាត្រូវបានគេចាត់ទុកថាជាការរំលោភបំពាន។

**តារាងតួលេខទី ៣៖ ចំនួនហេតុការណ៍នៃការរឹតត្បិតលើសេរីភាពមូលដ្ឋាន**




គម្រោងបានកត់សម្គាល់ថា ការរឹតត្បិតហាក់ដូចជាកើតឡើងនៅពេលដែលពលរដ្ឋមួយចំនួនធំព្យាយាមអនុវត្តសេរីភាពមូលដ្ឋានរបស់ខ្លួន។ ដូចបានបង្ហាញក្នុងតារាងតួលេខទី ៣ ព្រឹត្តិការណ៍ចំនួន ៣ គឺខួប ៣ ឆ្នាំនៃការសម្លាប់លោកបណ្ឌិត កែម ឡី នៅខែកក្កដា ឆ្នាំ២០១៩ ផែនការរបស់លោក សម រង្ស៊ី នឹងវិលត្រឡប់មកប្រទេសកម្ពុជាវិញនៅខែកញ្ញា និងខែតុលាឆ្នាំ ២០១៩ និងការចាប់ផ្តើមនៃការរីករាលដាលនៃជំងឺរាតត្បាតកូវីដ១៩ នៅដើមឆ្នាំ២០២០ ជាចំណែកគួរកត់សម្គាល់ដែលបង្កឱ្យមានការកើនឡើងនៃការរឹតត្បិតចំពោះសេរីភាពមូលដ្ឋាន។ ការកើនឡើងនៅខែឧសភា ឆ្នាំ២០១៩ ឆ្លុះបញ្ចាំងពីការកោះហៅជាលក្ខណៈប្រព័ន្ធចំពោះអតីតសមាជិកគណបក្សសង្គ្រោះជាតិពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាកម្ពុជា ប៉ុន្តែហាក់មិនមានព្រឹត្តិការណ៍ច្បាស់លាស់ណាមួយអាចបញ្ជាក់ពីរបត់នេះនៅឡើយទេ។

ហេតុការណ៍ដែលបានកត់ត្រាដោយគម្រោងជារឿយៗមានការរំលោភបំពាន ឬការរឹតត្បិតចំពោះសេរីភាពមូលដ្ឋានជាច្រើន។ គម្រោងបានកត់ត្រានូវចំនួនហេតុការណ៍ទាំងការការរឹតត្បិត ឬការរំលោភបំពានសេរីភាពមូលដ្ឋានដែលបានកើតឡើង ព្រមទាំងចំនួនសរុបនៃការរឹតត្បិត និងការរំលោភបំពានលើបុគ្គលចំពោះសេរីភាពមូលដ្ឋាននីមួយៗ។

**តារាងតួលេខទី ៤៖ ចំនួនសរុបនៃការរឹតត្បិតចំពោះសេរីភាពមូលដ្ឋាននីមួយៗបើប្រៀបធៀបទៅនឹងឆ្នាំទី២ និងទី៣**[3]




[3] ចំនួនសរុបនៃការរឹតត្បិត និងការរំលោភបំពានលើសិទ្ធិនីមួយៗ រួមមានការរឹតត្បិត ឬការរំលោភបំពានជាច្រើនពីហេតុការណ៍តែមួយ ហើយដូច្នេះចំនួននេះគឺវាច្រើនជាងចំនួនហេតុការណ៍នៃការរឹតត្បិតឬការរំលោភបំពាន។

សេរីភាពខាងសមាគមគឺជាសេរីភាពដែលត្រូវបានរឹតត្បិតខ្លាំងបំផុតនៅក្នុងឆ្នាំទី ៤ បន្ទាប់ពីសេរីភាពខាងការបញ្ចេញមតិ។ ផ្ទុយទៅវិញ សេរីភាពខាងការជួបប្រជុំភាគច្រើនត្រូវបានគោរព ដោយចំនួននៃការរឹតត្បិតសេរីភាពខាងការជួបប្រជុំមានការថយចុះគួរឱ្យកត់សម្គាល់ចាប់ពីឆ្នាំទី ២ និងទី ៣ ។

ការយល់ដឹងឱ្យបានច្បាស់លាស់អំពីសេរីភាពមូលដ្ឋាន គឺចាំបាច់ណាស់ដើម្បីឱ្យបុគ្គលម្នាក់ៗអនុវត្តនូវសិទ្ធិសេរីភាពរបស់ខ្លួន។ បើគ្មានការយល់ដឹងអំពីសិទ្ធិទាំងនេះទេ នោះប្រជាពលរដ្ឋទំនងជាមិនអាចកំណត់ថាតើការរឹតត្បិតរបៀបណាដែលជាការរឹតត្បិតខុសច្បាប់ទៅលើសេរីភាពមូលដ្ឋាននោះឡើយ។ ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ គម្រោងបានមើលឃើញថាការយល់ដឹងរបស់សាធារណជនអំពីសេរីភាពមូលដ្ឋាននៅតែបន្តធ្លាក់ចុះដោយក្នុងឆ្នាំទី៤នេះបានកត់ត្រានូវកម្រិតនៃការយល់ដឹងទាបបំផុត។

**តារាងតួលេខទី ៥៖ ពលរដ្ឋបានបង្ហាញពីការយល់ដឹងពេញលេញរបស់ខ្លួនអំពីសេរីភាពនីមួយៗដោយប្រៀបធៀបទៅនឹងឆ្នាំទី ២ និងទី ៣**




សេរីភាពខាងសមាគមនៅតែជាសេរីភាពដែលត្រូវបានគេយល់ដឹងតិចតួចបំផុត ដែលឥឡូវនេះការយល់ដឹងមានត្រឹមតែមួយភាគបីនៃការយល់ដឹងបើធៀបទៅនឹងការយល់ដឹងនៅក្នុងឆ្នាំទី ២ ។ សេរីភាពនៃការបញ្ចេញមតិក៏បានបង្ហាញពីការធ្លាក់ចុះយ៉ាងខ្លាំងចាប់តាំងពីឆ្នាំទី ៣ តែនៅតែជាសេរីភាពដែលត្រូវបានគេយល់ច្រើនជាងគេបំផុត។ ការយល់ដឹងអំពីសេរីភាពខាងការជួបប្រជុំបានថយចុះចាប់តាំងពីឆ្នាំទី ២ មកត្រឹមតែ ៥ ភាគរយប៉ុណ្ណោះ ។

## សេរីភាពខាងសមាគម

នៅក្នុងឆ្នាំទី៤ នេះ គម្រោងបានកត់ត្រាករណីរឹតត្បិតចំនួន ៣៣៨ ករណី និងករណីរំលោភលើសេរីភាពខាងសមាគមចំនួន ១៨៦ ករណី។

### តារាងតួលេខទី ៦៖ ក្រុមដែលសេរីភាពខាងសមាគមរបស់ពួកគេត្រូវបានរឹតត្បិតជាញឹកញាប់ដោយរាជរដ្ឋាភិបាលកម្ពុជា




*មុខសញ្ញាទី១៖* អតីតគណបក្សជំទាស់ (គណបក្សសង្គ្រោះជាតិ)

*មុខសញ្ញាទី២៖* សង្គមស៊ីវិល

*មុខសញ្ញាទី៣៖* សហជីព

*មុខសញ្ញាទី៤៖* ក្រុមសហគមន៍ក្រៅផ្លូវការ[4]

ទិន្នន័យពីឆ្នាំទី៤ បង្ហាញថាបុគ្គលម្នាក់ៗត្រូវបានគេកំណត់មុខសញ្ញាដោយសារតែគេយល់ថាមានការពាក់ព័ន្ធជាក់ស្តែងជាមួយគណបក្សសង្គ្រោះជាតិ។ អ្នកដែលពាក់ព័ន្ធនឹងគណបក្សសង្គ្រោះជាតិ[5]បានប្រឈមនឹងការយាយីតាមផ្លូវតុលាការជាលក្ខណៈប្រព័ន្ធដោយមានករណីចោទប្រកាន់ចំនួន ១២០ ករណីចាប់ខ្លួន ១០៣ នាក់ និងករណីកោះហៅចំនួន ៩៧ ករណី ។ នៅក្នុងការស្ទង់មតិសាធារណៈមានតែ ២៨%នៃអ្នកឆ្លើយតបបានយល់ថាមានសេរីភាពក្នុងការចូលរួមក្នុងវិស័យនយោបាយ។

### តារាងតួលេខទី៧៖ បុគ្គលដែលយល់ថាមានសេរីភាពក្នុងការចូលរួមក្នុងវិស័យនយោបាយ




### តារាងតួលេខទី ៨៖ សាធារណជនបង្ហាញថាគាត់ជាជនរងគ្រោះដោយសារការចូលរួមជាមួយសង្គមស៊ីវិល[6]




***ភាពរងគ្រោះពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិល៖***

ការស្ទង់មតិសាធារណៈបានកត់សម្គាល់ពីចំនួនបុគ្គលដែលត្រូវបានរងគ្រោះដោយសារតែការចូលរួមជាមួយអង្គការសង្គមស៊ីវិលដោយ ២៥% នៃអ្នកឆ្លើយតបបានឆ្លើយតបយ៉ាងជាក់លាក់ចំពោះសំណួរនេះ។

អង្គការសង្គមស៊ីវិលបន្តរងនូវការតាមដាន និងការឃ្លាំមើលពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា ជ្រៀតជ្រែកសកម្មភាពរបស់អង្គការសង្គមស៊ីវិលដែលរំលោភលើសិទ្ធិសេរីភាពខាងសមាគម។ នៅ

---

[4] ក្រុមសហគមន៍ក្រៅផ្លូវការសំដៅលើប្រជាពលរដ្ឋដែលមានជម្លោះដីធ្លីដែលមិនមានទំនាក់ទំនងជាមួយនីតិបុគ្គល។

[5] នេះរាប់បញ្ចូលទាំងអតីតសមាជិកគណៈបក្សសង្គ្រោះជាតិ និងមន្ត្រីរបស់គេ ព្រមទាំងអ្នកដែលត្រូវបានគេចាត់ទុកថា ជាអតីតអ្នកគាំទ្រ ឬអ្នកកំពុងគាំទ្រគណៈបក្សសង្គ្រោះជាតិ។

[6] សំណួរនេះមិនត្រូវបានគេសួរនៅក្នុងការស្ទង់មតិសាធារណៈដែលបានធ្វើឡើងនៅឆ្នាំទី ១ ទេ។

ក្នុងឆ្នាំទី ៤ គម្រោងបានកត់ត្រានូវហេតុការណ៍ចំនួន ៦៣ ដែលរាជរដ្ឋាភិបាលកម្ពុជាកម្ពុជាតាមដាន ឬជ្រៀតជ្រែកសកម្មភាពសង្គមស៊ីវិលដោយបំពានលើច្បាប់អន្តរជាតិរួមមាន៖

- ១៥ ករណីដែលអាជ្ញាធរបានថតរូបអ្នកចូលរួមឬបុគ្គលិក[7]
- ១២ ករណី ដែលអាជ្ញាធរបានស្នើសុំព័ត៌មានលម្អិតរបស់អ្នកចូលរួម ឬបុគ្គលិក[8] និង
- ៣ ករណី ដែលអាជ្ញាធរបានកត់ត្រានូវព្រឹត្តការណ៍ឯកជនរបស់អង្គការសង្គមស៊ីវិល។[9]

## សេរីភាពខាងការបញ្ចេញមតិ

សេរីភាពខាងការបញ្ចេញមតិនៅតែទទួលរងការគាបសង្កត់ ដែលនេះបានបំពានលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ) ។ នៅក្នុងឆ្នាំទី ៤ គម្រោងបានចងក្រងជាឯកសារនូវការរឹតត្បិតចំនួន ២៤៥ និងការរំលោភលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិចំនួន ១០៣ ក្នុងនោះមានការកោះហៅចំនួន ១៦៦ និងការចាប់ខ្លួនចំនួន ៩៩ ចំពោះការអនុវត្តសេរីភាពខាងការបញ្ចេញមតិ។ ការបញ្ចេញទស្សនៈផ្ទុយ និងការការរិះគន់តាមអ៊ិនធឺណិតត្រូវបានរារាំងជាប្រចាំ។ ស្ទើរតែពាក់កណ្តាលនៃការរំលោភបំពានលើសេរីភាពខាងការបញ្ចេញមតិដែលបានកត់ត្រា គឺទាក់ទងទៅនឹងការបញ្ចេញមតិតាមប្រព័ន្ធអ៊ិនធឺណិត រួមមានការចាប់ខ្លួនចំនួន ៤៨ នាក់ផង។

### តារាងតួលេខទី ៩៖ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល / សហជីពដែលធ្វើការកម្រិតនូវសិទ្ធិសេរីភាពខ្លួនឯងនៅពេលនិយាយជាសាធារណៈ[10]

**ការកម្រិតសេរីភាពខ្លួនឯង៖** ៨៨% នៃអ្នកឆ្លើយតបនៅក្នុងការស្ទង់មតិអ្នកដឹកនាំសង្គមស៊ីវិល / សហជីព បានបង្ហាញថាពួកគេបានរឹតត្បិតសិទ្ធិសេរីភាពខ្លួនឯង ដែលនេះជាចំនួនច្រើនបំផុតនៃអ្នកឆ្លើយតបធៀបនឹងរបាយការណ៍ឆ្នាំមុនៗ។ នេះបង្ហាញពីការភ័យខ្លាចកាន់តែខ្លាំងឡើងនៃការអនុវត្តសេរីភាពខាងបញ្ចេញមតិក្នុងចំណោមអង្គការសង្គមស៊ីវិល។




[7] សូមមើលឧទាហរណ៍ការរាយការណ៍ពីករណីហេតុការណ៍ IRAD147 និង IRCC161

[8] សូមមើលឧទាហរណ៍ការរាយការណ៍ពីហេតុការណ៍ IRAD142 and IRCC205

[9] ការរាយការណ៍ពីហេតុការណ៍ IRCC166 IRCC153 និង IRCC184

[10] ទិន្នន័យដែលបានបង្ហាញនៅក្នុងក្រាហ្វនេះ រួមមានចំនួននៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល / សហជីព ដែលបានបង្ហាញថា (ជានិច្ចកាល) (ជាប្រចាំ) និង(ពេលខ្លះ) វាចាំបាច់ក្នុងការរឹតត្បិតនូវសិទ្ធិសេរីភាពខ្លួន នៅពេលនិយាយជាសាធារណៈ។

**តារាងតួលេខទី១០៖ សាធារណជនដែលយល់ថាមានសេរីភាពខាងការបញ្ចេញមតិនៅលើបណ្ដាញសង្គម**[11]




**ប្រព័ន្ធផ្សព្វផ្សាយសង្គម៖** មានតែ ២៩ % នៃអ្នកឆ្លើយតបនៅក្នុងការស្ទង់មតិសាធារណៈប៉ុណ្ណោះដែលបានបង្ហាញថាមានសេរីភាពក្នុងការនិយាយដោយបើកចំហនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម។ នេះជាការថយចុះយ៉ាងខ្លាំងដែលការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល/សហជីពបានកត់ត្រាថា ៨២ %នៃអ្នកឆ្លើយតបយល់ថាមិនមានសុវត្ថិភាពក្នុងការចែកចាយព័ត៌មានតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម។

នៅដើមដំបូងនៃការរាតត្បាតជំងឺកូវីត-១៩ (ត្រីមាសទី៤ នៃឆ្នាំទី៤ ពីខែមករា ដល់ខែមីនា ឆ្នាំ ២០២០) គម្រោងបានកត់សម្គាល់ឃើញថាមានការកើនឡើងជាលំដាប់នៃការរឹតត្បិតចំពោះសេរីភាពខាងការបញ្ចេញមតិ។ មានចំនួន ២៦ ករណី នៃការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិទាក់ទងនឹងជំងឺកូវីត-១៩ គិតដល់ថ្ងៃទី ៣១ ខែមីនាឆ្នាំ ២០២០។[12] ការរឹតត្បិតទាំងនេះបានធ្វើឡើងតាមទម្រង់នៃការចោទប្រកាន់ ការចាប់ខ្លួន និងការចោទប្រកាន់ពីបទផ្សព្វផ្សាយ" ព័ត៌មានក្លែងក្លាយ"[13]រួមទាំង ការរិះគន់ស្របតាមច្បាប់លើការឆ្លើយតបរបស់រាជរាជរដ្ឋាភិបាលកម្ពុជាចំពោះការរាតត្បាតនៃជំងឺនេះ និងការគំរាមរបស់រាជរដ្ឋាភិបាលកម្ពុជាប្រឆាំងនឹងការផ្សព្វផ្សាយ" ព័ត៌មានក្លែងក្លាយ" ។

## សេរីភាពខាងការជួបប្រជុំ

សេរីភាពខាងការជួបប្រជុំត្រូវបានអនុវត្តជាញឹកញាប់នៅក្នុងប្រទេសកម្ពុជា ជាពិសេសអ្នកតស៊ូមតិដើម្បីសិទ្ធិដីធ្លី និងកម្មករនិយោជិតដែលប្រើប្រាស់សេរីភាពខាងការជួបប្រជុំដើម្បីអំពាវនាវឱ្យមានការគោរពសិទ្ធិ

[11] សំណួរនេះមិនត្រូវបានគេសួរនៅក្នុងការស្ទង់មតិសាធារណៈដែលបានធ្វើឡើងនៅឆ្នាំទី ១ ទេ។

[12] សូមកត់សម្គាល់ថាការរឹតត្បិតទាំងនេះបានបន្តកើតឡើងជាបន្តបន្ទាប់ក្រោយពីពេលបញ្ចប់របាយការណ៍នេះហើយនឹងត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំបន្ទាប់របស់យើង (ឆ្នាំទី ៥)។

[13] " ព័ត៌មានក្លែងក្លាយ" គឺជាបទល្មើសព្រហ្មទណ្ឌនៅក្នុងប្រទេសកម្ពុជាយោងតាមមាត្រា ៤២៥ នៃក្រមព្រហ្មទណ្ឌ "ការក្លែងបន្លំព័ត៌មាន" ។ រដ្ឋមន្ត្រីក្រសួងសុខាភិបាលបានចេញសេចក្ដីប្រកាសព័ត៌មាននៅខែមករាឆ្នាំ ២០២០ ដោយព្រមានថានឹងចាត់វិធានការតាមផ្លូវច្បាប់តាមមាត្រា ៤២៥ ប្រឆាំងនឹងការផ្សព្វផ្សាយព័ត៌មានមិនពិតនៅលើហ្វេសប៊ុក។ សូមមើល *លោក ហុល រស្មី* "ក្រសួងសុខាភិបាលព្រមានសកម្មភាពហ្វេសប៊ុកថាវីរុសកូរ៉ូណាបានឆ្លងចូលប្រទេសកម្ពុជា"(វិទ្យុអាស៊ីសេរី ២៦ មករា ២០២០) https://www.rfa.org/khmer/news/health/health-ministry-warns-fake-news-on-facebook-01272020042835.html ។ សូមមើលឧទាហរណ៍នៃបទល្មើសដែលត្រូវបានអនុវត្ត៖ ហ៊ុល រស្មី លោកស ខេង ថ្លែងការពារការចាប់ខ្លួនបុគ្គលដែលចែករំលែកព័ត៌មានក្លែងក្លាយអំពី Covid-19 (វីអូអេ, ១២ មីនា ២០២០) https://khmer.voanews.com/a/third-cambodian-arrested-for-fake-news-on-covid-19-sar-kheng-defends-arrests/5326092.html

នៅកន្លែងការងារ។ នៅឆ្នាំទី ៤ នេះ គម្រោងបានកត់ត្រាការជួបប្រជុំចំនួន ១៨៥ ។ គម្រោងក៏បានកត់ត្រានូវការរឹតត្បិតសរុបចំនួន ៥៣ និងការរំលោភសិទ្ធិសេរីភាពខាងការជួបប្រជុំដោយសន្តិវិធីចំនួន ២១ លើករួមមាន៖

- ការជួបប្រជុំចំនួន៥ ត្រូវបានហាមឃាត់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា។
- ការជួបប្រជុំចំនួន៩ ទទួលរងការរឹតត្បឹតមុនពេលជួបប្រជុំ។
- ការជួបប្រជុំចំនួន២០ ត្រូវបានជ្រៀតជ្រែកពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ក្នុងនោះមាន៩ ករណីដែលរាជរដ្ឋាភិបាលកម្ពុជាប្រើប្រាស់កម្លាំងទៅលើអ្នកតវ៉ាដោយសន្តិវិធី។

**តារាងតួលេខទី១១៖ ថ្នាក់ដឹកនាំសង្គមស៊ីវិលនិងសហជីពដែលយល់ថាមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំ**

៦៧% នៃអ្នកឆ្លើយតបនៅក្នុងការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិលនិងសហជីពបានរាយការណ៍ថា" មានសេរីភាពខ្លះដែរ" ឬ" ខ្លាំងណាស់" ក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំ ដែលផ្ទុយពីនិន្នាការថយចុះដែលបានកត់សម្គាល់នៅក្នុងឆ្នាំមុន។




**តារាងតួលេខទី១២៖ បុគ្គលដែលយល់ថាមានសេរីភាពក្នុងការជួបជុំដោយសន្តិវិធី**




ទោះបីជាមានការកើនឡើងជាវិជ្ជមាន ដែលត្រូវបានកត់សម្គាល់នៅក្នុងការស្ទង់មតិរបស់ថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីពក៏ដោយ ការស្ទង់មតិសាធារណៈបានបង្ហាញពីការថយចុះ ៨% ចំពោះបុគ្គលដែលយល់ថាមានសេរីភាពខាងការជួបប្រជុំដោយសន្តិវិធីចាប់ពីឆ្នាំទី ៣ និងថយចុះ ២០% ចាប់តាំងពីឆ្នាំទី ២ ។ ទោះជាយ៉ាងណាក្តី សេរីភាពខាងការជួបប្រជុំនៅតែត្រូវបានការពារច្រើនបំផុតក្នុងចំណោមសេរីភាពមូលដ្ឋានទាំងបីនៅក្នុងប្រទេសកម្ពុជា។

របកគំហើញទាំងអស់ក្នុងឆ្នាំទី៤ គឺបានបង្ហាញក្នុងរបាយការណ៍លម្អិត និងនៅក្នុងឧបសម្ព័ន្ធដែលភ្ជាប់ជាមួយ។ របកគំហើញបានវិភាគអំពីក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋាន (ចំណុចគន្លឹះទី១) វិសាលភាពនៃច្បាប់ និងគោលនយោបាយដែលបានអនុវត្តត្រឹមត្រូវ(ចំណុចគន្លឹះទី២) ការយល់ដឹងរបស់សាធារណជន និងលទ្ធភាពក្នុងការអនុវត្តសេរីភាពមូលដ្ឋាន(ចំណុចគន្លឹះទី៣) និងវិសាលភាពរបស់អង្គការសង្គមស៊ីវិលនិងសហជីពដែលត្រូវបានទទួលស្គាល់ជាដៃគូអភិវឌ្ឍដែលស្របច្បាប់ និងមានសមត្ថភាពដោយរាជរដ្ឋាភិបាលកម្ពុជា(ចំណុចគន្លឹះ៤)។

# ១.សេចក្ដីផ្ដើម

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានចាប់ផ្ដើមអនុវត្តពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦ គឺជាគម្រោងរយៈពេលវែងដែលពិនិត្យតាមដាន និងវាយតម្លៃអំពីស្ថានភាពសេរីភាពមូលដ្ឋានចំនួនបី គឺសេរីភាពខាងសមាគម សេរីភាពខាងបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ ("សេរីភាពមូលដ្ឋាន")[14] នៅក្នុងប្រទេសកម្ពុជា។ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានតាមដានការអនុវត្តសេរីភាពមូលដ្ឋាន ដោយប្រើប្រាស់ឧបករណ៍តាមដានការឃ្លាំមើល(MTT)។ នេះជារបាយការណ៍ឆ្នាំទី ៤ ដែលពិនិត្យតាមដានចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩ និងបញ្ចប់នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ ។

គោលបំណងរបស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន គឺដើម្បីផ្ដល់នូវទិដ្ឋភាពបែបសត្យានុម័តអំពីស្ថានភាពសេរីភាពមូលដ្ឋាននៅកម្ពុជានាពេលបច្ចុប្បន្ននេះ ដោយកំណត់និន្នាការដែលទាក់ទងទៅនឹងច្បាប់ និងការអនុវត្តសេរីភាពមូលដ្ឋាន។ ដើម្បីសម្រេចបាននូវគោលបំណងនេះ ក្រុមការងារគម្រោងបានបង្កើតនូវឧបករណ៍តាមដានការឃ្លាំមើល(MTT) ដើម្បីផ្ដល់ជាក្របខ័ណ្ឌសត្យានុម័ត និងតុល្យភាព សម្រាប់ពិនិត្យអំពីស្ថានភាពសេរីភាពមូលដ្ឋាននៅកម្ពុជាដោយផ្ដោតលើការចូលរួមរបស់អង្គការសង្គមស៊ីវិលនិងពលរដ្ឋ។ ឧបករណ៍តាមដានឃ្លាំមើលវាយតម្លៃ ជាលក្ខណៈប្រព័ន្ធ និងបែបសត្យានុម័ត ថាតើសេរីភាពខាងសមាគម សេរីភាពខាងការប្រមូលផ្ដុំ និងសេរីភាពខាងការបញ្ចេញមតិ ត្រូវបានធានា និងអនុវត្តនៅក្នុងប្រទេសកម្ពុជាដល់កម្រិតណា។

ឧបករណ៍តាមដានការឃ្លាំមើលមានធាតុផ្សំចំនួន ៩២ ដែលឆ្លើយតបទៅនឹងចំណុចគន្លឹះសំខាន់ៗចំនួន ៤ ដែលពិនិត្យមើលថាតើ៖

**ចំណុចគន្លឹះទី១៖** ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានស្របតាមបទដ្ឋានអន្តរជាតិ

**ចំណុចគន្លឹះទី២៖**ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានត្រូវបានអនុវត្ត និងប្រតិបត្តិតាម

**ចំណុចគន្លឹះទី៣៖** បុគ្គលម្នាក់ៗមានការយល់ដឹងអំពីសេរីភាពមូលដ្ឋាន និងសិទ្ធិដែលពាក់ព័ន្ធ និងយល់ថាពួកគេមានសេរីភាពក្នុងការអនុវត្តសេរីភាពនេះ និង

**ចំណុចគន្លឹះទី៤៖** អង្គការសង្គមស៊ីវិល និងសហជីពត្រូវបានទទួលស្គាល់ និងអាចធ្វើការក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាល។

---

[14] ក្នុងគោលបំណងនៃរបាយការណ៍នេះ៖ សេរីភាពមូលដ្ឋានរួមមាន៖ សេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបជុំ។ គម្រោងប្រើប្រាស់នូវនិយមន័យនៃពាក្យសមាគម ដែលកំណត់ដោយអ្នករាយការណ៍ពិសេសស្ដីពីសិទ្ធិខាងការជួបប្រជុំដោយសន្តិវិធី និងសមាគម។

នៅក្នុងឆ្នាំទី ៤ មានវិធីសាស្ត្រប្រមូលទិន្នន័យចំនួន ៦ ដែលត្រូវបានប្រើដើម្បីវាស់ចំណុចគន្លឹះទាំងនេះ៖យន្តការរាយការណ៍ពីហេតុការណ៍ដែលបានកើតឡើង[15] ការតាមដានប្រព័ន្ធផ្សព្វផ្សាយ[16] ការពិនិត្យមើលលើច្បាប់ដែលពាក់ព័ន្ធ ("ការពិនិត្យច្បាប់")[17] ឧបករណ៍វាយតម្លៃការចុះបញ្ជិកាសហជីព[18] ការស្ទង់មតិជាសាធារណៈ[19] និងការស្ទង់មតិជាមួយនឹងថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ("ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព")[20]។ របាយការណ៍ នេះបង្ហាញពីការវិភាគនូវរបកគំហើញសំខាន់ៗ និងនិន្នាការដែលពាក់ព័ន្ធនឹងការអនុវត្តសេរីភាពមូលដ្ឋានដែលបានឃ្លាំមើលក្នុងឆ្នាំទី៤។

[15] ការរាយការណ៍ពីហេតុការណ៍ ត្រូវបានប្រមូលតាមរយៈទម្រង់មួយ ដែលត្រូវបានបង្កើតឡើងដើម្បីកត់ត្រានូវការរឹតត្បិតទៅលើសេរីភាពខាងសមាគម និងសិទ្ធិដែលទាក់ទងដទៃទៀតជាមួយបុគ្គល និងសមាគម។

[16] ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយត្រូវបានតាមដានជាប្រចាំដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។ ការតាមដាននេះផ្តោតទៅលើការផ្សព្វផ្សាយរបស់សារព័ត៌មានពីសេរីភាពខាងសមាគម និងសិទ្ធិទាក់ទិនដទៃទៀត និងត្រូវកំណត់ដោយគោលការណ៍ណែនាំអំពីការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយដោយផ្អែកទៅលើឧបករណ៍តាមដានការឃ្លាំមើល។

[17] ការពិនិត្យលើច្បាប់ត្រូវបានធ្វើឡើងដោយមានការវិភាគពីអ្នកជំនាញទៅលើខ្លឹមសារនៃច្បាប់ គោលនយោបាយ របាយការណ៍ និងឯកសារផ្លូវការដទៃទៀត ដើម្បីធ្វើការវាយតម្លៃឱ្យដឹងថាតើមានការធានាដោយច្បាប់ប៉ុណ្ណា និងមានលក្ខខណ្ឌណាផ្សេងទៀតដែរឬទេដែលធានាដល់សេរីភាពខាងសមាគម ។

[18] ឧបករណ៍វាយតម្លៃការចុះបញ្ជីសហជីពកត់ត្រាទុកនូវបទពិសោធន៍របស់តំណាងសហជីព ដែលព្យាយាមចុះបញ្ជីរបស់ពួកគេដែលតម្រូវតាមច្បាប់សហជីព។

[19] ការស្ទង់មតិជាសាធារណៈគឺដើម្បីស្វែងយល់ពីការយល់ដឹងរបស់សាធារណជនអំពីសេរីភាពមូលដ្ឋាន។ ការស្ទង់មតិនេះត្រូវបានធ្វើឡើងជាភាសាខ្មែរចន្លោះពីថ្ងៃទី១៧ ខែកុម្ភៈ ដល់ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០។

[20] ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព មានគោលបំណងស្វែងយល់ពីទស្សនៈ និងបទពិសោធន៍របស់ថ្នាក់ដឹកនាំពាក់ព័ន្ធនឹងលទ្ធភាពរបស់ពួកគេក្នុងការអនុវត្តសេរីភាពមូលដ្ឋាន ហើយការស្ទង់មតិនេះត្រូវបានធ្វើជាប្រចាំឆ្នាំ។ ការស្ទង់មតិនេះគឺបំពេញតាមប្រព័ន្ធអ៊ីនធឺណិត និងការសម្ភាសផ្ទាល់។ ការស្ទង់មតិនេះត្រូវបានធ្វើឡើងចន្លោះថ្ងៃទី១៨ ខែវិច្ឆិកា និងថ្ងៃទី៨ ខែមករា ឆ្នាំ២០២០។

## ២.ចំណុចគន្លឹះទី១៖ តើក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានស្របតាមបទដ្ឋានអន្តរជាតិដែរឬទេ?

ចំណុចគន្លឹះទី១ ពិនិត្យមើលពីវិសាលភាពក្របខ័ណ្ឌច្បាប់នៃប្រទេសកម្ពុជាក្នុងការអនុលោមទៅតាមច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ និងបទដ្ឋានអន្តរជាតិនានាដែលពាក់ព័ន្ធនិងសេរីភាពមូលដ្ឋាន។[21]

**របកគំហើញសំខាន់ៗ ៖** ក្នុងឆ្នាំទី ៤ ដែលគិតពីថ្ងៃទី ១ ខែមេសា ឆ្នាំ២០១៩ ដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២០ ច្បាប់ស្តីពីសហជីពត្រូវបានធ្វើវិសោធនកម្ម។ ទោះបីយ៉ាងនេះក្តី ការធ្វើវិសោធនកម្មច្បាប់នេះមិនបានធ្វើឱ្យច្បាប់នេះអនុលោមទៅតាមកាតព្វកិច្ចនៃសិទ្ធិមនុស្សរបស់ប្រទេសកម្ពុជានៅឡើយទេ។

ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ត្រូវបានប្រកាសឱ្យប្រើនៅខែមេសា ឆ្នាំ២០២០។ ច្បាប់នេះមានវិសាលភាពខ្លាំងក្នុងការរឹតត្បិតលើសេរីភាពមូលដ្ឋានយ៉ាងធ្ងន់ធ្ងរ តែនឹងត្រូវលើកយកមកពិភាក្សាដោយសង្ខេបនៅក្នុងចំណុចគន្លឹះទីមួយ បើទោះជាច្បាប់នេះត្រូវបានអនុម័តបន្ទាប់ពីការបញ្ចប់នូវរបាយការណ៍ឆ្នាំទីបួននៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានក៏ដោយ។ ការវិភាគពេញលេញទៅលើច្បាប់នេះនឹងបង្ហាញនៅក្នុងរបាយការណ៍របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅឆ្នាំទី ៥ ។

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន មិនបានកត់ត្រានូវច្បាប់ឬបទប្បញ្ញត្តិសំខាន់ៗ ឬលិខិតបទដ្ឋានផ្សេងទៀតដែលមិនប៉ះពាល់ដល់សេរីភាពមូលដ្ឋាននោះទេ នៅក្នុងឆ្នាំទី៤ នេះ។

---

[21] របកគំហើញនានានៅក្នុងចំណុចគន្លឹះទី១ គឺផ្តោតទៅលើការពិនិត្យមើលឡើងវិញលើច្បាប់ដែលពាក់ព័ន្ធ(ការពិនិត្យមើលឡើងទៅលើច្បាប់)។ គឺជាការវិភាគអំពីវិសាលភាពដែលក្របខ័ណ្ឌច្បាប់ជាតិទាក់ទងទៅនឹងសេរីភាពមូលដ្ឋានអនុលោមទៅតាមច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលកើតចេញពីសន្ធិសញ្ញាអន្តរជាតិ និងបទដ្ឋានអន្តរជាតិដែលបកស្រាយដោយគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ។

នៅក្នុងរបាយការណ៍នេះ" ច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ" សំដៅដល់ច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិទាក់ទងនឹងសេរីភាពមូលដ្ឋាន តួយ៉ាងសេរីភាពខាងបង្កើតសមាគម សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិដែលកើតចេញពីសន្ធិសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាជារដ្ឋហត្ថលេខី។ មាត្រា ៣១ នៃច្បាប់រដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាផ្តល់ធម្មនុញ្ញភាពដល់សិទ្ធិមនុស្សដែលមានចែងនៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ព្រមទាំងកតិកាសញ្ញា និងអនុសញ្ញាទាក់ទងនឹងសិទ្ធិមនុស្សសិទ្ធិស្ត្រីនិងសិទ្ធិកុមារ។ សេចក្តីសម្រេចចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាបានបកស្រាយជាផ្លូវការនូវមាត្រា៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាដែលមានន័យថា សន្ធិសញ្ញាអន្តរជាតិដែលបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជាគឺអាចអនុវត្តបានដោយផ្ទាល់នៅក្នុងច្បាប់ជាតិ។ សូមមើលសេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧(ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧) របស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ សន្ធិសញ្ញាដែលត្រូវបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជា រួមមាន កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ចសង្គម និងវប្បធម៌ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនិងស្ត្រី និងអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ក្រៅពីសន្ធិសញ្ញាទាំងនេះ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានក៏ប្រើបទដ្ឋានអន្តរជាតិផ្សេងៗ ដែលគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិបានបកស្រាយផងដែរ។

នៅក្នុងឆ្នាំទី ៤ រកឃើញមានសេចក្តីព្រាងច្បាប់ ឬសេចក្តីព្រាងវិសោធនកម្មច្បាប់ជាច្រើនដែលបង្កការគំរាមកំហែងដល់ការអនុវត្តសេរីភាពមូលដ្ឋាន តួយ៉ាងដូចជាការធ្វើវិសោធនកម្ម *ច្បាប់ស្តីពីរបបសារព័ត៌មាន* សេចក្តីព្រាង (១៩៩៥)ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា និងសំណើច្បាប់ប្រឆាំងនឹងព័ត៌មានក្លែងក្លាយ។ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននឹងបន្តពិនិត្យតាមដានអំពីវឌ្ឍនភាពផ្នែកច្បាប់ និងសេចក្តីព្រាងវិសោធនកម្មច្បាប់ទាំងនេះ។ នៅពេលដែលច្បាប់ទាំងនេះត្រូវបានអនុម័ត គម្រោងនឹងធ្វើការវិភាគផ្នែកច្បាប់ឱ្យបានពេញលេញដូចដែលមានក្នុងឧបករណ៍តាមដានឃ្លាំមើល ដើម្បីវិភាគអំពីអនុលោមភាពនៃច្បាប់ទាំងនេះទៅនឹងបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ។

## ២.១ ការធ្វើវិសោធនកម្មច្បាប់ស្តីពីសហជីពអាចថមថយនូវការរំលោភបំពានសេរីភាពមូលដ្ឋានប៉ុន្តែការរឹតត្បិតនៅតែមាន

### ២.១.១ ច្បាប់នេះនៅតែបន្តរំលោភបំពានលើសេរីភាពខាង

ច្បាប់ស្តីពីសហជីព[22] ត្រូវបានធ្វើវិសោធនកម្ម[23] កាលពីខែមករា ឆ្នាំ២០២០។ វិសោធនកម្មនេះបានកែសម្រួលមាត្រាចំនួនដប់។[24] បើទោះបីជាមានការធ្វើវិសោធនកម្មដែលមានចំណុចមួយចំនួនបានធ្វើឱ្យប្រសើរឡើងនូវច្បាប់នេះក៏ដោយ[25] ក៏ច្បាប់ស្តីពីសហជីពបន្តប៉ះពាល់ដល់សេរីភាពខាងបង្កើតសមាគម។[26] ច្បាប់នេះមានវិសាលភាពតូចចង្អៀត ដែលបានផាត់ចេញកម្មករជាច្រើនពីការការពាររបស់ច្បាប់។ ច្បាប់នេះក៏បានដាក់បន្ទុកលក្ខខណ្ឌមួយចំនួនដែលរឹតត្បិតនូវលទ្ធភាពរបស់សហជីពនៅក្នុងកិច្ចដំណើរការ និងអនុញ្ញាតឱ្យមានការជ្រៀតជ្រែកខ្លាំងនៅក្នុងកិច្ចការរបស់សហជីព។

---

[22] ច្បាប់ស្តីពីសហជីព(២០១៦) <http://sithi.org/temp.php?url=law_detail.php&lg=&id=278> សូមមើលផងដែរនូវការវិភាគផ្នែកច្បាប់៖ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និងមជ្ឈមណ្ឌលអន្តរជាតិដើម្បីច្បាប់ដោយមិនយកកម្រៃ 'គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន–របាយការណ៍ឆ្នាំទី១'(ខែសីហាឆ្នាំទី១)ទំព័រទី៤ <https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf>.

[23] ត្រូវបានអនុម័តដោយរដ្ឋសភានៅខែវិច្ឆិកា ឆ្នាំ២០១៩ ហើយដែលព្រឹទ្ធសភា និងក្រុមប្រឹក្សាធម្មនុញ្ញបានអនុម័តនៅខែធ្នូ ឆ្នាំ២០១៩ មុននឹងត្រូវប្រកាសឱ្យប្រើនៅខែមករា ឆ្នាំ ២០២០។

[24] មាត្រាដែលត្រូវបានធ្វើវិសោធនកម្មរួមមានមាត្រា ៣, ១៧, ២០, ២១, ២៧, ២៨, ២៩, ៥៤, ៥៥ និងមាត្រា ៥៩។

[25] ជាតួយ៉ាង មាត្រា ២៩ ត្រូវបានធ្វើវិសោធនកម្មក្នុងលក្ខណៈវិជ្ជមានដោយហេតុថាបញ្ញត្តិនេះអនុញ្ញាតឱ្យរំលាយចោលសហជីពក្នុងករណីដែលអ្នកដឹកនាំគ្រប់គ្រងសហជីពមានកំហុសធ្ងន់ក្នុងការប្រព្រឹត្តល្មើសត្រូវបានដកហូតពីតំណែង។ ការធ្វើវិសោធនកម្មមាត្រា ២៨ ក៏ត្រូវបានស្វាគមន៍ផងដែរព្រោះវាបានបញ្ចូលបន្ថែមនូវលក្ខខណ្ឌស្តីពីប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងទៀតដែលត្រូវទូទាត់គ្រប់ចំនួនដល់កម្មករ និយោជិតទាំងអស់មុនពេលនៃការរំលាយចោលសហជីពដោយស្វ័យប្រវត្តិនៅពេលដែលសហគ្រាសត្រូវបានបិទលែងដំណើរការ។

[26] សិទ្ធិសេរីភាពខាងបង្កើតសមាគមត្រូវបានការពារតាមរយៈមាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ វារួមបញ្ចូលទាំងសិទ្ធិរបស់បុគ្គលក្នុងការបង្កើត ចូលជាសមាជិក និងចូលរួមជាក្រុមដើម្បីស្វែងរកផលប្រយោជន៍រួម។ ទាំងនេះអាចរួមបញ្ចូលទាំងអង្គការសង្គមស៊ីវិល សហជីព គណបក្សនយោបាយ ឬក្រុមហ៊ុនសាជីវកម្ម។ មាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយលេខ ៩៩៩ UNTS ១៧១ (ត្រូវបានអនុម័តថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦ ចូលជាធរមាននៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ១៩៧៦)។ សេរីភាពខាងបង្កើតសមាគមក៏ត្រូវបានការពារផងដែរក្រោមច្បាប់ក្នុងស្រុកតាមរយៈមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ។

ដើម្បីគោរពទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ការរឹតត្បិតសេរីភាពខាងបង្កើតសមាគមត្រូវតែគោរពតាមលក្ខខណ្ឌ ៣ ចំណុចដូចដែលបានចែងក្នុងមាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ រាល់ការរឹតត្បិតសេរីភាពខាងបង្កើតសមាគមត្រូវតែ៖ កំណត់ (១)ដោយច្បាប់ (២ (មានគោលបំណងស្របច្បាប់ សន្តិសុខជាតិ)សុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ (៣) និង (មានភាពចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ។[27] ក្រៅពី កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សេរីភាពខាងបង្កើតសមាគមរបស់កម្មករ និយោជិត និងនិយោជករួមជាមួយនឹងសិទ្ធិរបស់ពួកគេក្នុងការរៀបចំសមាគមត្រូវបានការពារដោយបទដ្ឋានអង្គការពលកម្មអន្តរជាតិ ជាពិសេសក្នុងអនុសញ្ញាលេខ ៨៧ ដែលបានផ្តល់សច្ចាប័នប្រទេសកម្ពុជានៅថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៩។[28] អង្គការពលកម្មអន្តរជាតិ ផ្តល់នូវយុត្តាធិការសម្រាប់គោលការណ៍ដែលដាក់បញ្ចូលនូវសេរីភាពរបស់សមាគមដោយបានទទួលស្គាល់ថា ជាមធ្យោបាយមួយក្នុងការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ។

**មាត្រា ៣**

មាត្រា ៣ ចែងពីវិសាលភាពនៃការអនុវត្តច្បាប់ស្តីពីសហជីព ត្រូវបានធ្វើវិសោធនកម្ម។ វិសាលភាពនៃច្បាប់ស្តីពីសហជីពនេះកាន់តែមានលក្ខណៈតូចចង្អៀត ដោយគ្របដណ្តប់ទៅលើតែ "*សហគ្រាស ឬគ្រឹះស្ថាន និងជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ* " ប៉ុណ្ណោះ។ បុគ្គលិកដែលបម្រើការក្នុងវិស័យដឹកជញ្ជូនតាមផ្លូវអាកាស និងតាមផ្លូវសមុទ្រដូចដែលបានចែងនៅក្នុងមាត្រា៣កាលពីមុន លែងស្ថិតនៅក្នុងដែនវិសាលភាពនៃច្បាប់នេះហើយ។ លើសពីនេះទៀត សេចក្តីព្រាងវិសោធនកម្មនៃមាត្រា ៣ រួមមានការពង្រីកវិសាលភាពនៃច្បាប់ស្តីពីសហជីពរហូតដល់អ្នកបម្រើការតាមផ្ទះ ប៉ុន្តែការធ្វើវិសោធនកម្មទាំងនេះមិនបានដាក់បញ្ចូលក្នុងសេចក្តីព្រាងច្បាប់ចុងក្រោយទេ ដូច្នេះវិសាលភាពនៃច្បាប់ស្តីពីសហជីពមិនត្រូវបានពង្រីកវិសាលភាពដើម្បីដាក់បញ្ចូលអ្នកបម្រើការតាមផ្ទះទេ។ អ្នកបម្រើការតាមផ្ទះរួមជាមួយវិស័យជាច្រើនទៀតនៃកម្លាំងពលកម្មនៅកម្ពុជា ដែលក្នុងនោះរួមមានជាអាទិ៍ អ្នកប្រកបមុខរបរផ្ទាល់ខ្លួន អ្នកបម្រើការក្នុងជួរមន្ត្រីសាធារណៈ គ្រូបង្រៀន និងកម្មករ និយោជិតក្នុងវិស័យក្រៅប្រព័ន្ធនៅតែត្រូវបានផាត់ចេញពីការការពារពីច្បាប់សហជីពនេះ។[29] ដូចនេះ មាត្រា ៣ រំលោភបំពានលើកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ

[27] មាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយលេខ ៩៩៩ UNTS ១៧១ (ត្រូវបានអនុម័តថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមាននៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ១៩៧៦) ។

[28] អនុសញ្ញាលេខ ៨៨៧ ចុះថ្ងៃទី ៩ ខែកក្កដា ឆ្នាំ១៩៤៨ ស្តីពីសេរីភាពខាងបង្កើតសមាគម និងការការពារសិទ្ធិក្នុងការរៀបចំសមាគមរបស់អង្គការពលកម្មអន្តរជាតិ(ILO) <https://www.ilo.org/dyn/normlex/en/f?p=NORMLEXPUB:12100:0::NO::P12100_ILO_CODE:C087>.

[29] នៅពេលពិនិត្យភ្ជាប់ជាមួយមាត្រា ១០ ដែលចែងថាកម្មករនិយោជិតយ៉ាងតិច ១០ នាក់នៅក្នុងសហគ្រាស ឬគ្រឹះស្ថានមួយចាំបាច់ត្រូវបង្កើតសហជីពមូលដ្ឋានមួយ មាត្រា ៣ ថ្មីដែលត្រូវបានធ្វើវិសោធនកម្មក៏មិនបានផ្តល់ការការពារសិទ្ធិក្នុងការបង្កើតសហជីពរបស់បុគ្គលដែលធ្វើការតែម្នាក់ឯង ឬជាក្រុមតូចៗដែរ ដូចជាអ្នកបម្រើការតាមផ្ទះ ជាដើម ជាមួយមាត្រា ១០ ដែលរឹតត្បិតសេរីភាពខាងបង្កើតសមាគម និងធ្វើឱ្យអានុភាពនៃវិសោធនកម្មមាត្រា ៣ ប្រែជាឥតបានការ។

របស់ប្រទេសកម្ពុជា ពោលគឺមាត្រា ២ នៃអនុសញ្ញាលេខ ៨៧ របស់អង្គការពលកម្មអន្តរជាតិ ដែលផ្តល់សិទ្ធិឱ្យកម្មករ និយោជិតក្នុងការបង្កើត និងចូលរួមក្នុងសមាគម *"ដោយមិនមានការបែងចែកអ្វីទាំងអស់*[30] "។

ការផាត់ចេញនូវអ្នកប្រកបមុខរបរផ្ទាល់ខ្លួន អ្នកបម្រើការក្នុងជួរមន្ត្រីសាធារណៈ គ្រូបង្រៀន និងកម្មករនិយោជិតក្នុងវិស័យក្រៅប្រព័ន្ធពីច្បាប់ ស្តីពីសហជីពគឺផ្ទុយនឹងមាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រោះបានរឹតត្បិតនូវសេរីភាពខាងបង្កើតសមាគមដោយមិនគោរពតាមគោលបំណងស្របច្បាប់ ដែលនាំឱ្យមិនចូលក្នុងលក្ខខណ្ឌតម្រូវទី២ ក្នុងចំណោមលក្ខខណ្ឌ៣ចំណុចនៃមាត្រា២២ ។ ដើម្បីបំពេញតាមលក្ខខណ្ឌនេះ ភារកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជាកម្ពុជា គឺត្រូវបង្ហាញថាការផាត់ចេញនូវកម្មករនិយោជិតទាំងនេះពីច្បាប់ស្តីពីសហជីព ត្រូវបានធានាដើម្បីឆ្លើយតបនឹងការគំរាមកំហែងជាក់លាក់ចំពោះសន្តិសុខជាតិ សុវត្ថិភាពសាធារណៈ ឬសណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ ឬសីលធម៌សង្គម ឬមានចេតនាដើម្បីការពារសិទ្ធិនិងសេរីភាពរបស់អ្នកដទៃ។ ទោះបីជាយ៉ាងនេះក្តី ទឡ្ហីករណ៍នេះមិនត្រូវបានដាក់ចេញ ដើម្បីផ្តល់យុត្តិកម្មលើដែនកំណត់នៃវិសាលភាពរបស់ច្បាប់ស្តីពីសហជីពទេ។

**មាត្រា ១៧**

មាត្រា ១៧ ត្រូវបានពិនិត្យកែសម្រួលឡើងវិញ ដើម្បីឱ្យសហជីពរក្សាបញ្ជិការបស់ខ្លួន៖ (១)សហជីពត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាពប្រចាំឆ្នាំ និង (២) សហជីពត្រូវធ្វើសវនកម្មដោយសវនកម្មឯករាជ្យ ក្នុងករណីមានការស្នើសុំម្ចាស់ជំនួយណាមួយឬសមាជិកចាប់ពី ១០ ភាគរយ នៃសមាជិកសរុប ឬសមាជិកចាប់ពី ៥ ភាគរយ នៃចំនួនសមាជិកសរុប ចំពោះសហព័ន្ធសហជីព សហភាពសហជីព និងសហព័ន្ធនិយោជក។[31] មាត្រា១៧ បន្តរឹតត្បិតខ្លាំងលើសេរីភាពខាងបង្កើតសមាគម ពីព្រោះយោងតាមច្បាប់អន្តរជាតិ សហជីពមានសិទ្ធិកំណត់វិធានផ្ទាល់ខ្លួន និងលក្ខខណ្ឌនៃការរាយការណ៍។ អនុសញ្ញាលេខ ៨៧ របស់អង្គការពលកម្មអន្តរជាតិ ផ្តល់សិទ្ធិផ្តាច់មុខដល់សហជីពក្នុងការតាក់តែង និងអនុម័ត

---

[30] ការផាត់ចេញនូវសមាជិកនៃកងកម្លាំងប្រដាប់អាវុធ និងនគរបាលពីវិសាលភាពនៃច្បាប់ស្តីពីសហជីពគឺមានលក្ខណៈស្របច្បាប់ព្រោះទាំងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងអនុសញ្ញាលេខ ៨៧ របស់អង្គការពលកម្មអន្តរជាតិ មានបញ្ញត្តិចែងពីអញ្ញត្រកម្មទាក់ទងនឹងប្រភេទកម្មករនិយោជិតទាំងពីរប្រភេទនេះ។ មាត្រា ២២ (២) នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយចែងថា " មាត្រានេះនឹងមិនរារាំងការដាក់កំហិតស្របច្បាប់លើសមាជិកនៃកងកម្លាំងប្រដាប់អាវុធ និងនគរបាលក្នុងការអនុវត្តសេរីភាពក្នុងការចូលរួមជាមួយអ្នកដទៃទេ "។ ចំពោះ អនុសញ្ញាលេខ ៨៧ របស់អង្គការពលកម្មអន្តរជាតិ មាត្រា ៩ នៃអនុសញ្ញានេះចែងថា " *វិសាលភាពនៃការធានាដូចបានបញ្ញត្តិនៅក្នុងអនុសញ្ញានេះដែលត្រូវអនុវត្តចំពោះកងកម្លាំងប្រដាប់អាវុធ និងនគរបាលត្រូវកំណត់ដោយច្បាប់ ឬបទប្បញ្ញត្តិជាតិ" ។*

[31] មាត្រា ១៧ - ថ្មី៖ "*ដើម្បីរក្សាបញ្ជិកាដែលបានយល់ព្រមរួចហើយឱ្យនៅមានសុពលភាព សហជីព ឬសមាគមនិយោជកនីមួយៗត្រូវ៖ (ក) ធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពប្រចាំឆ្នាំដោយផ្អែកលើសៀវភៅហិរញ្ញវត្ថុ និងកំណត់ត្រាដែលបានរក្សាទុកជូនសមាជិករបស់ខ្លួនដើម្បីទទួលបានព័ត៌មានយ៉ាងយូរត្រឹមដំណាច់ខែមីនានៃឆ្នាំបន្ទាប់ និងត្រូវធ្វើសវនកម្មដោយស្ថាប័នសវនកម្មឯករាជ្យដែលបានចុះបញ្ជីស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងករណីដែលមានការស្នើសុំពី៖*

- ចាប់ពី ១០% (ដប់ភាគរយ) នៃចំនួនសមាជិកសរុបរបស់សហជីព ឬម្ចាស់ជំនួយណាមួយសម្រាប់សហជីពមូលដ្ឋាន និងសមាគមនិយោជក។

- ៥% (ប្រាំភាគរយ) នៃចំនួនសមាជិកសរុប ឬម្ចាស់ជំនួយណាមួយសម្រាប់សហព័ន្ធសហជីព សហភាពសហជីព និងសហព័ន្ធនិយោជក។

លក្ខន្តិកៈ និងវិធានផ្ទាល់ខ្លួន ក៏ដូចជាក្នុងការរៀបចំកិច្ចការរដ្ឋបាល និងសកម្មភាពរបស់ខ្លួនដោយគ្មានការជ្រៀតជ្រែកពីសំណាក់អាជ្ញាធររាជរដ្ឋាភិបាលកម្ពុជា។[32] សិទ្ធិទាំងពីរនេះត្រូវបានរំលោភបំពានដោយមាត្រា ១៧។ លក្ខខណ្ឌដែលជានាដល់ការរៀបចំ និងការបង្ហាញរបាយការណ៍ និងសវនកម្មដូចដែលបានចែងក្នុងមាត្រា ១៧ គួរត្រូវបានក (ក)ំណត់ដោយសហជីពផ្ទាល់។ ជាការពិតណាស់គោលបំណងចម្បងនៃការរៀបចំរបាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុ គឺដើម្បីឱ្យសហជីពមានតម្លាភាព និងគណនេយ្យភាពចំពោះសមាជិករបស់ខ្លួន។ ការជ្រើសរើសពេលវេលា និងរបៀបធ្វើសវនកម្មក៏ត្រូវទុកឱ្យសហជីពកំណត់ដោយខ្លួនឯងផងដែរ។ លក្ខខណ្ឌផ្នែកច្បាប់ដែលបានបង្ខំឱ្យសហជីពធ្វើសវនកម្មគឺជ្រៀតជ្រែកទៅលើសិទ្ធិរបស់សហជីពក្នុងការគ្រប់គ្រងកិច្ចការផ្ទាល់របស់ខ្លួន។ លក្ខខណ្ឌដែលមាត្រា ១៧ ដាក់កំណត់ទៅលើសហជីពមានលក្ខណៈផ្ទុយនឹងអនុសញ្ញាលេខ ៨៧ របស់អង្គការពលកម្មអន្តរជាតិ។

**មាត្រា ២០** ការធ្វើវិសោធនកម្មលើមាត្រា២០ នៃច្បាប់ស្តីពីសហជីពបានលុបចោលនូវលក្ខខណ្ឌរឹតត្បិតចំនួន ២ សម្រាប់ការកាន់តំណែងជាអ្នកដឹកនាំសហជីព។ អ្នកដឹកនាំសហជីពដែលជាពលរដ្ឋខ្មែរ មិនចាំបាច់បញ្ជាក់ថាមានកម្រិតវប្បធម៌ចេះអាន ចេះសរសេរអក្សរខ្មែរទៀតទេ ហើយអ្នកដឹកនាំសហជីពទាំងអស់ដោយមិនគិតពីសញ្ជាតិ មិនចាំបាច់បញ្ជាក់ថាពុំធ្លាប់ទទួលការផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌទេ។[33] ទោះបីយ៉ាងនេះក្តី លក្ខខណ្ឌដែលមានបញ្ហាចម្រូងចម្រាសចំនួនពីរនៅតែរក្សាទុកនៅក្នុងមាត្រា ២០ ដដែល ។

លក្ខខណ្ឌដែលមានបញ្ហាចម្រូងចម្រាសទី១គឺអ្នកដឹកនាំសហជីព *"ត្រូវមានអាយុយ៉ាងតិច១៨ (ដប់ប្រាំបីឆ្នាំ) ឬជាអនីតិជនដែលមានអត្តាធិនភាព"*។ លក្ខខណ្ឌនេះត្រូវបានគណៈកម្មាធិការខាងសេរីភាពក្នុងការបង្កើតសមាគម[34] រកឃើញថាមិនស៊ីសង្វាក់ជាមួយនឹងបទដ្ឋានអន្តរជាតិ។ ការដាក់កម្រិតអាយុរបស់អ្នកដឹកនាំសហ

---

[32] មាត្រា ៣ នៃអនុសញ្ញាលេខ ៨៨ ថ្ងៃទី ៩ ខែកក្កដា ឆ្នាំ ១៩៤៨ របស់អង្គការពលកម្មអន្តរជាតិ សេរីភាពខាងបង្កើតសមាគម និងការការពារសិទ្ធិក្នុងការរៀបចំសមាគម
<https://www.ilo.org/dyn/normlex/en/f?p=NORMLEXPUB:12100:0::NO::P12100_ILO_CODE:C087>.សូមមើលផងដែរនូវកថាខណ្ឌ ៦៦៦ នៃកម្រងសេចក្តីសម្រេចរបស់គណៈកម្មាធិការខាងសេរីភាពក្នុងការបង្កើតសមាគមរបស់អង្គការពលកម្មអន្តរជាតិ ឆ្នាំ ២០១៨" *សេរីភាពខាងបង្កើតសមាគមសំដៅដល់សិទ្ធិរបស់កម្មករ និយោជិត និងនិយោជកក្នុងការបោះឆ្នោតជ្រើសរើសតំណាងរបស់ពួកគេដោយមានសេរីភាពពេញលេញ និងរៀបចំរដ្ឋបាល និងសកម្មភាពរបស់ពួកគេដោយគ្មានការជ្រៀតជ្រែកពីសំណាក់អាជ្ញាធរសាធារណៈ"*
<https://www.ilo.org/wcmsp5/groups/public/---ed_norm/---normes/documents/publication/wcms_632659.pdf>. សូមមើលផងដែរនូវរបាយការណ៍លេខ ១០៣ កថាខណ្ឌ ១៦០ (អេក្វាឌ័រ) ១៦៣ ករណីលេខ ៤២២ -របស់គណៈកម្មាធិការខាងសេរីភាពក្នុងការបង្កើតសមាគម ។

[33] មាត្រា ២០ (ឃ) ចាស់ តម្រូវឱ្យអ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់សហជីពដែលជាពលរដ្ឋខ្មែរ *"ធ្វើសេចក្តីប្រកាសផ្ទាល់ខ្លួនថាមិនធ្លាប់ទទួលការផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌ"* ។ ពាក្យថា *"បទល្មើសព្រហ្មទណ្ឌ"* រាប់បញ្ចូលទាំងបទមជ្ឈិម និងបទឧក្រិដ្ឋ។

[34] គណៈកម្មាធិការខាងសេរីភាពក្នុងការបង្កើតសមាគម ត្រូវបានបង្កើតឡើងដោយអង្គការពលកម្មអន្តរជាតិ ក្នុងឆ្នាំ ១៩៥១ ក្នុងគោលបំណងពិនិត្យពាក្យបណ្តឹងអំពីការរំលោភលើសេរីភាពខាងបង្កើតសមាគមដោយបណ្តាប្រទេសនានា ដោយមិនគិតថាតើសាមីប្រទេសនោះបានផ្តល់សច្ចាប័នលើអនុសញ្ញាលេខ៨៧ និង៩៨ របស់អង្គការពលកម្មអន្តរជាតិ ស្តីពីសេរីភាពខាងបង្កើតសមាគម និងការចរចាអនុសញ្ញារួមឬអត់នោះទេ។ គណៈកម្មាធិការខាងសេរីភាពក្នុងការបង្កើតសមាគមមានសមាសភាពប្រធានដែលឯករាជ្យមួយរូប និង

ជីពមានវិសមិតភាពជាមួយនឹងគោលការណ៍ស្តីពីសេរីភាពខាងបង្កើតសមាគម ព្រោះជ្រៀតជ្រែកទៅលើសិទ្ធិរបស់អង្គការកម្មករនិយោជិតក្នុងការបោះឆ្នោតជ្រើសរើសតំណាងរបស់ពួកគេដោយសេរី។[35] លក្ខខណ្ឌដែលមានបញ្ហាចម្រូងចម្រាសទី ២ គឺអ្នកដឹកនាំសហជីពត្រូវ“ ធ្វើសេចក្តីប្រកាសផ្ទាល់ខ្លួនអំពីអាសយដ្ឋានលំនៅដ្ឋានស្របច្បាប់ និងជាក់លាក់ ”។ ទោះបីជាយ៉ាងនេះក្តី គណៈកម្មាធិការខាងសេរីភាពក្នុងការបង្កើតសមាគមបានរកឃើញថា*មានលក្ខណៈ.. “ ផ្ទុយនឹង អនុសញ្ញាលេខ ៨៧ របស់អង្គការពលកម្មអន្តរជាតិ (ក្នុងការទាមទារព័ត៌មានពីស្ថាបនិករបស់អង្គការដូចជាលេខទូរស័ព្ទ ស្ថានភាពអាពាហ៍ពិពាហ៍ ឬអាសយដ្ឋានលំនៅឋានរបស់ពួកគេ នេះមិនរាប់បញ្ចូលដោយប្រយោល)នូវកម្មករនិយោជិតជាសមាជិកដែលគ្មានទីលំនៅ ឬអ្នកដែលមិនមានលទ្ធភាពបង់ថ្លៃទូរស័ព្ទ(” ។*[36]

យោងតាមច្បាប់អន្តរជាតិ ការកំណត់លក្ខខណ្ឌអំពីលក្ខណៈសម្បត្តិរបស់អ្នកដឹកនាំសហជីពគឺជាបញ្ហាមួយដែលគួរតែរក្សាទុកជាការសម្រេចដោយបទបញ្ញាផ្ទៃក្នុងរបស់សហជីព។ អាជ្ញាធរសាធារណៈគប្បីចៀសវាងពីការចូលរួមក្នុងអន្តរាគមន៍ណាមួយដែលអាចរារាំងដល់ការអនុវត្តសិទ្ធិនេះ។[37] លក្ខន្តិកៈនេះធានាបាននូវសិទ្ធិរបស់កម្មករនិយោជិតផង និងនិយោជកផង“*ក្នុងការបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួនដោយសេរី*[38] យោងតាមលក្ខខណ្ឌទាំងនេះ មាត្រា ២០ មិនបានផ្តល់ការការពារគ្រប់គ្រាន់ចំពោះសេរីភាពខាងបង្កើតសមាគមនោះទេ។

**មាត្រា ២១**

មាត្រា ២១ នៃច្បាប់ស្តីពីសហជីពត្រូវបានធ្វើវិសោធនកម្មដើម្បីលុបចោលនូវលក្ខខណ្ឌដែលថាអ្នកដឹកនាំគ្រប់គ្រងនិងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាល របស់សមាគមនិយោជកមិនធ្លាប់ទទួលការផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌ។ ទោះបីជាយ៉ាងនេះក្តី មាត្រា ២១ នៅតែតម្រូវឱ្យអ្នកដឹកនាំ*សមាគមនិយោជក*“ ត្រូវមានអាយុយ៉ាងតិច ១៨ (ដប់ប្រាំបី)ឆ្នាំ” *និង ធ្វើសេចក្តីប្រកាសផ្ទាល់ខ្លួនអំពីអាសយដ្ឋានស្នាក់នៅជាក់លាក់*”។ ដូចដែលបានពិភាក្សាខាងលើ ដែលលក្ខខណ្ឌទាំងនេះរំលោភបំពានលើអនុសញ្ញាលេខ ៨៧ របស់អង្គការពលកម្មអន្តរជាតិ។

---

តំណាងបីរូប ដែលតំណាងនីមួយៗមកពីរាជរដ្ឋាភិបាលកម្ពុជា និយោជក និងកម្មករនិយោជិត។ ប្រសិនបើខ្លួនរកឃើញថាមានការរំលោភបំពានលើសេរីភាពខាងបង្កើតសមាគម ឬគោលការណ៍របស់សមាគម នោះគណៈកម្មាធិការនេះនឹងផ្តល់អនុសាសន៍អំពីវិធីដែលអាចដោះស្រាយស្ថានភាពបាន។ បន្ទាប់មករាជរដ្ឋាភិបាលកម្ពុជាត្រូវបានស្នើសុំឱ្យរាយការណ៍អំពីការអនុវត្តតាមអនុសាសន៍របស់គណៈកម្មាធិការខាងសេរីភាពក្នុងការបង្កើតសមាគម ។

[35] របាយការណ៍លេខ៣៤៣ កថាខណ្ឌ៣១០ ករណីលេខ ២៤៤៣ (កម្ពុជា) របស់គណៈកម្មាធិការដើម្បីសេរីភាពខាងបង្កើតសមាគម។

[36] កថាខណ្ឌ ១០០៥ នៃរបាយការណ៍លេខ ៣៦៣ ករណីលេខ ២៨៦៨ (ប៉ាណាម៉ា) របស់គណៈកម្មាធិការខាងសេរីភាពក្នុងការបង្កើតសមាគម “*...វាផ្ទុយនឹងអនុសញ្ញាលេខ ៨៧ ក្នុងការទាមទារព័ត៌មានពីស្ថាបនិករបស់អង្គការដូចជាលេខទូរស័ព្ទ ស្ថានភាពអាពាហ៍ពិពាហ៍ ឬអាសយដ្ឋានស្នាក់នៅ (នេះមិនរាប់បញ្ចូលដោយប្រយោលនូវកម្មករនិយោជិតជាសមាជិកដែលគ្មានទីលំនៅ ឬអ្នកដែលមិនមានលទ្ធភាពបង់ថ្លៃទូរស័ព្ទ)” ។*

[37] កថាខណ្ឌ ៦០៦ នៃ“កម្រងសេចក្តីសម្រេចរបស់គណៈកម្មាធិការខាងសេរីភាពក្នុងការបង្កើតសមាគមឆ្នាំ២០១៨” របស់អង្គការពលកម្មអន្តរជាតិ<https://www.ilo.org/wcmsp5/groups/public/---ed_norm/---normes/documents/publication/wcms_632659.pdf>.

[38] មាត្រា ៣ នៃអនុសញ្ញាលេខ *C87* ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ ១៩៤៨ “ *សេរីភាពខាងបង្កើតសមាគម និងការការពារសិទ្ធិក្នុងការរៀបចំសមាគមរបស់អង្គការពលកម្មអន្តរជាតិ*” <https://www.ilo.org/dyn/normlex/en/f?p=NORMLEXPUB:12100:0::NO::P12100_ILO_CODE:C087>.

**មាត្រា ២៧** មាត្រា ២៧ ត្រូវបានធ្វើវិសោធនកម្មស្រដៀងគ្នានឹងមាត្រា ១៧ ហើយបញ្ជាក់ជាថ្មីថា“ *របាយការណ៍ហិរញ្ញវត្ថុ*”[39] របស់សហជីព អាចត្រូវបានធ្វើសវនកម្ម បើមានការស្នើសុំរបស់ម្ចាស់ជំនួយ ឬសមាជិកចំនួនយ៉ាងតិចសម្រាប់សហជីព %១០) មូលដ្ឋាន និង ៥សម្រាប់ %សហព័ន្ធសហជីព/សហភាពសហជីព។[40] (សំខាន់ទៀតនោះ មាត្រា ១៧ និង ២៧ មានបញ្ញត្តិដូចគ្នា ហេតុដូច្នេះបញ្ហាកង្វល់ដូចគ្នានឹងការលើកឡើងចំពោះមាត្រា ១៧ )សូមមើលខាងលើកើត (មានឡើងចំពោះមាត្រា ២៧ ពេលគឺលក្ខខណ្ឌធានាការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុអាចត្រូវបានកំណត់ដោយសហជីព និងម្ចាស់ជំនួយរបស់ពួកគេរួមគ្នាជាជាងដោយច្បាប់។ លើសពីនេះទៀត ការកម្រិតលក្ខខណ្ឌដែលតម្រូវសមាជិកតិចតួចបំផុតនេះក្នុងការជំរុញដល់ការធ្វើសវនកម្មនាំឱ្យមានការព្រួយបារម្ភដូចក្នុងមាត្រា ១៧, មាត្រា ២៧ អាចត្រូវបានប្រើខុសដើម្បីជ្រៀតជ្រែក និងរំខានលើកិច្ចការរបស់សហជីពដោយរំលោភបំពានលើអនុសញ្ញាលេខ ៨៧ របស់អង្គការពលកម្មអន្តរជាតិ។

**មាត្រា ២៨** មាត្រា ២៨ ត្រូវបានធ្វើវិសោធនកម្មដើម្បីផ្លាស់ប្តូរកាលៈទេសៈនៃការរំលាយចោលសហជីពដោយស្វ័យប្រវត្តិ។ មាត្រានេះធ្លាប់បានចែងថាសហជីពអាចត្រូវបានរំលាយចោលក្នុងករណីដែលសហគ្រាស ឬគ្រឹះស្ថានត្រូវបានបិទលែងដំណើរការជាស្ថាពរ។ ឥឡូវនេះ មាត្រា ២៨ តម្រូវឱ្យមានការរំលាយចោលដោយស្វ័យប្រវត្តិ *“ក្នុងករណីដែលសហគ្រាស ឬគ្រឹះស្ថានត្រូវបានបិទលែងដំណើរការជាស្ថាពរ និងបន្ទាប់ពីបានបើកប្រាក់ឈ្នួលឱ្យកម្មករនិយោជិត និងប្រាក់បៀវត្ស រួមទាំងអត្ថប្រយោជន៍បន្ទាប់បន្សំផ្សេងទៀត*”។ ទោះបីជាយ៉ាងនេះក្តី សហជីពនៅតែអាចមានផលប្រយោជន៍ស្របច្បាប់ក្នុងការបន្តប្រតិបត្តិការបន្ទាប់ពីការបិទសហគ្រាស និងការទូទាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតគ្រប់ចំនួន។ ឧទាហរណ៍ សហជីពអាចនឹងធ្វើការទាមទារ ឬការពារបណ្តឹងទាមទារក្នុងនាមខ្លួនផ្ទាល់ ឬសមាជិករបស់ខ្លួន តួយ៉ាងការដាក់ពាក្យបណ្តឹងចំពោះសហគ្រាស បើទោះបីបន្ទាប់ពីសហគ្រាសត្រូវបានបិទទ្វារក៏ដោយដើម្បីទាមទារប្រាក់ភាគទានសហជីពដែលបានកាត់ដោយមិនត្រឹមត្រូវ។ ដូច្នេះ មាត្រា ២៨ នៅតែជាបញ្ហាពីព្រោះអនុញ្ញាតឱ្យមានការរំលាយចោលដោយស្វ័យប្រវត្តិដែលរារាំងសហជីពក្នុងការបំពេញមុខងាររបស់ខ្លួន។

**មាត្រា ២៩** មាត្រា ២៩ ត្រូវបានធ្វើវិសោធនកម្មឱ្យមានភាពប្រសើរឡើងខ្លះ។ មាត្រានេះការពារដល់សហជីពពីការរំលាយចោលក្នុងករណីដែលអ្នកដឹកនាំគ្រប់គ្រងរបស់សហជីពមានកំហុសធ្ងន់ក្នុង

---

[39] មាត្រា ២៧ គ្រប់គ្រងលើ *"របាយការណ៍ហិរញ្ញវត្ថុ"* ខណៈដែលមាត្រា ១៧ គ្រប់គ្រងលើ *"របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ"* ។

[40] មាត្រា ២៧ - ថ្មី: សហជីព ឬសមាគមនិយោជកទាំងអស់ត្រូវរក្សាទុកនូវរបាយការណ៍ហិរញ្ញវត្ថុស្របទៅតាមទម្រង់បែបបទដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ហើយត្រូវបង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនេះដល់សមាជិកសហជីពឬសមាគមនិយោជកស្របតាមលក្ខន្តិកៈនៃសហជីព ឬសមាគមនិយោជកនោះ ហើយត្រូវធ្វើសវនកម្មដោយស្ថាប័នសវនកម្មឯករាជ្យដែលបានចុះបញ្ជីស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងករណីដែលមានការស្នើសុំពី៖

- ១០% (ដប់ភាគរយ) នៃចំនួនសមាជិកសរុប ឬម្ចាស់ជំនួយណាមួយសម្រាប់សហជីពមូលដ្ឋាន និងសមាគមនិយោជក។
- ៥% (ប្រាំភាគរយ) នៃចំនួនសមាជិកសរុប ឬម្ចាស់ជំនួយណាមួយសម្រាប់សហព័ន្ធសហជីព សហភាពសហជីព និងសហព័ន្ធនិយោជក។

ការប្រព្រឹត្តបទល្មើស។[41] ទោះបីជាយ៉ាងនេះក្តី មានមូលហេតុផ្សេងទៀតដើម្បីរំលាយចោលសហជីព ដែលមិនមានភាពច្បាស់លាស់ ទូលំទូលាយ និងផ្ទុយនឹងច្បាប់អន្តរជាតិមិនត្រូវបានធ្វើវិសោធនកម្ម និងដកចេញនោះទេ។ មាត្រា ២៩ ចែងថាសហជីព (ក)ឬអង្គការនិយោជកអាចត្រូវបានរំលាយចោល ប្រសិនបើសកម្មភាពរបស់ខ្លួន *"មានលក្ខណៈផ្ទុយនឹងច្បាប់ ឬគោលដៅរបស់សហជីព ឬសមាគមនិយោជកដូចមានចែងក្នុងលក្ខន្តិកៈរបស់ខ្លួន"* ។ ដើម្បីឱ្យស្របតាមបទដ្ឋានអន្តរជាតិ រាល់ការរឹតត្បិតលើសេរីភាពខាងបង្កើតសមាគមត្រូវតែគោរពតាមលក្ខខណ្ឌបីចំណុចដូចមានចែងក្នុងមាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ទោះបីជាយ៉ាងនេះក្តី មាត្រា ២៩ មិនបានបំពេញតាម (ក)ជាតុផ្សំអង្គច្បាប់ក្នុងលក្ខខណ្ឌទី១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយទេ ដោយមិនបានកំណត់នូវអ្វីដែលជាលក្ខខណ្ឌ *"ផ្ទុយនឹងច្បាប់"* ។ តាមន័យទូលាយនៃមាត្រានេះបង្ហាញថាសូម្បីតែការរំលោភបំពានបន្តិចបន្តួចទៅលើច្បាប់ណាមួយ ឬការបំពានតិចតួចលើកម្មវត្ថុរបស់សហជីពនឹងនាំឱ្យមានការរំលាយចោលសហជីព។ ការរំលាយក្នុងកាលៈទេសៈទាំងនេះអាចនឹងមិនគោរពតាមធាតុផ្សំក្នុងលក្ខខណ្ឌទី៣ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ពីព្រោះការរំលាយចោលមិនមែនជាវិធានការរឹតត្បិតដែលចាំបាច់ដើម្បីការពារគោលបំណងស្របច្បាប់នោះទេ។ ការរឹតត្បិតលើសេរីភាពខាងការបង្កើតសមាគម មិនសមាមាត្រទៅនឹងគោលបំណងស្របច្បាប់ក្នុងការការពារសិទ្ធិនិងសេរីភាពរបស់អ្នកដទៃនោះទេ។ វិធានការដែលមានលក្ខណៈបន្ធូរបន្ថយអាចត្រូវបានប្រើដើម្បីដាក់ពិន័យចំពោះសហជីព ឬសមាគមនិយោជកដែលធ្វើសកម្មភាពផ្ទុយនឹងច្បាប់ ឬគោលដៅរបស់ខ្លួនដែលបានចែង។ ការរំលាយចោលគួរត្រូវបានធ្វើឡើងសម្រាប់តែករណីដែលធ្ងន់ធ្ងរបំផុតប៉ុណ្ណោះ។

**មាត្រា ៥៤ & ៥៥**

ការធ្វើវិសោធនកម្មលើមាត្រា ៥៤ និង ៥៥ បានកែសម្រួលលក្ខខណ្ឌដើម្បីឱ្យសហជីពទទួលបានភាពជាតំណាងបំផុត។ ឥឡូវនេះ មាត្រាទាំងពីរតម្រូវឱ្យសហជីពដែលដាក់ស្នើសុំភាពជាតំណាងបំផុត ឱ្យដាក់ជូនបញ្ជីឈ្មោះសមាជិករបស់ខ្លួន ដែលបង់ប្រាក់ភាគទាន។[42] ទោះបីជាយ៉ាងនេះក្តី គណៈកម្មាធិការខាងសេរីភាពក្នុងការបង្កើតសមាគម ធ្លាប់បានរកឃើញថាលក្ខខណ្ឌនេះបង្កជាបញ្ហាចោទនឹងគោលការណ៍ ស្តីពីសេរីភាពខាងបង្កើតសមាគមដោយពិចារណាលើហានិភ័យចំពោះការសងសឹកនិងការរើសអើងប្រឆាំងសហជីពដែលកម្មករនិយោជិតមានឈ្មោះក្នុងបញ្ជីនោះអាចនឹងជួបប្រឈម។[43] មាត្រា ៥៤ និងមាត្រា ៥៥ ទោះបីត្រូវបានធ្វើវិសោធនកម្មក៏ដោយ ក៏នៅតែផ្តល់សិទ្ធិផ្តាច់មុខក្នុងការចរចាអនុ

---

[41] មុនពេលធ្វើវិសោធនកម្មឆ្នាំ ២០២០ មាត្រា ២៩ បានអនុញ្ញាតឱ្យមានការរំលាយចោលនៅពេលដែល " *អ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលត្រូវបានរកឃើញថាមានកំហុសធ្ងន់ ក្នុងការប្រព្រឹត្តល្មើស ក្នុងនាមសហជីព ឬសមាគមនិយោជក"* ។

[42] មាត្រា ៥៤ (២) (គ) ចែងថាសហជីពនឹងទទួលបានភាពជាតំណាងបំផុតប្រសិនបើខ្លួនមាន " បញ្ជីឈ្មោះសមាជិកបង់ប្រាក់ភាគទានច្រើនជាងគេ" ។ មាត្រា ៥៥ ចែងថាដើម្បីក្លាយជាសហជីពដែលមានភាពជាតំណាងបំផុត សហជីពត្រូវមានជាអាទិ៍ " បញ្ជីឈ្មោះសមាជិកដែលប្រាក់ភាគទានសមាជិកភាពត្រូវបានកាត់ពី ៣០% នៃចំនួនកម្មករនិយោជិតសរុប ឬលើសពីនេះ" ។

[43] កថាខណ្ឌ ៥៣៦ "កម្រងសេចក្តីសម្រេចរបស់គណៈកម្មាធិការខាងសេរីភាពក្នុងការបង្កើតសមាគមឆ្នាំ ២០១៨ " របស់អង្គការ ILO <https://www.ilo.org/wcmsp5/groups/public/---ed_norm/---normes/documents/publication/wcms_632659.pdf>.

សញ្ញារួម និងដោះស្រាយវិវាទការងារដល់សហជីពដែលមានភាពជាតំណាងបំផុត។[44] ដូច្នេះមាត្រាទាំងពីរនៅតែរារាំងដល់លទ្ធភាពរបស់សហជីពដែលមានសមាជិកភាគតិចក្នុងការចូលរួមចរចាអនុសញ្ញារួម និងដោះស្រាយវិវាទការងារជាមួយសហជីពដែលមានភាពជាតំណាងបំផុត។ ការហាមឃាត់សហជីពដែលមានសមាជិកភាគតិចមិនឱ្យចូលរួមក្នុងការចរចាអនុសញ្ញារួម និងដោះស្រាយវិវាទជាមួយសហជីពដែលមានភាពជាតំណាងបំផុត មាត្រា ៥៤ និង ៥៥ បានដកហូតដោយមិនត្រឹមត្រូវពីសហជីពដែលមានសមាជិកភាគតិចនូវមធ្យោបាយជាសារវន្តចំនួនពីរដើម្បីការពារផលប្រយោជន៍ការងាររបស់សមាជិករបស់ពួកគេ។[45]

**មាត្រា ៥៩** មាត្រា ៥៩ ត្រូវបានធ្វើវិសោធនកម្ម ដើម្បីបញ្ចូលបន្ថែមនូវអញ្ញត្រកម្មមួយ ដែលអនុញ្ញាតឱ្យសហជីពដែលមានសមាជិកភាគតិច " *ធ្វើជាតំណាងឱ្យសមាជិករបស់ខ្លួនដោយផ្ទាល់នៅក្នុងវិវាទការងាររួមដែលមិនមែនកើតចេញពីអនុសញ្ញារួម* "។ ឥឡូវនេះ បញ្ញត្តិនេះការពារនូវសិទ្ធិរបស់សហជីពដែលមានភាពជាតំណាងភាគតិចដើម្បីតំណាងឱ្យសមាជិករបស់ខ្លួននៅក្នុងវិវាទការងាររួមដែលមិនមែនកើតចេញពីអនុសញ្ញារួម។ ទោះបីជាយ៉ាងនេះក្តី អញ្ញត្រកម្មនេះមានវិសាលភាពតូច ហើយច្បាប់ស្តីពីសហជីពនៅតែដកហូតសិទ្ធិក្នុងការចូលរួមរបស់សហជីពដែលមានសមាជិកភាគតិចនៅក្នុងការចរចាអនុសញ្ញារួម ឬការដោះស្រាយវិវាទការងាររួមជាមួយសហជីពដែលមានភាពជាតំណាងបំផុត ។ ដូច្នេះហើយ មាត្រា ៥៤ មាត្រា ៥៥ និងមាត្រា៥៩ នៅតែបន្តរារាំងសហជីពដែលមានសមាជិកភាគតិច ពីការធ្វើជាតំណាងឱ្យសមាជិករបស់ខ្លួននៅក្នុងវិវាទទាំងអស់ ដោយបានរឹតត្បិតលើសេរីភាពខាងបង្កើតសមាគម ដែលមានលក្ខណៈផ្ទុយនឹងបទដ្ឋានអន្តរជាតិ។ ជារួម ច្បាប់ស្តីពីសហជីពដែលបានធ្វើវិសោធនកម្មរួចនៅតែមិនទាន់បានបំពេញតាមបទដ្ឋានពលកម្មអន្តរជាតិ ហើយរឹតត្បិតលើសេរីភាពខាងបង្កើតសមាគម។ មាត្រាដែលត្រូវបានធ្វើវិសោធនកម្មរួចរួមជាមួយបញ្ញត្តិដែលមានបញ្ហាចម្រូងចម្រាសដទៃទៀតដែលមិនទាន់ត្រូវបានធ្វើវិសោធនកម្ម[46]បង្ហាញថា ច្បាប់ស្តីពីសហជីពមិនបានការពារសេរីភាពខាងបង្កើតសមាគម ឱ្យបានពេញលេញដូចដែលបានចែងទាំងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងអនុសញ្ញាលេខ៨៧ របស់អង្គការពលកម្មអន្តរជាតិនោះទេ។

---

[44] មាត្រា ៥៤ (១) ចែងថា" [...] សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម សហជីពដែលមានភាពជាតំណាងបំផុតត្រូវបានផ្តល់សិទ្ធិផ្តាច់មុខក្នុងការធ្វើដូច្នេះ" ។ មាត្រា ៥៥ (២) ចែងថា " សហជីពដែលមានភាពជាតំណាងបំផុតមានសិទ្ធិធ្វើជាតំណាងឱ្យកម្មករនិយោជិតទាំងអស់ក្នុងការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួមជាមួយនិយោជក ឬសមាគមនិយោជកនៃវិជ្ជាជីវៈ ឬសកម្មភាពសេដ្ឋកិច្ច ឬវិស័យនោះ" ។

[45] សូមមើលជាឧទាហរណ៍ កថាខណ្ឌ ៦២៧ ករណីលេខ ៣១២៣ (ប៉ារ៉ាហ្គាយ) របាយការណ៍លេខ ៣៧៨ (ខែមិថុនា ឆ្នាំ ២០១៦) របស់គណៈកម្មាធិការខាងសេរីភាពក្នុងការបង្កើតសមាគម "*ទាក់ទងនឹងបញ្ហានេះ គណៈកម្មាធិការពិចារណាថាច្បាប់ ឬការអនុវត្តមិនគួរកំណត់សិទ្ធិរបស់និយោជក និងអង្គការកម្មករនិយោជិកក្នុងការតំណាងសមាជិករបស់ខ្លួនឡើយ...*" ។ កថាខណ្ឌ៥៤៥ ករណីលេខ ១៣៨៥(នូវែលសេឡង់)របាយការណ៍លេខ២៥៩(ខែវិច្ឆិកា ឆ្នាំ១៩៨៨) របស់គណៈកម្មាធិការខាងសេរីភាពក្នុងការបង្កើតសមាគម "*...អង្គការ សំឡេងភាគតិចគួរត្រូវបានអនុញ្ញាតឱ្យអនុវត្តសកម្មភាពរបស់ពួកគេ ហើយយ៉ាងហោចណាស់ក៏មានសិទ្ធិបញ្ចេញមតិក្នុងនាមសមាជិករបស់ពួកគេ និងធ្វើជាតំណាងរបស់ពួកគេ*"។

[46] មាត្រា ៦៥ និង ៩២។ សូមមើល "ការការពារសេរីភាពមូលដ្ឋាន"៖ របាយការណ៍ត្រួតពិនិត្យសម្ភារឯកសារនីតិកម្មក្នុងស្រុក និងអនុលោមភាពតាមច្បាប់អន្តរជាតិ (ខែធ្នូ ឆ្នាំ ២០១៩) ទំព័រទី ៤០ - ៤១
<https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=140&id=5>.

## ២.២ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិក្នុងភាពអាសន្នផ្តល់អំណាចយ៉ាងធំទូលាយនិងគ្មានដែនកំណត់ដើម្បីរឹតត្បិតយ៉ាងខ្លាំងលើសេរីភាពមូលដ្ឋានក្នុងគ្រាមានអាសន្ន

*ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន(ច្បាប់ស្តីពីគ្រាអាសន្ន)* មានបញ្ញត្តិមួយចំនួនដែលរឹតត្បិតលើសិទ្ធិមនុស្សដែលបំពានលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់អន្តរ (រដ្ឋធម្មនុញ្ញ) ជាតិ។ ខណៈពេលដែលបណ្តារដ្ឋនានាអាចដាក់ចេញនូវច្បាប់ដើម្បីគ្រប់គ្រងការប្រកាសភាពអាសន្ន ច្បាប់ស្តីពីគ្រាអាសន្នត្រូវតែអនុលោមតាមបទដ្ឋានច្បាប់ពាក់ព័ន្ធនានា។[47] ច្បាប់សិទ្ធិមនុស្សអន្តរជាតិចែងថាច្បាប់បែបនេះអាចអនុញ្ញាតឱ្យមានការដកហូតសិទ្ធិ*ជាបណ្តោះអាសន្ន* នូវសិទ្ធិមនុស្សមួយចំនួននៅក្នុងកាលៈទេសៈនៃភាពអាសន្នជាសាធារណៈ ប៉ុន្តែការដកហូតសិទ្ធិដែលបានអនុញ្ញាតទាំងនេះស្ថិតនៅក្រោមលក្ខខណ្ឌច្បាប់តឹងរ៉ឹងដើម្បីធានាថាសិទ្ធិមនុស្សត្រូវបានការពារគ្រប់គ្រាន់ក្នុងពេលមានអាសន្ន។ *ច្បាប់ស្តីពីគ្រាអាសន្ន* មិនអនុលោមតាមលក្ខខណ្ឌទាំងនេះទេ។

*ច្បាប់ស្តីពីគ្រាអាសន្ន* ដាក់ចេញនូវវិធានការ ១២ ចំណុចដែលរាជរដ្ឋាភិបាលកម្ពុជាអាចអនុវត្តបានក្នុងគ្រាមាន អាសន្ន។ វិធានការទាំងនេះដែលមានចែងក្នុងមាត្រា ៥ មានលក្ខណៈទូលំទូលាយ ហើយមិនគោរពតាមបទដ្ឋានអន្តរជាតិទេ។ ជាលទ្ធផល *ច្បាប់ស្តីពីគ្រាអាសន្ន*មានការប៉ះពាល់ដល់សេរីភាពខាងបង្កើតសមាគម សេរីភាពខាងការការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ។ ទិដ្ឋភាពរួមអំពីបញ្ញត្តិចំនួនបួនដែលជះឥទ្ធិពលលើសេរីភាពមូលដ្ឋានមានដូចខាងក្រោម៖

**មាត្រា ៥ (២)** មាត្រា ៥អនុញ្ញាតឱ្យរាជ (២)រាជរដ្ឋាភិបាលកម្ពុជាកម្ពុជាធ្វើការ “ *ហាមឃាត់ ឬរឹតត្បិតទៅលើសិទ្ធិក្នុងការជួបប្រជុំ និងប្រមូលផ្តុំគ្នា* ” ។ នេះគឺជាអំណាចដែលគ្មានដែនកំណត់ក្នុងការហាមឃាត់ ឬដាក់កម្រិតពលរដ្ឋមិនឱ្យប្រមូលផ្តុំ ឬជួបប្រជុំ។ ការរឹតត្បិតលើសេរីភាពក្នុងការជួបប្រជុំ[48] និងបង្កើតសមាគមដោយសន្តិវិធីបែបនេះ ជាការរំលោភបំពានលើច្បាប់អន្តរជាតិ។

**មាត្រា ៥ (៣)** មាត្រា ៥អនុញ្ញាតឱ្យ (៣)រាជរាជរដ្ឋាភិបាលកម្ពុជាកម្ពុជា“ *ហាមឃាត់ ឬរឹតត្បិតលើសកម្មភាពការងារ ឬប្រកបអាជីវកម្ម* ”។ មាត្រានេះអាចត្រូវបានប្រើដើម្បីហាមឃាត់កិច្ចការអាជីវកម្មទាំងឡាយ រាប់បញ្ចូលទាំងអង្គការសង្គមស៊ីវិល ឬសហជីពដែលប៉ះពាល់ដល់សេរីភាពក្នុងការបង្កើតស

---

[47] មាត្រា ៤ នៃអនុសញ្ញា ICCPR ។ សូមមើលផងដែរ៖ សេចក្តីពន្យល់ទូទៅអំពី CCPR លេខ ២៩ របស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ៖ មាត្រា ៤៖ ការដកហូតសិទ្ធិក្នុងគ្រាអាសន្ន ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០១, CCPR/C/21/Rev.1/Add.11.

[48] សិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីដែលត្រូវបានទទួលស្គាល់ដោយមាត្រា ២១ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ រួមមានសិទ្ធិចូលរួមរាល់ការប្រមូលផ្តុំដោយសន្តិវិធី ដោយចេតនា និងបណ្តោះអាសន្ននៅកន្លែងឯកជន ឬសាធារណៈសម្រាប់គោលបំណងជាក់លាក់រួមមាន៖ ការជួបប្រជុំ ការប្រជុំផ្ទៃក្នុង បាតុកម្មតវ៉ា កូដកម្ម បាតុកម្មដោយការអង្គុយ បាតុកម្ម និងការប្រមូលផ្តុំបណ្តោះអាសន្នផ្សេងទៀតសម្រាប់គោលបំណងជាក់លាក់នានា។ កថាខណ្ឌ ២៤ នៃរបាយការណ៍ទិន្នន័យដំបូងរបស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងការបង្កើតសមាគម Maina Kiai, UN Doc. A/HRC/20/27 ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១២ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។ សិទ្ធិសេរីភាពក្នុងការជួបប្រជុំក៏ត្រូវបានការពារផងដែរនៅក្នុងច្បាប់ជាតិតាមរយៈមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញបន្ថែមលើសិទ្ធិធ្វើកូដកម្ម និងរៀបចំបាតុកម្មដោយសន្តិវិធីដែលត្រូវបានការពារក្នុងមាត្រា ៣៧ ។

មាគម។ មាត្រានេះក៏អាចត្រូវបានប្រើដើម្បីរំលោភលើសិទ្ធិក្នុងការប្រកបកិច្ចការនៃបណ្តាញប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអ្នកសារព័ត៌មាន ហើយថែមទាំងបានបិទបណ្តាញប្រព័ន្ធផ្សព្វផ្សាយ ដែលទាំងអស់នេះជាការរំលោភលើសេរីភាពក្នុងការបញ្ចេញមតិ។ វិធានការបែបនេះ មានលក្ខណៈស្របច្បាប់ទៅតាមច្បាប់អន្តរជាតិ នៅពេលវេលាចាំបាច់ដើម្បីលើកកម្ពស់សុខភាព ឬសុវត្ថិភាពសាធារណៈ ។

មាត្រា ៩

មាត្រា ៩ ចែងថានីតិបុគ្គលអាចទទួលខុសត្រូវព្រហ្មទណ្ឌពីបទមិនគោរព ឬការរាំងស្ទះដល់ការអនុវត្តវិធានការជាតិដែលមានចែងក្នុងច្បាប់ក្នុងពេលប្រកាសអាសន្ន។ ជាឧទាហរណ៍ អង្គការសង្គមស៊ីវិលអាចនឹងរងការដាក់ពិន័យ“ *មួយ ឬច្រើនបន្ថែមទៀតដូចដែលមានចែងក្នុង មាត្រា ១៦៨ នៃក្រមព្រហ្មទណ្ឌ*” រួមទាំងការរំលាយចោល ឬការបិទអង្គភាពដោយបង្ខំផងដែរ[49] ដែលមានវិសមិតភាពជាមួយនឹងសេរីភាពខាងបង្កើតសមាគម។

មាត្រា ៥ (១១)

មាត្រា ៥ផ្តល់អំណាចដល់ (១១)រាជរដ្ឋាភិបាលកម្ពុជាកម្ពុជាក្នុងការ “ *ហាមឃាត់ ឬរឹតត្បិតលើការចែករំលែកព័ត៌មាន ឬប្រព័ន្ធផ្សព្វផ្សាយ*” នៅពេលដែលការបញ្ចេញមតិនោះអាច “ *ធ្វើឱ្យប្រជាជនមានការភ័យខ្លាច ឬបង្កចលាចល ឬអន្តរាយដល់សន្តិសុខជាតិ*” ឬអាចបង្ក “*ការភាន់ច្រឡំ*” ដល់សាធារណជន។ មាត្រានេះរំលោភលើសេរីភាពខាងការបញ្ចេញមតិ[50] ពីព្រោះវាអនុញ្ញាតឱ្យមានការរឹតត្បិតលើការនិយាយស្តីដោយផ្អែកលើប្រភេទនៃការបញ្ចេញមតិដែលមិនច្បាស់លាស់ មិនបានកំណត់ត្រឹមត្រូវ ហើយដែលធ្វើឡើងតាមទំនើងចិត្ត។

ការវិភាគដោយលម្អិតលើអនុលោមភាពនៃច្បាប់ ស្តីពីគ្រាអាសន្នជាមួយនឹងសេរីភាពមូលដ្ឋាន ក្នុងការបង្កើតសមាគម ខាងការបញ្ចេញមតិ និងខាងការជួបប្រជុំដោយសន្តិវិធីនឹងត្រូវបានបញ្ចូលនៅក្នុងរបាយការណ៍ឆ្នាំទី៥ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ។

មានការវិវឌ្ឍផ្នែកច្បាប់តិចតួចនៅក្នុងឆ្នាំទី ៤ នេះ ដែលប៉ះពាល់ដល់សេរីភាពខាងបង្កើតសមាគម សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ។ ច្បាប់សំខាន់មួយដែលត្រូវបានធ្វើវិសោធនកម្ម គឺច្បាប់ស្តីពីសហជីពបន្តដាក់បញ្ចូលបញ្ញត្តិជាច្រើនដែលផ្ទុយនឹងច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ រាជរដ្ឋាភិបាលកម្ពុជាកម្ពុជាមានឱកាសក្នុងការធ្វើឱ្យច្បាប់ស្តីពីសហជីពមានលក្ខណៈស្របតាមច្បាប់អន្តរជាតិ ប៉ុន្តែ

---

[49] "ការព្យួរសកម្មភាព និងការរំលាយចោលសមាគមដោយបង្ខំគឺជាប្រភេទនៃការរឹតត្បិតធ្ងន់ធ្ងរបំផុតលើសេរីភាពខាងបង្កើតសមាគម។ ជាលទ្ធផល វាអាចធ្វើទៅបានលុះត្រាតែមានព្យសនកម្មច្បាស់លាស់ និងបណ្តាលឱ្យមានការបំពានជាក់ស្តែងលើច្បាប់ជាតិដែលអនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ" ។ កថាខណ្ឌ ៧៥ នៃរបាយការណ៍ទិន្នន័យដំបូងរបស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងការបង្កើតសមាគម Maina Kiai, UN Doc. A/HRC/20/27 ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១២ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។
<https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session20/A-HRC-20-27_en.pdf>.

[50] មាត្រា ១៩(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ *"មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពក្នុងការស្វែងរក ទទួលបាន និងចែកចាយព័ត៌មាន និងគំនិតគ្រប់ប្រភេទដោយគ្មានដែនកំណត់ មិនថាដោយផ្ទាល់មាត់ជាលាយលក្ខណ៍អក្សរឬការបោះពុម្ពក្នុងទម្រង់សិល្បៈ ឬតាមរយៈបណ្តាញផ្សព្វផ្សាយផ្សេងទៀតតាមជម្រើសរបស់ខ្លួន "* ។

វិសោធនកម្មដែលបានធ្វើឡើងគឺមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយ និងធ្វើឱ្យសេរីភាពខាងបង្កើតសមាគម ដោយគ្មានការការពារគ្រប់គ្រាន់។ រាជរាជរដ្ឋាភិបាលកម្ពុជាកម្ពុជាត្រូវបានផ្តល់ជូននូវព័ត៌មានយ៉ាងទូលំទូលាយ ដោយបណ្តាភាគីពាក់ព័ន្ធដែលកំពុងតស៊ូមតិ ដើម្បីឱ្យមានការធ្វើវិសោធនកម្មច្បាប់កាន់តែប្រសើរឡើង ហើយ ធ្វើយ៉ាងណាដើម្បីឱ្យច្បាប់នេះអនុលោមតាមបទដ្ឋានអន្តរជាតិ។ ទោះបីយ៉ាងនេះក៏ដោយ ក៏រាជរាជរដ្ឋាភិបាល កម្ពុជាកម្ពុជាមានចេតនាទុកចោលនូវចំណុចកែតម្រូវជាច្រើន ដែលភាគីពាក់ព័ន្ធបានស្នើឡើងក្នុងការធ្វើ វិសោធនកម្មនេះ ដោយជ្រើសរើសមិនវិសោធនកម្មច្បាប់នេះឱ្យអនុលោមទៅតាមកាតព្វកិច្ចសិទ្ធិមនុស្សរបស់ ប្រទេសកម្ពុជា។

សេចក្តីសន្និដ្ឋានដែលបានដកស្រង់ចេញពីការវិភាគផ្នែកក្របខ័ណ្ឌច្បាប់ក្នុងឆ្នាំទី៤នេះ គឺថាក្របខ័ណ្ឌច្បាប់ របស់ប្រទេសកម្ពុជានៅតែមិនអនុលោមតាមច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិនៅឡើយ ជុំវិញសេរីភាព មូលដ្ឋាន។ ច្បាប់ជាតិនៅតែរឹតត្បិតលើសេរីភាពខាងបង្កើតសមាគម និងសេរីភាពខាងការបញ្ចេញមតិ ខណៈ ដែលច្បាប់ពាក់ព័ន្ធនឹងសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីអនុលោមបានតិចតួចតាមកាតព្វកិច្ចសិទ្ធិមនុស្ស របស់ប្រទេសកម្ពុជា។

## ៣. ចំណុចគន្លឹះទីពីរៈ តើក្របខ័ណ្ឌច្បាប់សម្រាប់សេរីភាពមូលដ្ឋានត្រូវបានអនុវត្ត និងពង្រឹងការអនុវត្តបានត្រឹមត្រូវដែរឬទេ?[51]

ចំណុចគន្លឹះទីពីរ ពិនិត្យមើលពីវិសាលភាពនៃក្របខ័ណ្ឌច្បាប់ជាតិសម្រាប់សេរីភាពមូលដ្ឋាន ថាតើត្រូវបានអនុវត្ត និងពង្រឹងការអនុវត្តបានត្រឹមត្រូវក្នុងកម្រិតណា។

**របកគំហើញសំខាន់ៗ៖** ដើម្បីអនុលោមតាមច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ច្បាប់ដែលជះឥទ្ធិពលដល់សេរីភាពមូលដ្ឋានត្រូវតែអនុវត្តតាមបទដ្ឋានគតិយុត្ត ហើយត្រូវអនុវត្តប្រកបដោយសង្គតិភាព និងមិនតាមទំនើងចិត្ត។ នៅក្នុងឆ្នាំទីបួន គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន បានកត់ត្រាការរឹតត្បិតជាប្រចាំលើសេរីភាពមូលដ្ឋានដែលអាជ្ញាធរថ្នាក់ជាតិនិងថ្នាក់មូលដ្ឋានបានអនុវត្ត ដែលនេះបង្ហាញពីកង្វះការអនុវត្តឱ្យអនុលោមទៅតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់ជាតិ។ គម្រោងបានរកឃើញថាថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពត្រូវបានអាជ្ញាធរកំណត់ជាមុខសញ្ញាជាញឹកញាប់ដោយសារការអនុវត្តសេរីភាពមូលដ្ឋាន។

ជារួមគម្រោងបន្តកត់សម្គាល់ថាច្បាប់ដែលប៉ះពាល់ដល់សេរីភាពមូលដ្ឋាននៅតែបន្តប្រើប្រាស់ខុសទិសដៅជាលក្ខណៈ ប្រព័ន្ធ។ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានកត់ត្រាហេតុការណ៍សរុបចំនួន ៦៥៦ ករណីដែលទាក់ទងទៅនឹងការអនុវត្តសេរីភាពមូលដ្ឋានក្នុងឆ្នាំទី៤។ ក្នុងចំណោមហេតុការណ៍ទាំងនេះ មាន ៥៣៧ ករណីត្រូវបានកត់ត្រាតាមរយៈការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ និងការរាយការណ៍ពីហេតុការណ៍ចំនួន ១១៩ ករណីផ្សេងទៀតត្រូវបានរាយការណ៍តាមរយៈយន្តការ ការរាយការណ៍ពីហេតុការណ៍របស់គម្រោង។ របកគំហើញសំខាន់ៗពីការរាយការណ៍ពីហេតុការណ៍ទាំងនេះមានបង្ហាញដូចខាងក្រោម។

### ៣.១ សិទ្ធិសេរីភាពមូលដ្ឋានត្រូវបានរឹតត្បិត និងរំលោភបំពានដែលជាហេតុនាំឱ្យលំហសង្គមស៊ីវិលរួមតូច

ទោះបីសេរីភាពមូលដ្ឋានត្រូវបានការពារក្នុងច្បាប់ជាតិ និងអន្តរជាតិក៏ដោយ ការរឹតត្បិត និងការរំលោភបំពានលើសេរីភាពទាំងនេះនៅតែបន្តកើតមានជាប្រចាំ។ ការរឹតត្បិត និងការរំលោភបំពានសេរីភាពទាំងនេះគឺជាលទ្ធផលនៃការអនុវត្តច្បាប់ដោយមិនត្រឹមត្រូវជាលក្ខណៈប្រព័ន្ធ ។

ក្នុងឆ្នាំទីបួន គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានកត់ត្រាការរឹតត្បិតលើសេរីភាពមូលដ្ឋាននៅគ្រប់ខេត្តក្រុងទាំងអស់។ ការរឹតត្បិតហាក់ដូចជាកើតឡើងជាក់លាក់នៅពេលដែលពលរដ្ឋមួយចំនួនធំព្យាយាមអនុវត្តសេរីភាពមូលដ្ឋានរបស់ពួកគេ។ ពីភាគបីនៃហេតុការណ៍ទាំងអស់ដែលគម្រោងបានកត់ត្រា រួមមានការ

[51] របកគំហើញនៅក្នុងចំណុចគន្លឹះទីពីរផ្អែកលើលទ្ធផលការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ ការរាយការណ៍ពីហេតុការណ៍ ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលធ្វើឡើងនៅខែមករា ឆ្នាំ២០២០ ការស្ទង់មតិជាសាធារណៈធ្វើឡើងនៅខែមីនា ឆ្នាំ ២០២០ និងឧបករណ៍វាយតម្លៃការចុះបញ្ជីសហជីព។ វិធីសាស្ត្រប្រមូលទិន្នន័យទាំងនេះត្រូវបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ១ ។

រឹតត្បិត ឬការរំលោភបំពានលើសេរីភាពមូលដ្ឋានមួយ ឬច្រើន[52]។ ក្នុងចំណោមហេតុការណ៍ចំនួន ៦៥៦ ករណី ដែលបានកត់ត្រា មានហេតុការណ៍ចំនួន ៤៤០ ករណីដែលពាក់ព័ន្ធការរឹតត្បិតសេរីភាពមូលដ្ឋាន (៦៧%) និង ហេតុការណ៍ចំនួន ២៤៦ ករណីដែលពាក់ព័ន្ធការរំលោភបំពាន (៣៨%) ។

**តារាងតួលេខទី១៣៖ ផែនទីភូមិសាស្ត្រនៃហេតុការណ៍ដែលការរឹតត្បិតលើសេរីភាពមូលដ្ឋានត្រូវបានកត់ត្រា**




ការរឹតត្បិតត្រូវបានកត់ត្រានៅគ្រប់ខេត្តក្រុងទាំងអស់ដែលភាគច្រើនកើតឡើងនៅរាជធានីភ្នំពេញ។

[52] ការរឹតត្បិត និងការរំលោភបំពានលើសិទ្ធិគឺខុសគ្នាត្រង់ថាការរឹតត្បិតអាចត្រូវបានអនុញ្ញាតដោយច្បាប់ក្រោមកាលៈទេសៈជាក់លាក់ ខណៈដែលការរំលោភសិទ្ធិមនុស្សមានលក្ខណៈផ្ទុយជាក់ស្តែងនឹងបទដ្ឋានច្បាប់អន្តរជាតិ។ ឧទាហរណ៍ដើម្បីកំណត់ថា តើការរឹតត្បិតលើការនិយាយស្តីគឺជាការរំលោភបំពានឬអត់ គម្រោងនឹងពិនិត្យថាតើការរឹតត្បិតនោះចូលក្នុងលក្ខខណ្ឌ ៣ ចំណុចដែលមានចែងក្នុងមាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដែរឬទេ។ ប្រសិនបើការរឹតត្បិតបានចូលក្នុងលក្ខខណ្ឌបីចំណុច នោះនឹងចាត់ទុកថាជាការរំលោភបំពាន។

**តារាងតួលេខទី១៤ ៖ ភាពញឹកញាប់នៃហេតុការណ៍ដែលមានការរឹតត្បិត ឬការរំលោភលើសេរីភាពមូលដ្ឋាន**




ក្នុងអំឡុងពេលឆ្នាំទីបួននេះ ហេតុការណ៍នៃការរឹតត្បិត និងការរំលោភបំពានមាន ៤ ករណីធំៗដែលក្នុងនោះមួយករណីមិនផ្សារភ្ជាប់ទៅនឹងព្រឹត្តិការណ៍ជាក់លាក់ និងបីករណីទៀតកើតឡើងស្របពេលជាមួយនឹងព្រឹត្តិការណ៍ជាក់លាក់ដែលប៉ះពាល់ដល់សេរីភាពមូលដ្ឋាន៖

- **ខែឧសភា ឆ្នាំ២០១៩៖** ការចេញដីកាកោះហៅជាលក្ខណៈប្រព័ន្ធឱ្យសមាជិកអតីតគណបក្សសង្គ្រោះជាតិបង្ហាញខ្លួននៅតុលាការក្រោមការចោទប្រកាន់ពីបទរំលោភលើសាលដីការបស់តុលាការកំពូលកាលពីខែវិច្ឆិកា ឆ្នាំ ២០១៧ ដែលបានរំលាយគណបក្សសង្គ្រោះជាតិ។
- **ខែកក្កដា ឆ្នាំ២០១៩៖** ការជ្រៀតជ្រែកក្នុងការជួបប្រជុំ និងពិធីរំឭកវិញ្ញាណក្ខន្ធគម្រប់ខួប៣ឆ្នាំនៃការធ្វើឃាតលោកបណ្ឌិត កែម ឡី។
- **ខែកញ្ញា និងខែតុលា ឆ្នាំ២០១៩៖** ការកើនឡើងនៃសកម្មភាពរឹតត្បិតដោយរដ្ឋាភិបាលកម្ពុជាស្របពេលជាមួយនឹងការប្រកាសវិលត្រឡប់របស់ លោក សម រង្ស៊ី ។
- **ខែកុម្ភៈ និងមីនា ឆ្នាំ២០២០៖** ការកើនឡើងនៃការរឹតត្បិតជាបណ្ដើរៗ ជាពិសេសសេរីភាពក្នុងការបញ្ចេញមតិនៅពេលដែលមានការចាប់ផ្ដើមរីករាលដាលជាសកលនៃជំងឺកូវីដ ១៩ ។

ករណីដែលត្រូវបានកត់ត្រាដោយគម្រោង ជារឿយៗ មានការរំលោភបំពាន ឬការរឹតត្បិតចំពោះសេរីភាពមូលដ្ឋានជាច្រើន។ គម្រោងកត់ត្រាទាំងចំនួនហេតុការណ៍ដែលការរឹតត្បិត ឬការរំលោភលើសេរីភាពជាមូលដ្ឋានកើតឡើង ក៏ដូចជាការរឹតត្បិត និងការរំលោភលើសេរីភាពមូលដ្ឋាននីមួយៗដែលរួមបញ្ចូលទាំងការរឹតត្បិត ឬការបំពានផ្សេងៗចេញពីហេតុការណ៍ដូចគ្នា។ ចំនួនសរុបនៃការរឹតត្បិត និងការរំលោភលើសិទ្ធិនីមួយៗគឺច្រើនជាងចំនួនហេតុ**ការណ៍**ដែលមានការរឹតត្បិត ឬការរំលោភបំពាន។

**តារាងតួលេខទី១៥ ៖ ចំនួនសរុបនៃករណីរឹតត្បិត និងការបំពានមកលើសេរីភាពមូលដ្ឋាននីមួយៗ**




នៅក្នុងឆ្នាំទីបួននេះ បានកត់ត្រាការរឹតត្បិតចំនួន ៣៣៨ ករណី (ស្មើនឹង៥៨% នៃចំនួនករណីនៃការរឹតត្បិតសរុប) និងការរំលោភសេរីភាពខាងសមាគមចំនួន ១៨៦ ករណី (ស្មើនឹង ៦០% នៃចំនួនសរុបនៃរឹតត្បិត និងការរំលោភខាងសមាគម)។ ចំណែកសេរីភាពខាងការបញ្ចេញមតិត្រូវបានរឹតត្បិតផងដែរ នៅក្នុងឆ្នាំទីបួន ដោយមានការរឹតត្បិតជាក់លាក់ចំនួន ២៤៥ ករណីដែលក្នុងនោះ ១០៣ ករណី បានរំលោភលើច្បាប់ជាតិ និងអន្តរជាតិ។ ផ្ទុយទៅវិញ សេរីភាពខាងការជួបប្រជុំភាគច្រើនត្រូវបានគាំទ្រដោយមានតែ ៥៣ ករណីត្រូវបានរឹតត្បិត និង ២១ ករណីប៉ុណ្ណោះមានការរំលោភបំពាន។ តួលេខអំពីសេរីភាពខាងការជួបប្រជុំទាំងនេះបានធ្លាក់ចុះជាងពាក់កណ្ដាលចាប់តាំងពីឆ្នាំទីបី ដែលហាក់ដូចជាបង្ហាញពីភាពប្រសើរឡើងនៃការការពារសិទ្ធិនេះ។

ការថយចុះនូវសេរីភាពមូលដ្ឋាននាំឱ្យមានការបង្រួមលំហសង្គមស៊ីវិល។ សេរីភាពខាងសមាគម សេរីភាពខាងការការជួបជុំ និងសេរីភាពខាងការបញ្ចេញមតិគឺជាស្នូលនៃការអនុវត្តសិទ្ធិមនុស្សទាំងអស់។ សេរីភាពមូលដ្ឋានផ្ដល់អំណាចដល់ពលរដ្ឋឱ្យចូលរួមក្នុងសកម្មភាពដើម្បីទាមទារឱ្យមានការផ្លាស់ប្ដូរសង្គមកាន់តែប្រសើរឡើង។ បើគ្មានលទ្ធភាពក្នុងការអនុវត្តសេរីភាពមូលដ្ឋានរបស់ខ្លួននោះ ពលរដ្ឋកម្ពុជាត្រូវបានរាំងក្នុងការក្លាយជាសមាជិកសកម្មក្នុងសង្គម ព្រមទាំងត្រូវបានរាំងសិទ្ធិក្នុងការនាំជនដែលរំលោភសិទ្ធិមនុស្សឱ្យទទួលខុសត្រូវចំពោះមុខច្បាប់ផងដែរ។

## សេរីភាពខាងសមាគម

សេរីភាពខាងសមាគមត្រូវបានរឹតត្បិតក្នុងឆ្នាំទីបួនដោយរដ្ឋាភិបាលកម្ពុជា ដែលការរឹតត្បិតជាងពាក់កណ្ដាលគឺនាំឱ្យមានការរំលោភបំពាន។ ការរឹតត្បិតលើសេរីភាពខាងសមាគមត្រូវបានប្រើប្រាស់ជាញឹកញាប់ដើម្បីកំណត់ជាមុខសញ្ញាទៅលើនិន្នាការជំទាស់ និងដើម្បីបង្រួមវិសាលភាពការងាររបស់សង្គមស៊ីវិល។

**៣៣៨** ករណីរឹតត្បិតសេរីភាពខាងសមាគមក្នុងឆ្នាំទី៤

**១៨៦** ករណីរំលោភបំពានសេរីភាពខាងសមាគមក្នុងឆ្នាំទី៤

**តារាងតួលេខទី១៦៖ ៥៥%នៃការរឹតត្បិតសេរីភាពខាងការជួបប្រជុំទាំងអស់ហួសពីបទដ្ឋានច្បាប់ និងនាំទៅដល់ការរំលោភបំពាន ហើយមាន៤៥% គឺជាការរឹតត្បិតដែលអនុញ្ញាត**




**តារាងតួលេខទី១៧ ៖ ការរឹតត្បិតសេរីភាពខាងសមាគមបានឈានដល់កម្រិតខ្ពស់បំផុតនៅខែឧសភា មិថុនា កញ្ញា និងតុលា**




**ខែឧសភា៖** ការចេញដីកាកោះហៅអតីតសមាជិកគណបក្សសង្គ្រោះជាតិ

**ខែកក្កដា៖** ការរឹតត្បិតជុំវិញ ខួបមរណភាពលោកបណ្ឌិត កែម ឡី

**ខែកញ្ញា និងតុលា៖** ការកើនឡើងនូវករណីចាប់ខ្លួនមុនពេលគម្រោងវិលត្រឡប់របស់លោកសម រង្ស៊ី

**តារាងតួលេខទី១៨៖ ការជំទាស់ផ្នែកនយោបាយគឺជាមុខសញ្ញាញឹកញាប់បំផុតនៃការរឹតត្បិតសេរីភាពខាងសមាគមពីសំណាក់រដ្ឋាភិបាលកម្ពុជា**



## ៣.២ ការរឿតត្បិតរបស់រាជរដ្ឋាភិបាលកម្ពុជាមកលើសិទ្ធិសេរីភាពខាងសមាគម

នៅចន្លោះខែមេសា ឆ្នាំ ២០១៩ ដល់ខែមីនា ឆ្នាំ ២០២០ គម្រោងបានកត់ត្រានូវហេតុការណ៍សរុបចំនួន ១១៤ ករណីដែលរដ្ឋាភិបាលកំណត់មុខសញ្ញាទៅលើសិទ្ធិសេរីភាពខាងសមាគមរបស់អង្គការសង្គមស៊ីវិល ឬសហជីព ។ ក្នុងនោះមានការរឹតត្បិតចំនួន ១០១ ករណីមកលើអង្គការសង្គមស៊ីវិលឬ ការងាររបស់អង្គការសង្គមស៊ីវិល[53] និង ១៣ ករណីមកលើសហជីព។ ការរឹតត្បិតមានលក្ខណៈផ្សេងៗគ្នាពីវិធានការខាងព្រហ្មទណ្ឌដែលបានធ្វើឡើងប្រឆាំងនឹងសមាជិកអង្គការសង្គមស៊ីវិល[54] ការឃ្លាំមើល និងការរំខានដល់សកម្មភាព[55] ការហាមឃាត់ការប្រារព្ធព្រឹត្តិការណ៍របស់អង្គការសង្គមស៊ីវិល[56] ការបំភិតបំភ័យ និងការបៀតបៀនចំពោះបុគ្គលិកអង្គការសង្គមស៊ីវិល រួមទាំងការគំរាមកំហែងចាត់វិធានការតាមផ្លូវច្បាប់[57] ការហាមឃាត់សហជីពក្នុងការតវ៉ា[58] និងការយាយីតាមប្រព័ន្ធតុលាការទៅលើសមាជិកសហជីព។[59]

នៅក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព និងការស្ទង់មតិជាសាធារណៈ អ្នកឆ្លើយតបបានរាយការណ៍ថាខ្លួនត្រូវបានរដ្ឋាភិបាលកមណត់មុខសញ្ញាដោយសារពួកគេបានចូលរួមពាក់ព័ន្ធជាមួយអង្គការសង្គមស៊ីវិល ឬសហជីពដោយរដ្ឋាភិបាល។ សូមមើលតារាងតួលេខទី១៩និងទី២០ ។

---

[53] ទាំងបុគ្គលិកអង្គការសង្គមស៊ីវិល ព្រមទាំងសាធារណជនដែលចូលរួមពាក់ព័ន្ធជាមួយអង្គការសង្គមស៊ីវិល។

[54] សុទ្ធ គឹមសឿន 'តុលាការចេញដីកាកោះហៅបុគ្គលិកអង្គការអាដហុក' (កាសែតភ្នំពេញប៉ុស្តិ៍ចុះផ្សាយថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៩) <https://www.phnompenhpost.com/national/court-summons-adhoc-staffer>

[55] សេក បណ្ឌិត 'សមត្ថកិច្ចនគរបាលខេត្តបាត់ដំបងបានហាមឃាត់កិច្ចប្រជុំរបស់អង្គការមិនមែនរដ្ឋាភិបាល' (អាស៊ីសេរី ចុះផ្សាយថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០១៩) <https://www.rfa.org/khmer/news/human-rights/battambang-police-harasses-Adhoc-officer-101820 19053 713.html>

[56] យន សារី 'អាជ្ញាធររារាំងពិធីបំបួសរបស់សហគមន៍ព្រៃឡង់' (កាសែតភ្នំពេញប៉ុស្តិ៍ ចុះផ្សាយថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០២០) <https://www.phnompenhpost.com/national/authorities-block-prey-lang-community-ordination-event>

[57] សេក បណ្ឌិត 'លោក ហ៊ុន សែន ព្រមានចាប់ខ្លួននាយករងអង្គការសិទ្ធិមនុស្សលីកាដូពីបទការពារអ្នកផ្តល់ព័ត៌មានក្លែងក្លាយ' (អាស៊ីសេរី, ចុះផ្សាយថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០២០) <https://www.rfa.org/khmer/news/human-rights/hun-sen-warns-to-arrest-Am-Sam-Ath-a-rights-defender-03302020024938.html>

[58] វ៉ន ដារ៉ា 'ការហែក្បួនទិវាពលកម្មអន្តរជាតិ 'មិនត្រូវបានអនុញ្ញាត' (កាសែតភ្នំពេញប៉ុស្តិ៍ចុះផ្សាយថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩) <https://www.phnompenhpost.com/national/may-day-marches-not-allowed>.

[59] មុំ គន្ធា ' លោក អាត់ ធន់ ត្រូវបានចេញដីកាកោះហៅករណីការតវ៉ាដោយហិង្សានៅមុខរោងចក្រកាលពីឆ្នាំ ២០១៣' (កាសែតខ្មែរថាមស៍, ចុះផ្សាយថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩) <https://www.khmertimeskh.com/50654402/ath-thorn-summoned-over-violent-2013-factory-protest/>

**តារាងតួលេខទី១៩៖ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពបានរាយការណ៍ថាត្រូវបានកំណត់ជាមុខសញ្ញាដោយរដ្ឋាភិបាល[60]**




៣០%នៃអ្នកឆ្លើយតបក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពបានរាយការណ៍ថាត្រូវបានកំណត់ជាមុខសញ្ញាពីសំណាក់រាជរដ្ឋាភិបាលដោយសារតែពួកគេមានការពាក់ព័ន្ធជាមួយអង្គការសង្គមស៊ីវិលឬ សហជីព។

តួលេខនេះបង្ហាញថាមានការថយចុះបន្តិចពីឆ្នាំមុនៗ ។ ទោះបីយ៉ាងណាក៏ដោយ ក៏នៅតែគួរឱ្យព្រួយបារម្ភដោយស្ទើរតែមួយភាគបីនៃអ្នកឆ្លើយតបនៃការស្ទង់មតិបានរាយការណ៍ថាត្រូវបានកំណត់ជាមុខសញ្ញាដោយសារការអនុវត្តសិទ្ធិសេរីភាពខាងសមាគមរបស់ពួកគេ។

**តារាងតួលេខទី២០៖ សាធារណជនរាយការណ៍ថាបានក្លាយជាជនរងគ្រោះដោយសារពួកគេបានពាក់ព័ន្ធជាមួយនឹងអង្គការសង្គមស៊ីវិល[61]**




ការស្ទង់មតិសាធារណៈបានកត់ត្រាពីការកើនឡើងនូវចំនួនបុគ្គលដែលបានរាយការណ៍ថា ពួកគេបានក្លាយជាជនរងគ្រោះដោយសារពួកគេចូលរួមពាក់ព័ន្ធជាមួយអង្គការសង្គមស៊ីវិលដោយក្នុងនោះ២៥% នៃអ្នកឆ្លើយតបបានផ្តល់ចម្លើយដូចគ្នា បើប្រៀបធៀបទៅនឹង ១៩% នៅក្នុងឆ្នាំទីបី ។

### ៣.២.១ អង្គការសង្គមស៊ីវិលនៅតែតម្រូវឱ្យផ្តល់ការជូនដំណឹងជាមុន មុននឹងធ្វើសកម្មភាពផ្សេងៗ

បើទោះបីជាក្រសួងមហាផ្ទៃបានលុបចោលនូវលក្ខខណ្ឌនៃការជូនដំណឹងមុន ៣ ថ្ងៃ សម្រាប់រាល់សកម្មភាពរបស់អង្គការសង្គមស៊ីវិលកាលពីខែវិច្ឆិកា ឆ្នាំ២០១៨ ក៏ដោយ ក៏លក្ខខណ្ឌនៃការជូនដំណឹងជាមុននេះនៅតែត្រូវបានអនុវត្តដដែល។ គម្រោងបានកត់ត្រានូវករណីចំនួន ១៤ ដែលរដ្ឋាភិបាលបានទាមទារអង្គការសង្គមស៊ីវិលឱ្យមានការជូនដំណឹងជាមុន។ ជាឧទាហរណ៍ មានមន្រ្តីនគរបាលចំនួន ៣៤ រូបបានមករារាំងមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ ក្នុងការបើកវគ្គបណ្តុះបណ្តាលនៅភូមិសង្គមថ្មី ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ ដោយអាជ្ញាធរអះអាងថាសកម្មភាពរបស់មជ្ឈមណ្ឌលច្បាប់សម្រាប់សហគមន៍ មិនមានការ

[60] សំណួរនេះមិនត្រូវបានសួរក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលបានធ្វើឡើងក្នុងឆ្នាំទី១ ទេ។

[61] សំណួរនេះមិនត្រូវបានសួរនៅក្នុងការស្ទង់មតិសាធារណៈដែលបានធ្វើឡើងនៅឆ្នាំទី១ ទេ។

អនុញ្ញាតជាមុនពីអាជ្ញាធរឃុំនោះទេ។[62] គម្រោងក៏បានកត់ត្រាករណីបែបនេះចំនួនពីរបន្ថែមទៀតមកលើសហគមន៍មូលដ្ឋានដែលមិនគោរពតាមលក្ខខណ្ឌនៃការជូនដំណឹងជាមុនដែលបានលុបចោលកាលពីឆ្នាំ២០១៨។[63]

### ៣.២.២ ការឃ្លាំមើលអង្គការសង្គមស៊ីវិល និងសហជីពនៅតែបន្តមានលក្ខណៈហួសហេតុ

**តារាងតួលេខទី២១៖ ករណីនៃការត្រួតត្រា និងឃ្លាំមើលខុសច្បាប់ទៅលើសកម្មភាពរបស់អង្គការសង្គមស៊ីវិលពីរាជរដ្ឋាភិបាល**




អង្គការសង្គមស៊ីវិលបន្តប្រឈមនឹងការត្រួតត្រា និងការឃ្លាំមើលខុសច្បាប់ពីរដ្ឋាភិបាល។ ការជ្រៀតជ្រែកលើសកម្មភាពប្រចាំថ្ងៃរបស់អង្គការសង្គមស៊ីវិល ជាការរំលោភលើសិទ្ធិសេរីភាពខាងសមាគមពីរដ្ឋាភិបាល។ គម្រោងក៏បានកត់ត្រានូវហេតុការណ៍ចំនួន ៦៣ ករណីដែលមានការត្រួតត្រា ឬជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាលលើសកម្មភាពរបស់អង្គការសង្គមស៊ីវិលដែលបានរំលោភច្បាប់អន្តរជាតិ។ ទាំងនេះរាប់ទាំងហេតុការណ៍ចំនួន ១៥ ករណីដែលអាជ្ញាធរបានថតរូបអ្នកចូលរួម ឬបុគ្គលិកអង្គការសមាគម[64] ហេតុការណ៍ចំនួន ១២ ករណីដែលអាជ្ញាធរបានទាមទារព័ត៌មានលម្អិតរបស់អ្នកចូលរួម ឬបុគ្គលិក[65] និងមានហេតុការណ៍ចំនួន ៣ ករណីដែលអាជ្ញាធរមកកត់ត្រាការប្រារព្ធព្រឹត្តិការណ៍ឯកជនរបស់អង្គការសង្គមស៊ីវិល ។[66]

**តារាងតួលេខទី២២៖ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលរាយការណ៍ពីការតាមដាន ឬឃ្លាំមើលអង្គការរបស់ពួកគេពីសំណាក់រដ្ឋាភិបាល**

[62] ឃន សារី " អង្គការនេះអះអាងថាអាជ្ញាធរមូលដ្ឋាននៅតែបន្តរឹតត្បិតការជួបប្រជុំរបស់ពលរដ្ឋក្នុងការអប់រំ" (កាសែតភ្នំពេញប៉ុស្តិ៍ចុះផ្សាយថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩) <https://bit.ly/2KzWU2T>.

[63] ម៉ៅ សុធានី,' នគរបាលខេត្តស្ទឹងត្រែងរារាំងសហគមន៍ព្រៃឡង់ក្នុងការល្បាតព្រៃ' (អាស៊ីសេរី ចុះផ្សាយថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២០) <https://www.rfa.org/khmer/news/environment/logging-preylang-02222020054947.html>.

[64] ការរាយការណ៍ពីហេតុការណ៍ IRAD147 និង IRCC161 ។

[65] ការរាយការណ៍ពីហេតុការណ៍ IRAD142 និង IRCC205 ។

[66] ការរាយការណ៍ពីហេតុការណ៍ IRCC166, IRCC153 និង IRCC184 ។

បរិយាកាសតាមឃ្លាំមើលហួសហេតុពីរដ្ឋាភិបាលបានបង្ហាញនៅក្នុងលទ្ធផល នៃការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព។ ៥០% នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពបានរាយការណ៍ថា អាជ្ញាធរ រដ្ឋាភិបាលបានចូលរួមក្នុងការតាមដាន ឬឃ្លាំមើលសកម្មភាពអង្គការរបស់ពួកគេ។ នេះបង្ហាញពីការកើនឡើងបន្តិចបន្តួច ពីឆ្នាំទីបី ហើយដូចគ្នានឹងឆ្នាំទីពីរ ។




**តារាងតួលេខទី២៣៖ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលយល់ថា ការតាមដាន ឬឃ្លាំមើលស្ថាប័នរបស់ខ្លួនពីសំណាក់រដ្ឋាភិបាលមានលក្ខណៈហួសហេតុ**[67]




៧៩% ក្នុងចំណោមអ្នកដែលបានរាយការណ៍ពីការឃ្លាំមើល ឬការតាមដានស្ថាប័នរបស់ខ្លួនយល់ថា ការតាមដាននោះមានលក្ខណៈហួសហេតុដោយកើនឡើង ៥% ពីឆ្នាំទីពីរ ។ ដូច្នេះអ្នកឆ្លើយតបជិតបួនភាគប្រាំបានជឿថា ការឃ្លាំមើល ឬការតាមដានដោយរដ្ឋាភិបាល ដែលបានធ្វើឡើងចំពោះពួកគេគឺជាការជ្រៀតជ្រែកទៅលើសេរីភាពខាងសមាគម។

## ៣.២.៣ អង្គការសង្គមស៊ីវិល/សហជីពអាចបំពេញតាមលក្ខខណ្ឌនៃការធ្វើរបាយការណ៍ប៉ុន្តែពួកគេយល់ថាជាបន្ទុកនិងមានលក្ខណៈហួសកម្រិត

**តារាងតួលេខទី២៤៖ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលបានរាយការណ៍ថាពួកគេអាចបំពេញតាមលក្ខខណ្ឌនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍មិនមែនហិរញ្ញវត្ថុរបស់រដ្ឋាភិបាល**




[67] សំណួរនេះមិនត្រូវបានសួរក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលបានធ្វើឡើងក្នុងឆ្នាំទីមួយទេ។

ផ្អែកតាមទិន្នន័យពីការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពបានបង្ហាញថា ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលកាន់តែមានលទ្ធភាពក្នុងការបំពេញបែបបទទាំងកំណត់ត្រាហិរញ្ញវត្ថុ និងរបាយការណ៍មិនមែនហិរញ្ញវត្ថុស្របតាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និង/ឬច្បាប់ស្តីពីសហជីព ។ (សូមមើលតារាងតួលេខទី២៤ខាងលើ)។

**តារាងតួលេខទី២៥៖ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលយល់ឃើញថាលក្ខខណ្ឌនៃការធ្វើរបាយការណ៍មានលក្ខណៈហួសកម្រិត និងជាការដាក់បន្ទុក**




ទោះបីយ៉ាងណាក៏ដោយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពភាគច្រើនយល់ឃើញថាលក្ខខណ្ឌនៃការធ្វើរបាយការណ៍នៅក្រោមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលគឺមានលក្ខណៈហួសកម្រិត ឬដាក់បន្ទុកច្រើនខ្លាំង។ ទាំងថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពបានរាយការណ៍អំពីលក្ខខណ្ឌនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុថាមានបន្ទុកធ្ងន់ជាងលក្ខខណ្ឌនៃការធ្វើរបាយការណ៍មិនមែនហិរញ្ញវត្ថុ។

### ៣.២.៤ អង្គការសង្គមស៊ីវិល/សហជីពមួយចំនួនតូចជួបប្រទះការរឹតត្បិតចំពោះការផ្តល់មូលនិធិបរទេស

**តារាងតួលេខទី២៦៖ សមាមាត្រនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលរាយការណ៍ថា អង្គការសង្គមស៊ីវិលរបស់ពួកគេបានប្រឈមនឹងការរឹតត្បិតពីសំណាក់រដ្ឋាភិបាលនៅពេលដែលពួកគេព្យាយាមទទួលមូលនិធិពីម្ចាស់ជំនួយបរទេសក្នុងឆ្នាំចុងក្រោយ[68]**




ក្នុងឆ្នាំទីបួន ៦% នៃអ្នកឆ្លើយតបនៅក្នុងការស្ទង់មតិ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពបានលើកឡើងថាអង្គការរបស់ពួកគេប្រឈមនឹងការរឹតត្បិតពីសំណាក់រដ្ឋាភិបាលនៅពេលទទួលមូលនិធិពីប្រភពបរទេស។ ទោះជាយ៉ាងណាក៏ដោយ ភាគច្រើនមិនបានរាយការណ៍ពីការជ្រៀតជ្រែកបែបនេះទេ។ នៅឆ្នាំទីបួននេះក៏បានកត់សម្គាល់ផងដែរពីនិន្នាការនៃការជ្រៀតជ្រែកពីភាគីទីបីក្នុងការទទួលបានមូលនិធិបរទេស។ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន បានកត់ត្រានូវករណីចំនួនបីដែលបុគ្គលិកធនាគារបានទូរស័ព្ទមកអង្គការសង្គមស៊ីវិលដើម្បី

[68] សំណួរនេះមិនត្រូវបានសួរក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលបានធ្វើឡើងក្នុងឆ្នាំទីមួយទេ។

សាកសួរអំពីគោលបំណងនៃការផ្ទេរប្រាក់តាមធនាគារអន្តរជាតិ។ ភាគីធនាគារបានស្នើសុំឱ្យអង្គការសង្គមស៊ីវិលឱ្យផ្តល់កិច្ចព្រមព្រៀងក្នុងការផ្តល់មូលនិធិ មុនពេលធនាគារបញ្ចេញមូលនិធិទាំងនោះ។ ទោះបីជាយ៉ាងនេះក្តី ក្នុងករណីទាំងបី អង្គការសង្គមស៊ីវិលបានបដិសេធ ហើយមូលនិធិត្រូវបានផ្ទេរចូលគណនីជាធម្មតា ។[69]

### ៣.២.៥ ថ្នាក់ដឹកនាំសហជីពនិងសមាជិកប្រឈមហានិភ័យ នៃការបញ្ឈប់ពីការងារដោយសារភាពជាសហជីពរបស់ពួកគេ

ពេញមួយឆ្នាំទីបួន របាយការណ៍ស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាន និងហេតុការណ៍បានកត់ត្រាមនុស្សចំនួន ១៦៨ នាក់ដែលត្រូវបានព្យួរ ឬបញ្ឈប់ពីការងារ ឬមិនបានទទួលការបន្តកិច្ចសន្យាដោយសារតែភាពជាសហជីពរបស់ពួកគេ។[70] ជាឧទាហរណ៍ ក្នុងខែឧសភា ឆ្នាំ ២០១៩ កម្មករ និយោជិតចំនួន ១០៥ នាក់នៅក្រុមហ៊ុនរោងចក្រកាត់ដេរ មីន រ៉ុង ត្រូវបានបញ្ចប់កិច្ចសន្យាការងាររបស់ពួកគេដោយសារមិនព្រមលាឈប់ពីសហជីពរបស់ពួកគេ ពោលគឺសហជីពបេះដូងកម្មករខ្មែរ។ លើសពីនេះទៀតលោកស្រី សយ សុកណ្ណ ដែលជាប្រធានសហជីពនេះមិនត្រូវបានអនុញ្ញាតឱ្យបន្តការងាររបស់ខ្លួនទេ បន្ទាប់ពីគាត់វិលត្រឡប់ពីការឈប់សម្រាកលំហែមាតុភាពវិញ។[71]

## ៣.៣ សហជីពនៅតែជួបបញ្ហាប្រឈមក្នុងដំណើរការចុះបញ្ជី

ការធ្វើវិសោធនកម្មលើច្បាប់ស្តីពីសហជីពកាលពីខែមករា ឆ្នាំ ២០២០ មិនបានបន្ធូរបន្ថយលក្ខខណ្ឌណាមួយនៃការចុះបញ្ជីដែលដាក់បន្ទុកចំពោះសហជីពទេ។ ដូច្នេះសហជីពទំនងជាបន្តជួបនូវបញ្ហាប្រឈមនៅពេលព្យាយាមចុះបញ្ជី។ ឧបករណ៍វាយតម្លៃការចុះបញ្ជីសហជីព (ឧបករណ៍វាយតម្លៃ) នៅក្នុងឆ្នាំទីបួន បានកត់ត្រាបទពិសោធន៍របស់សហជីពចំនួន ២៩ ដែលប៉ុនប៉ងចុះបញ្ជីសហជីពរបស់ខ្លួនដោយអនុលោមតាមលក្ខខណ្ឌនេះ។ ក្នុងចំណោមសហជីពទាំង ២៩ នេះ មាន ១៨ (ឬ ៦២%) បានចុះបញ្ជីដោយជោគជ័យខណៈការប៉ុនប៉ងរបស់សហជីពដែលនៅសេសសល់មិនបានជោគជ័យ។ នេះបង្ហាញថាលក្ខខណ្ឌចុះបញ្ជីដែលត្រូវបានអនុវត្តនៅក្រោមច្បាប់សហជីព គឺជាបន្ទុកសម្រាប់សហជីពមួយចំនួនធំ។[72]

---

[69] ការរាយការណ៍ពីហេតុការណ៍ IRCC222, IRCCC228 និង IRCC229

[70] មាត្រា ៨ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ចែងយ៉ាងច្បាស់ពីការដាក់បញ្ចូល *"សិទ្ធិក្នុងការបង្កើត និងចូលរួមសហជីពដើម្បីការពារផលប្រយោជន៍របស់ខ្លួន "*។ រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាពង្រឹងសិទ្ធិនេះនៅក្នុងមាត្រា ៣៦៖ *"ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបង្កើតសហជីព និងចូលរួមជាសមាជិកសហជីព"* ។

[71] ការរាយការណ៍ពីហេតុការណ៍ IRSC044

[72] 'គម្រោងឃ្លាំមើលសេរីភាពជាមូលដ្ឋាន - របាយការណ៍ប្រចាំឆ្នាំដំបូង' (ខែសីហា ឆ្នាំ ២០១៧) ទំព័រទី ៤ របស់ CCHR, ADHOC, SC និង ICNL <https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf>

**តារាងតួលេខទី២៧៖ សហជីពដែលរាយការណ៍ថាបានព្យាយាមច្រើនដងក្នុងការចុះបញ្ជីសហជីពរបស់ពួកគេ**




ឧបករណ៍វាយតម្លៃ បានកត់សម្គាល់ពីការថយចុះ នៃចំនួនសហជីពដែលរាយការណ៍ថាបានព្យាយាមជាច្រើនដងក្នុងការចុះបញ្ជី។ ក្នុងឆ្នាំទីបួន សហជីពចំនួន ១១ បានរាយការណ៍ថាបានព្យាយាមជាច្រើនដងក្នុងការចុះបញ្ជីដែលប្រាំបួនក្នុងចំណោមនោះ ត្រូវបានចុះបញ្ជីដោយជោគជ័យនៅជំណាច់ឆ្នាំទីបួន ។

## ៣.៤ បុគ្គលដែលត្រូវបានកំណត់ជាមុខសញ្ញាដោយសារតែពួកគេមាន ឬត្រូវបានសន្មតថាមានសម្ព័ន្ធភាពជាមួយគណបក្សសង្គ្រោះជាតិ

ក្នុងឆ្នាំទីបួន គម្រោងបានរកឃើញថា៥១ % នៃករណីរឹតត្បិត និង ៥៤ % នៃករណីរំលោភលើសេរីភាពខាងសមាគមពាក់ព័ន្ធនឹងបុគ្គលដែលមានជាប់ពាក់ព័ន្ធជាមួយ ឬសន្មតថាមានសម្ព័ន្ធភាពជាមួយគណបក្សសង្គ្រោះជាតិ ( ទំនាក់ទំនងជាមួយគណបក្សសង្គ្រោះជាតិ ) ។ ការរឹតត្បិតសរុបចំនួន ១៧១ ករណី និងការរំលោភលើសេរីភាពខាងសមាគមចំនួន ១០០ ករណីបានកើតមានចំពោះអ្នកគាំទ្រគណបក្សសង្គ្រោះជាតិ អតីតសមាជិកគណបក្សសង្គ្រោះជាតិ ឬអតីតមន្ត្រីគណបក្សសង្គ្រោះជាតិ។ ការបង្ក្រាបដែលផ្តើមចេញពីការរំលាយគណបក្សសង្គ្រោះជាតិ និងការហាមឃាត់សមាជិកសភាគណបក្សសង្គ្រោះជាតិចំនួន ១១៨ នាក់ ក្នុងការធ្វើនយោបាយនៅឆ្នាំ ២០១៧ បានបន្តពង្រីកវិសាលភាពក្នុងឆ្នាំទីបួនទាំងមូល ។ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ជាមុខសញ្ញាបុគ្គលដែលមានទំនាក់ទំនងជាមួយ ឬសន្មតថាមានសម្ព័ន្ធភាពជាមួយគណបក្សសង្គ្រោះជាតិ ដោយមិនគិតថាសម្ព័ន្ធភាពនេះកំពុងតែបន្ត ឬត្រូវបានបញ្ចប់រួចទៅហើយនោះទេ ។ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ ២០១៩ លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានដាក់បម្រាមដាច់ខាតចំពោះរាល់សកម្មភាពទាំងឡាយដែលទាក់ទងនឹងគណបក្សសង្គ្រោះជាតិ និងបានគំរាមថានឹងចាត់វិធានការប្រឆាំងនឹងការជួបប្រជុំណាមួយដើម្បីគាំទ្រគណបក្សសង្គ្រោះជាតិ។[73] ការហាមឃាត់រាល់សកម្មភាពសមាគមជាមួយគណបក្សសង្គ្រោះជាតិគឺជាការរំលោភលើសេរីភាពខាងសមាគមតាមមាត្រា ២២ នៃក.ស.អ.ព.ន ដែលចែងយ៉ាងច្បាស់ពីការការពារសិទ្ធិសេរីភាពក្នុងការចូលរួមជាមួយគណបក្សនយោបាយ និងមាត្រា ៣៥ និង ៤២ នៃ រដ្ឋធម្មនុញ្ញដែលការពារសិទ្ធិនយោបាយ និងសេរីភាពខាងសមាគម។[74] ការហាមឃាត់ដាច់ខាតនេះមិនបានបំពេញតាមបទដ្ឋានកំណត់របស់

---

[73] នៀម ឆេង 'ការគាំទ្រគណបក្សសង្គ្រោះជាតិនឹងមិនត្រូវបានអត់ឱនឡើយ' (កាសែតភ្នំពេញប៉ុស្តិ៍ចុះផ្សាយថ្ងៃទី២៩ ខែសីហា ឆ្នាំ ២០១៩) <https://m.phnompenhpost.com/national-politics/cnrp-support-will-not-be-tolerated>

[74] មាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា៖ 'ពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ', មាត្រា ៤២, *'ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ'* ។

ក.ស.អ.ព.ន ដោយសារបានផាត់ចេញការពិចារណាលើកាលៈទេសៈដាក់លាក់ ដូច្នេះហើយដាក់ស្តែងណាស់វាមិនសមាមាត្រ និងមានការរើសអើង។ ជារឿយៗរដ្ឋាភិបាលផ្តោតគោលដៅទៅលើអ្នកដែលគេជឿថាមានសម្ព័ន្ធភាពជាមួយគណបក្សសង្គ្រោះជាតិ តាមរយៈការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ និងការបៀតបៀនតាមប្រព័ន្ធតុលាការ។ ក្នុងឆ្នាំទីបួន សមាជិកគណបក្សសង្គ្រោះជាតិចំនួន ១២០ នាក់ត្រូវបានចោទប្រកាន់ ១០៣ នាក់ត្រូវបានចាប់ខ្លួន និង ៩៧ នាក់ត្រូវបានទទួលដីកាកោះហៅ។

**តារាងតួលេខទី២៨៖ ចំនួនទណ្ឌកម្មផ្នែកព្រហ្មទណ្ឌដោយសារមានសម្ព័ន្ធភាពគណបក្សសង្គ្រោះជាតិ**




## ៣.៤.១ បុគ្គលដែលត្រូវបានវាយប្រហារដោយសារ ឬត្រូវបានសន្មតថាមានសម្ព័ន្ធភាពជាមួយគណបក្សសង្គ្រោះជាតិ

បន្ថែមពីលើការដាក់ទណ្ឌកម្មព្រហ្មទណ្ឌបុគ្គលដែលគេជឿថាមានសម្ព័ន្ធភាពជាមួយគណបក្សសង្គ្រោះជាតិបានទទួលរងនូវអំពើហិង្សាលើរាងកាយ។[75] គម្រោងបានកត់ត្រានូវហេតុការណ៍ចំនួនប្រាំបីនៃករណីដែលមានជនទីបី មិនស្គាល់អត្តសញ្ញាណបានប្រព្រឹត្តអំពើហិង្សាមកលើបុគ្គលដែលទំនាក់ទំនងជាមួយគណបក្សសង្គ្រោះជាតិ។[76] ហេតុការណ៍នីមួយៗគឺជាការវាយប្រហារភ្លាមៗ និងនឹកស្មានមិនដល់ដោយប្រើបំពង់ទីបដែកសម្រាប់ធ្វើជាអាវុធដែលធ្វើឡើងដោយអ្នកដែលជិះម៉ូតូហើយជនរងគ្រោះមិនអាចស្គាល់អត្តសញ្ញាណពួកគេទេ។ ការវាយប្រហារដោយជនទីបីទាំងនេះតំណាងឱ្យការខកខានរបស់រដ្ឋាភិបាលក្នុងនាមជាអ្នកមានកាតព្វកិច្ចផ្លូវច្បាប់ដើម្បីធានាការការពារសិទ្ធិសេរីភាពខាងសមាគមនៅលើដែនដីរបស់ខ្លួន។ រដ្ឋាភិបាលបានបញ្ជាក់ថាការវាយប្រហារកំពុងត្រូវបានស៊ើបអង្កេត ក៏ប៉ុន្តែស្ថានភាពនៃការស៊ើបអង្កេតទាំងនេះមិនទាន់បានដឹងច្បាស់នៅឡើយទេ ហើយក៏មិនទាន់មានការចាប់ខ្លួនណាមួយដែរ។

[75] លោក ហ៊ុន សេរីវឌ្ឍ 'អតីតសកម្មជនប្រឆាំងម្នាក់ទៀតបានទទួលរងអំពើហិង្សានៅសាលារាជធានីភ្នំពេញ (វីអូឌី ចេញផ្សាយថ្ងៃទី ២០ ខែមករា ឆ្នាំ២០២០) <https://vodkhmer.news/2020/01/20/another-ex-cnrp-activist-got-attack/>

[76] សូមមើលឧទាហរណ៍ Joshua Lipe 'ការផ្ទេក់លើសកម្មជនគណបក្សប្រឆាំងនៅកម្ពុជាចុងក្រោយបង្អស់នៅក្នុងការវាយប្រហារជាច្រើនមុនពេលការវិលត្រឡប់របស់លោក សម រង្ស៊ី' អាស៊ីសេរី, ចេញផ្សាយថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ <https://www.rfa.org/english/news/cambodia/attacks-09252019160320.html>

## សេរីភាពខាងការបញ្ចេញមតិ

សេរីភាពខាងការបញ្ចេញមតិនៅតែបន្តរងការគាបសង្កត់ពីសំណាក់រដ្ឋាភិបាលដែលរំលោភលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងរដ្ឋធម្មនុញ្ញ។ មតិជំទាស់ ឬរិះគន់ត្រូវបានបំបិទជាប្រព័ន្ធដែលជារឿយៗតាមរយៈការចាប់ខ្លួន ឬការគំរាមកំហែងតាមប្រព័ន្ធតុលាការដែលបង្កើតបរិយាកាសនៃការភ័យខ្លាច និងការកម្រិតសេរីភាពខ្លួនឯង។ រដ្ឋាភិបាលមិនលើកលែងចំពោះពាក្យសម្ដីទាក់ទងនឹងមន្ត្រីរដ្ឋាភិបាល គោលនយោបាយរដ្ឋាភិបាល ឬនាយករដ្ឋមន្ត្រីនោះទេដែលជាញឹកញាប់បណ្ដាលមកពីខ្វះការជជែកជាសាធារណៈលើបញ្ហាគោលនយោបាយ។

**២៤៥** ការរឹតត្បិតសេរីភាពខាងការបញ្ចេញមតិក្នុងឆ្នាំទី៤

**១០៣** ការរំលោភបំពានសេរីភាពខាងការបញ្ចេញមតិក្នុងឆ្នាំទី៤

### តារាងតួលេខទី២៩៖ ការរឹតត្បិតសេរីភាពខាងការបញ្ចេញមតិបានឈានដល់កម្រិតខ្ពស់បំផុតនៅក្នុងខែឧសភា កញ្ញា និងខែមីនា




**ខែឧសភា៖** ការចេញដីកាកោះហៅអតីតសមាជិកគណបក្សសង្គ្រោះជាតិ

**ខែកញ្ញា៖** ការបំបិទសិទ្ធិក្នុងការបញ្ចេញមតិទាក់ទងនឹងគម្រោងវិល ត្រឡប់វិញរបស់លោក សម រង្ស៊ី

**ខែមីនា៖** ការបង្ក្រាបដំណឹងក្លែងក្លាយក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ ១៩

### តារាងតួលេខទី៣០៖ ការដាក់ទោសព្រហ្មទណ្ឌត្រូវបានរដ្ឋាភិបាលប្រើដើម្បីបំបិទសិទ្ធិសេរីភាពខាងការបញ្ចេញមតិ



**តារាងតួលេខទី៣១៖ ការចោទប្រកាន់ពីបទបរិហាកេរ្តិ៍ស្របតាមក្រមព្រហ្មទណ្ឌ ត្រូវបានយកមកប្រើដើម្បីបំបិទមាត់មនុស្សចំនួន ១៩ នាក់**




**តារាងតួលេខទី៣២៖ ការនិយាយដោយសេរីទាក់ទងនឹងនាយករដ្ឋមន្ត្រីហ៊ុន សែន និងរដ្ឋាភិបាលត្រូវបានរឹតត្បិតយ៉ាងជាក់លាក់**




## ៣.៥ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិមិនទទួលបានការការពារគ្រប់គ្រាន់

**តារាងតួលេខទី៣៣៖ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពកម្រិតសេរីភាពខ្លួនឯងនៅពេលនិយាយនៅទីសាធារណៈ[77]**




នៅក្នុងការស្ទង់មតិថ្នាក់ដឹកនាំរបស់អង្គការសង្គមស៊ីវិល និងសហជីពក្នុងឆ្នាំទីបួន ៨៨% នៃអ្នកឆ្លើយសំណួរបានរាយការណ៍ថាពួកគេបានកម្រិតសេរីភាពខ្លួនឯង ដែលចំនួនច្រើនបំផុតនៃអ្នកឆ្លើយតបរាយការណ៍អំពីការកម្រិតសេរីភាពខ្លួនឯងរហូតមកដល់បច្ចុប្បន្ន។ នេះបង្ហាញពីការភ័យខ្លាចកាន់តែខ្លាំងឡើងនៃការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិនៅក្នុងចំណោមសង្គមស៊ីវិល។ ការឃ្លាំមើល និងការបំភិតបំភ័យអង្គការសង្គមស៊ីវិល និងសហជីពពីរដ្ឋាភិបាល (សូមមើល ៣.២.២) និងការដាក់ទោសព្រហ្មទណ្ឌចំពោះការនិយាយដោយសេរី (សូមមើលតារាងតួលេខទី៣០) បង្កើតបរិយាកាសនៃការបំភិតបំភ័យ និងការកម្រិតសេរីភាពខ្លួនឯង។

### ៣.៥.១ ការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិតបន្តរងការរឹតត្បិត និងរំលោភបំពានជាពិសេសតាមបណ្តាញទំនាក់ទំនងសង្គម

[77] ទិន្នន័យដែលបង្ហាញនៅក្នុងរូបភាពនេះរួមមានចំនួនថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលបានឆ្លើយតបថា *"ជានិច្ចកាល"* *"ជាប្រចាំ"* និង *"នៅពេលខ្លះ"* មានអារម្មណ៍ថាចាំបាច់ក្នុងការត្រួតពិនិត្យខ្លួនឯងនៅពេលនិយាយស្តីជាសាធារណៈ។

## តារាងតួលេខទី៣៤៖ ការរឹតត្បិត ការរំលោភបំពាន និងការចាប់ខ្លួនមកលើការបញ្ចេញមតិតាមអ៊ីនធឺណិត

ឆ្នាំទីបួនបានកត់ត្រានូវការរឹតត្បិតចំនួន ១០៤ ករណីមកលើសេរីភាពខាងការបញ្ចេញមតិទាក់ទងនឹងការបញ្ចេញមតិតាមអ៊ីនធឺណិត (៥២%នៃករណីរឹតត្បិតមកលើការបញ្ចេញមតិ) មានការរំលោភបំពានចំនួន ៥០ ករណី (៤៨% នៃករណីរំលោភបំពានលើការបញ្ចេញមតិ)។ បុគ្គលចំនួន ៤៨ នាក់ត្រូវបានចាប់ខ្លួនដោយសារអនុវត្តសេរីភាពបញ្ចេញមតិតាមអ៊ីនធឺណិត។




## តារាងតួលេខទី៣៥៖ ការរឹតត្បិតសេរីភាពខាងការបញ្ចេញមតិតាមបណ្តាញទំនាក់ទំនងសង្គម




ក្នុងឆ្នាំទីបួន គម្រោងបានកត់ត្រាការរឹតត្បិតសេរីភាពខាងការបញ្ចេញមតិចំនួន ៧២ ករណីដែលបានបញ្ចេញមតិលើបណ្តាញសង្គម។ ៦៩ ករណីកើតឡើងដោយសារ ការបញ្ចេញមតិតាមហ្វេសប៊ុក ២ ករណីលើអ្នកប្រើប្រាស់យូធូប(YouTube) និងមួយទៀតលើ បណ្តាញសង្គម Tik Tok ។ បុគ្គលចំនួន ៤៣ នាក់ត្រូវបានចាប់ខ្លួនដោយសារអនុវត្តការបញ្ចេញមតិនៅលើហ្វេសប៊ុក។ ហេតុការណ៍ចំនួន ៣៩ ករណីមានបុគ្គលត្រូវបានចោទប្រកាន់ពីបទផ្សព្វផ្សាយ *"ដំណឹងក្លែងក្លាយ"* [78] មនុស្សចំនួន ១១ នាក់ត្រូវបានចាប់ខ្លួន ឬឃុំខ្លួនដើម្បីធ្វើការសាកសួរ ហើយត្រូវបានដោះលែងវិញបន្ទាប់ពីបានផ្តិតមេដៃលើកិច្ចសន្យាព្រមព្រៀងថានឹងមិនចែកចាយ "*ដំណឹងក្លែងក្លាយ*"ជាថ្មីទៀត។[79] មនុស្សផ្សេងទៀតត្រូវបានចោទប្រកាន់ និងឃុំខ្លួនរង់ចាំការជំនុំជម្រះ។[80]

---

[78] "ព័ត៌មានក្លែងក្លាយ" គឺជាបទល្មើសព្រហ្មទណ្ឌនៅក្នុងប្រទេសកម្ពុជាតាមមាត្រា ៤២៥ នៃក្រមព្រហ្មទណ្ឌ *"ការក្លែងព័ត៌មាន"*។

[79] ហ្វ្រេសញូវ 'សមត្ថកិច្ចនគរបាលខេត្តកោះកុងបានចាប់ខ្លួនយុវជនម្នាក់បន្ទាប់ពីគាត់បានបង្ហោះព័ត៌មានតាមហ្វេសប៊ុកទាក់ទងនឹងការឆ្លងវីរុសក្សូរ៉ូណាវីរុស' (ហ្វ្រេសញូវ ចេញផ្សាយថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០) <http://freshnewsasia.com/index.php/en/localnews/146833-2020-01-29-07-13-37.html>.

[80] ឧទាហរណ៍: ហ្វ្រេសញូវ ,'យុវជននៅខេត្តតាកែវត្រូវបានចាប់ខ្លួន និងបញ្ជូនទៅតុលាការពីបទផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ (ហ្វ្រេសញូវ, ចេញផ្សាយថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០) <http://freshnewsasia.com/index.php/en/localnews/151312-2020-03-12-08-29-46.html>

**តារាងតួលេខទី៣៦៖ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលរាយការណ៍ថាមិនមានអារម្មណ៍សុវត្ថិភាពក្នុងការចែកចាយព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយសង្គម[81]**




ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពត្រូវបានសួរថាតើពួកគេយល់ថាមានសុវត្ថិភាពក្នុងការចែកចាយព័ត៌មានតាមរយៈប្រភេទប្រព័ន្ធផ្សព្វផ្សាយផ្សេងៗគ្នាដែរឬទេ? ចម្លើយ៖ ប្រព័ន្ធផ្សព្វផ្សាយសង្គមត្រូវបានកត់ត្រាជាមធ្យោបាយមួយដែលអ្នកឆ្លើយតបយល់ថាមានសុវត្ថិភាពតិចតួចបំផុតក្នុងការបញ្ចេញមតិដោយ ៨២% មានយល់ថាមិនមានសុវត្ថិភាពក្នុងការចែករំលែកព័ត៌មានតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមដែលនេះបង្ហាញពីការកើនឡើង ៩ % ពីឆ្នាំទីបី។

## ៣.៥.២ អ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវបានកំណត់ជាមុខសញ្ញា

**តារាងតួលេខទី៣៧៖ អ្នកសារព័ត៌មាន និងបណ្ដាញផ្សព្វផ្សាយព័ត៌មានត្រូវបានកំណត់ជាមុខសញ្ញាសំរាប់រឹតត្បិតសេរីភាពមូលដ្ឋាន**




គម្រោងបានកត់ត្រានូវហេតុការណ៍ចំនួន ២៥ ករណីនៅក្នុងឆ្នាំទីបួនដែលអ្នកសារព័ត៌មាន ឬប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបានប្រឈមនឹងចំណាត់ការរបស់តុលាការដោយសារចូលរួមក្នុងសកម្មភាពពាក់ព័ន្ធនឹងសារព័ត៌មាន។

ចំណាត់ការរបស់តុលាការដែលបានកត់ត្រារួមមានដីកាកោះហៅ ការសាកសួរ ការចាប់ខ្លួន និងការចោទប្រកាន់។[82] ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលត្រូវកំណត់មុខសញ្ញាទាំងនោះរួមមាន៖ *កាសែតឌឹខេមបូឌាដេលី ទូរទស្សន៍អប្សរា សំឡេងប្រជាធិបតេយ្យ វិទ្យុវីទីសែន ស្ទើកម្ពុជាដេលី និងមនោរម្យអ៊ីនហ្វូ*។

## ៣.៥.៣ ការស្លៀកពាក់ និងម៉ូតសម្លៀកបំពាក់ត្រូវបានរឹតត្បិត

ក្នុងឆ្នាំទីបួន គម្រោងបានកត់ត្រាហេតុការណ៍ចំនួនប្រាំបីករណីនៃការរឹតត្បិតសេរីភាពខាងការបញ្ចេញមតិទាក់ទងនឹងការស្លៀកពាក់។ សេរីភាពខាងការបញ្ចេញមតិពង្រីកវិសាលភាពមកលើការបញ្ចេញមតិ "*រួមទាំងក្នុងទម្រង់សិល្បៈ ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ*" [83] និងមធ្យោបាយក្នុងការបញ្ចេញមតិដែលត្រូវបាន

---

[81] ទិន្នន័យនេះមិនត្រូវបានប្រមូលនៅឆ្នាំទីមួយទេ។

[82] ម.ស.ម.ក, " អង្គការសង្គមស៊ីវិលអំពាវនាវឱ្យបញ្ឈប់ការចោទប្រកាន់គ្មានមូលដ្ឋានទៅលើអ្នកសារព័ត៌មាន" (ថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០១៩) <https://cchrcambodia.org/index_old.php?title=Civil-society-organizations-call-for-all-baseless-charges-against-journalists-to-be-dropped&url=media/media.php&p=press_detail.php&prid=738&id=5>

[83] មាត្រា ១៩ នៃក.អ.ស.ព.ន

ការពាររួមមាន *"ការស្លៀកបំពាក់"*។[84] ហេតុការណ៍នេះរួមមាន៖ (ក) ការចាប់ខ្លួនមនុស្ស ៤ នាក់ពីពាក់ព័ន្ធនឹងការលក់អាវយឺតដែលបង្ហាញពីរូបភាពលោកបណ្ឌិត កែម ឡី ។[85] (ខ) ការបញ្ចប់កិច្ចសន្យាការងាររបស់បុគ្គលិកម្នាក់ដោយសារការពាក់អាវយឺតគាំទ្រដល់ការដំឡើងប្រាក់ឈ្នួលនៅកាស៊ីណូណាហ្គាវើល[86] និង (គ) ការចាប់ខ្លួនអ្នកលក់តាមហ្វេសប៊ុកម្នាក់ដោយសារការស្លៀកសម្លៀកបំពាក់ដែលត្រូវបានចាត់ទុកថាជាការញុះញង់។[87] ករណីចុងក្រោយគឺ អ្នកនាង ថៃ ស្រីនាង ត្រូវបានចាប់ខ្លួនដោយសារស្លៀកពាក់ "សិចស៊ី"នៅពេលនាងលក់សម្លៀកបំពាក់ និងគ្រឿងសម្អាងតាមហ្វេសប៊ុក ហើយត្រូវបានចោទប្រកាន់ពីបទប្រើរូបភាពអាសអាភាសតាមមាត្រា ៣៩ នៃ*ច្បាប់ស្ដីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ*។ ការចាប់ខ្លួនអ្នកនាងក៏បានឈានទៅដល់ការបង្កើតក្រុមអន្តរក្រសួងដើម្បីតាមដានសកម្មភាពអ្នកលក់តាមអ៊ីនធឺណិតដែលប្រើប្រាស់រូបភាពសិុចស៊ីដើម្បីលក់ផលិតផលរបស់ពួកគេ ដូចជា *"បង្ហាញពីការសិុចស៊ីមានលក្ខណៈហួសហេតុ"*។[88]

## ៣.៦ រដ្ឋាភិបាលឃ្លាំមើលការប្រាស្រ័យទាក់ទងឯកជនដោយពុំមានការអនុញ្ញាតតាមប្រព័ន្ធតុលាការ

*ច្បាប់ស្ដីពីទូរគមនាគមន៍* អនុញ្ញាតឱ្យមានការលួចស្ដាប់ និងថតសំឡេងទុកជាការសម្ងាត់នៃការសន្ទនាតាមទូរសព្ទប្រសិនបើមានការយល់ព្រមពី *"អាជ្ញាធរស្របច្បាប់"*ដែលមិនបានកំណត់ច្បាស់លាស់។[89] ច្បាប់នេះមានលក្ខណៈស្រពេចស្រពិលខ្លាំងដែលមិនបំពេញតាមបទដ្ឋានអន្តរជាតិស្ដីពីសេរីភាពក្នុងខាងការបញ្ចេញមតិ និងបង្កើតបរិយាកាសឱ្យមានការរំលោភបំពាន។[90] គម្រោងបានកត់ត្រានូវហេតុការណ៍ចំនួនប្រាំមួយករណីនៃការឃ្លាំមើលរបស់រដ្ឋាភិបាលក្នុងការប្រាស្រ័យទាក់ទងជាលក្ខណៈឯកជនដោយពុំមានបញ្ជាពីតុលាការ។ បីករណីពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងអំពីការវិលត្រឡប់របស់លោក សម រង្ស៊ី។ មួយករណី លើការ

---

[84] អនុសាសន៍ទូទៅលេខ ៣៤ របស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ៖ មាត្រា ១៩ សេរីភាពក្នុងការបញ្ចេញ និងសម្ដែងមតិថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១, CCPR/GC/៣៤

[85] តាំង វីដា ' សកម្មជនត្រូវបានចោទប្រកាន់ពីបទញុះញង់ដោយការលក់អាវយឺតរូបលោកកែម ឡី ' (កាសែតខ្មែរថាមន៍ ចេញផ្សាយថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៩) <https://www.khmertimeskh.com/50623244/activist-charged-with-incitement-over-kem-ley-t-shirt-sales/>

[86] យុត សុគន្ធ ' មេដឹកនាំសហជីពណាហ្គាវើលត្រូវបានបញ្ឈប់ការងារ ' (វីអូឌី ចេញផ្សាយថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៩) <https://vodkhmer.news/2019/09/25/naga-world-union-chiefs-ousted-from-company-after-plans-to-lead-members-to-wage-hike>

[87] មុំ គន្ធា ' ស្ត្រីម្នាក់ត្រូវបានចាប់ដាក់ពន្ធនាគារពីបទប្រើរូបថតសិចស៊ីដើម្បីផ្សព្វផ្សាយខោខូវប៊ិយតាមអ៊ិនធឺណិត '។ (កាសែតខ្មែរថាមន៍ ចេញផ្សាយថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០) <https://www.khmertimeskh.com/50694281/woman-jailed-for-using-sexy-photos-to-promote-lingerie-online>

[88] សុទ្ធ គឹមសឿន ក្រសួងគាំទ្រការហាមឃាត់ *"សិុចស៊ី"*, (កាសែតភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០) <https://www.phnompenhpost.com/national/ministry-supports-sexy-ban>

[89] ច្បាប់ស្ដីពីទូរគមនាគមន៍ (ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦) មាត្រា ៩៧<http://www.sithi.org/temp.php?url=law_detail.php&lg=&id=277>

[90] ម.ស.ម.ក 'កំហុសឌីជីថល? ទិដ្ឋភាពរួមនៃស្ថានភាពសិទ្ធិឌីជីថលនៅក្នុងប្រទេសកម្ពុជា'(២០១៦) ទំព័រទី ១២ <https://cchrcambodia.org/admin/media/analysis/analysis/english/2016_03_03_CCHR_Briefing_NoteDigitalWrongs_ENG.pdf>

ប្រាស្រ័យទាក់ទងតាមទូរស័ព្ទឯកជនរវាងអតីតមន្ត្រីគណបក្សសង្គ្រោះជាតិពីររូបត្រូវបានថតសំឡេងទុក និងប្រើប្រាស់ជាមូលដ្ឋាននៃការចោទប្រកាន់។ នគរបាលដែលមិនមានដីកាអនុញ្ញាតឱ្យថតសំឡេងការសន្ទនាភ្ជាប់មកជាមួយនោះបានអានកំណត់ហេតុនៃការហៅទូរសព្ទឯកជនទៅកាន់អ្នកទាំងពីរ និងមេធាវីរបស់ពួកគេក្នុងពេលសាកសួរនៅស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ។[91] ហេតុការណ៍ចំនួន ៣ ករណីផ្សេងទៀតនៃការឃ្លាំមើលរបស់រដ្ឋាភិបាល គឺទាក់ទងទៅនឹងព័ត៌មានអំពីការចែករំលែកការសន្ទនាតាមទូរសព្ទ ឬសារជាសំឡេងដែលបានផ្ញើតាមហ្វេសប៊ុក។[92] ហេតុការណ៍មួយករណី អ្នកលក់ទូរស័ព្ទម្នាក់មកពីខេត្តកណ្តាលត្រូវបានឃាត់ខ្លួន និងសាកសួរអំពីសារជាសំឡេងឯកជនដែលគាត់បានផ្ញើតាមសារហ្វេសប៊ុកដោយបញ្ជាក់ថាមានករណីវិជ្ជមានចំពោះជំងឺកូវីដ ១៩ នៅក្នុងភូមិរបស់គាត់។[93]

**តារាងតួលេខទី៣៨៖ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពយល់ថាកាលពីឆ្នាំមុនការប្រាស្រ័យទាក់ទងរបស់អង្គការពួកគេត្រូវបានឃ្លាំមើលដោយអាជ្ញាធរ**




ក្នុងឆ្នាំទីបួន ៥០% នៃអ្នកឆ្លើយសំណួរក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពបានរាយការណ៍ថាការប្រាស្រ័យទាក់ទងរបស់ពួកគេកំពុងត្រូវបានតាមដានដោយរដ្ឋាភិបាល។ ដែលនេះគឺជាការកើនឡើងពីឆ្នាំមុនៗ និងបង្ហាញពីចំនួនច្រើនបំផុតចាប់តាំងពីឆ្នាំដំបូងនៃការអនុវត្តគម្រោង។

## ៣.៧ ឥទ្ធិពលនៃជំងឺកូវីដ ១៩ មកលើសេរីភាពខាងការបញ្ចេញមតិ

ក្នុងរយៈពេលបីខែដំបូងនៃឆ្នាំ២០២០ (ត្រីមាសទី៤)គម្រោងបានកត់ត្រាហេតុការណ៍ចំនួន ២៦ ករណីដែលបានរឹតត្បិតសេរីភាពខាងការបញ្ចេញមតិទាក់ទងទៅនឹងជំងឺកូវីដ ១៩ ។ ១៩ ករណីនៃការរឹតត្បិតទាំងនេះ មានទម្រង់ជាការចោទប្រកាន់ ការចាប់ខ្លួន និងការចោទប្រកាន់ពីបទផ្សព្វផ្សាយ *"ដំណឹងក្លែងក្លាយ"* ខណៈដែលមានការគំរាមកំហែងចំនួន ៥ គឺជាការគំរាមកំហែងពីរដ្ឋាភិបាលមកលើការផ្សព្វផ្សាយ *"ព័ត៌មានក្លែង*

---

[91] Andrew Nachemson និង គង់ មេត្តា ‘ការឃ្លាំមើលប្រព័ន្ធឌីជីថលនៅកម្ពុជាជួយបំបិទសំឡេងប្រឆាំង និងបង្ក្រាបការរិះគន់រដ្ឋាភិបាល’ (*PostMagazine*, ចេញផ្សាយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៩) <https://www.scmp.com/magazines/post-magazine/long-reads/article/3033508/cambodias-digital-surveillance-serves-silence>

[92] អាស៊ីសេរី 'សមត្ថកិច្ចនគរបាលក្រុងភ្នំពេញចាប់ខ្លួនមន្ត្រីប្រឆាំងម្នាក់ទៀតនៅខេត្តព្រៃវែងតាមទូរសព្ទទាក់ទងនឹងការព្រួយបារម្ភអំពីជំងឺនេះ' (អាស៊ីសេរី ចេញផ្សាយថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០) <https://www.rfa.org/khmer/news/politics/an-opposition-activist-in-prey-veng-arrested-because-talking-about-covid-19-fear-on-phone-03182020105614.html> និងគេហទំព័រហ្វេសប៊ុកនគរបាលខេត្តកំពង់ស្ពឺ(ថ្ងៃទី១៩ខែមីនាឆ្នាំ២០២០) <https://web.facebook.com/watch/?v=663756797785924>

[93] សែន ដាវីត ' បុរសខេត្តកណ្តាលម្នាក់ត្រូវបានសាកសួរជុំវិញការចែកចាយព័ត៌មានក្លែងក្លាយ' (ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០) <https://www.khmertimeskh.com/50706332/kandal-man-questioned-over-alleged-fake-news-distribution/>

*ក្លាយ"* ។[94] ករណី ២ ទៀតដែលនៅសល់គឺការរិះគន់លើការឆ្លើយតបរបស់រដ្ឋាភិបាលចំពោះវីរុសនេះ។ ហេតុការណ៍ ១ ករណី លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានគំរាមចាប់ខ្លួនលោក អំ សំអាត អនុប្រធានអង្គការសិទ្ធិមនុស្សលីកាដូចំពោះការលើកឡើងថារដ្ឋាភិបាលកំពុងរឹតត្បិតសេរីភាពខាងការបញ្ចេញមតិអំពីការរាតត្បាតនៃជំងឺ។ លោកនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា *"លោកឯងត្រូវតែប្រុងប្រយ័ត្នចំពោះសំដីនៅក្នុងកាលៈទេសៈនេះ។ បើទោះបីជាច្បាប់ដាក់ប្រទេសក្នុងគ្រាអាសន្នមិនទាន់ចូលជាធរមាន ក៏ខ្ញុំអាចចាប់លោកឯងបានដែរ ចាប់លោកឯងបានដែរ"* ។[95] ហេតុការណ៍ទីពីរ ពលរដ្ឋម្នាក់ត្រូវបានចាប់ខ្លួនដោយសារនិយាយ អរគុណដល់ប្រទេសវៀតណាមចំពោះការជូនដំណឹងអំពីការធ្វើតេស្តវិជ្ជមានចំពោះជំងឺកូវីដ ១៩ លើបុរសម្នាក់ដែលបានធ្វើដំណើរពីប្រទេសកម្ពុជាទៅប្រទេសវៀតណាម។[96] ករណីទាំងនេះបង្កើតបានជាផ្នែកមួយនៃការបំបិទសំឡេងជាលក្ខណៈប្រព័ន្ធនៃព័ត៌មានទាំងអស់ដែលទាក់ទងនឹងការរាតត្បាតនៃជំងឺដែលរំលោភលើសេរីភាពខាងការបញ្ចេញមតិ។

ឧទាហរណ៍ជាក់ស្តែងមួយអំពីកម្រិតដែលរដ្ឋាភិបាលបានរឹតត្បិតលើសេរីភាពក្នុងការបញ្ចេញមតិទាក់ទងនឹងជំងឺកូវីដគឺជាអ្នកយកព័ត៌មាន និងជាចាងហ្វាង TVFB គឺលោក សុវណ្ណ រិទ្ធី។ លោក រិទ្ធីត្រូវបានចាប់ខ្លួនដោយសារដកស្រង់សម្តីរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បង្ហោះតាមហ្វេសប៊ុក។ ការបង្ហោះរបស់រិទ្ធីបានដកស្រង់ពីសម្តីរបស់លោកនាយករដ្ឋមន្ត្រី ថាអ្នករត់ម៉ូតូឌុបគួរតែលក់ម៉ូតូរបស់ខ្លួនដើម្បីដោះស្រាយការលំបាកផ្នែកហិរញ្ញវត្ថុដែលបណ្តាលមកពីជំងឺរាតត្បាតសាកលកូវីដ ១៩ ។ លោក រិទ្ធីត្រូវបានចោទប្រកាន់ពីបទ "ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ " តាមមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ។ អាជ្ញាធរបានអះអាងថា ពាក្យសម្តីនេះត្រូវបានដកស្រង់ចេញខុសបរិបទ និងមានចេតនាញុះញង់ឱ្យមានភាពវឹកវរក្នុងសង្គម។ ទោះបីយ៉ាងណាក៏ដោយមិនច្បាស់លាស់ដែលថាការណ៍ដែលរិទ្ធីគ្រាន់តែដកស្រង់ឡើងវិញនូវពាក្យសម្តីមួយអាចញុះញង់ឱ្យមនុស្សប្រព្រឹត្តបទឧក្រិដ្ឋបើសូម្បីតែពាក្យនោះមិនបង្ហាញដូច្នោះផងនោះ។ បន្ថែមលើការចាប់ខ្លួនលោកទ្ធី ក្រសួងព័ត៌មានបានដកហូតអាជ្ញាប័ណ្ណប្រតិបត្តិការរបស់ TVFB និងបានបិទគេហទំព័រនេះថែមទៀត។ ទោះបីជាហេតុការណ៍នេះបានកើតឡើងបន្ទាប់ពីឆ្នាំទីបួនបានបញ្ចប់ក៏ដោយ ក៏វាត្រូវបានគូសបញ្ជាក់នៅទីនេះព្រោះវាតំណាងឱ្យស្ថានភាពសេរីភាពខាងការបញ្ចេញមតិក្នុងអំឡុងពេលជំងឺរាតត្បាតសាកលកូវីដ ១៩ ។

---

[94] សូមមើលឧទាហរណ៍ ហេង រស្មី 'ក្រសួងសុខាភិបាលនឹងចាត់វិធានការចំពោះអ្នកដែលបន្តផ្សព្វផ្សាយព័ត៌មានវីរុសកូរ៉ូណានៅកម្ពុជា' (អាស៊ីសេរី, ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២០) <https://www.rfa.org/khmer/news/health/health-ministry-warns-fake-news-on-facebook-01272020042835.html>

[95] សេក បណ្ឌិត, 'លោក ហ៊ុន សែនព្រមានចាប់ខ្លួននាយករងអង្គការសិទ្ធិមនុស្ស Licadho ពីបទការពារអ្នកផ្តល់ព័ត៌មានក្លែងក្លាយ ' (អាស៊ីសេរី, ចេញផ្សាយថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២០) <https://www.rfa.org/khmer/news/human-rights/hun-sen-warns-to-arrest-Am-Sam-Ath-a-rights-defender-03302020024938.html>

[96] ហេង រស្មី " អាជ្ញាធរក្នុងរាជធានីភ្នំពេញបានចាប់ខ្លួនពលរដ្ឋម្នាក់ដែលបានបង្ហោះសារលើបណ្តាញសង្គមទាក់ទងនឹងជំងឺនេះ" (អាស៊ីសេរី, ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០ ) <https://www.rfa.org/khmer/news/law/facebook-user-arrested-after-flying-covid-19-related-news-03092020111159.html>

## ៣.៧.១ បុគ្គលសម្ព័ន្ធភាពជាមួយគណបក្សសង្គ្រោះជាតិត្រូវបានកំណត់ជាគោលដៅដោយមិនសមាមាត្រពីបទផ្សព្វផ្សាយ "ព័ត៌មានក្លែងក្លាយ" អំពីជំងឺកូវីដ ១៩

ក្នុងចំណោមហេតុការណ៍ទាំង ២៦ ករណីដែលបានរឹតត្បិតសេរីភាពខាងការបញ្ចេញមតិទាក់ទងនឹងជំងឺកូវីដ ១៩ មាន៦ករណីត្រូវបានចោទប្រកាន់មកលើសមាជិកអតីតគណបក្សសង្គ្រោះជាតិដែលនាំឱ្យមានការចាប់ខ្លួនពួកគេម្នាក់ៗ។ មានចំនួន១ករណីដែល ឈ្មោះងិន ឃាន អាយុ ២៩ ឆ្នាំដែលជាប្រធានយុវជនគណបក្សសង្គ្រោះជាតិនៅស្រុកព្រះស្តេច ខេត្តព្រៃវែង ត្រូវបាននគរបាលរាជធានីភ្នំពេញចាប់ខ្លួន និងចោទប្រកាន់ពីបទផ្សព្វផ្សាយ *"ព័ត៌មានក្លែងក្លាយ"* ទាក់ទងនឹងជំងឺកូវីដ ១៩ នៅលើទំព័រហ្វេសប៊ុករបស់គាត់។ ។ គាត់ត្រូវបានសាកសួរ និងចោទប្រកាន់ជាបន្តបន្ទាប់ពីបទ *"រួមគំនិតក្បត់"* និង *"ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍"* តាមមាត្រា ៤៥៣ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ។ លោក ឃាន ត្រូវបានបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារព្រៃសក្នុងរាជធានីភ្នំពេញ។[97] ការចោទប្រកាន់នេះឆ្លុះបញ្ចាំងអ្នកដទៃទៀតដែលមានទំនាក់ទំនងជាមួយអតីតគណបក្សសង្គ្រោះជាតិ ត្រូវបានធ្វើទុក្ខបុកម្នេញជាលក្ខណៈប្រព័ន្ធក្នុងឆ្នាំទីបួនទាំងមូល (សូមមើលផ្នែកទី ៣.៤) ហើយករណី *"ដំណឹងក្លែងក្លាយ"* ខុសគ្នាផ្សេងទៀតមិនជាប់ពាក់ព័ន្ធនឹងអតីតគណបក្សសង្គ្រោះជាតិ ។ ក្នុងករណី *"ដំណឹងក្លែងក្លាយ"* ដែលមិនជាប់ពាក់ព័ន្ធនឹងសមាជិកអតីតគណបក្សសង្គ្រោះជាតិដែលត្រូវបានគម្រោងកត់ត្រាគឺមនុស្សត្រូវបានចាប់ខ្លួនតាមមាត្រា ៤២៥ នៃក្រមព្រហ្មទណ្ឌ *"ការក្លែងព័ត៌មាន"* ។ ចំនួនមិនសមាមាត្រដែលប៉ះពាល់តែចំពោះបុគ្គលដែលជាប់ទាក់ទងនឹងអតីតគណបក្សប្រឆាំងអាចបង្ហាញពីហេតុផលនយោបាយឬជាការបង្កើនការត្រួតត្រាទៅលើអ្នកដែលមានទំនាក់ទំនងជាមួយអតីតគណបក្សសង្គ្រោះជាតិ។[98]

---

[97] អង្គការឃ្លាំមើលសិទ្ធិមនុស្ស 'បញ្ជីឈ្មោះចាប់ខ្លួន និងអ្នកដែលកំពុងជាប់ឃុំឃាំងពីបទបទល្មើសទាក់ទងនឹងជំងឺកូវីដ ១៩ (ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០) <https://www.hrw.org/video-photos/interactive/2020/03/23/list-arrests-and-persons-detention-covid-19-related-offenses>

[98] អង្គការឃ្លាំមើលសិទ្ធិមនុស្ស 'កម្ពុជា៖ បញ្ចប់ការបង្ក្រាបលើក្រុមប្រឆាំង (ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០២០) <https://www.hrw.org/news/2020/06/17/cambodia-end-crackdown-opposition> និង UNOHCHR, អាស៊ី៖ Bachelet សម្តែងការព្រួយបារម្ភដោយការគាបសង្កត់លើសេរីភាពក្នុងការបញ្ចេញមតិក្នុងអំឡុងពេលជំងឺកូវីដ ១៩ នៅហ្សីណែវ (ថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០២០) <https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=25920&LangID=E>

# សេរីភាពខាងការជួបប្រជុំ

សេរីភាពខាងការជួបប្រជុំត្រូវបានអនុវត្តជាញឹកញាប់នៅក្នុងប្រទេសកម្ពុជាជាពិសេសដោយអ្នកស្វែងរកមតិគាំទ្រដើម្បីសិទ្ធិដីធ្លី និងដោយនិយោជិតដែលអំពាវនាវឱ្យមានការគោរពសិទ្ធិនៅកន្លែងធ្វើការ។ សេរីភាពនេះគឺជាសេរីភាពដែលទទួលបានការគាំពារច្រើនដោយមានការរឹតត្បិត និងការរំលោភបំពានតិចតួចបំផុតនៅក្នុងឆ្នាំទីបួននេះ។

**តារាងតួលេខទី៣៩៖ ការជួបប្រជុំចំនួន ១៨៥ ករណីបានកើតឡើងក្នុងឆ្នាំទីបួនដែលភាគច្រើននៅត្រីមាសទីបី**




**១៨៥** ការជួបប្រជុំក្នុងឆ្នាំទី៤

**តារាងតួលេខទី៤០៖ ការជួបប្រជុំភាគច្រើនត្រូវបានរៀបចំឡើងដើម្បីតស៊ូមតិលើសិទ្ធិដីធ្លី ខណៈដែលសិទ្ធិរបស់កម្មករនិយោជិតជាមូលហេតុញឹកញាប់បំផុតលំដាប់ទីពីរ**

ការជួបប្រជុំសរុប ១៨៥ ករណីដែលគម្រោងបានកត់ត្រាក្នុងឆ្នាំទី ៤ រួមមាន៖

- ១០១ ករណីជាការជួបប្រជុំដើម្បីសិទ្ធិដីធ្លី( ៥៤% )។
- ៦៨ ករណីជាការជួបប្រជុំដើម្បីសិទ្ធិកម្មករនិយោជិត ( ៣៧% )។
- ១៦ ករណីជាការជួបប្រជុំមូល




**៥៣** ករណីរឹតត្បិតលើសេរីភាពខាងការជួបប្រជុំក្នុងឆ្នាំទី៤

**២១** ករណីរំលោភបំពានលើសេរីភាពខាងការជួបប្រជុំក្នុងឆ្នាំទី៤

**តារាងតួលេខទី៤១៖ ភាពញឹកញាប់នៃការរឹតត្បិតសេរីភាពខាងការជួបប្រជុំតាមខែនីមួយៗ**




**ខែឧសភា៖** ការរឹតត្បិតលើការជួបប្រជុំក្នុងទិវាពលកម្មអន្តរជាតិ

**ខែកក្កដា៖** ការរឹតត្បិតលើការជួបប្រជុំដើម្បីរំឭកខួបមរណភាពរបស់លោកបណ្ឌិត កែម ឡី

**ខែមករា៖** ការកើនឡើងនូវ កូដកម្មរបស់កម្មករនិយោជិត

## ៣.៨ សេរីភាពខាងការជួបប្រជុំត្រូវបានលើកកម្ពស់ភាគច្រើនប៉ុន្តែមានការរឹតត្បិតម្តងម្កាល

**តារាងតួលេខទី៤២៖ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលបានរាយការណ៍ថាមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំ**




នៅក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពសម្រាប់ឆ្នាំទីបួន ៦៧% នៃអ្នកឆ្លើយតបបានរាយការណ៍ថាមាន *"មានសេរីភាពខ្លះដែរ"* ឬ *"មានសេរីភាពខ្លាំងណាស់"* ក្នុងការអនុវត្តសិទ្ធិសេរីភាពខាងការជួបប្រជុំដែលចំនួននេះមានការថយចុះពីចំនួនដែលបានកត់សម្គាល់នៅក្នុងឆ្នាំមុនៗ។

**តារាងតួលេខទី៤៣៖ ថ្នាក់ដឹកនាំសមាគមដែលបានរាយការណ៍ថាមាន ឬគ្មានសេរីភាពខ្លាំងក្នុងការអនុវត្តសិទ្ធិសេរីភាពខាងការជួបប្រជុំ**




ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលបានរាយការណ៍ថាពួកគេថាមានសេរីភាពជាងថ្នាក់ដឹកនាំសហជីពក្នុងការជួបប្រជុំគ្នាដោយសន្តិវិធីដោយ ៩% នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលបានរាយការណ៍ថាពួកគេមានអារម្មណ៍ថា *"មានសេរីភាពខ្លាំងណាស់"* ខណៈពេលដែលមានតែ ៤% នៃថ្នាក់ដឹកនាំសហជីពយល់ឃើញដូចគ្នា។ ស្រដៀងគ្នានេះដែរស្ទើរតែចំនួនទ្វេដងនៃថ្នាក់ដឹកនាំសហជីពយល់ថា *"មិនមានសេរីភាពទាល់តែសោះ"* បើប្រៀបធៀបទៅនឹងថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល។ ភាពខុសគ្នារវាងថ្នាក់ដឹកនាំអង្គការ

សង្គមស៊ីវិល និងសហជីពបានបង្ហាញថាការជួបប្រជុំ ឬកូដកម្មដែលធ្វើឡើងដោយសហជីពទំនងជាមានផលវិបាកអវិជ្ជមានច្រើន។

## ៣.៨.១ ចំណាត់ការរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីហាមឃាត់ការជួបប្រជុំ

នៅឆ្នាំទីបួនគម្រោងបានកត់ត្រាការជួបប្រជុំដែលមានផែនការគ្រោងទុកជាក់លាក់ចំនួន៥ករណីប៉ុន្តែត្រូវបានហាមឃាត់ពីសំណាក់រដ្ឋាភិបាល។ ការជួបប្រជុំដែលហាមឃាត់រួមមានការប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ[99] ការជួបជុំគ្នាដើម្បីរំឭកខួបបីឆ្នាំនៃការសម្លាប់របស់លោកបណ្ឌិត កែម ឡី[100] និងការជួបប្រជុំមួយអំពាវនាវឱ្យមានការរក្សាកិច្ចព្រមព្រៀងពាណិជ្ជកម្ម "*អ្វីៗគ្រប់យ៉ាងលើកលែងតែសព្វាវុធ*" របស់សហភាពអឺរ៉ុប។[101] ការហាមឃាត់មួយចំនួនមិនមានគោលបំណងស្របច្បាប់នោះទេ ដូចជាការមិនអនុញ្ញាតឱ្យមានការប្រារព្ធទិវាសិទ្ធិមនុស្សសម្រាប់សហគមន៍មួយនៅខេត្តកំពត ដែលការហាមឃាត់ទាំងប្រាំមិនមានភាពចាំបាច់នោះទេព្រោះរដ្ឋាភិបាលមានវិធានការណ៍រឹតត្បិតតិចតួចជាងនេះ ហើយគ្រប់គ្រាន់ដើម្បីការពារសន្តិសុខជាតិ សុវត្ថិភាពសាធារណៈ សុខភាពសាធារណៈ ឬសីលធម៌ ឬសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។[102] ឧទាហរណ៍ រដ្ឋាភិបាលអាចដាក់កម្រិតលើការហែក្បួន ឬការជួបប្រជុំនៅទីតាំងផ្សេងៗដែលមានសុវត្ថិភាព ឬអាចផ្តល់សន្តិសុខគ្រប់គ្រាន់ដល់ការពារការជួបប្រជុំ។ ដូច្នេះការហាមឃាត់នីមួយៗនេះបានលើសពីដែនកំណត់នៃការរឹតត្បិតដែលបានអនុញ្ញាតក្នុងក.ស.អ.ព.ន និងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ។

## ៣.៨.២ ការជួបប្រជុំមួយចំនួនតូចត្រូវបានដាក់កម្រិតដោយរាជរដ្ឋាភិបាលកម្ពុជា

គម្រោងបានកត់ត្រាការរឹតត្បិតមកលើការជួបប្រជុំចំនួន៩ករណី ដែលត្រូវបានរឹតត្បិតមុនពេលការជួបប្រជុំកើតឡើង។ ការរឹតត្បិតនេះរួមមានការរឹតត្បិតលើការជួបប្រជុំលើទីតាំងដែលបានគ្រោងទុក ដែលជា

---

[99] ការរាយការណ៍ពីហេតុការណ៍ IRCC219 ។

[100] ខ្លីខ្លី "អាជ្ញាធរមិនអនុញ្ញាតឱ្យមានការជួបប្រជុំនៅកន្លែងដែលលោក កែម ឡី បានស្លាប់ " (សារព័ត៌មានខ្លីខ្លី ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ ២០១៩) <http://kleykley.sabay.com.kh/article/1149462#utm_campaign=onpage>

[101] ញឹម សាខន ' គ្រូបង្រៀនជំរុញឱ្យមានសេរីភាពអ្នកនយោបាយសម្រាប់ EBA' (ការសែតវីអូឌី, ចុះផ្សាយថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៩) <https://vodhotnews.com/2019/07/31/rong-chhun-announces-plans-to-urge-the-government-to-maintain-the-eba/>

[102] ការរឹតត្បិតលើសិទ្ធិសេរីភាពក្នុងការជួបប្រជុំត្រូវ ' (ក) បានកំណត់ដោយអនុលោមតាមច្បាប់។ (ខ) ស្របតាមគោលដៅស្របច្បាប់។ និង (គ) មានភាពចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ។ មាត្រា ២១នៃ ក.អ.ស.ព.ន

ញុំកញ្ញាប់នោះគឺទីលានប្រជាធិបតេយ្យ[103] ការរារាំងអ្នកតវ៉ាមិនឱ្យដង្ហែក្បួន[104] ការកំណត់ចំនួនអ្នកចូលរួម[105] និងកំណត់ម៉ោងតវ៉ា។[106] ការរឹតត្បិតទាំង៩ ករណីបានធ្វើឱ្យថមថយនូវឥទ្ធិពលនៃការជួបប្រជុំដែលបានគ្រោងទុក។ ពេលវេលាកំណត់ និងការរឹតត្បិតស្របច្បាប់ ប្រើសម្រាប់ការរឹតត្បិតត្រូវបានផ្តល់ជាមូលហេតុតែ២ករណីប៉ុណ្ណោះក្នុងចំណោម៩ករណី ។

ការរឹតត្បិតមកលើការជួបប្រជុំអាចមានលក្ខណៈស្របតាមបទដ្ឋានអន្តរជាតិតែក្នុងករណីដែលការរឹតត្បិតនោះអនុលោមទៅតាមច្បាប់ដែលពាក់ព័ន្ធប៉ុណ្ណោះ ហើយត្រូវបានធ្វើឡើងក្នុងគោលដៅស្របច្បាប់ និងមានភាពចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ។[107] ការរឹតត្បិតដែលបំពេញតាមលក្ខខណ្ឌទាំងនេះបើទោះបីវាអាចធ្វើឱ្យថមថយនូវឥទ្ធិពលនៃការជួបប្រជុំ ប៉ុន្តែវាមិនត្រូវបានចាត់ទុកថាជាការរំលោភបំពានលើសេរីភាពខាងការជួបប្រជុំនោះទេ។

## ៣.៩ ១១% នៃការជួបប្រជុំទាំងអស់ធ្លាប់ទទួលរងការជ្រៀតជ្រែកហួសហេតុពីអាជ្ញាធរ

**តារាងតួលេខទី៤៤៖ ការជួបប្រជុំដែលត្រូវបានជ្រៀតជ្រែកដោយរដ្ឋាភិបាល**




បន្ថែមលើការជួបប្រជុំដែលមានការរឹតត្បិតជាមុនរដ្ឋាភិបាល ក៏បានជ្រៀតជ្រែកលើការជួបប្រជុំនោះបន្ទាប់ពីពួកគេបានចាប់ផ្តើមប្រមូលផ្តុំ។ ក្នុងចំណោមការជួបប្រជុំចំនួន ១៨៥ ករណីដែលគម្រោងបានកត់ត្រាមាន ២០ ករណី (១១%) បានជួបប្រទះការជ្រៀតជ្រែកពីអាជ្ញាធរ។ ការជួបប្រជុំចំនួន ១៦៥ ករណីទៀតបានប្រព្រឹត្តទៅដោយគ្មានឧបសគ្គរាំងហើយត្រូវបានការពារដោយអាជ្ញាធរ។ ជាឧទាហរណ៍ ការជ្រៀតជ្រែករួមមានការបិទផ្លូវរបស់

[103] មុំ គន្ធា 'សាលារាជធានីហាមឃាត់គម្រោងហែក្បួនរបស់គ្រូបង្រៀន' (ការសែតខ្មែរថាមន៍, ថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០១៩) <https://www.khmertimeskh.com/50646072/city-hall-prohibits-planned-teacher-march/>

[104] ខន លក្ខិណា ' លោកស្នងការបានចាត់ទុកគម្រោងហែក្បួនរបស់សហជីពជាទង្វើខុសច្បាប់ (វីអូឌី ចុះផ្សាយថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១៩) <https://vodhotnews.com/2019/04/30/99341/the-phnom-penh-municipal-police-did-not-allow-the-unions-to-march/>

[105] *ថ្មីថ្មី* ' អាជ្ញាធររាជធានីភ្នំពេញមិនអនុញ្ញាតឱ្យអតីតមន្ត្រីគណបក្សសង្គ្រោះជាតិ ១១៨ ចូលរួមពិធីរំឭកវិញ្ញាណក្ខន្ធលោកជា វិជ្ជា' (*ថ្មីថ្មី*, ចុះផ្សាយថ្ងៃទី ២១ ខែមករា ឆ្នាំ ២០២០) <https://thmeythmey.com/?page=detail&id=87359>

[106] ខន លក្ខិណា ' អាជ្ញាធរខេត្តមណ្ឌលគីរីរារាំងការរៀបចំពិធីផ្សេងៗរបស់ជនជាតិដើមភាគតិច (ការសែតវីអូឌី, ចុះផ្សាយថ្ងៃទី ៩ ខែសីហា ឆ្នាំ ២០១៩) <https://vodhotnews.com/2019/08/09/190809-vod-leakhena-f-gg-mondulkiri-authorities-prevent-the-celebration-of-world-indigenous-peoples-day-meta-ed/>

[107] មាត្រា ២១ នៃក.អ.ស.ព.ន

ក្រុមអ្នកតវ៉ា [108] ការដកហូតបដា ឬឧបករណ៍បំពងសំឡេងពីក្រុមអ្នកតវ៉ា[109] ការឃាត់មធ្យោបាយដឹកជញ្ជូន[110] ព្រមទាំងចាប់ខ្លួន និងឃុំខ្លួនក្រុមអ្នកតវ៉ា។[111]

## ៣.៩.១ រាជរដ្ឋាភិបាលកម្ពុជាបានប្រើកម្លាំងលើការជួបប្រជុំចំនួនប្រាំបួនករណី

គម្រោងបានកត់ត្រាការជួបប្រជុំចំនួន៩ករណីដែលរដ្ឋាភិបាលបានប្រើកម្លាំងមកលើក្រុមអ្នកតវ៉ាដោយសន្តិវិធី។ យោងតាមបទដ្ឋានច្បាប់អន្តរជាតិចែងថាការប្រើប្រាស់កម្លាំងដោយមន្ត្រីអនុវត្តច្បាប់គួរតែជាករណីលើកលែង ហើយការជួបប្រជុំនានាគួរត្រូវបានគ្រប់គ្រងជាធម្មតាដោយមិនមានប្រើប្រាស់កងកម្លាំងសន្តិសុខ។ លើសពីនេះការប្រើប្រាស់កងកម្លាំងសន្តិសុខណាមួយត្រូវតែគោរពតាមគោលការណ៍នៃភាពចាំបាច់ និងសមាមាត្រ។ បទដ្ឋានច្បាប់អន្តរជាតិក៏ចែងលម្អិតបន្ថែមទៀតអំពីការអនុញ្ញាតឱ្យប្រើកងកម្លាំងនៅកន្លែងជួបប្រជុំដោយធានាថាកម្លាំងត្រូវបានប្រើតែលើបុគ្គលដែលប្រើអំពើហិង្សាប៉ុណ្ណោះ ឬដើម្បីបញ្ចៀសការគំរាមកំហែងដែលអាចកើតមានជាយថាហេតុ។[112] ជាឧទាហរណ៍ ការប្រើកងកម្លាំងរបស់រដ្ឋាភិបាលនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩ នៅពេលដែលអ្នកភូមិប្រមាណ ១០០ នាក់បានធ្វើការតវ៉ានៅមុខក្រសួងរៀបចំដែនដីទាក់ទងនឹងជម្លោះដីធ្លីជាមួយក្រុមហ៊ុន ហេង ហ៊ុយ។ កម្លាំងកងសន្តិសុខខណ្ឌចំការមនបានរុញច្រាន និងវាយអ្នកតវ៉ាដោយសន្តិវិធីនោះ ដែលភាគច្រើនជាស្ត្រីបណ្តាលឱ្យជនរងគ្រោះម្នាក់ត្រូវបានវាយដំរហូតដល់សន្លប់បាត់ស្មារតី។[113]

---

108 ខន លក្ខិណា "អាជ្ញាធរក្រុងតាខ្មៅបានរារាំងកម្មកររោងចក្រពីការធ្វើកូដកម្មនៅខុទ្ទកាល័យនាយករដ្ឋមន្ត្រី" (វីអូឌី ចុះផ្សាយថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០២០) <https://vodkhmer.news/2020/01/17/takhmao-authorities-prevent-factory-workers-from-petitioning-the-pm-office/>

109 សុទ្ធ គឹមសឿន, អ្នកមានទំនាស់ដីធ្លីដាក់ញត្តិនៅស្ថានទូតចិន (កាសែតភ្នំពេញប៉ុស្តិ៍ ចុះផ្សាយថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៩) <https://www.phnompenhpost.com/national/chinese-embassy-petitioned>

110 សេក បណ្ឌិត 'សមត្ថកិច្ចនគរបាលបានរារាំងអ្នកភូមិចំនួន ២០០នាក់មិនឱ្យធ្វើដំណើរដើម្បីគាំទ្រតំណាងរបស់ពួកគេ' (អាស៊ីសេរី, ចុះផ្សាយថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៩) <https://www.អាស៊ីសេរី.org/khmer/news/land/tbaung-khmum-police-bars-200-villagers-from-accompanying-their-representatives-at-court-and-demand-release-2-others-10222019104106.html>.

111 ព័ត៌មានប្រចាំថ្ងៃ 'ការចាប់យកដីធ្លីនៅពន្ធនាគារខេត្តបន្ទាយមានជ័យបណ្តាលឱ្យមនុស្សម្នាក់ស្លាប់ និងរបួស ៤ នាក់ (ព័ត៌មានប្រចាំថ្ងៃ ចុះផ្សាយថ្ងៃទី ៧ ខែមករា ឆ្នាំ ២០២០) <http://www.fridaydailynews.com/Detail/202016203455394>

112 ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ" របាយការណ៍រួមរបស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីនិងខាងសមាគមនិងរបស់អ្នករាយការណ៍ពិសេសស្តីពីការអនុវត្តដោយបង្ខំក្រៅប្រព័ន្ធតុលាការភ្លាមៗ ឬតាមទំនើងចិត្តលើការគ្រប់គ្រងត្រឹមត្រូវនៃការជួបប្រជុំ។" (ថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ ២០១៦) UN Doc. A/HRC/៣១/៦៦ កថាខណ្ឌ ៥៧ ។

113 អាស៊ីសេរី, 'អាជ្ញាធរខណ្ឌចំការមននៅតែប្រើអំពើហិង្សាទៅលើប្រជាជនអំពីរឿងដីធ្លីនៅខេត្តកោះកុង' (អាស៊ីសេរី, ចុះផ្សាយថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៩) <https://www.rfa.org/khmer/news/land/200-families-from-koh-kong-protest-for-land-08222019061357.html>

## ៣.១០ ខាងពាក់កណ្តាលនៃការជួបប្រជុំទាំងអស់ដែលកើតឡើងគឺទាក់ទងនឹងសិទ្ធិដីធ្លី

ក្នុងចំណោមការជួបប្រជុំសរុបចំនួន ១៨៥ ករណី មាន ១០១ ករណី (ឬ ៥៥%) គឺជាការជួបប្រជុំទាក់ទងនឹងសិទ្ធិដីធ្លី។ នេះរួមបញ្ចូលទាំងការជួបប្រជុំនានាពាក់ព័ន្ធនឹងការរំលោភយកដីធ្លី និងការជួបប្រជុំដោយ ឬក្នុងនាមសកម្មជនបរិស្ថាន។ សេរីភាពខាងការជួបប្រជុំជាញឹកញាប់ត្រូវបានអនុវត្តដោយសហគមន៍ការពារសិទ្ធិដីធ្លីដែលបង្ហាញពីតម្លៃនិងឥទ្ធិពលនៃសេរីភាពខាងការជួបប្រជុំ។ សហគមន៍ទាំងនេះដែលជារឿយៗស្ថិតក្នុងចំណោមក្រុមងាយរងគ្រោះបំផុតនៃសង្គមដែលពឹងផ្អែកលើការជួបប្រជុំដោយសន្តិវិធីដើម្បីតស៊ូមតិដើម្បីសិទ្ធិរបស់ពួកគេ។ ស្ទើរតែមួយភាគបួននៃការជួបប្រជុំដើម្បីសិទ្ធិដីធ្លីដែលបានកត់ត្រាក្នុងឆ្នាំទីបួន បានកើតឡើងដោយសារតែសកម្មភាពរបស់ក្រុមហ៊ុន ហេង ហ៊ុយ និងក្រុមហ៊ុនចិនយូញៀន ឌីវីឡុបមិនគ្រុប (UDG)។ ក្រុមហ៊ុនទាំងពីរត្រូវបានផ្តល់ដីសម្បទានសេដ្ឋកិច្ចនៅខេត្តកោះកុងដែលជាហេតុធ្វើឱ្យសហគមន៍ច្រើនគ្រួសារបាត់បង់ដីស្រែ និងផ្ទះសម្បែង។

**តារាងតួលេខទី៤៥៖ ទីតាំងមានការតវ៉ាសិទ្ធិដីធ្លី**[114]



[115]

114 តារាងតួលេខទី៤៥ មិនតំណាងឱ្យទីតាំងនៃការជួបប្រជុំនេះទេពីព្រោះទិន្នន័យមិនសមាត្រនេះផ្តោតជាសំខាន់ទៅលើនៅទីក្រុងភ្នំពេញដែលមានប្រជាពលរដ្ឋជាច្រើនទៅធ្វើការតវ៉ា។ ផ្ទុយទៅវិញ ផែនទីថ្មីៗបង្ហាញពីទីតាំងនៃការរំលោភសិទ្ធិដីធ្លី និងទីលំនៅរបស់អ្នកតវ៉ា។

115 ចំនួនសរុបបានកើនឡើងដល់ ១១៣ ដែលខ្ពស់ជាងចំនួននៃការជួបប្រជុំដើម្បីសិទ្ធិដីធ្លីសរុបចំនួន ១០១ ។ នេះគឺដោយសារតែការជួបប្រជុំខ្លះមានវត្តមានអ្នកតវ៉ាមកពីបណ្តាខេត្តផ្សេងៗគ្នា។

## ៣.១១ ការកើនឡើងចំនួនការជួបប្រជុំដើម្បីសិទ្ធិកម្មករនិយោជិត

**តារាងតួលេខទី៤៦៖ ការជួបប្រជុំសិទ្ធិកម្មករនិយោជិត**




ត្រីមាសទីបួននៃឆ្នាំទីបួន បានឃើញការកើនឡើងនូវចំនួននៃការជួបប្រជុំដែលធ្វើឡើងដោយកម្មករនិយោជិតដែលទាមទារសិទ្ធិកម្មករនិយោជិតដោយមានការជួបប្រជុំចំនួន ៣៧ ករណីកើតឡើង។ ក្នុងត្រីមាសទីបួនប៉ុណ្ណោះ ការជួបប្រជុំចំនួន ២១ លើករបស់កម្មករនិយោជិតគឺដើម្បីទាមទារប្រាក់ឈ្នួលដែលមិនបានបង់ ឬប្រាក់បំណាច់។ ហេតុការណ៍ប្រមូលផ្តុំទាំងនេះ ភាគច្រើនចំពោះវិស័យការដ្ឋានសំណង់[116] និងរោងចក្រ[117] ដែលត្រូវបានផ្អាកឬបិទលែងដំណើរការដោយសារតែជំងឺកូវីដ ១៩ ដោយមិនបានបង់ប្រាក់បៀវត្ស ឬសំណងអ្វីទាំងអស់។ ផ្នែកមួយនៃការបិទអាជីវកម្មដ៏ច្រើនក៏អាចបណ្តាលមកពីការប្រកាសដកផ្នែកខ្លះនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មរបស់សហភាពអឺរ៉ុបកាលពីខែកុម្ភៈ ឆ្នាំ២០២០ ផងដែរ។[118] ការរឹតត្បិតពាណិជ្ជកម្មនាពេលខាងមុខនេះទំនងជានឹងជះឥទ្ធិពលយ៉ាងខ្លាំងដល់វិស័យការងារជាច្រើននៅក្នុងប្រទេសកម្ពុជា ហើយសេចក្តីប្រកាសនេះអាចនឹងជំរុញឱ្យម្ចាស់អាជីវកម្មបិទដំណើរការអាជីវកម្ម។

ជារួមនៅក្នុងឆ្នាំទីបួន គម្រោងបានសង្កេតថាច្បាប់ដែលទាក់ទងទៅនឹងសេរីភាពមូលដ្ឋាននៅតែបានអនុវត្តតាមអំពើចិត្ត ព្រមទាំងត្រូវបានប្រើប្រាស់ខុសទិសដៅជាលក្ខណៈប្រព័ន្ធ។ សកម្មភាពដែលលើសពីការអនុញ្ញាតបន្តកើតឡើងនៅក្នុងប្រទេសកម្ពុជា ខណៈពេលដែលរដ្ឋាភិបាលហាក់ដូចជាកំពុងអនុវត្តដោយមិនគោរពនីតិរដ្ឋដើម្បីបង្រួមលំហសង្គមស៊ីវិល និងការរឹតត្បិតលើការអនុវត្តសេរីភាពមូលដ្ឋាន។ បរិយាកាសនេះបាននាំឱ្យមានការកំហិតសេរីភាពខ្លួនឯងយ៉ាងទូលំទូលាយក្នុងចំណោមថ្នាក់ដឹកនាំសង្គមស៊ីវិលនិងសហជីព រួមជាមួយនឹងការឃាយឃីជាប្រចាំចំពោះបុគ្គលដែលមានទំនាក់ទំនងជាមួយអង្គការសង្គមស៊ីវិល ឬសហជីព។ បើទោះបីជាសេរីភាពខាងការជួបប្រជុំត្រូវបានការពារខ្លះៗក៏នៅតែប្រឈមនឹងការឃ្លាំមើល ការតាមដាន និងការបៀតបៀន ក៏នៅបន្តកើតមានជាទូទៅដែលជាហេតុធ្វើឱ្យមានបរិយាកាសរឹតត្បិតចំពោះសង្គមស៊ីវិល។

---

[116] ឡុង គីមម៉ារីតា ' កម្មករនិយោជិតទទួលបានការឧបត្ថម្ភថវិកា ១០០ ដុល្លារជំនួសប្រាក់ឈ្នួល ' (កាសែតភ្នំពេញប៉ុស្តិ៍ ចុះផ្សាយថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០២០) <https://www.phnompenhpost.com/national/workers-get-100-handout-lieu-wages>

[117] សែន ដារីត ' កម្មកររោងចក្រដែលត្រូវបានព្យួរការងារទាមទារប្រាក់ឈ្នួល (កាសែតខ្មែរថាមន៍, ចុះផ្សាយថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០) <https://www.khmertimeskh.com/50707269/suspended-factory-workers-demand-partial-pay/>

[118] សហភាពអឺរ៉ុប 'សេចក្តីសម្រេចលេខ (EU) ២០២០/៥៥០ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់គណៈកម្មាធិការរបស់សហភាពអឺរ៉ុប' (ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០២០) <https://eur-lex.europa.eu/legalcontent/EN/TXT/?uri=uriserv:OJ.L_.2020.127.01.0001.01.ENG&toc=OJ:L:2020:127:TOC>

## ចំណុចគន្លឹះទី៣៖ តើបុគ្គលម្នាក់ៗមានការយល់ដឹងពីសេរីភាពមូលដ្ឋាន ហើយយល់ថាខ្លួនមានសេរីភាពក្នុងការអនុវត្តសិទ្ធិទាំងនេះដែរឬទេ?

ចំណុចគន្លឹះទី៣ ធ្វើការវាយតម្លៃពីវិសាលភាពដែលបុគ្គលម្នាក់ៗនៅក្នុងប្រទេសកម្ពុជាយល់ដឹងពីសិទ្ធិសេរីភាពរបស់ពួកគេក្នុងការបង្កើតសមាគម ខាងការបញ្ចេញមតិ និងខាងការជួបប្រជុំគ្នា និងវិសាលភាពដែលថា តើសេរីភាពក្នុងការអនុវត្តសិទ្ធិទាំងនេះមានកម្រិតប៉ុណ្ណាដែរ។[119] ទិន្នន័យសម្រាប់ចំណុចគន្លឹះទីបីត្រូវបានចងក្រងតាមរយៈការស្ទង់មតិសាធារណៈក្នុងចំណោមពលរដ្ឋកម្ពុជាចំនួន ៧៧៩ នាក់នៅទូទាំង ២៥ រាជធានី/ខេត្តចាប់ពីខែកុម្ភៈ ឆ្នាំ២០២០ រហូតដល់ ខែមីនា ឆ្នាំ២០២០។[120] ដោយសារហានិភ័យចំពោះសុខភាពបណ្ដាលមកពីជំងឺឆ្លងរាតត្បាតជាសកលកូវីត១៩ ការស្ទង់មតិសាធារណៈ មិនត្រូវបានបញ្ចប់តាមការគ្រោងទុកនោះទេ។ ក្នុងប៉ុន្មានឆ្នាំកន្លងមក គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន បានស្ទង់មតិមនុស្សប្រមាណ ១.០០០ នាក់នៅឆ្នាំនេះ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន បានស្ទង់មតិមនុស្សចំនួន ៧៧៩ នាក់មុនពេលជំងឺឆ្លងរាតត្បាតជាសកល កូវីត១៩ ចាប់ផ្ដើមរាលដាលខ្លាំង។ ហានិភ័យដែលជាប់ទាក់ទងនឹងជំងឺឆ្លងរាតត្បាតជាសកលនេះត្រូវបានចាត់ទុកថាមានទំហំធំធេងណាស់ ដែលមិនអាចបន្តការស្ទង់មតិសាធារណៈបាន។ ទោះជាយ៉ាងណាក្ដី ទំហំនៃការស្ទង់មតិចំនួន ៧៧៩ នាក់នេះគឺជាចំនួនប្រហាក់ប្រហែលដែលអាចធ្វើការប្រៀបធៀបជាមួយនឹងឆ្នាំផ្សេងទៀតបាន។

**របកគំហើញសំខាន់ៗ៖** ទិន្នន័យដែលបានមកពីចំណុចគន្លឹះទីបី គូសបញ្ជាក់ថាការយល់ដឹងរបស់សាធារណជនអំពីសេរីភាពខាងសមាគម ខាងការបញ្ចេញមតិ និងខាងការជួបប្រជុំគ្នាមានកម្រិតតិចតួចបំផុត។ ចំណេះដឹងអំពីក្របខ័ណ្ឌច្បាប់ជាតិដែលពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានទាំងនេះបានធ្លាក់ចុះចាប់តាំងពីឆ្នាំមុនៗ។ យោងតាមលទ្ធផលពីការស្ទង់មតិសាធារណៈ ពលរដ្ឋខ្មែរកាន់តែច្រើនឡើងមានអារម្មណ៍ថា ការមិនមានសេរីភាពក្នុងការអនុវត្តសេរីភាពមូលដ្ឋានរបស់ពួកគេទេ។

## ៤.១ ការយល់ដឹងរបស់សាធារណជនអំពីសេរីភាពមូលដ្ឋាននៅតែបន្តធ្លាក់ចុះ

ជាការចាំបាច់ណាស់សម្រាប់សាធារណជនទូទៅត្រូវមានការយល់ដឹងឱ្យបានច្បាស់ពីសេរីភាពមូលដ្ឋាន ដើម្បីឱ្យបុគ្គលម្នាក់ៗ អាចដឹងនិងអនុវត្តសិទ្ធិសេរីភាពរបស់ពួកគេឱ្យបានពេញលេញ។ កង្វះខាតនូវការយល់ដឹងអំពីសិទ្ធិ នាំឱ្យបុគ្គលម្នាក់ៗ ហាក់មិនអាចកំណត់ដឹងថាមានការការរឹតត្បិតខុសច្បាប់លើសេរីភាពមូលដ្ឋាននោះឡើយ។ ការស្ទង់មតិសាធារណៈនេះមើលនូវចំនួនសមាមាត្រសាធារណជនដែលបានឆ្លើយតបថា ពួកគេមានការយល់ដឹងពេញលេញអំពីសេរីភាពមូលដ្ឋាន។ បុគ្គលទាំងនោះបានឆ្លើយតបថា " បាទចា/ស៎ខ្ញុំដឹងច្បាស់ " នៅពេលត្រូវបានសួរថា" តើអ្នកដឹងថាសេរីភាព____មានន័យដូចម្ដេច?" ត្រូវបានកត់ត្រាថាមានការ

[119] ទិន្នន័យសម្រាប់ចំណុចគន្លឹះទី៣ ត្រូវបានដកស្រង់ពីការស្ទង់មតិសាធារណៈរបស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ដែលបានធ្វើក្នុងខែតុលា ឆ្នាំ២០១៦ (ឆ្នាំទី១) ខែមីនា ឆ្នាំ២០១៨ (ឆ្នាំទី២) ខែមីនា ឆ្នាំ២០១៩ (ឆ្នាំទី៣) និងខែមីនា ឆ្នាំ២០២០ (ឆ្នាំទី៤)។
[120] លទ្ធផលពេញលេញដែលបានពីការស្ទង់មតិសាធារណៈឆ្នាំទីបួនមានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី ៣។

យល់ដឹងពេញលេញ[121]។ កម្រិតនៃការយល់ដឹងអំពីសេរីភាពមូលដ្ឋាននីមួយៗ ត្រូវបានរាយការណ៍ថាមានការថយចុះនៅឆ្នាំទី៤ ដែលនេះជាកំណត់ត្រាកម្រិតនៃការយល់ដឹងទាបបំផុតធៀបនឹងឆ្នាំមុនៗ។

**តារាងតួលេខទី៤៧៖ ភាគរយនៃចំនួនពលរដ្ឋខ្មែរដែលរាយការណ៍ថាមានការយល់ដឹងពេញលេញអំពីសេរីភាពមូលដ្ឋាន[122]**




នៅតែបន្តមានការយល់ដឹងតិចបំផុតអំពីសេរីភាពខាងសមាគម ក្នុងចំណោមសេរីភាពមូលដ្ឋានដែលបច្ចុប្បន្នមានកម្រិតស្មើនឹងមួយភាគបីនៃអ្វីដែលមាននៅក្នុងឆ្នាំទីពីរ។ ការចរចាអនុសញ្ញារួមដែលជាផ្នែកដ៏សំខាន់មួយនៃសេរីភាពខាងសមាគមនៅតែបន្តមានការយល់តិចតួចនៅឡើយ។ ខណៈពេលដែលសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំគ្នាត្រូវបានយល់ដឹងប្រសើរឡើង តែមានតែអ្នកឆ្លើយតបតិចតួចបំផុតដែលបង្ហាញថាមានការយល់ដឹងពេញលេញ។

## ៤.២ កម្រិតយល់ដឹងរបស់សាធារណជនអំពីច្បាប់ជាតិដែលគ្របដណ្តប់លើសេរីភាពមូលដ្ឋាននៅតែមានកម្រិតទាប ហើយមានការធ្លាក់ចុះយ៉ាងខ្លាំងនៃការយល់ដឹងអំពីសេរីភាពខាងការបញ្ចេញមតិ

ការស្ទង់មតិសាធារណៈពិនិត្យពីកម្រិតនៃការយល់ដឹងអំពីច្បាប់ជាតិ ដែលគ្របដណ្តប់លើសេរីភាពមូលដ្ឋានដោយសួរថា តើអ្នកឆ្លើយតបជឿថាសកម្មភាពជាក់លាក់ណាមួយមានលក្ខណៈស្របច្បាប់ ឬខុសច្បាប់។ ការយល់ដឹងអំពីច្បាប់គឺមានសារៈសំខាន់ណាស់ សម្រាប់ពលរដ្ឋធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ។ ការយល់ច្រលំអាចនាំឱ្យពលរដ្ឋធ្វើសកម្មភាពខុសច្បាប់ ឬប្រសិនបើសាធារណជនជឿថា ក្របខ័ណ្ឌច្បាប់ជាតិមានការរឹតត្បិតខ្លាំងជាងការពិតជាក់ស្តែង នោះពលរដ្ឋមិនបានអនុវត្តសិទ្ធិស្របច្បាប់របស់ពួកគេឡើយ។

### ៤.២.១ សេរីភាពខាងសមាគម

**តារាងតួលេខទី៤៨៖ អ្នកឆ្លើយតបដែលយល់ថា ការបង្កើតក្រុមសន្សំប្រាក់ដោយមិនមានការអនុញ្ញាតជាទង្វើខុសច្បាប់[123]**

[121] ការយល់ដឹងអំពីការចរចាអនុសញ្ញារួមត្រូវបានកំណត់ដោយការសួរសំណួរក្នុងទម្រង់ដូចគ្នា។
[122] ទិន្នន័យនេះមិនអាចកំណត់បានសម្រាប់ឆ្នាំទីមួយដោយសារទម្រង់សំណួរមានការផ្លាស់ប្តូរក្នុងឆ្នាំទីពីរ។
[123] សំណួរនេះមិនត្រូវបានសួរនៅក្នុងការស្ទង់មតិសាធារណៈដែលបានធ្វើឡើងនៅឆ្នាំទីមួយទេ។




យោងតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល សមាគមទាំងអស់រួមទាំងក្រុមសន្សំប្រាក់ត្រូវចុះបញ្ជីនៅក្រសួងមហាផ្ទៃ។ ដូច្នេះ ទោះបីក្រុមសន្សំប្រាក់ មានការពេញនិយមនៅទូទាំងប្រទេសកម្ពុជាក៏ដោយក៏ក្រុមប្រភេទនេះមិនស្របច្បាប់ដែរប្រសិនបើមិនបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ។[124] លទ្ធផលពីឆ្នាំទី៤ បង្ហាញថាចំនួនអ្នកឆ្លើយតបពាក់កណ្តាលយល់ដឹងថា ក្រុមសន្សំប្រាក់ដែលមិនបានចុះបញ្ជី គឺបំពានលើច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដែលនេះបង្ហាញថាមានការយល់ដឹងនិងប្រសើរឡើងជាងឆ្នាំមុនៗ។

**តារាងតួលេខទី៤៩៖ អ្នកដែលឆ្លើយតបយល់ថា អង្គការសង្គមស៊ីវិល ដែលធ្វើសកម្មភាពដោយមិនបានជូនដំណឹងដល់អាជ្ញាធររបស់រាជរដ្ឋាភិបាលកម្ពុជាជាទង្វើខុសច្បាប់**[125]




អ្នកឆ្លើយតបភាគច្រើនយល់ខុសថាគឺជាអំពើខុសច្បាប់ដែលអង្គការសង្គមស៊ីវិលធ្វើសកម្មភាពដោយមិនជូនដំណឹងដល់អាជ្ញាធររបស់រាជរដ្ឋាភិបាលកម្ពុជា។ អ្នកឆ្លើយតបពីការស្ទង់មតិតិចជាង៤០ %យល់ថា គឺជាអំពើស្របច្បាប់ដែលអង្គការសង្គមស៊ីវិលធ្វើសកម្មភាពដោយមិនបាច់ជូនដំណឹង ឬទទួលបានការអនុញ្ញាតជាមុនពីអាជ្ញាធរ។ ទោះបីជាការជូនដំណឹងជាមុនសម្រាប់ការធ្វើសកម្មភាពរបស់អង្គការសង្គមស៊ីវិលត្រូវបានដាក់ចេញយ៉ាងចម្រូងចម្រាស់ក៏ដោយ ក៏ត្រូវបានលុបចោលវិញនៅឆ្នាំ ២០១៨ ។[126]

ចំនួនភាគរយនៃអ្នកយល់ដោយមិនត្រឹមត្រូវថា គឺជាទង្វើខុសច្បាប់ដែលអង្គការសង្គមស៊ីវិលធ្វើសកម្មភាពដោយមិនជូនដំណឹងជាមុននៅតែមានភាពស៊ីសង្វាក់គ្នាជាមួយនឹងឆ្នាំមុនៗ។ នេះអាចបណ្តាលមកពីការពិតដែលថាសេចក្តីណែនាំដែលលុបចោលនូវការសុំការអនុញ្ញាតជាមុនមិនត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ

[124] មាត្រា ៩ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបានហាមឃាត់អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមដែលមិនបានចុះបញ្ជីក្នុងការធ្វើសកម្មភាពគ្រប់ប្រភេទ។ មាត្រា ៣២ ចែងពីការផ្តន្ទាទោសព្រហ្មទណ្ឌក្នុងករណីមានការរំលោភលើមាត្រា ៩ ។ ដូចបានកត់សម្គាល់នៅក្នុងរបាយការណ៍ប្រចាំឆ្នាំសម្រាប់ឆ្នាំទីមួយ បញ្ញត្តិនៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនេះបានរំលោភលើមាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។

[125] សំណួរនេះមិនត្រូវបានសួរទេនៅក្នុងការស្ទង់មតិសាធារណៈដែលបានធ្វើឡើងក្នុងឆ្នាំទីមួយ។

[126] ចំណុច ៩១ ចំណុចគន្លឹះទីមួយ.១. 'របាយការណ៍ប្រចាំឆ្នាំទីបី៖ ការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា' (ខែកញ្ញា ឆ្នាំ២០១៩ ម.ស.ម.ក , អាដហុក, មជ្ឈមណ្ឌលសាមគ្គី និងមជ្ឈមណ្ឌលអន្តរជាតិដើម្បីច្បាប់ដោយមិនយកកម្រៃ។

នោះទេកាលពីឆ្នាំ២០១៨។ ចំណុចគន្លឹះទី២ បានកំណត់ថា លក្ខខណ្ឌតម្រូវនេះនៅតែត្រូវបានអនុវត្តជារឿយៗ ដោយអាជ្ញាធរមួយចំនួន។ ជាការគួរឱ្យព្រួយបារម្ភដោយសារពលរដ្ឋភាគច្រើននៅតែយល់ថា អង្គការសង្គមស៊ីវិលត្រូវមានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជាមុន ពេលអនុវត្តការជួបប្រជុំ ធ្វើសកម្មភាព ការបណ្តុះ បណ្តាល ឬធ្វើព្រឹត្តិការណ៍ណាមួយ។

## ៤.២.២ សេរីភាពខាងការបញ្ចេញមតិ

### តារាងតួលេខទី៥០៖ អ្នកឆ្លើយតបយល់ថា ការជជែកពិភាក្សាពីនយោបាយជាទង្វើខុសច្បាប់[127]




ឆ្នាំទីបួនបានបង្ហាញពីការកើនឡើងគួរឱ្យកត់សម្គាល់នៃអ្នកឆ្លើយតបដែលយល់មិនត្រឹមត្រូវថា ការពិភាក្សាពីនយោបាយជាមួយអ្នកដទៃគឺ ជាអំពើខុសច្បាប់។ យោងតាមច្បាប់ជាតិ ពលរដ្ឋមានសេរីភាពក្នុងការពិភាក្សាពីនយោបាយ។ ការយល់ច្រលំកាន់តែច្រើននេះអាចបណ្តាលមកពី ការលាបពណ៌ក្រុមនយោបាយប្រឆាំងថាជា " *បដិវត្តពណ៌*" និងការបំបាក់ទឹកចិត្ត ក្នុងការបញ្ចេញមតិរឿងនយោបាយដែលមានទស្សនៈផ្ទុយ ដូចដែលបានកំណត់នៅក្នុងចំណុចគន្លឹះទីពីរ។

### តារាងតួលេខទី៥១៖ អ្នកឆ្លើយតបយល់ថាការរិះគន់គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាជាទង្វើខុសច្បាប់[128]




២២នៃ %អ្នកឆ្លើយតបនៅក្នុងឆ្នាំទី ៤ បានបង្ហាញថាពួកគេយល់ថាការរិះគន់គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ជាទង្វើខុសច្បាប់។ នេះបង្ហាញថាស្ទើរតែមួយភាគបួននៃសាធារណជនយល់ថាក្របខ័ណ្ឌច្បាប់ជាតិ សម្រាប់សេរីភាពខាងការបញ្ចេញមតិ មានភាពរឹតត្បិតខ្លាំង ជាងការពិតជាក់ស្តែង។ ដូច្នេះនេះអាចបំបិទនូវសិទ្ធិខាងការបញ្ចេញមតិ ដោយសារតែការភ័យខ្លាចដោយមិនត្រឹមត្រូវថាជាការធ្វើសកម្មភាពដោយខុសច្បាប់។

## ៤.២.៣ សេរីភាពខាងការជួបប្រជុំ

[127] សំណួរនេះមិនត្រូវបានសួរនៅក្នុងការស្ទង់មតិសាធារណៈកាលពីឆ្នាំទីមួយនោះទេ។

[128] សំណួរនេះមិនត្រូវបានសួរនៅក្នុងការស្ទង់មតិសាធារណៈកាលពីឆ្នាំទីមួយនោះទេ។

**តារាងតួលេខទី៥២៖ អ្នកឆ្លើយតបយល់ថា ការធ្វើកូដកម្មដោយមិនមានការអនុញ្ញាតពីនិយោជក ឬអាជ្ញាធរជា ទង្វើខុសច្បាប់**[129]




លទ្ធផលនៃការស្ទង់មតិសាធារណៈក្នុងឆ្នាំទី៤ បង្ហាញថា អ្នកឆ្លើយតបចំនួន ៥៤% យល់ថាកម្មករនិយោជិត ត្រូវមានការអនុញ្ញាតពីនិយោជក ឬរាជរដ្ឋាភិបាលកម្ពុជាមុនពេលធ្វើកូដកម្ម ដែលជាការយល់ឃើញមួយស្របគ្នានឹងឆ្នាំមុនៗ។ លទ្ធភាពធ្វើកូដកម្មដើម្បីទាមទារលក្ខខណ្ឌការងារកាន់តែល្អប្រសើរ ឬការទូទាត់ប្រាក់គឺជាផ្នែកសំខាន់មួយ នៃសេរីភាពខាងសមាគម ហើយសិទ្ធិនេះ មិនត្រូវបានរារាំងដោយការអនុញ្ញាតពីនិយោជក ឬអាជ្ញាធរឡើយ។ របកគំហើញនេះបង្ហាញថា សាធារណជនមួយចំនួនធំនៅតែបន្តយល់ច្រលំអំពីក្របខ័ណ្ឌច្បាប់ជាតិស្តីពីសិទ្ធិធ្វើកូដកម្ម ហើយពួកគេយល់ថា ក្របខ័ណ្ឌច្បាប់នេះមានលក្ខណៈរឹតត្បិតខ្លាំងជាងការពិតជាក់ស្តែង។ ការយល់ច្រលំនេះអាចរារាំងដល់ការអនុវត្តសិទ្ធិធ្វើកូដកម្ម និងអនុញ្ញាតឱ្យមានការរំលោភសិទ្ធិមនុស្សនៅកន្លែងធ្វើការ។

## ៤.៣ ពលរដ្ឋខ្មែរភាគច្រើនមិនយល់ថាមានសេរីភាពក្នុងការអនុវត្តសិទ្ធិសេរីភាពមូលដ្ឋានទេ

ការស្ទង់មតិសាធារណៈបង្ហាញពីចំណាប់អារម្មណ៍របស់ពលរដ្ឋ ចំពោះសេរីភាពក្នុងការអនុវត្តសិទ្ធិសេរីភាពមូលដ្ឋានរបស់ខ្លួន។ ចំពោះការឆ្លើយសំណួរនីមួយៗដែលបានសួរថា *“តើអ្នកយល់ថាមានសេរីភាពកម្រិតណាក្នុងការ___” “មានសេរីភាពខ្លាំងណាស់“ ”មានសេរីភាពខ្លះដែរ“ , ”មានសេរីភាពតិចតួច ”ឬ“ មិនមានសេរីភាពទាល់តែសោះ”*។ ការកំណត់ពីការយល់ឃើញរបស់អ្នកឆ្លើយតបថា*”មានសេរីភាព”* ត្រូវបានគណនាដោយការបូកចំនួនសរុបនៃអ្នកឆ្លើយតបដែលយល់ថា” *មានសេរីភាពខ្លាំងណាស់”* និង*”មានសេរីភាពខ្លះដែរ”* ចំពោះសំណួរជាក់ លាក់នេះ។ ចម្លើយលម្អិតចំពោះសំណួរនីមួយៗអាចមើលបាននៅក្នុងឧបសម្ព័ន្ធទី ៣។ ជារួមមាននិន្នាការថយចុះនូវកម្រិតសេរីភាពដែលប្រជាពលរដ្ឋយល់ចំពោះការអនុវត្តសិទ្ធិសេរីភាពរបស់ខ្លួន។

### ៤.៣.១ ការអនុវត្តសិទ្ធិសេរីភាពខាងសមាគម

129 សំណួរនេះមិនត្រូវបានសួរនៅក្នុងការស្ទង់មតិសាធារណៈកាលពីឆ្នាំទីមួយនោះទេ។

**តារាងតួលេខទី៥៣៖ អ្នកឆ្លើយតបយល់ថា ពួកគេមានសេរីភាពក្នុងការចូលរួមជាមួយក្រុមស្របច្បាប់**




ក្នុងឆ្នាំទីបួនមានមនុស្សតែ ៤១ % ប៉ុណ្ណោះបានយល់ថា មានសេរីភាពក្នុងការចូលរួមជាមួយក្រុមស្របច្បាប់ណាមួយ ដែលជាភាគរយទាបបំផុតសម្រាប់កំណត់ត្រានេះ ចាប់តាំងពីការចាប់ផ្តើមគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ។[130] របកគំហើញនេះបង្ហាញថា តិចជាងពាក់កណ្តាលនៃពលរដ្ឋខ្មែរយល់ថា មានសេរីភាពក្នុងការអនុវត្តសេរីភាពខាងសមាគមរបស់ខ្លួន។

**តារាងតួលេខទី៥៤៖ ក្រុមអាយុដែលបុគ្គលយល់ថាមានសេរីភាពក្នុងការចូលរួមជាមួយក្រុមដែលស្របច្បាប់**




លទ្ធផលនៃ ការស្ទង់មតិសាធារណៈឆ្នាំទីបួនបង្ហាញថា អ្នកឆ្លើយតបដែលមានអាយុច្រើនយល់ថាមិនមានសេរីភាពក្នុងការចូលរួមជាមួយក្រុមដែលស្របច្បាប់ និងអនុវត្តសិទ្ធិសេរីភាពខាងសមាគមច្រើនជាងយុវជនជំនាន់ក្រោយ។ យុវជនទំនងជាយល់ថាមានសេរីភាពក្នុងការចូលរួមជាមួយក្រុមដែលស្របច្បាប់ច្រើនជាងអ្នកដែលមានវ័យចាប់ពី ៤៦ ឆ្នាំឡើង។

**តារាងតួលេខទី៥៥៖ អ្នកដែលយល់ថាមានសេរីភាពក្នុងការចូលរួមខាងនយោបាយ**




មានអ្នកឆ្លើយតបសំណួរត្រឹមតែ២៨% ប៉ុណ្ណោះ ដែលយល់ថាមានសេរីភាពក្នុងការចូលរួមខាងនយោបាយ។ នេះគឺជាចំនួនសមាមាត្រទាបបំផុតដែលបានកត់ត្រាដោយគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន។ និន្នាការនេះកើតមានស្របពេលនឹងការបង្ក្រាបលើ

[130] សំណួរនេះត្រូវបានសួរខុសគ្នានៅក្នុងឆ្នាំទីមួយ *តើអ្នកយល់"ថាមានសេរីភាពកម្រិតណាដែលអ្នកអាចចូលរួមក្រុមណាមួយជាមួយអ្នកដទៃសម្រាប់គោលបំណងរួមមួយ"?*

អតីតគណបក្សជំទាស់ ពោលគឺគណបក្សសង្គ្រោះជាតិដែលអាចផ្តល់ជាការបកស្រាយមួយដល់ប្រជាពលរដ្ឋភាគច្រើន ដែលនាំឱ្យមិនយល់ថាមានសេរីភាពក្នុងការចូលរួមពាក់ព័ន្ធនឹងនយោបាយ។

**តារាងតួលេខទី៥៦៖ អ្នកឆ្លើយតបជាបុរសស្ត្រីដែលយល់ថាមានសេរីភាពក្នុងការចូលរួមខាងនយោបាយ[131]-**




ក្នុងរយៈពេល៤ឆ្នាំនៃការឃ្លាំមើល ការស្ទង់មតិសាធារណៈបានបង្ហាញស្រដៀងគ្នាថា អ្នកឆ្លើយតបជាស្ត្រីយល់ថា មានសេរីភាពក្នុងការចូលរួមខាងនយោបាយតិចជាង បើប្រៀបធៀបទៅនឹងបុរសដែលបានឆ្លើយតប។ លទ្ធផលឆ្នាំទីបួន បានបង្ហាញថាមានអ្នកឆ្លើយតបជាស្ត្រីតែ ២៣ប៉ុណ្ណោះដែលបានយល់ % ថាមានសេរីភាពក្នុងការចូលរួមខាងនយោបាយ។ នេះអាចបណ្តាលមកពីបទដ្ឋានវប្បធម៌ដែលចាក់ឫសគល់ខ្លាំង ដែលរារាំងដល់លទ្ធភាពរបស់ស្ត្រី ក្នុងការចូលរួមគ្រប់វិស័យនៃនយោបាយ។ អ្នកឆ្លើយតបជាបុរសដែលយល់ថា មានសេរីភាពក្នុងការចូលរួមខាងនយោបាយបានធ្លាក់ចុះជិតពាក់កណ្តាលចាប់តាំងពីឆ្នាំទីមួយ។ អ្នកឆ្លើយតបជាស្ត្រីដែលយល់ថាមានសេរីភាពក៏មានការថយចុះជាលំដាប់ផងដែរ។

## ៤.៣.២ សេរីភាពខាងការបញ្ចេញមតិ

**តារាងតួលេខទី៥៧៖ អ្នកឆ្លើយតបដែលយល់ថាមានសេរីភាពក្នុងការនិយាយស្តីដោយបើកចំហចំពោះគ្រប់ប្រធានបទទាំងអស់ជាសាធារណៈ**




ឆ្នាំទី៤ បានកត់ត្រាភាគរយទាបបំផុតនៃអ្នកឆ្លើយតបដែលយល់ថាមានសេរីភាពក្នុងការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិជាសាធារណៈ។ ភាគរយនៃអ្នកឆ្លើយតបដែលយល់ថាមានសេរីភាពក្នុងការនិយាយស្តីដោយបើកចំហចំពោះគ្រប់ប្រធានបទទាំងអស់ជាសាធារណៈបានធ្លាក់ចុះពាក់កណ្តាលពី ៦៤ក្នុងឆ្នាំទី %មួយដល់ ៣២នៅឆ្នាំទី %បួន ។

---

[131] ១នៃ %អ្នកឆ្លើយតបដែលមិនបានដាក់អត្តសញ្ញាណប្រុស ឬស្រី ឬមិនមានបំណងឆ្លើយតបមិនត្រូវបានដាក់បញ្ចូលក្នុងទិន្នន័យនេះទេ។

**តារាងតួលេខទី៥៨៖សាធារណជនដែលយល់ថាមានសេរីភាពក្នុងការនិយាយដោយបើកចំហនៅលើបណ្តាញសង្គម[132]**




ឆ្នាំទី៤បានកត់ត្រានូវការធ្លាក់ចុះបន្ថែមទៀតនៃចំនួនសមាមាត្រ របស់អ្នកដែលយល់ថាមានសេរីភាពក្នុងការនិយាយដោយបើកចំហនៅលើបណ្តាញសង្គម ឧទាហរណ៍) ហ្វេសបុកនិងអ៊ិន ,ធីកថក ,យូធូប ,ធ្វីតធើ , (ស្កាក្រាម។ មានអ្នកឆ្លើយតបតែ ២៩% ប៉ុណ្ណោះ ដែលបានយល់ថា មានសេរីភាពក្នុងការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួននៅលើបណ្តាញសង្គម។

**តារាងតួលេខទី៥៩៖ អ្នកឆ្លើយតបជាបុរសស្ត្រីដែលយល់ថាមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួននៅលើ បណ្តាញសង្គម[133]**




មានភាពខុសគ្នាគួរឱ្យកត់សម្គាល់ចំពោះចំនួនរបស់បុរសនិងស្ត្រីដែលយល់ថា មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួននៅលើបណ្តាញសង្គម។ មានតែ ៩ %នៃអ្នកឆ្លើយតបជាស្ត្រីប៉ុណ្ណោះដែលបានឆ្លើយថាមានសេរីភាពក្នុងការធ្វើដូច្នេះ បើប្រៀបធៀបទៅនឹងបុរសចំនួន ១៩។ ភាពខុសគ្នានេះអាចជាផ្នែកមួយដែលបណ្តាលមកពី %គម្លាត យេនឌ័រឌីជីថល។ កម្រិតនៃការប្រើប្រាស់អ៊ីនធឺណិត និងភាពជាម្ចាស់លើទូរស័ព្ទទំនើប គឺមិនមានសមភាពទេរវាងបុរស និងស្ត្រី។[134] វិសមភាពយេនឌ័រតាមអ៊ិនធឺណិត គឺជាឧបសគ្គមួយដល់ការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិតាមអ៊ិនធឺណិតដែលធ្វើឱ្យស្ត្រី និងក្មេងស្រីជួបនូវគុណវិបត្តិ។ វិសមភាពនេះ ត្រូវតែមានដំណោះស្រាយដើម្បីឱ្យមនុស្សគ្រប់រូបអាចប្រើប្រាស់បណ្តាញសង្គមជាវេទិកាដ៏មានតម្លៃសម្រាប់ការបញ្ចេញមតិដោយសេរីនៅក្នុងយុគសម័យឌីជីថលនេះ។

**តារាងតួលេខទី៦០៖ អ្នកដែលយល់ថាមានសេរីភាពក្នុងការនិយាយតាមប្រព័ន្ធផ្សព្វផ្សាយ**

132 សំណួរនេះមិនត្រូវបានសួរទេនៅក្នុងការស្ទង់មតិសាធារណៈដែលបានធ្វើឡើងក្នុងឆ្នាំទីមួយ។

133 ១នៃ %អ្នកឆ្លើយតបតបដែលមិនបានដាក់អត្តសញ្ញាណប្រុស ឬស្រី ឬមិនមានបំណងឆ្លើយតបមិនត្រូវបានដាក់បញ្ចូលក្នុងទិន្នន័យនេះទេ។

134 ករណីសិក្សាលទ្ធភាពប្រើប្រាស់ស្តីពី *'រឿងរ៉ាវអំពីអ៊ីនធឺណិតនៅក្នុងទ្វីបអាហ្វ្រិក អាស៊ី និងអាមេរិកឡាទីន'* (២០១៨) នៅលើគេហទំព័រ <https://afteraccess.net/wp-content/uploads/After-Access-Website-layout-r1.pdf> ដែលកត់សម្គាល់ឃើញថានៅក្នុងប្រទេសកម្ពុជាមានបុរស ៤៥ %ជាអ្នកប្រើប្រាស់អ៊ីនធឺណិតខណៈដែលស្ត្រីមានតែ ៣០ %ប៉ុណ្ណោះ ហើយបុរស ៥២នៅក្នុងប្រទេស %កម្ពុជាមានទូរស័ព្ទទំនើបប្រើជាកម្មសិទ្ធិបើប្រៀបធៀបទៅនឹងស្ត្រីដែលមាន ៤៦។%

នៅក្នុងឆ្នាំទី៤ មានតែ ៣២នៃ %អ្នកឆ្លើយតបប៉ុណ្ណោះដែលយល់ថា មានសេរីភាពក្នុងការនិយាយស្តីតាមប្រព័ន្ធផ្សព្វផ្សាយ។ លទ្ធផលទាំងនេះជាចំនួនដ៏ទាបបំផុត ចាប់តាំងពីពេលចាប់ផ្តើមការស្ទង់មតិសាធារណៈមក។ របកគំហើញនេះនាំឱ្យមានការព្រួយបារម្ភ ចំពោះសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងព័ត៌មាន។ ប្រព័ន្ធផ្សព្វផ្សាយសេរី និងឯករាជ្យគឺជាទិដ្ឋភាពសំខាន់មួយនៃការសម្រេចបាននូវសិទ្ធិទាំងនេះ យ៉ាងពិតប្រាកដ។ បច្ចុប្បន្នពលរដ្ឋហាក់ដូចជាមិនសូវនិយាយស្តីតាមប្រព័ន្ធផ្សព្វផ្សាយដូចដែលធ្លាប់បានធ្វើឡើងកាលពីបួនឆ្នាំមុនទេ ដែលនេះរារាំងដល់លទ្ធភាពរបស់ប្រព័ន្ធបណ្តាញផ្សព្វផ្សាយក្នុងការចែកចាយព័ត៌មានឯករាជ្យដល់ប្រជាជន។




### ៤.៣.៣ សេរីភាពខាងការជួបប្រជុំ

**តារាងតួលេខទី៦១៖ អ្នកដែលយល់ថាមានសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី**




នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សេរីភាពខាងការជួបប្រជុំ ត្រូវបានកត់ត្រាជាប្រចាំថាត្រូវបានការពារបំផុត ក្នុងចំណោមសេរីភាពមូលដ្ឋានទាំងបីនៅក្នុងប្រទេសកម្ពុជា។ ទោះបីជាយ៉ាងនេះក្តីទិន្នន័យពីឆ្នាំទីបួនបង្ហាញថា មានការធ្លាក់ចុះ ៨ %ចំពោះអ្នកដែលយល់ថាមានសេរីភាពខាងការជួបប្រជុំដោយសន្តិវិធីពីឆ្នាំទី៣ និងថយចុះ ២៨ %ចាប់តាំងពីឆ្នាំទីពីរ ។

**តារាងតួលេខទី៦២៖ បុគ្គលតាមប្រភេទអាយុនីមួយៗដែលយល់ថាមានសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី**

តាមលទ្ធផលនៃការស្ទង់មតិសាធារណៈឆ្នាំទីបួន បានបង្ហាញថា អ្នកឆ្លើយតបដែលមានអាយុច្រើនយល់ថា មិនមានសេរីភាពខាងការជួបប្រជុំដោយសន្តិវិធីជាងអ្នកឆ្លើយតប ដែលមានអាយុតិច។ ខណៈដែល ៥០ នៃអ្នកដែលមាន %អាយុពី ១៦ ទៅ ២៥ ឆ្នាំ មានយល់ថា មានសេរីភាពក្នុងការអនុវត្តសិទ្ធិសេរីភាពខាងការជួបប្រជុំរបស់ពួកគេ



ហើយមានត្រឹមតែ ២៧% ប៉ុណ្ណោះនៃអ្នកដែលមានអាយុចាប់ពី ៤៦ ឆ្នាំឡើងដែលមានទស្សនស្រដៀងគ្នានេះ។

## ៤.៤ ការមានទំនុកចិត្តនៅមានកម្រិតនៅក្នុងការដោះស្រាយបញ្ហារំលោភសិទ្ធិមនុស្ស

ជាការចាំបាច់ណាស់ក្នុងការលើកកម្ពស់ និងការពារសេរីភាពមូលដ្ឋានដែលពលរដ្ឋមានការជឿជាក់លើលទ្ធភាពរបស់ខ្លួនក្នុងការទទួលបានយន្តការដោះស្រាយ ឬមធ្យោបាយផ្សេងៗទៀតប្រសិនបើសិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពាន។ នៅប្រទេសកម្ពុជា កម្រិតនៃការជឿទុកចិត្តតិចតួចថារដ្ឋាភិបាលនិងប្រព័ន្ធយុត្តិធម៌អាចផ្តល់ដំណោះស្រាយចំពោះការរំលោភសិទ្ធិមនុស្ស។

**តារាងតួលេខទី៦៣៖ អ្នកដែលយល់ថាមានភាពងាយស្រួលក្នុងការប្តឹងទៅរាជរដ្ឋាភិបាលកម្ពុជា ឬតុលាការពីការរំលោភសិទ្ធិមនុស្ស**[135]




មានតែ ១៩% នៃអ្នកឆ្លើយតបប៉ុណ្ណោះដែលបានយល់ថាមានភាពងាយស្រួលក្នុងការប្តឹងពីករណីរំលោភសិទ្ធិមនុស្សទៅកាន់រាជរដ្ឋាភិបាលកម្ពុជា ឬតុលាការ។ តួលេខនេះស្របគ្នានឹងឆ្នាំមុនៗប៉ុន្តែវានៅតែមានកម្រិតទាបនៅឡើយ។

**តារាងតួលេខទី៦៤៖ អ្នកដែលមានជំនឿទុកចិត្តថារាជរដ្ឋាភិបាលកម្ពុជា ឬតុលាការនឹងផ្តល់ដំណោះស្រាយចំពោះការរំលោភសិទ្ធិមនុស្ស**[136]

កម្រិតនៃការជឿទុកចិត្តចំពោះរាជរដ្ឋាភិបាលកម្ពុជា ឬតុលាការ ក្នុងការផ្តល់ដំណោះស្រាយចំពោះការរំលោភសិទ្ធិមនុស្សនៅតែមានកម្រិតទាប។ តិចជាងមួយភាគបី នៃអ្នកឆ្លើយតបបានបង្ហាញពីជំនឿទុកចិត្តថា នឹងមានការផ្តល់ដំណោះស្រាយពីអាជ្ញាធរ។ កង្វះទំនុកចិត្តលើយន្តការដោះស្រាយរបស់រដ្ឋា




[135] តួលេខអ្នកដែលយល់ថា *"ងាយស្រួល"* ក្នុងការដាក់ពាក្យបណ្តឹងត្រូវបានគណនាដោយការបូកសរុបជាមួយនឹងចំនួនអ្នកឆ្លើយតបតបដែលបង្ហាញថា *"មានភាពងាយស្រួលខ្លាំងណាស់"* និង *"មានភាពងាយស្រួលខ្លះដែរ"*។

[136] តួលេខអ្នកដែល *មានជំនឿ"ទុកចិត្ត"* ត្រូវបានគណនាដោយការបូកសរុបជាមួយនឹងចំនួនអ្នកឆ្លើយតបសំណួរដែលបានបង្ហាញថា *ជឿទុកចិត្តខ្លាំង"ណាស់"* និង *"មានជំនឿចិត្តខ្លះដែរ "*។

ភិបាលនេះ គឺជាការពិតមួយដែលគួរឱ្យព្រួយបារម្ភ ហើយអាចបំបាក់ទឹកចិត្តរបស់ជនរងគ្រោះ ពីការរំលោភសិទ្ធិមនុស្សក្នុងការស្វែងរកដំណោះស្រាយ។

ក្នុងរយៈពេលបួនឆ្នាំនៃការឃ្លាំមើលកន្លងមក ទិន្នន័យដែលបានពីចំណុចគន្លឹះទី ៣ បង្ហាញថា មានការធ្លាក់ចុះជាបន្តបន្ទាប់ នៃអ្នកឆ្លើយតបដែលយល់ថា មានសេរីភាពក្នុងការអនុវត្តសិទ្ធិសេរីភាពខាងបង្កើតសមាគម ខាងការបញ្ចេញមតិ និងខាងការជួបប្រជុំគ្នា។ បុគ្គលម្នាក់ៗនៅតែបន្តជឿថា ក្របខ័ណ្ឌច្បាប់ជាតិដែលគ្រប់គ្រងលើសេរីភាពមូលដ្ឋានមានលក្ខណៈរឹតត្បិតខ្លាំងជាងការពិតជាក់ស្តែង។ នេះទំនងជារាំងដល់ការអនុវត្តយ៉ាងពេញលេញនូវសេរីភាពមូលដ្ឋាន និងរារាំងដល់ការចូលរួមរបស់សាធារណជន និងសកម្មភាពពលរដ្ឋ។ ទាំងនេះជាការចាំបាច់ដែលត្រូវអប់រំពលរដ្ឋអំពីច្បាប់ដែលគ្រប់គ្រងលើសេរីភាពមូលដ្ឋាន ដើម្បីឱ្យពលរដ្ឋទទួលបានអំណាចក្នុងការអនុវត្តសិទ្ធិមនុស្សរបស់ខ្លួន។

# ៥. ចំណុចគន្លឹះទី ៤៖ តើអង្គការសង្គមស៊ីវិល និងសហជីព ត្រូវបានទទួលស្គាល់ និងអាចធ្វើការក្នុងភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា ដែរឬទេ?[137]

ចំណុចគន្លឹះទី ៤ ពិនិត្យមើលពីវិសាលភាពដែលរាជរដ្ឋាភិបាលកម្ពុជាមានទស្សនៈយល់ឃើញ និងប្រព្រឹត្តចំពោះអង្គការសង្គមស៊ីវិល (រាប់បញ្ចូលទាំងអង្គការមិនមែនរដ្ឋាភិបាល សហជីព និងអង្គការសហគមន៍តាមមូលដ្ឋាន ។ល។) ដែលជាភាគីពាក់ព័ន្ធដ៏សំខាន់នៅក្នុងសង្គមកម្ពុជា។

**របកគំហើញសំខាន់ៗ៖** ទិន្នន័យដែលបានមកពីចំណុចគន្លឹះទី៤ គូសបញ្ជាក់ថាសង្គមស៊ីវិលយល់ថាមិនមានការទទួលស្គាល់ ឬការផ្តល់តម្លៃគ្រប់គ្រាន់ពីរាជរដ្ឋាភិបាលកម្ពុជានោះទេ។ ទិន្នន័យនេះក៏បានបង្ហាញបន្ថែមទៀតថា កិច្ចសហការ និងភាពជាដៃគូរវាងសង្គមស៊ីវិល និងរាជរដ្ឋាភិបាលកម្ពុជានៅមានកម្រិតនៅឡើយ ហើយចាំបាច់ធ្វើឱ្យមានភាពប្រសើរឡើងថែមទៀត។ អង្គការសង្គមស៊ីវិល និងសហជីពបានរាយការណ៍ថា ឱកាសសហប្រតិបត្តិការ ឬស្វែងរកមូលនិធិពីរាជរដ្ឋាភិបាលកម្ពុជាគឺមិនសូវមានភាពច្បាស់លាស់ បើកចំហ និងតម្លាភាពទេក្នុងអំឡុងពេល ៣ ឆ្នាំនៃការធ្វើរបាយការណ៍។

## ៥.១ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពជឿជាក់ថាពួកគេត្រូវបានរាជរដ្ឋាភិបាលទទួលស្គាល់ថាមានភាពស្របច្បាប់ ប៉ុន្តែមិនមានសមត្ថភាព




**តារាងតួលេខ៦៥៖ ថ្នាក់ដឹកនាំ អង្គការសង្គមស៊ីវិល និងសហជីពដែលយល់ថា ពួកគេត្រូវបានទទួលស្គាល់ជាដៃគូអភិវឌ្ឍន៍ ដែលមានសមត្ថភាព/ស្របច្បាប់**

អ្នកឆ្លើយតប៦៣ ភាគរយ ក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពនៅឆ្នាំទី៤បានបង្ហាញថា ពួកគេជឿថារាជរដ្ឋាភិបាល កម្ពុជាចាត់ទុកអង្គការសង្គមស៊ីវិល និងសហជីព ជាដៃគូអភិវឌ្ឍន៍*ស្របច្បាប់* ខណៈអ្នកឆ្លើយតប មានតែ៤៦ ភាគរយប៉ុណ្ណោះដែលបង្ហាញថា ពួកគេជឿថា រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថាអង្គការសង្គមស៊ីវិលនិងសហជីព*មានសមត្ថភាព។* ទិន្នន័យនេះបង្ហាញថា អង្គការនានាយល់ថា ការចូលរួមចំណែករបស់ពួកគេចំពោះប្រទេសកម្ពុជាមិនត្រូវបានសាទរ និងផ្តល់តម្លៃខ្ពស់ពីរាជរដ្ឋាភិបាលកម្ពុជានោះទេ។

[137] ទិន្នន័យអំពីចំណុចគន្លឹះទី ៤ ត្រូវបានដកស្រង់ចេញពីការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល/សហជីព របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ដែលធ្វើឡើងនៅ ខែធ្នូ ឆ្នាំ ២០១៦(ឆ្នាំទី ១) ខែធ្នូ ឆ្នាំ ២០១៧ (ឆ្នាំទី ២) ខែមករា ឆ្នាំ ២០១៩ (ឆ្នាំទី ៣) និងខែមករា ឆ្នាំ ២០២០ (ឆ្នាំទី ៤) ។

## ៥.២ កិច្ចសហការជាផ្លូវការជាមួយរាជរដ្ឋាភិបាលកម្ពុជាកំពុងមានការថយចុះ

**តារាងតួលេខទី៦៦៖ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពរាយការណ៍អំពីការសហការជាផ្លូវការ និងក្រៅផ្លូវការជាមួយរាជរដ្ឋាភិបាលកម្ពុជាលើគម្រោង**[138]




កម្រិតនៃកិច្ចសហប្រតិបត្តិការ ជាផ្លូវការរវាងអង្គការសង្គមស៊ីវិល និងសហជីព ក៏ដូចជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា បានថយចុះក្នុងឆ្នាំកន្លងទៅ។ មានការថយចុះ ៤% ពីឆ្នាំទី៣ ខណៈពេលដែលចំនួននៃភាពជាដៃគូក្រៅផ្លូវការ (មិនផ្លូវការ) រវាងអង្គការសង្គមស៊ីវិល និងសហជីព ក៏ដូចជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា នៅតែមានភាពស៊ីសង្វាក់គ្នាមួយភាគធំជាមួយនឹងលទ្ធផលនៃការស្ទង់មតិពីឆ្នាំមុនៗ។ ការថយចុះនូវកិច្ចសហការជាផ្លូវការគឺជាក្តីកង្វល់មួយ ដោយសារប្រជាជនកម្ពុជានឹងទទួលបាននូវអត្ថប្រយោជន៍ច្រើនបំផុតនៅពេលដែលអង្គការសង្គមស៊ីវិលនិងសហជីពអាចធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍។

**តារាងតួលេខទី៦៧៖ការប្រៀបធៀបថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលជាមួយនឹងសហជីពរាយការណ៍អំពីកិច្ចសហការជាមួយរាជរដ្ឋាភិបាលកម្ពុជាលើគម្រោង**[139]




គួរកត់សម្គាល់ថា ថ្នាក់ដឹកនាំសហជីពបានរាយការណ៍ថាទាំងការសហការជាផ្លូវការ និងក្រៅផ្លូវការជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅមានកម្រិតទាបខ្លាំងជាងថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល។ ទិន្នន័យនេះបង្ហាញ ពីភាពខុសគ្នារវាងភាពជាដៃគូដែលរាជរដ្ឋាភិបាលកម្ពុជាចូលរួមជាមួយអង្គការសង្គមស៊ីវិល និងជាមួយសហជីព។ កម្រិតនៃភាពជាដៃគូរវាងអង្គការសង្គមស៊ីវិល និងជាពិសេស សហជីពជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាគួរតែត្រូវបានធ្វើឱ្យល្អប្រសើរឡើង។

[138] ទិន្នន័យដែលបានបង្ហាញនៅក្នុងក្រាហ្វនេះដាក់បញ្ចូលនូវចំនួនថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពបានរាយការណ៍ថា "ញឹកញាប់ណាស់" " ជានិច្ចកាល" ឬ "ម្តងម្កាល" ធ្វើការក្រៅផ្លូវការជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំកន្លងមក។ សំណួរនេះមិនត្រូវបានសួរនៅក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពដែលបានធ្វើឡើងនៅឆ្នាំទី ១ ។

[139] ទិន្នន័យដែលបានបង្ហាញនៅក្នុងក្រាហ្វនេះដាក់បញ្ចូលនូវចំនួនថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពបានរាយការណ៍ថា "ញឹកញាប់ណាស់" "ជានិច្ចកាល" ឬ "ម្តងម្កាល" ធ្វើការក្រៅផ្លូវការជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំកន្លងមក។

## ៥.៣ ឱកាសសម្រាប់ការផ្តល់ហិរញ្ញប្បទានសាធារណៈ និងការចូលរួមក្នុងក្រុមប្រឹក្សា និង គណៈកម្មាធិការរាជរដ្ឋាភិបាលកម្ពុជាត្រូវបានយល់ថាមិនមានភាពច្បាស់លាស់បើក ចំហ និងមានតម្លាភាព

**តារាងតួលេខទី៦៨៖ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពបានដឹងអំពីឱកាសទទួលបានមូលនិធិពីរាជរដ្ឋាភិបាលកម្ពុជា[140]**




មានតែ៧ ភាគរយ ពីអ្នកឆ្លើយតបការស្ទង់មតិពីថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពប៉ុណ្ណោះដែលបានដឹងពីឱកាសផ្តល់ហិរញ្ញប្បទាន របស់រាជរដ្ឋាភិបាលកម្ពុជាដែលសមាគមរបស់ពួកគេមានសិទ្ធិទទួលបាន។ លទ្ធផលនេះគឺស្របទៅនឹងនិន្នាការក្នុងប៉ុន្មានឆ្នាំកន្លងទៅ។ វាហាក់ដូចជាអង្គការសង្គមស៊ីវិល និងសហជីពមានការយល់ដឹងតិចតួចបំផុតអំពីឱកាសផ្តល់ហិរញ្ញប្បទាន ឬមូលនិធិពីរាជរដ្ឋាភិបាលកម្ពុជា។

**តារាងតួលេខទី៦៩៖ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពដែលជឿជាក់ថាឱកាសផ្តល់ហិរញ្ញប្បទានរបស់រដ្ឋាភិបាលគឺច្បាស់លាស់ បើកចំហ និងមានតម្លាភាព[141]**




ខណៈពេលដែល ចំនួនអ្នកឆ្លើយតបការស្ទង់មតិយល់ដឹងអំពីឱកាស ផ្តល់ ហិរញ្ញប្បទាននៅតែមានភាពស៊ីសង្វាក់គ្នាជាមួយនឹងប៉ុន្មានឆ្នាំមុនៗ (សូមមើលតារាងតួលេខទី៦៨) ឆ្នាំទី ៤ ឃើញមានការថយចុះយ៉ាងខ្លាំងនៃអ្នកឆ្លើយតបដែលយល់ឃើញថាឱកាសហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាលកម្ពុជាមានភាពច្បាស់លាស់ បើកចំហ និងមានតម្លាភាព។ មានអ្នកឆ្លើយតបតែ ៩ ភាគរយប៉ុណ្ណោះបានរាយការណ៍ថាឱកាសផ្តល់មូលនិធិមានភាពច្បាស់លាស់ បើកចំហ និងមានតម្លាភាព ពោលគឺមានការថយចុះ ៣១ ភាគរយពីឆ្នាំទី៣។

[140] សំណួរនេះមិនត្រូវបានសួរនៅក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពដែលបានធ្វើឡើងនៅឆ្នាំទី ១ ទេ។
[141] សំណួរនេះមិនត្រូវបានសួរនៅក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល /សហជីពដែលបានធ្វើឡើងនៅឆ្នាំទី ១ ទេ។

**តារាងតួលេខទី៧០៖ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពបានដឹងអំពីឱកាសចូលរួមនៅក្នុងការពិគ្រោះយោបល់របស់រាជរដ្ឋាភិបាលកម្ពុជា ក្រុមប្រឹក្សា និង/ឬគណៈកម្មាធិការ[142]**




ការស្ទង់មតិ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពក៏បានសួរផងដែរ ថាតើអ្នកឆ្លើយតបបានដឹងអំពីឱកាសណាមួយ ដើម្បីចូលរួមក្នុងការពិគ្រោះយោបល់របស់រាជរដ្ឋាភិបាលកម្ពុជា ក្រុមប្រឹក្សា និងគណៈកម្មាធិការ។ ជិតពាក់កណ្ដាលនៃអ្នកឆ្លើយតបទាំងអស់(៤៦%) បានដឹងពី ឱកាសនេះដែលជាការកើនឡើងគួរឱ្យកត់សម្គាល់ពីឆ្នាំមុនៗ។

**តារាងតួលេខទី៧១៖ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពដែលជឿជាក់ថាឱកាសចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាគឺមានភាពច្បាស់លាស់ បើកចំហ និងមានតម្លាភាព[143]**




ខណៈពេលដែលអ្នកឆ្លើយតបកាន់តែច្រើនយល់ដឹងពីឱកាសក្នុងការចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា (សូមមើលតារាងតួលេខ៧០) មានតែ ២៤% ប៉ុណ្ណោះ បានរាយការណ៍ថាឱកាសសម្រាប់ការចូលរួមនេះ គឺមានភាពច្បាស់លាស់បើកចំហ និងមានតម្លាភាព ដែលមានការថយចុះពីឆ្នាំទី៣។ ការថយចុះនេះបង្ហាញពីភាពចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងកាផ្សាយនិងពន្យល់ឱ្យកាន់តែល្អប្រសើរអំពីឱកាសទាំងនេះនិងដំណើរការនៃការជ្រើសរើស។

ការអភិវឌ្ឍក្នុងប្រទេសកម្ពុជា គឺជាការទទួលខុសត្រូវរបស់វិស័យទាំងអស់នៅក្នុងសង្គម។ របកគំហើញពីការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពគូសបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាមិនបានប្រើប្រាស់ ឱ្យបានពេញលេញនូវសមត្ថភាព របស់សង្គមស៊ីវិលតាមរយៈការសហការគ្នា ឬភាពជាដៃគូប្រកបដោយអត្ថន័យនោះទេ។ អង្គការសង្គមស៊ីវិល និងសហជីពដើរតួនាទីយ៉ាងសំខាន់ក្នុងការតស៊ូមតិដើម្បីផលប្រយោជន៍របស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា ហើយរាជរដ្ឋាភិបាលកម្ពុជា គួរតែទាញយកប្រយោជន៍ពីផ្នត់គំនិតដ៏វិសេសវិសាលរបស់អង្គការសង្គមស៊ីវិល និងសហជីព ដើម្បីធានាបានការអភិវឌ្ឍន៍ប្រទេសជាតិប្រកបដោយការទទួលខុសត្រូវ និងចីរភាព។

[142] សំណួរនេះមិនត្រូវបានសួរនៅក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល /សហជីពដែលបានធ្វើឡើងនៅឆ្នាំទី ១ ទេ។
[143] សំណួរនេះមិនត្រូវបានសួរនៅក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពដែលបានធ្វើឡើងនៅឆ្នាំទី ១ ទេ។

# សេចក្តីសន្និដ្ឋាន

ការវិភាគដែលបានធ្វើឡើងក្នុងឆ្នាំទី៤ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន បានបង្ហាញពីការកើនឡើងនូវការរឹតត្បិតលើការអនុវត្តសេរីភាពមូលដ្ឋាន និងរារាំងដល់សកម្មភាពរបស់អង្គការសង្គមស៊ីវិល។ របាយការណ៍នេះបង្ហាញថា កាតព្វកិច្ចសិទ្ធិមនុស្សដែលមានចែងក្នុងច្បាប់អន្តរជាតិនិងរដ្ឋធម្មនុញ្ញមិនត្រូវបានអនុលោមពេញលេញទេ។ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានកត់ត្រាការរឹតត្បិតចំពោះសេរីភាពមូលដ្ឋាននៅគ្រប់ខេត្តក្រុង ដែលបង្ហាញថាការរំលោភសេរីភាពមូលដ្ឋានបានរាលដាលពាសពេញប្រទេសកម្ពុជា។ ការវិភាគឆ្នាំទី ៤ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានរកឃើញថាមានការរារាំងសេរីភាពខាងនយោបាយដែលហាក់ដូចជាមានលក្ខណៈជាប្រព័ន្ធក្នុងការបំបិតសំឡេងដែលប្រឆាំងឬរិះគន់ដល់រាជរដ្ឋាភិបាល និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ល។

ក្របខ័ណ្ឌច្បាប់នៃសេរីភាពខាងសមាគម និងសេរីភាពខាងការបញ្ចេញមតិនៅបន្តការរឹតត្បិត និងគាបសង្កត់ ហើយនឹងច្បាប់ដែលកំពុងតាក់តែងនាំឱ្យកាត់បន្ថយសេរីភាពទាំងនេះថែមទៀត។ ផ្ទុយពីនេះ ក្របខ័ណ្ឌច្បាប់ទាក់ទងនឹងសេរីភាពខាងការជួបប្រជុំ គឺមានភាពអនុលោមច្រើនតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

ការអនុវត្តច្បាប់នៅកម្ពុជាមិនសូវមានភាពស៊ីចង្វាក់គ្នានោះទេដែលនេះ នាំឱ្យមានការគំរាមកំហែងដល់ការអនុវត្តសេរីភាពមូលដ្ឋាន។ ក្នុងរបាយការណ៍ឆ្នាំទី៤នេះ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានឃ្លាំមើលច្បាប់មួយចំនួន ដូចជា ក្រមព្រហ្មទណ្ឌកម្ពុជា ច្បាប់ស្តីពីទូរគមនាគមន៍ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី និងច្បាប់ផ្សេងៗទៀត នៅតែបន្តត្រូវបានអនុវត្តមិនត្រឹមត្រូវជាលក្ខណៈប្រព័ន្ធ។ សកម្មភាពនៃការរឹតត្បិតសេរីភាពមូលដ្ឋានលើសពីដែនកំណត់នៅតែបន្តកើតមានជាទូទៅ។ រដ្ឋាភិបាលហាក់ដូចជាប្រើប្រាស់ច្បាប់មិនមែនដើម្បីការពារសេរីភាពមូលដ្ឋានទេ តែផ្ទុយទៅវិញគឺកាត់បន្ថយលំហសេរីភាពរបស់ពលរដ្ឋ និងរឹតត្បិតការអនុវត្តសេរីភាពមូលដ្ឋាន។

នៅក្នុងឆ្នាំទី៤ នេះ សេរីភាពខាងសមាគមត្រូវបានរឹតត្បិត និងបំពានជាញឹកញាប់ ហើយការរឹតត្បិតនិងបំពាននេះមានកម្រិតខ្ពស់ជាងឆ្នាំមុនៗ។ សេរីភាពខាងការបញ្ចេញមតិនៅតែត្រូវបានគាបសង្កត់រួមទាំងការបញ្ចេញមតិតាមប្រព័ន្ធអ៊ិនធឺណិត។ ការបំពានលើសេរីភាពខាងការបញ្ចេញមតិដែលត្រូវបានអនុវត្តតាមរយៈប្រព័ន្ធអ៊ីនធឺ ណិតមានចំនួន៤៨%។ ខណៈពេលដែលសេរីភាពខាងការជួបប្រជុំមួយភាគធំត្រូវបានគេរកឃើញថាត្រូវបានការពារ តែគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានឃើញថា មានអំពើហិង្សាចំនួន ៩ ករណី ក្នុងពេលតវ៉ាដោយសន្តិវិធី។ រហូតមកដល់ពេលនេះគ្មាននរណាម្នាក់ត្រូវបានចាប់ខ្លួនចំពោះអំពើខុសច្បាប់ទាំងនេះទេ។

ការយល់ដឹងរបស់សាធារណៈអំពីសេរីភាពខាងសមាគម ខាងការបញ្ចេញមតិ និងការជួបប្រជុំនៅតែមានកម្រិតទាបនៅឡើយ។ របាយការណ៍ឆ្នាំទី ៤ បានកត់ត្រាកម្រិតទាបបំផុតនៃការយល់ដឹងអំពីសេរីភាពមូលដ្ឋានចាប់តាំងពីគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានចាប់ផ្តើមមក។ ស្រដៀងគ្នានេះដែរ ចំណេះដឹងអំពីក្របខ័ណ្ឌច្បាប់ជាតិដែលពាក់ព័ន្ធសេរីភាពមូលដ្ឋានមានភាពថយចុះបើធៀបទៅនឹងឆ្នាំមុនៗ ។ បុគ្គលម្នាក់ៗនៅតែបន្តយល់ថាច្បាប់ដែលគ្របដណ្តប់សេរីភាពមូលដ្ឋានមានការរឹតត្បិតជាងបញ្ញត្តិស្តែង។ ការយល់នេះអាច

ជាការរារាំងដល់ការអនុវត្តពេញលេញចំពោះសេរីភាពមូលដ្ឋាន និងរារាំងការចូលរួមរបស់សាធារណជន និងសកម្មភាពពលរដ្ឋ។

តាមរយៈទិដ្ឋភាពដែលបានបង្ហាញក្នុងរបាយការណ៍នេះគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន សង្ឃឹមថានឹងផ្តល់នូវព័ត៌មានជុំវិញការវិវត្តច្បាប់ ដើម្បីឱ្យច្បាប់ជាតិទាំងនេះស្របតាមស្តង់ដារអន្តរជាតិ និងលើកទឹកចិត្តឱ្យមានការស្ថាបនា ដើម្បីបង្កើតបរិយាកាសអំណោយផលសម្រាប់សកម្មភាពដ៏សកម្មរបស់សង្គមស៊ីវិល។ លទ្ធភាពនៃការអនុវត្តសេរីភាពពលរដ្ឋគឺជាសិទ្ធិមនុស្សមូលដ្ឋានដែល មានសារៈសំខាន់បំផុតសម្រាប់ឱ្យសង្គមប្រជាធិបតេយ្យមានភាពរឹងមាំ ។

# ឧបសម្ព័ន្ធទី១ ៖ វិធីសាស្ត្រ និងការប្រមូលទិន្នន័យ

ឧបសម្ព័ន្ធនេះ បង្ហាញអំពីវិធីសាស្ត្រនិងឧបករណ៍ប្រមូលទិន្នន័យ ដែលបានប្រើប្រាស់ដើម្បីប្រមូលនិងវិភាគទិន្នន័យរបស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន។

## វិធីសាស្ត្រ

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានចាប់ផ្តើម ដោយប្រើប្រាស់នូវឧបករណ៍តាមដានការឃ្លាំមើល។ ឧបករណ៍តាមដានការឃ្លាំមើលនេះមានគោលបំណងផ្តល់នូវយន្តការដ៏ច្បាស់លាស់ និងស៊ីសង្វាក់គ្នាមួយសម្រាប់ធ្វើការត្រួតពិនិត្យតាមដានក្របខ័ណ្ឌគតិយុត្តនានា ពាក់ព័ន្ធនឹងការចូលរួមរបស់ប្រជាពលរដ្ឋ និងសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជាដោយផ្តោតលើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ដទៃទៀតដែលប៉ះពាល់ដល់សេរីភាពខាងសមាគម សេរីភាពខាងការប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ (សេរីភាពមូលដ្ឋាន)។ ឧបករណ៍តាមដានការឃ្លាំមើលនេះ ត្រូវបានរៀបចំឡើងសម្រាប់ប្រើប្រាស់នៅក្នុងគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានក្នុងរយៈពេលវែង និងត្រូវបានរៀបចំជាលក្ខណៈប្រព័ន្ធដើម្បីបង្ហាញឱ្យដឹងថាតើក្របខ័ណ្ឌច្បាប់ជាតិស្របតាមបទដ្ឋានអន្តរជាតិដែរឬយ៉ាងណា ហើយប្រជាពលរដ្ឋកម្ពុជាមានការយល់ដឹង និងអនុវត្តសេរីភាពមូលដ្ឋានយ៉ាងដូចម្តេចខ្លះ។

សម្រាប់ឆ្នាំទី៤ នៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានចាប់ផ្តើមពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០។ លទ្ធផលដែលបានពីការឃ្លាំមើលនេះត្រូវបានធ្វើការប្រៀបធៀប និងពិនិត្យឡើងវិញជារៀងរាល់ត្រីមាស៖ ត្រីមាសទី១ ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។ ត្រីមាសទី២ ចាប់ពីថ្ងៃទី១ ខែកក្កដា ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩។ ត្រីមាសទី៣ ចាប់ពីថ្ងៃទី១ ខែតុលា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងត្រីមាសទី៤ ចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០។

ឧបករណ៍តាមដានការឃ្លាំមើលនេះមានសូចនាករ ៩៤ ដែលឆ្លើយតបចំពោះចំណុចគន្លឹះចំនួន ៤៖[144]

**(ចំណុចគន្លឹះទី១)** ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានស្របតាមបទដ្ឋានអន្តរជាតិ

**(ចំណុចគន្លឹះទី២)** ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានត្រូវបានអនុវត្ត និងប្រតិបត្តិតាមត្រឹមត្រូវ

**(ចំណុចគន្លឹះទី៣)** បុគ្គលម្នាក់ៗមានការយល់ដឹងអំពីសេរីភាពមូលដ្ឋាន និងសិទ្ធិដែលពាក់ព័ន្ធ និងយល់ថាពួកគេមានសេរីភាពក្នុងការអនុវត្តសេរីភាពនេះ និង

[144] សម្រាប់វិធីសាស្ត្រពេញលេញសូមចូលមើល ម.ស.ម.ក, អាដហុក, អេសស៊ី, អាយ.ស៊ី.អិន.អិល, ការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា, របាយការណ៍ប្រចាំឆ្នាំទី៣ (កក្កដា ២០១៩) ឧបសម្ព័ន្ធទី ១ <https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=130&id=5>.

(ចំណុចគន្លឹះទី៤) អង្គការសង្គមស៊ីវិល និងសហជីពត្រូវបានទទួលស្គាល់ និងអាចធ្វើការក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាល។

ឧបករណ៍តាមដានការឃ្លាំមើល បានគូសបញ្ជាក់អំពីសកម្មភាពសំខាន់ៗជាលម្អិតសម្រាប់ក្រុមការងារអនុវត្តផងដែរ។ ឧបករណ៍នេះបង្កើតនិយមន័យដើម្បីជានាទូវការអនុវត្តស៊ីសង្វាក់គ្នានូវគោលគំនិតជាគន្លឹះ ព្រមទាំងបង្ហាញយ៉ាងច្បាស់នូវធាតុទាំងឡាយនៃចំណុចគន្លឹះទាំង៤។ ឧបករណ៍តាមដានការឃ្លាំមើលនេះមានលម្អិត សូចនាករ និងមានតារាងវិភាគដែលត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃនូវការផ្លាស់ប្តូរធៀបជាមួយធាតុនីមួយៗ និង ចំណុចគន្លឹះទាំងនោះ ក៏ដូចជាធ្វើការប្រៀបធៀបជាមួយប្រភពទិន្នន័យ បុគ្គលទទួលខុសត្រូវចំពោះការប្រមូលទិន្នន័យ និងភាពញឹកញាប់នៃការប្រមូលទិន្នន័យផងដែរ។[145]

## វិធីសាស្ត្រប្រមូលទិន្នន័យ

គម្រោងបានប្រើប្រាស់នូវវិធីសាស្ត្រប្រមូលទិន្នន័យចំនួន ៦ យ៉ាងដើម្បីធ្វើការវាស់វែង សូចនាករពាក់ព័ន្ធជាមួយធាតុនីមួយៗនៅក្រោមចំណុចគន្លឹះទាំងនោះ។




### ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ

ការតាមដានប្រព័ន្ធផ្សព្វផ្សាយផ្តោតលើការផ្សព្វផ្សាយព័ត៌មានអំពីសេរីភាពមូលដ្ឋាន។ វិធីសាស្ត្រនេះត្រូវបានប្រើជាពីរវិធី៖ ទីមួយប្រើដើម្បីប្រមូលទិន្នន័យ សម្រាប់សូចនាករដែលព្យាយាមវាស់វែងការផ្លាស់ប្តូរ នៅក្នុងការអនុវត្តរបស់រដ្ឋាភិបាលឬការបកស្រាយច្បាប់ដែលជះឥទ្ធិពលដល់សេរីភាពមូលដ្ឋាន។ ទីពីរផ្តល់នូវមធ្យោបាយនៃការតាមដានចំនួន និងប្រភេទនៃហេតុការណ៍ដែលសេរីភាពមូលដ្ឋានត្រូវបានរំលោភឬរឹតត្បិត។ ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយត្រូវបានអនុវត្តជាប្រចាំថ្ងៃដោយក្រុមការងារគម្រោង។

### យន្តការរាយការណ៍អំពីហេតុការណ៍

ការរាយការណ៍អំពីហេតុការណ៍ កត់ត្រាពីហេតុការណ៍នៃការរឹតត្បិត និងការរំលោភបំពានលើសេរីភាពមូលដ្ឋានដែលមិនមាននៅក្នុងប្រព័ន្ធផ្សព្វផ្សាយ។ បែបបទនៃយន្តការអំពីហេតុការណ៍ផ្តល់មធ្យោបាយសម្រាប់បុគ្គល ឬសមាគមដែលជឿថាសេរីភាពមូលដ្ឋានរបស់ពួកគេត្រូវបានគេរំលោភបំពាន ដើម្បីរាយការណ៍ពីហេតុការណ៍ទាំងនេះទៅក្រុមការងារគម្រោង។ ទម្រង់បែបបទនៃហេតុការណ៍ត្រូវបានបំពេញនៅពេលដែលជនរងគ្រោះទៅជួបជាមួយក្រុមការងារគម្រោង ហើយក្រុមការងារនឹងស្វែងយល់ពីបញ្ហានេះ និងធ្វើការសាកសួរព័ត៌មានលម្អិតជាមួយជនរងគ្រោះ។ ទម្រង់របាយការណ៍ពីហេតុការណ៍កត់ត្រានូវទិន្នន័យទាំងបែបគុណភាព និងបរិមាណ រួមមានព័ត៌មានអំពីហេតុការណ៍ អំពីទីតាំង និងអំពីមនុស្សដែលពាក់ព័ន្ធ រួមទាំងប្រភេទនៃសមាគម (ប្រសិនបើពាក់ព័ន្ធ) និងប្រភេទនៃការរំលោភបំពានផងដែរ។

---

[145] ព័ត៌មានបន្ថែមទាក់ទងនឹងវិធីសាស្ត្រនៃឧបករណ៍តាមដានការឃ្លាំមើល គឺអាចរកបានតាមការស្នើសុំ។

សារព័ត៌មានជាតិធំៗរបស់ប្រទេសកម្ពុជា និងប្រភពបណ្តាញផ្សព្វផ្សាយដទៃទៀតត្រូវបានតាមដានឃ្លាំមើលដើម្បីរកនូវអត្ថបទរឿងរ៉ាវផ្សេងៗដែលពាក់ព័ន្ធ។[146]

នៅពេលអត្ថបទរឿងដែលពាក់ព័ន្ធនានាត្រូវបានកំណត់ ក្រុមការងារគម្រោង នឹងពិនិត្យទៅលើអត្ថបទទាំងនោះហើយបញ្ចូលព័ត៌មានសំខាន់ៗចូលទៅក្នុងប្រព័ន្ធទិន្នន័យ។ ប្រព័ន្ធទិន្នន័យនេះត្រូវបានរៀបចំឡើងដើម្បីធ្វើចំណាត់ថ្នាក់ ទៅតាមប្រភេទដែលឆ្លើយតបជាមួយសូចនាករនីមួយៗ និងធាតុទាំងឡាយដែលមាននៅក្នុងឧបករណ៍តាមដានឃ្លាំមើល។ ប្រព័ន្ធទិន្នន័យនេះត្រូវបានពិនិត្យមើលជារៀងរាល់ត្រីមាសនីមួយៗ។

ក្នុងឆ្នាំទី ៤ ក្រុមការងារគម្រោងបានកត់ត្រាហេតុការណ៍ចំនួន ៥៣៧ តាមរយៈការឃ្លាំមើលប្រព័ន្ធផ្សព្វផ្សាយ។

នៅពេលទម្រង់នៃការរាយការណ៍ពីហេតុការណ៍ត្រូវបានបំពេញចប់រួចរាល់ហើយ ក្រុមការងារគម្រោងបញ្ចូលព័ត៌មានសំខាន់ៗទៅក្នុងប្រព័ន្ធទិន្នន័យនៃការរាយការណ៍ពីហេតុការណ៍ ដែលក្រុមការងារគម្រោងអាចវិភាគទិន្នន័យទាំងនេះបាន។

ការពិនិត្យលើគុណភាពនៃទិន្នន័យ ត្រូវធ្វើឡើងជាប្រចាំនៅរៀងរាល់ចុងត្រីមាសនីមួយៗ។ នៅក្នុងឆ្នាំទី៤ គម្រោងបានកត់ត្រានូវហេតុការណ៍ជាក់លាក់ចំនួន១១៩ ករណី តាមរយៈការរាយការណ៍ពីហេតុការណ៍។

## ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព

ការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិលនិងសហជីព គឺជាការស្ទង់មតិប្រចាំឆ្នាំដែលត្រូវបានរៀបចំឡើងដើម្បីបង្ហាញពីទស្សនៈយល់ឃើញ និងបទពិសោធន៍របស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពអំពីលទ្ធភាពរបស់ពួកគេក្នុងការអនុវត្តសេរីភាពមូលដ្ឋាន។

ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ត្រូវបានជ្រើសរើសដោយចៃដន្យ ដើម្បីចូលរួមក្នុងការស្ទង់មតិនេះ តាមរយៈការប្រើប្រាស់នូវសំណាកបច្ចេកទេស ដោយផ្អែកលើព័ត៌មានពីសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល និងសហព័ន្ធសហជីព។

នៅក្នុងឆ្នាំទី៤ នេះ ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ថ្ងៃទី៨ ខែមករា ឆ្នាំ២០២០។ ការស្ទង់មតិគឺត្រូវបានបំពេញតាមអនឡាញ និងតាមរយៈការសម្ភាសផ្ទាល់ជាមួយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពចំនួន ១៤២ នាក់ដែលបានឆ្លើយ

## ការស្ទង់មតិជាសាធារណៈ

ការស្ទង់មតិជាសាធារណៈនេះ ធ្វើឡើងក្នុងគោលបំណងយល់ដឹងអំពីការយល់ឃើញរបស់សាធារណជនទូទៅទាក់ទងនឹងការអនុវត្តសេរីភាពជាមូលដ្ឋានរបស់គេ ហើយការស្ទង់មតិនេះនឹងធ្វើជារៀងរាល់ឆ្នាំ ដើម្បីស្វែងយល់អំពីការផ្លាស់ប្តូរនូវទស្សនៈយល់ឃើញរបស់សាធារណជន។

ការជ្រើសរើសសំណាកដែលមានលក្ខណៈងាយៗ ត្រូវបានប្រើប្រាស់ដើម្បីគ្រប់គ្រងលើដំណើរការស្ទង់មតិនេះ។ ការស្ទង់មតិនេះធ្វើឡើងនៅទីតាំងសាធារណៈជុំវិញប្រទេសកម្ពុជា។ ក្រុមការងារគម្រោងបានចុះទៅទីតាំងដែលប្រជាពលរដ្ឋ ធ្វើដំណើរទៅមកមានដូចជា (ផ្សារ សួនច្បារ បណ្តុំហាងលក់ទំនិញ ។ល។) និងធ្វើការជ្រើសរើសប្រជាពលរដ្ឋឱ្យចូលរួមនៅក្នុងការស្ទង់មតិនេះដោយចៃដន្យ។

ឧបករណ៍ស្ទង់មតិជាសាធារណៈនេះ ត្រូវបានធ្វើចន្លោះថ្ងៃទី១៧ ខែកុម្ភៈ ដល់ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ នៅក្នុង ២៥ ខេត្ត/ក្រុង និងមានអ្នកចូលរួមឆ្លើយចំនួន ៧៧៩ នាក់។ លទ្ធផលនៃការ

[146] ប្រភពព័ត៌មានរួមមាន៖ កាសែតភ្នំពេញប៉ុស្តិ៍ (ខ្មែរ និងអង់គ្លេស) កាសែតខ្មែរថាមស៍ វិទ្យុអាស៊ីសេរី វិទ្យុបារាំងអន្តរជាតិ កាសែតដើមអម្ពិល សំឡេងប្រជាធិបតេយ្យ (ខ្មែរ និងអង់គ្លេស) វិទ្យុសំឡេងសហរដ្ឋអាមេរិកវីអូអេ វាយោ កោះសន្តិភាព កាសែតរស្មីខេមបូឌាដេលី កាសែតកម្ពុជាថ្មី, Freshnews, សារព័ត៌មានដើមត្នោត, មជ្ឈមណ្ឌលព័ត៌មានស្ត្រី, Preinokor, Swift News Daily, TVFB, Kley Kley Sabay, CEN, Camnews, Cambojanews, Cambodia Peace Channel, Cambonomist, Cambodianess និង Norkorwat News Daily ។ ដែនកំណត់សំខាន់នៃវិធីសាស្ត្រនេះគឺថា ការថយចុះចំនួនប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ការរាយការណ៍អាចមានភាពលំអៀង។

តប។ លទ្ធផលនៃស្ទង់មតិនេះត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ ហើយត្រូវបានផ្ទៀងផ្ទាត់ បកប្រែ និងសម្អាត មុនធ្វើការវិភាគដើម្បីកំណត់និន្នាការនៅក្នុងលក្ខណៈផ្សេងៗគ្នារបស់អង្គការសង្គមស៊ីវិល ឬសហជីពដែលបានចូលរួមនៅក្នុងការស្ទង់មតិ រួមទាំងនៅក្នុងសូចនាករដែលឧបករណ៍តាមដានការឃ្លាំមើលបានកំណត់។

ស្ទង់មតិត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ ដោយក្រុមការងារគម្រោង បន្ទាប់មកទិន្នន័យនេះត្រូវបានវិភាគដើម្បីកំណត់និន្នាការនៅក្នុងលក្ខណៈផ្សេងៗគ្នារបស់អ្នកផ្តល់ចម្លើយ រួមទាំងសូចនាករដែលឧបករណ៍តាមដានការឃ្លាំមើលបានបង្កើតឡើង។

## ការពិនិត្យឡើងវិញនៅលើច្បាប់

ការពិនិត្យឡើងវិញទៅលើច្បាប់ គឺជាការវិភាគផ្នែកច្បាប់ពាក់ព័ន្ធរបស់ប្រទេសកម្ពុជា ប្រកាស សារាចរណែនាំ គោលនយោបាយ របាយការណ៍ និងបទប្បញ្ញត្តិផ្សេងទៀតដែលមានប៉ះពាល់លើការការពារ និងការអនុវត្តសេរីភាពមូលដ្ឋាន។ ការពិនិត្យ និងសិក្សាឯកសារច្បាប់ ដើម្បីវាយតម្លៃអំពីកម្រិតដែលក្របខ័ណ្ឌច្បាប់របស់ប្រទេសកម្ពុជា អាចធានាបាននូវសេរីភាពមូលដ្ឋាន ដូចដែលបានតម្រូវនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ដូចនេះ ការពិនិត្យច្បាប់ទៅការចែងរបស់ច្បាប់ជាជាងការអនុវត្តរបស់វា។[147]

របាយការណ៍ចេញពីការសិក្សា លើការពិនិត្យច្បាប់ពាក់ព័ន្ធនេះ នឹងធ្វើឡើងជាប្រចាំត្រីមាស ដើម្បីធ្វើបច្ចុប្បន្នភាពនៃការវិភាគច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិដែលត្រូវបានធ្វើវិសោធនកម្ម ក៏ដូចជាការបញ្ចូលការវិភាគទៅលើច្បាប់ថ្មី ឬលិខិតបទដ្ឋានគតិយុត្តិទាំងឡាយណា ដែលបានពិនិត្យឡើងវិញថ្មីៗនេះផងដែរ។[148]

## ការវាយតម្លៃការចុះបញ្ជីសហជីព

ការចុះបញ្ជីគឺជាដំណើរការចាំបាច់មួយ ដែលតម្រូវដោយច្បាប់ស្តីពីសហជីពដែលជាក៏ឱកាសមួយសម្រាប់រដ្ឋាភិបាលបដិសេធសិទ្ធិសហជីពផងដែរ។ ការត្រួតពិនិត្យប្រសិទ្ធភាពនៃដំណើរការចុះបញ្ជីបង្ហាញឱ្យឃើញថា តើសិទ្ធិក្នុងការបង្កើតសហជីពត្រូវបានការពារ និងអនុវត្តដោយរបៀបណា។

ក្រុមការងារគម្រោងបានកត់ត្រាទិន្នន័យទាំងនេះ តាមរយៈការអនុវត្ត "ដោយសាកសួរព័ត៌មានពីដំណើរការចុះបញ្ជី" ចំពោះសហជីពដែលបានជ្រើសរើស និងវាយតម្លៃពីបទពិសោធន៍នៃការចុះបញ្ជីរបស់ពួកគេតាមច្បាប់ស្តីពីសហជីព ដោយប្រើប្រាស់ទម្រង់វាយតម្លៃនេះដែលបង្កើតដោយក្រុមការងារគម្រោង។ ទម្រង់វាយតម្លៃនេះក៏អាចតាមដានការឆ្លើយតបរបស់មន្ត្រីរាជរដ្ឋាភិបាលនៅពេលដែលសហជីពកំពុងដំណើរការនៃការចុះបញ្ជីរបស់ខ្លួនផងដែរ។ ឧបករណ៍វាយតម្លៃនេះ បានកត់ត្រាបទពិសោធន៍ការចុះបញ្ជីរបស់សហជីពចំនួន ២៩ នៅក្នុងឆ្នាំទី៤ ដែលពួកគេបានព្យាយាមចុះបញ្ជីតាមច្បាប់ស្តីពីសហជីព។

[147] ឧបសម្ព័ន្ធទី ២

[148] ព័ត៌មានបន្ថែមទាក់ទងនឹងការពិនិត្យច្បាប់គឺអាចរកបានតាមការស្នើសុំ។

## ឧបសម្ព័ន្ធទី ២ ៖ តារាងលទ្ធផលនៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន

តារាងខាងក្រោមនេះ ផ្តល់នូវទិន្នន័យសង្ខេបដែលក្រុមការងារគម្រោងបានប្រមូលចងក្រងក្នុងរយៈពេល "ឆ្នាំទី៤" (ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០)។ សូចនាករទាំងនេះសុទ្ធតែពឹងផ្អែកទៅលើប្រភពទិន្នន័យផ្សេងៗ ដូចមាននៅក្នុងឧបសម្ព័ន្ធទី១។

<u>ការពិនិត្យមើលទៅលើច្បាប់ដែលពាក់ព័ន្ធ</u>៖ នៅពេលបញ្ចប់ការវិភាគច្បាប់ឬលិខិតបទដ្ឋានពាក់ព័ន្ធ ពិន្ទុ ៥ នឹងត្រូវវាស់ទៅលើក្របខ័ណ្ឌច្បាប់ជាតិពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានដែលស្របតាមបទដ្ឋានច្បាប់សិទ្ធិមនុស្សអន្តរជាតិ (ពិន្ទុ ១= ស្ថិតក្នុងកម្រិតខ្សោយ, ពិន្ទុ៣= កម្រិតពិន្ទុមធ្យម, ៥= កម្រិតពិន្ទុខ្ពស់)។ ក្រុមការងារគម្រោងឱ្យពិន្ទុដោយមិនលំអៀងទៅលើកម្មវត្ថុនិងសូចនាករ ផ្អែកលើច្បាប់និងលិខិតបទដ្ឋានដែលមានស្រាប់។ ចំពោះច្បាប់ឬលិខិតបទដ្ឋានដែលលំបាកនឹងរកបាន សូចនាករនេះត្រូវបានបញ្ជាក់ថាមិនអាចវាស់វែងបាន។

<u>ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយនិងការរាយការណ៍ពីហេតុការណ៍</u>៖ ទិន្នន័យត្រូវបានកត់ត្រារយៈពេលពេញ ១ឆ្នាំ និងជាត្រីមាសដែលត្រូវបានប្រើប្រាស់សំរាប់ការវិភាគ។

<u>ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ការស្ទង់មតិជាសាធារណៈ ការវាយតម្លៃការចុះបញ្ជីអង្គការសង្គមស៊ីវិល</u> ៖ ការឆ្លើយតបរបស់អ្នកចូលរួមទៅលើការស្ទង់មតិ និងការវាយតម្លៃ ការចុះបញ្ជីត្រូវបានរួមបញ្ចូលនិងវិភាគ។ ចំនួនតួលេខនិងភាគរយដែលបង្ហាញទាំងអស់ត្រូវបានយកចេញពីការវិភាគចម្លើយរបស់អ្នកឆ្លើយតប។

លទ្ធផលរបាយការណ៍ប្រចាំឆ្នាំត្រូវរួមបញ្ចូលគ្នានូវសូចនាករទាំងអស់ ហើយត្រូវបានឱ្យពិន្ទុតាមលេខកូដពណ៌ដូចខាងក្រោម៖

| |
|---|
| កម្រិតពិន្ទុខ្ពស់ |
| កម្រិតពិន្ទុមធ្យម |
| ស្ថិតក្នុងកម្រិតខ្សោយ |
| មិនអាចឱ្យពិន្ទុបាន |

| ចំណុចគន្លឹះទី១ ៖ ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធសេរីភាពខាងការបង្កើតសមាគម សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ ស្របតាមបទដ្ឋានអន្តរជាតិ | | | | | | | |
|---|---|---|---|---|---|---|---|
| ធាតុផ្សំ | សូចនាករ | ប្រភពទិន្នន័យ | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | កំណត់សម្គាល់ |
| ១.១ សេរីភាពខាងការបង្កើតសមាគម សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ ត្រូវបានធានាដោយច្បាប់ជាតិ | កម្រិតនៃច្បាប់ជាតិ ឬគោលនយោបាយ បានគោរពដល់សេរីភាពខាងការបង្កើតសមាគម សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៣ | ៣ | ៣ | ៣ | កម្ពុជាពុំបានបំពេញចំណុចនេះឱ្យបានពេញលេញនៅឡើយទេ។ សិទ្ធិសេរីភាពខាងសមាគម ការជួបប្រជុំ និងការបញ្ចេញមតិត្រូវបានធានាដោយមាត្រា៤២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ)។[149] ទោះជាយ៉ាងណាមាត្រា៤២ នេះ អនុវត្តចំពោះប្រជាពលរដ្ឋកម្ពុជា ដោយមិនមានវិសាលភាពសម្រាប់ជនជាតិផ្សេងទៀតដែលកំពុងរស់នៅកម្ពុជានោះឡើយ។[150] ប៉ុន្តែ ការធានាទាំងនេះត្រូវបានធ្វើឱ្យខ្សោយចុះគួរឱ្យកត់សម្គាល់ដោយសារការធ្វើវិសោធនកម្មលើបទប្បញ្ញត្តិមួយចំនួននៃរដ្ឋធម្មនុញ្ញនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៨ ។[151]ម្យ៉ាងទៀត ច្បាប់ជាតិដែលគ្រប់គ្រងមកលើសេរីភាពខាងសមាគមដូចជាច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីពក៏មានបទប្បញ្ញត្តិមួយចំនួនរឹតត្បិតលើសេរីភាពមូលដ្ឋានផងដែរ។[152] វិសោធនកម្មច្បាប់ស្តីពីសហជីពឆ្នាំ២០២០ មានការរឹតត្បិតតិចជាងមុនទៅលើសេរីភាពខាងសមាគម។[153] សេរីភាពខាងការបញ្ចេញមតិត្រូវបានកាត់បន្ថយយ៉ាងខ្លាំងនៅក្នុងច្បាប់មួយចំនួនដូចជាច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពីការអប់រំ ក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីទូរគមនាគមន៍ និងប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ខណៈបញ្ញត្តិខ្លះស្របនឹងបទដ្ឋានអន្តរជាតិនោះ ក៏មានបទប្បញ្ញត្តិមួយចំនួនមានខ្លឹមសារមិនច្បាស់លាស់ដែលអាចធ្វើឱ្យប៉ះពាល់ដល់សេរីភាពខាងការជួបប្រជុំ។ នៅក្នុងឆ្នាំ២០២០ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសស្ថិតក្នុងភាពអាសន្នបង្ហាញពីលទ្ធភាពក្នុងការដកហូតសិទ្ធិខ្លះនៃសេរីភាពខាងសមាគម សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ។[154] |
| **សេរីភាពខាងការបង្កើតសមាគម** | | | | | | | |

[149] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ថ្ងៃទី១០ កក្កដា ឆ្នាំ២០០៧ បានបកស្រាយតាមសមត្ថកិច្ចលើមាត្រា៣១ នៃរដ្ឋធម្មនុញ្ញទាក់ទងនឹងអត្ថន័យសន្ធិសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន ក្នុងនោះរួមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដែលត្រូវអនុវត្តដោយផ្ទាល់ក្នុងច្បាប់កម្ពុជា។ សូមមើលសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ (ថ្ងៃទី១០ កក្កដា ឆ្នាំ២០០៧) ។

[150] អនុក្រឹត្យលេខ១៤៨ ស្តីការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសបានពង្រីកវិសាលភាពមកលើកម្មករនិយាជិតដែលធ្វើការនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។

[151] ការប្រើពាក្យពេចន៍មានអត្ថន័យទូលំទូលាយខ្លាំងពេក តម្រូវឱ្យបុគ្គលនិងគណបក្សនយោបាយ "តម្កល់ផលប្រយោជន៍ជាតិ" និងហាមប្រាមការធ្វើសកម្មភាពណាមួយដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជានិងប្រជាពលរដ្ឋ ទោះដោយផ្ទាល់ឬដោយប្រយោលក្តី"។ ហ្វ្រេសញូវ 'សេចក្តីព្រាងវិសោធនកម្មក្រមព្រហ្មទណ្ឌពាក់ព័ន្ធនឹងការប្រមាថព្រះមហាក្សត្រ និងវិសោធនកម្មបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ (ហ្វ្រេសញូវ, ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៨) <https://bit.ly/2DZYnKM>

[152] ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលកំណត់លក្ខខណ្ឌសម្រាប់ការចុះបញ្ជី (មាត្រា៦) ចែងលក្ខខណ្ឌតម្រូវសម្រាប់ចុះបញ្ជីមានបន្ទុកច្រើន លំបាក និងមិនច្បាស់លាស់ (ជំពូក២ និងជំពូក៣)។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលព្រមទាំងចែងពីការត្រួតពិនិត្យរបស់រដ្ឋាភិបាលទូលំទូលាយដើម្បីបដិសេធលើការចុះបញ្ជី(មាត្រា៨) និងកំណត់នូវសកម្មភាពលំបាក និងលក្ខខណ្ឌតម្រូវឱ្យធ្វើរបាយការណ៍ហិរញ្ញវត្ថុ (មាត្រា២៥) ព្រមទាំងកំណត់ទោសទណ្ឌដោយពុំសមាមាត្រ (មាត្រា៣០)។ ច្បាប់ស្តីពីសហជីពកំណត់លក្ខខណ្ឌតម្រូវសម្រាប់ការចុះបញ្ជីមានបន្ទុកច្រើននិងស្មុគស្មាញ និងមូលហេតុទូលំទូលាយសម្រាប់ការបដិសេធលើការចុះបញ្ជី (មាត្រា១៥ និងប្រកាសលេខ២៤៩) និងលក្ខខណ្ឌតម្រូវឱ្យធ្វើរបាយការណ៍មានបន្ទុកច្រើន (មាត្រា១៧)។

[153] វិសោធនកម្មបានបន្ថយវិសាលភាពរបស់ច្បាប់ដែលមិនរួមបញ្ចូលការធ្វើដំណើរតាមអាកាសនិងការធ្វើដំណើរទៅបរទេស ហើយបានដកចេញចំណុចដែលតម្រូវឱ្យថ្នាក់ដឹកនាំសហជីពមិនធ្លាប់ត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌពីមុនមក ហើយការតម្រូវឱ្យបង់ប្រាក់ឈ្នួលនិងអត្ថប្រយោជន៍ផ្សេងទៀតត្រូវធ្វើមុនពេលការរំលាយសហជីព និងដកចេញចំណុចដែលសហជីពត្រូវរំលាយនៅពេលមានថ្នាក់ដឹកនាំឬគណៈគ្រប់គ្រងត្រូវបានកាត់ទោសពីបទល្មើសព្រហ្មទណ្ឌ។ សូមមើលចំណុចគន្លឹះទី១ ។

[154] ការពិនិត្យមើលទៅលើច្បាប់នៃច្បាប់ស្តីពីការគ្រប់គ្រងប្រទេសស្ថិតក្នុងភាពអាសន្ននឹងធ្វើការឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ឆ្នាំទី៥ នៃគម្រោង។

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១.២ ដំណើរការចុះបញ្ជីអង្គការសមាគមមានភាពត្រឹមត្រូវ និងតម្លាភាព | កម្រិតនៃដំណើរការនៃការចុះបញ្ជី និងតាមដានតម្លៃសម្រាប់ការចុះបញ្ជីសមាគម ត្រូវបានផ្សព្វផ្សាយជាសាធារណៈ និងចែងយ៉ាងច្បាស់លាស់ | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ១ | ១ | ១ | កម្ពុជាពុំបានបំពេញចំណុចនេះ។ លក្ខខណ្ឌនៃការចុះបញ្ជីសម្រាប់អង្គការសង្គមស៊ីវិលនិងសហជីពក្រោមច្បាប់ស្ដីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលនិងច្បាប់ស្ដីពីសហជីពមានខ្លឹមសារស្រពេចស្រពិល លំបាក និងមានបន្ទុកច្រើន ព្រមទាំងមិនស្របជាមួយបទដ្ឋានអន្តរជាតិ។[155] ជាពិសេស មាត្រា ៥ នៃច្បាប់ស្ដីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលបានរារាំងបុគ្គលមួយចំនួនដូចជា បុគ្គលដែលពុំមែនជាសញ្ជាតិខ្មែរ និងបុគ្គលដែលមានអាយុក្រោម ១៨ ឆ្នាំ ពីការបង្កើតសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល។ ព្រមទាំង កង្វះវិធានផ្នែកនីតិវិធីការពារក្នុងដំណើរការចុះបញ្ជីដែលកំណត់ក្នុងច្បាប់ស្ដីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល[156] ក្នុងនោះរួមទាំងការចែងពុំច្បាស់លាស់ពីមូលហេតុនៃការបដិសេធលើសំណើសុំចុះបញ្ជីជាដើម ដែលប្រការនេះទុកចន្លោះប្រហោងសម្រាប់ការបដិសេធតាមតែអំពើចិត្ត។ ផ្ទុយពីនេះ វិសោធនកម្មច្បាប់ស្ដីពីសហជីពឆ្នាំ២០២០ បានលុបចោលការរឹតត្បិត២ចំណុចមកលើសហជីព ប៉ុន្តែនៅតែមានភាពលំបាកក្នុងការចុះបញ្ជីដដែល។ មាត្រា២០ បានរឹតត្បិតលទ្ធភាពក្នុងការអនុវត្តសកម្មភាព ដោយតម្រូវឱ្យថ្នាក់ដឹកនាំមានអាយុចាប់១៨ ឆ្នាំ មានសេចក្តីប្រកាសផ្ទាល់ខ្លួនអំពីអាសយដ្ឋានរស់នៅ[157] ដែលទាំងនេះមិនស្របតាមការអនុវត្តល្អបំផុតអន្តរជាតិ និងមិនស្របតាមសិទ្ធិក្នុងការជ្រើសរើសតំណាងរបស់ពួកគេដោយសេរី។[158] ជាចុងក្រោយច្បាប់ស្ដីពីសហជីពបង្កើតគ្រាន់តែជានីតិវិធីសម្រាប់សហជីពដែលតម្រូវឱ្យមានការយល់ព្រមពីរដ្ឋាភិបាលផ្ទុយពីច្បាប់សិទ្ធិមនុស្សអន្តរជាតិតែប៉ុណ្ណោះ។[159] |
| ១.៣ ពុំមានការរឹតត្បិតលើចំនួនសមាគមដែលមាន គោលបំណងប្រហាក់ប្រហែលគ្នា | កម្រិតនៃ ច្បាប់ ឬគោលនយោបាយដែលរឹតត្បិតលើចំនួនសមាគមដែលមានគោលបំណងប្រហាក់ប្រហែលគ្នា | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៥ | ៥ | ៥ | ៥ | កម្ពុជាបានបំពេញចំណុចនេះ ព្រោះពុំមានការកម្រិតលើចំនួនសមាគមឬអង្គការមិនមែនរដ្ឋាភិបាលដែលអាចមានគោលបំណងស្រដៀងគ្នាក្នុងច្បាប់ស្ដីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលឬច្បាប់ដទៃទៀតដែរ។ មាត្រា ៧ នៃច្បាប់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលចែងថាឈ្មោះជាអក្សរពេញ ឬអក្សរកាត់ និងនិមិត្តសញ្ញានៃសមាគមឬអង្គការមិនមែនរដ្ឋាភិបាល ("អង្គការ") នឹងមិនត្រូវចម្លងតាមឈ្មោះជាអក្សរពេញ ឬអក្សរកាត់របស់សមាគមឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីមុនរួចហើយ ឬ រូបសញ្ញា បដិរូបកាកបាទក្រហម ឬអឌ្ឍចន្ទក្រហម ឬស្ថាប័នអន្តរជាតិឡើយ។ ការរឹតត្បិតនេះបង្ហាញពីហេតុផលសមស្រប និងសមាមាត្រដរាបណាត្រូវបានគេអនុវត្តក្នុងលក្ខខណ្ឌត្រឹមត្រូវ តម្លាភាពនិងសង្គតិភាព។ |
| ១.៤ សមាគមអាចបង្កើតបណ្ដាញនៃអង្គការ សម្ព័ន្ធ សហព័ន្ធ ឬសហជីពប្រភេទដទៃទៀតដោយសេរី | កម្រិតនៃច្បាប់ ឬគោលនយោបាយអនុញ្ញាត ឱ្យសមាគមបង្កើតបណ្ដាញនៃអង្គការ សម្ព័ន្ធ សហព័ន្ធ សហជីពនៃប្រភេទដទៃទៀត | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៣ | ៣ | ៣ | ៣ | កម្ពុជាបានបំពេញផ្នែកខ្លះលើចំណុចនេះ។ ច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលកំណត់ថាសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបង្កើតឡើងដោយ "រូបវន្ត ឬ/និងនីតិបុគ្គល" ដែលនេះបង្ហាញថាទោះជាបណ្ដាញរបស់អង្គការមិនមែនរដ្ឋាភិបាល ឬសម្ព័ន្ធនៃអង្គការជាដើម នឹងទទួលបានការអនុញ្ញាត។ ទន្ទឹមនេះច្បាប់ស្ដីពីសហជីពទទួលស្គាល់ជាក់លាក់នូវសិទ្ធិរបស់សហជីពនិងសមាគមនិយោជកក្នុងការប្រឹក្សាយោបល់គ្នាដោយសេរី និងចូលជាសមាជិកជាមួយសហជីពនិងសមាគមនិយោជកដទៃទៀត ច្បាប់ស្ដីពីសហជីពក៏ចែងផងដែរពីលក្ខខណ្ឌរឹតត្បិតដែលពុំអនុលោមតាមច្បាប់ ដែលបង្កជាឧបសគ្គពុំសមហេតុផលចំពោះការបង្កើតបណ្ដាញនេះ។[160] |

155 សូមមើលរបាយការណ៍ប្រចាំឆ្នាំលើកទីពីរស្ដីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក និងមជ្ឈមណ្ឌលសាមគ្គីភាព និង អាយ.ស៊ី. អិន.អិល (ខែកញ្ញា ឆ្នាំ២០១៨) ទំព័រ៤-៧ អាចស្វែងរកបានតាមរយៈ https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf.។

156 មាត្រា៨ ក្រសួងមហាផ្ទៃអាចបដិសេធការស្នើសុំចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលបានរកឃើញថាមាន "គោលបំណង និងទិសដៅ" ដែលអាចធ្វើឱ្យ "ប៉ះពាល់ដល់សន្តិសុខ ស្ថិរភាពនិងសណ្ដាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា"។ ច្បាប់ស្ដីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ទុកចន្លោះនូវនីតិវិធីចុះបញ្ជីជាក់ស្ដែង សម្រាប់ការកំណត់របស់ក្រសួងមហាផ្ទៃ តាមរយៈបញ្ញត្តិរដ្ឋបាល ឬប្រកាស។

157 សូមមើលចំណុចគន្លឹះទី១។

158 អនុសញ្ញាលេខ៨៧ នៃអង្គការពលកម្មអន្តរជាតិ ស្ដីពីសេរីភាពខាងសមាគម និងការការពារការរៀបចំ អនុម័តថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៤៨, មានសុពលភាពអនុវត្តថ្ងៃទី០៤ ខែកក្កដា ឆ្នាំ១៩៥០) <http://www.refworld.org/docid/425bc1914.html>

159 មាត្រា៨ នៃអនុសញ្ញាសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (អនុម័តថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, មានសុពលភាពអនុវត្តថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៧៦)។

160 មាត្រា១០ នៃច្បាប់ស្ដីពីសហជីព។

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១.៥ ការចុះបញ្ជីសមាគម គឺជាការស្ម័គ្រចិត្ត | កម្រិតនៃ ច្បាប់ ឬគោលនយោបាយ អនុញ្ញាតដល់ការចុះបញ្ជីសមាគមដោយស្ម័គ្រចិត្ត | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | ១ | ១ | ១ | ១ | កម្ពុជាពុំបានបំពេញចំណុចនេះ ពីព្រោះថាច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីគណបក្សនយោបាយ ហើយនិងច្បាប់ស្តីពីសហគមន៍កសិកម្មតម្រូវឱ្យចុះបញ្ជីតាមលក្ខន្តិកៈច្បាប់។ និយមន័យនៃពាក្យសមាគមក្នុងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានអត្ថន័យទូលំទូលាយពេកដែលអាចអនុវត្តទៅលើក្រុមក្នុងវិស័យក្រៅប្រព័ន្ធនៅកម្ពុជា។[161] នៅក្រោមច្បាប់ទាំងនេះការខកខានមិនបានចុះបញ្ជីការធ្វើឱ្យសមាគមក្លាយជាសមាគមដែលខុសច្បាប់។ ការបដិសេធលើសមត្ថភាពផ្លូវច្បាប់និងការហាមប្រាមស្ថាប័ននានាដែលពុំបានចុះបញ្ជីពីការអនុវត្តសកម្មភាពណាមួយគឺពុំស្របជាមួយសិទ្ធិសេរីភាពខាងសមាគម ដែលសមាគមទាំងនោះគួរតែត្រូវបានចាត់ទុកថាកំពុងធ្វើប្រតិបត្តិការដោយស្របច្បាប់ លើកលែងតែបានបង្ហាញសកម្មភាពផ្ទុយពីនោះ។ ការចុះបញ្ជីគួរតែត្រូវបានធ្វើឡើងតាមការស្ម័គ្រចិត្ត ដោយផ្អែកលើប្រព័ន្ធនៃការជូនដំណឹង ជាជាងសុំការអនុញ្ញាត និងក្នុងគោលបំណងទទួលបានសមត្ថភាពផ្លូវច្បាប់តែប៉ុណ្ណោះ ដែលនេះពុំគួរតម្រូវឱ្យមានការស្នើសុំការអនុញ្ញាតជាមុនចំពោះការអនុវត្តសកម្មភាពស្របច្បាប់ឡើយ។ |
| ១.៦ បទប្បញ្ញត្តិដែលមានការត្រួតត្រាលើសមាគម អនុលោមតាមបទដ្ឋានអន្តរជាតិ | កម្រិតនៃច្បាប់ ឬគោលនយោបាយដែលត្រួតត្រាលើសមាគម ដែលស្របទៅតាមបទដ្ឋានអន្តរជាតិ | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | ២ | ១ | ២ | ២ | កម្ពុជាពុំបានបំពេញចំណុចនេះទេ។ ការអនុវត្តល្អប្រសើរជាអន្តរជាតិបង្ហាញពីតម្រូវការតិចតួចក្នុងការតាមដានព្រមទាំងការប៉ុនប៉ងត្រួតពិនិត្យយ៉ាងជិតដល់រដើម្បីរារាំងសមាគមនិងសមាជិកក្នុងការបង្កើតជម្រើសសម្រាប់អង្គការនិងការងាររបស់អង្គការ។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល តម្រូវឱ្យសមាគមឬអង្គការមិនមែនរដ្ឋាភិបាលជូនដំណឹងជាមុនអំពីសកម្មភាពជាក់លាក់ដែលធ្វើឡើងក្នុងដែនសមត្ថកិច្ចរដ្ឋបាលរាជធានី ឬខេត្តណាមួយត្រូវជូនដំណឹងដោយផ្ទាល់ទៅរដ្ឋបាលរាជធានីខេត្តនោះ និងទាមទារអោយអង្គការអន្តរជាតិនៅកម្ពុជាធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល។ ច្បាប់ស្តីពីសហជីពបញ្ជាក់ពីខ្លឹមសារនៃលក្ខន្តិកៈរបស់សហជីពកំណត់ចំនួននៃសមាជិក និងអាណត្តិសម្រាប់អ្នកដឹកនាំគ្រប់គ្រង។ យន្តការត្រួតពិនិត្យច្បាប់នេះនៅមិនបានធ្វើឱ្យថមថយនៅក្នុងវិសោធនកម្មច្បាប់ស្តីពីសហជីពនោះទេ។ ក្រសួងមហាផ្ទៃបានចេញសេចក្តីជូនដំណឹងមួយនៅក្នុងខែតុលា ឆ្នាំ២០១៧ ជាការអនុវត្តលើការជូនដំណឹងជាមុនសម្រាប់សកម្មភាពរបស់អង្គការសង្គមស៊ីវិលទាំងអស់ដែលសេចក្តីប្រកាសនេះផ្ទុយទៅនឹងបទដ្ឋានអន្តរជាតិព្រោះជាការគ្រប់គ្រងលើសកម្មភាពសមាគម ។ នេះនាំឱ្យពិន្ទុទាក់ទងនឹងការគោរពសេរីភាពមូលដ្ឋានធ្លាក់ចុះរហូតមកដល់ ១ ក្នុងរបាយការណ៍អង្កេតនៅក្នុងឆ្នាំទី២ ប៉ុន្តែរបៀបរបបនៃការជូនដំណឹងជាមុននេះត្រូវបាននិរាករណ៍វិញ តាមរយៈសេចក្តីជូនដំណឹងរបស់ក្រសួងមហា ផ្ទៃក្នុងខែវិច្ឆិកា ឆ្នាំ២០១៨។ វិសាលភាពនៃសេចក្តីជូនដំណឹងឆ្នាំ២០១៨ នោះ បានកំណត់លើក្រុមសង្គមស៊ីវិលដែលបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ ដែលនោះជាការទុកចន្លោះប្រហោងអាចឱ្យអាជ្ញាធរមូលដ្ឋានរារាំងសកម្មភាពនានារបស់ក្រុម ឬ សហគមន៍តូចៗដែលពុំបានចុះបញ្ជី។ |
| ១.៧ ការការពារសមាគមពីភាគីទីបីត្រូវបានអនុវត្ត | កម្រិតនៃ ច្បាប់ ឬគោលនយោបាយដែល ការពារសមាគមពី ការជ្រៀតជ្រែកពី ភាគីទីបី | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៣ | ៣ | ៣ | ៣ | កម្ពុជាពុំបានគោរពចំណុចនេះឱ្យបានពេញលេញទេ។ សេរីភាពខាងសមាគមត្រូវបានធានាក្នុងរដ្ឋធម្មនុញ្ញ ប៉ុន្តែច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ពុំមានចែងពីកិច្ចការពារជាក់លាក់ចំពោះសមាគម ឬដាក់ទោសទណ្ឌលើភាគីទីបីដែលរារាំងសមាគមឡើយ។ តែយ៉ាងណាក្តី ច្បាប់ស្តីសហជីពចែងពីកិច្ចការពារដល់សហជីព ពីការចូលជ្រៀតជ្រែកពីសំណាក់និយោជកក្នុងកិច្ចការផ្ទៃក្នុងរបស់ពួកគេ ព្រមទាំងអនុសញ្ញារួម ហើយនិងការរំខានដោយខុសច្បាប់ចំពោះកូដកម្ម។ ច្បាប់នេះមានកំណត់ទោសទណ្ឌផងដែរចំពោះបុគ្គលដែលរារាំងដល់ការបង្កើតសហជីព សហព័ន្ធសហជីពនិងសហភាពសហជីព។[162] គណៈកម្មាធិការដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេសមានសិទ្ធិអំណាចទទួលពាក្យបណ្តឹងប៉ុន្តែអាចទទួលពាក្យបណ្តឹងតែពីវិនិយោគិន ឬក្រុមហ៊ុនអភិវឌ្ឍន៍ក្នុងតំបន់សេដ្ឋកិច្ចពិសេសតែប៉ុណ្ណោះ។ វិនិយោគិន ឬក្រុមហ៊ុនអភិវឌ្ឍន៍ក្នុងតំបន់សេដ្ឋកិច្ចពិសេស អាចប្រើប្រាស់យន្តការដោះស្រាយវិវាទតាមរយៈគណៈកម្មាធិការនេះបានក្នុងករណីមានវិវាទជាមួយសមាគមដូចជាសហជីពជាដើម។ |

[161] លិខិតរបស់ ម.ស.ម.ក ស្នើក្រសួងមហាផ្ទៃបញ្ជាក់នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥ និងលិខិតឆ្លើយតបដែលម.ស.ម.កបានទទួលនៅថ្ងៃទី២២ ខែកញ្ញា។ ជាការលើកទឹកចិត្តលិខិតឆ្លើយតបពីក្រសួងមហាផ្ទៃបានចង្អុលបង្ហាញថាច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលមិនគួរអនុវត្តចំពោះសហគមន៍មូលដ្ឋានទេ។ ទោះយ៉ាងណាក៏ដោយវានៅតែមានវិសាលភាពគួរឱ្យកត់សំគាល់សម្រាប់អាជ្ញាធរមូលដ្ឋាននិងមន្ត្រីក្នុងការអនុវត្តខុសច្បាប់ដោយសារតែពាក្យដែលមិនច្បាស់លាស់នៃច្បាប់៖ សូមអាន ម.ស.ម.ក លិខិតរបស់ ម.ស.ម.ក ស្នើក្រសួងមហាផ្ទៃបញ្ជាក់ពីការប្រើប្រាស់ពាក្យ)ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥ (<https://cchrcambodia.org/index_old.php?title=CCHR-Open-Letter-Seeks-Clarification-Regarding-Application-of-the-LANGO-to-CBOs-and-Informal-Groups&url=media/media.php&p=press_detail.php&prid=569&id=5>

[162] បន្ថែមលើនេះ គណៈកម្មាធិការដោះស្រាយនៃតំបន់សេដ្ឋកិច្ចពិសេសមានសិទ្ធិអំណាចទទួលពាក្យបណ្តឹងប៉ុន្តែអាចទទួលពាក្យបណ្តឹងតែពីវិនិយោគិន ឬក្រុមហ៊ុនអភិវឌ្ឍន៍ក្នុងតំបន់សេដ្ឋកិច្ចពិសេសតែប៉ុណ្ណោះ។ វិនិយោគិន ឬក្រុមហ៊ុនអភិវឌ្ឍន៍ក្នុងតំបន់សេដ្ឋកិច្ចពិសេស អាចប្រើប្រាស់យន្តការដោះស្រាយវិវាទតាមរយៈគណៈកម្មាធិការនេះបានក្នុងករណីមានវិវាទជាមួយសមាគម ដូចជា សហជីពជាដើម។

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១.៨ លក្ខខណ្ឌ តម្រូវឱ្យធ្វើរបាយការណ៍ទៅរដ្ឋាភិបាល អនុលោម តាមបទដ្ឋាន អន្តរជាតិ | តម្រូវនៃលក្ខខណ្ឌធ្វើរបាយការណ៍អនុលោមតាមបទដ្ឋាន អន្តរជាតិ | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | ២ | ២ | ២ | ២ | | កម្ពុជាពុំបានបំពេញចំណុចនេះទេ។ លក្ខខណ្ឌតម្រូវឱ្យធ្វើរបាយការណ៍សម្រាប់អង្គការសង្គមស៊ីវិល និងសហជីពក្រោមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីពគឺជាលក្ខខណ្ឌលំបាក និងមិនអនុលោមតាមបទដ្ឋានអន្តរជាតិ។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិអនុញ្ញាតរដ្ឋអាចតម្រូវឱ្យសមាគមរាយការណ៍ប្រសិនបើពួកគេបង្កើតឡើងក្នុងគោលបំណងស្របច្បាប់ តម្លាភាព និងគណនេយ្យភាព។[163] ទោះជាយ៉ាងណាក៏ដោយបទដ្ឋានអន្តរជាតិតម្រូវឱ្យមានកាតព្វកិច្ចរាយការណ៍ដោយមិនតាមទំនើងចិត្ត[164]ឬជាបន្ទុក។[165] អង្គការតូចៗ ឬក្រុមនៅតាមមូលដ្ឋានអាចរងការប៉ះពាល់ដោយពុំសមាមាត្រ ព្រោះពួកគេមានធនធានតិចតួចក្នុងការគោរពតាមលក្ខខណ្ឌតម្រូវជាច្រើនទាំងនោះ។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ហើយនិងច្បាប់ស្តីពីសហជីព តម្រូវឱ្យអង្គការសង្គមស៊ីវិលឬសហជីពធ្វើរបាយការណ៍សកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុទៅក្រសួងមហាផ្ទៃ។[166] នៅឆ្នាំទី៤នេះមាត្រា១៧ នៃច្បាប់ស្តីពីសហជីពត្រូវបានកែសម្រួលឡើងវិញពីប្រើពាក្យថា "រៀបចំ" ជំនួសឱ្យ "ដាក់ជូន" នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងរបាយការណ៍សកម្មភាពសម្រាប់សវនកម្មតាមសំណើរបស់ម្ចាស់ជំនួយឬសំណើរបស់សមាជិកសរុបយ៉ាងតិច១០%សម្រាប់សហជីពមូលដ្ឋាន ឬ ៥% នៃសមាជិកសរុបសម្រាប់សហព័ន្ធឬសហភាព។ មាត្រា១៧ ដដែលនេះក៏នៅតែបន្តតឹតត្បិតនៃដល់កិច្ចការផ្ទៃក្នុងរបស់សមាគមដដែល។[167] |
| ១.៩ ទណ្ឌកម្មមកលើសមាគម ត្រូវបានចែងដោយច្បាប់ សមាមាត្រ ផ្សព្វផ្សាយជាសាធារណៈ មាននិយមន័យច្បាស់លាស់ មានតម្លាភាព និងងាយស្រួលយល់ | តម្រូវនៃ ទណ្ឌកម្មលើសមាគមដែលត្រូវបានចែងដោយច្បាប់ ដែលមានលក្ខណៈសមាមាត្រ ផ្សព្វផ្សាយជាសាធារណៈ មាននិយមន័យច្បាស់លាស់ មានតម្លាភាព និងងាយស្រួលយល់ | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | ២ | ១,៥ | ១,៥ | ១,៥ | | កម្ពុជាពុំបានបំពេញចំណុចនេះទេ។ ទោសទណ្ឌចំពោះអង្គការសង្គមស៊ីវិលនិងគណបក្សនយោបាយក្រោមច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីសហជីព និងវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ពុំសមាមាត្រ និងពុំស្របតាមបទដ្ឋានអន្តរជាតិ។[168] ទោសទណ្ឌជាច្រើនក្រោមច្បាប់ស្តីពីសហជីព ហើយនិងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក៏ពុំបានឲ្យន័យអត្ថន័យឱ្យបានល្អិតល្អន់ ងាយយល់ និងតម្លាភាព។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលកំណត់ទោសទណ្ឌជាច្រើន រួមទាំងការរំលាយសហជីព និងការលុបបញ្ជិកា ដែលមានខ្លឹមសារស្រពេចស្រពិល និយមន័យមិនច្បាស់លាស់ ហើយពិបាកយល់ពីចំណាត់ការទាំងនោះដូចជាពាក្យ "អព្យាក្រឹតផ្នែកនយោបាយ" ជាដើម។ ខណៈដែលវិសោធនកម្មច្បាប់ស្តីពីសហជីពនៅក្នុងឆ្នាំទី៤ នេះបានដកចេញការរំលាយដោយស្វ័យប្រវត្តិ ប្រសិនបើថ្នាក់ដឹកនាំឬគណៈគ្រប់គ្រងណាម្នាក់ប្រព្រឹត្តបទឧក្រិដ្ឋ[169] ច្បាប់ស្តីពីសហជីពក៏ចែងចំណាត់ការដែលនាំទៅកការដាក់ទោសទណ្ឌដោយស្រដៀងគ្នានេះដែរពីនិយមន័យមិនច្បាស់លាស់និងចំណាត់ការដូចជាការហាមប្រាមការក្នុងការរៀបចំទាំងឡាយណាក្នុងគោលបំណងបំរើនិន្នាការនយោបាយ ឬមហិច្ចតាផ្ទាល់ខ្លួន" ជាដើម។ម្យ៉ាងវិញទៀត ក្រមព្រហ្មទណ្ឌពិពណ៌នាអំពីទោសទណ្ឌក្នុងអត្ថន័យមិនច្បាស់លាស់ និងពុំសមាមាត្រដែលអាចអនុវត្តទៅលើសមាគមនិងអ្នកដឹកនាំដូចជា "ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស" "ការប្រមាថ" "ការរិះគន់លើសេចក្តីបង្គាប់របស់តុលាការ" និងបទបរិហារកេរ្តិ៍។ ច្បាប់ស្តីពីទូរគមនាគមន៍[170] ច្បាប់ស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម[171] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនិងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ ក៏មានចែងពីទោសទណ្ឌនានា ចំពោះចំណាត់ការដែលពុំសមាមាត្រ ទូលំទូលាយនិងមិនច្បាស់លាស់នេះផងដែរ។[172] |

163 គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម ,Maina Kiai,' UN Doc. A/HRC/២០/២៧, ( ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២( , កថាខណ្ឌ៦៥ <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session20/A-HRC-20-27_en.pdf>

164 ដូចយោងខាងលើ។

165 គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិឡើកឡើងថាកាតព្វកិច្ចរាយការណ៍មិនត្រូវ រារាំងដល់ស្វយ័តភាពរបស់សមាគម។ UN Doc A/HRC/២២/L.១៣ (ថ្ងៃទី១៥ ខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌទី៩ ( <https://documents-dds-ny.un.org/doc/RESOLUTION/LTD/G13/120/26/PDF/G1312026.pdf?OpenElement>

166 សូមមើលរបាយការណ៍ប្រចាំឆ្នាំលើកទីមួយស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា ផលិតរួមគ្នាដោយ ម.ស.ម.ក អាដហុក និងមជ្ឈមណ្ឌលសាមគ្គីភាព និង ICNL (ខែសីហា ឆ្នាំ២០១៨) ទំព័រ ៤ - ៧ អាចស្វែងរកបានតាមរយៈ https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf

167 សូមមើលចំណុចគន្លឹះទី១។

168 សូមមើលរបាយការណ៍ប្រចាំឆ្នាំលើកទីមួយស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក និងមជ្ឈមណ្ឌលសាមគ្គីភាព និង ICNL (ខែសីហា ឆ្នាំ២០១៨) ទំព័រ៤ - ៧ អាចស្វែងរកបានតាមរយៈ https://cchrcambodia.org/ admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf

169 មាត្រា២៩ នៃច្បាប់ស្តីពីសហជីព។

170 មាត្រា១០៧ នៃច្បាប់ស្តីពីទូរគមនាគមន៍។

171 មាត្រា៧ មាត្រា ៧៦ មាត្រា៧៧ និងមាត្រា៧៨ នៃច្បាប់ស្តីពីប្រឆាំងនឹងអំពើភេរវកម្ម។

172 មាត្រា៧៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់។

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១.១០ ការការពារផ្នែកនីតិវិធីត្រូវបានដាក់ឱ្យអនុវត្ត សម្រាប់សមាគមដែលប្រឈមនឹងទណ្ឌកម្ម | កម្រិតនៃការការពារត្រូវបានដាក់ឱ្យអនុវត្តសម្រាប់សមាគម ដែលប្រឈមនឹងទណ្ឌកម្ម | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ២ | ២ | ២ | ២ | កម្ពុជាមិនបំពេញចំណុចនេះទេ។ មានកិច្ចការពារមួយចំនួនត្រូវបានបញ្ចូលក្នុងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដូចជា ការបង្កើនទោស និងសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងករណីលុបឈ្មោះចេញពីបញ្ជី ប៉ុន្តែកិច្ចការពាររួមទាំងនេះពុំទាន់គ្រប់គ្រាន់នៅឡើយ។ ច្បាប់ស្តីពីសហជីពពុំមានចែងពីសិទ្ធិប្តឹងទាស់ទៅសាលាឧទ្ធរណ៍ចំពោះការពិន័យផ្នែករដ្ឋបាលឡើយ ទោះបីជាប្រកាសលេខ ២៥១ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្កើតសិទ្ធិមានដែនកំណត់ទាក់ទងនឹងបណ្តឹងទាស់ផ្នែករដ្ឋបាលទៅក្រសួងការងារនៅពេលទទួលបានលិខិតព្រមាន ឬការផាកពិន័យក៏ដោយ។ សម្រាប់ទោសមានចែងក្នុងក្រមព្រហ្មទណ្ឌ មានសិទ្ធិប្តឹងទាស់។ ច្បាប់ស្តីពីគណបក្សនយោបាយចែងពីកិច្ចការពារមានដែនកំណត់ចំពោះទោសទណ្ឌនានា បើទោះជាស្ថាប័ននីតិប្រតិបត្តិទទួលបានឆន្ទានុសិទ្ធិខ្ពស់ក្នុងការដាក់ទោសទណ្ឌ ដែលមានអត្ថន័យទូលំទូលាយ និងមិនច្បាស់លាស់យ៉ាងណាក៏ដោយ។ |
| ១.១១ សិទ្ធិក្នុងការរំលាយដោយស្ម័គ្រចិត្តត្រូវបានការពារដោយច្បាប់ | កម្រិតនៃការរំលាយដោយស្ម័គ្រចិត្តត្រូវបានការពារដោយច្បាប់ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៤ | ៤ | ៤ | ៤ | ជាទូទៅកម្ពុជាបានបំពេញចំណុចនេះ។ មាត្រា ២៦ នៃច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលចែងថាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក "អាចផ្អាកសកម្មភាពរបស់ខ្លួនដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃហើយមុននឹងផ្អាកសកម្មភាពត្រូវធ្វើរបាយការណ៍សកម្មភាពការងារនិងរបាយការណ៍ហិរញ្ញវត្ថុ"។ ប៉ុន្តែ បទប្បញ្ញត្តិមិនច្បាស់លាស់នៃមាត្រា២៦ (២) អាចបង្កើតជាឧបសគ្គដល់ការរំលាយសមាគមឬអង្គការមិនមែនរដ្ឋាភិបាលដោយស្ម័គ្រចិត្ត ព្រោះបទប្បញ្ញត្តិទាំងនោះតម្រូវថា "សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មុននឹងរំលាយត្រូវជម្រះកាតព្វកិច្ចតាមនីតិវិធីនិងបទប្បញ្ញត្តិជាធរមាន"។ ក្រមរដ្ឋប្បវេណីជានាដល់ការរំលាយស្ថាប័ននីតិបុគ្គលដោយស្ម័គ្រចិត្តមាត្រា ៦៤ (១)។ តាមមាត្រា៦៤ (១) នីតិបុគ្គលត្រូវរំលាយ "ដោយមូលហេតុនៃការរំលាយដែលបានកំណត់នៅក្នុងលក្ខន្តិកៈ"។ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលអាចរំលាយតាមសេចក្តីសម្រេចនៃមហាសន្និបាតសមាជិក ដោយទទួលបានការគាំទ្រភាគច្រើនពីសមាជិកទាំងអស់ ត្រូវមានការយល់ព្រមពីសមាជិកចាប់ពីពាក់កណ្តាលឡើងទៅ ដោយមានសំឡេងចាប់ពី ៣ ភាគ ៤ (បីភាគបួន) ឡើងទៅ នៃសិទ្ធិសម្រេចរបស់សមាជិកទាំងអស់ (មាត្រា ៦៤ (២) និង (៣)។ |
| ១.១២ ការរំលាយអាចធ្វើទៅបានបន្ទាប់ពីបានប្រើប្រាស់ច្បាប់ដទៃទៀតអស់លទ្ធភាពនិងបង្ហាញថាសមាគមអាចបង្កគ្រោះថ្នាក់ | កម្រិតនៃ ដំណើរការរំលាយសមាគមត្រូវបានដាក់ឱ្យអនុវត្ត | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ១ | ១ | ១ | ១ | កម្ពុជាខកខានបំពេញចំណុចនេះ។ ការរំលាយសមាគមឬអង្គការមិនមែនរដ្ឋាភិបាលអាចធ្វើទៅបានក្រោមក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីសហជីព។ ក្នុងករណីនីមួយៗ ការរំលាយអាចត្រូវបានគេកំណត់ថាជាវិធានការវិន័យតែប៉ុណ្ណោះ ពុំមែនជាការឆ្លើយតបដោយ សមាមាត្រនិងជាដំណោះស្រាយចុងក្រោយចំពោះគ្រោះថ្នាក់លើការបន្តប្រតិបត្តិការរបស់សមាគមឬអង្គការមិនមែនរដ្ឋាភិបាលឡើយ។ ជាពិសេស វិធានការនៃការផ្អាក ឬការរំលាយសហជីពតាមអំណាចផ្នែករដ្ឋបាលបង្កការប៉ះពាល់ធ្ងន់ធ្ងរលើគោលការណ៍សេរីភាពខាងសមាគម។[173] |
| ១.១៣ សមាគមត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពសេដ្ឋកិច្ច | កម្រិតនៃច្បាប់ ឬគោលនយោបាយ អនុញ្ញាតឱ្យសមាគមធ្វើសកម្មភាពសេដ្ឋកិច្ច | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៥ | ៤ | ៤ | ៤ | ជាទូទៅកម្ពុជាបំពេញចំណុចនេះ។ ពុំមានច្បាប់កំណត់ឱ្យមានការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងសកម្មភាពសេដ្ឋកិច្ចនោះទេ។ ទោះបីជាសិទ្ធិនេះពុំត្រូវបានការពារ តែសិទ្ធិនេះក៏ពុំត្រូវបានហាមប្រាមផងដែរ។ តែយ៉ាងណាក្តី ច្បាប់ស្តីពីសហជីពរារាំងសហជីពក្នុងការបង្កើតមុខជំនួញលើកលែងតែបុគ្គលដែលទទួលបានភាពជាតំណាងបំផុតនៅកន្លែងការងារ។ |
| ១.១៤ ការទទួលមូលនិធិបរទេសត្រូវបានអនុញ្ញាតនៅក្រោមច្បាប់ | កម្រិតនៃការទទួលបានមូលនិធិបរទេសត្រូវបាន អនុញ្ញាតដោយច្បាប់ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៤ | ៤ | ៤ | ៤ | កម្ពុជាបានបំពេញចំណុចនេះ។ ពុំមានការហាមប្រាមផ្នែកច្បាប់លើសមាគមក្នុងការទទួលមូលនិធិបរទេសឡើយ។ ប៉ុន្តែជាការសំខាន់ត្រូវកត់សម្គាល់ថា មាត្រា ២៧ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលកំណត់បន្ថែមទៀតនូវលក្ខខណ្ឌតឹងរ៉ឹងក្នុងការធ្វើរបាយការណ៍ សម្រាប់សមាគមឬអង្គការមិនមែនរដ្ឋាភិបាលដែលស្វែងរក និង / ឬទទួលមូលនិធិបរទេស។ ម្យ៉ាងទៀត មាត្រា ២៥ នៃច្បាប់ដដែលតម្រូវថាសមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលទទួលការគាំទ្រពីម្ចាស់ជំនួយ ត្រូវធ្វើរបាយការណ៍ដែលចម្លងចេញពីឯកសារដើមដែលផ្ញើទៅកាន់ម្ចាស់ជំនួយមកក្រសួងមហាផ្ទៃ ឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងការបរទេស ក្នុងអំឡុងពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ ព្រមទាំងឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទានជាមួយម្ចាស់ជំនួយដោយចម្លងចេញពីឯកសារដើមឱ្យបានក្នុងអំឡុងពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម ។ ព្រោះថាការផ្តល់មូលនិធិពីភាគីទីពាភាគច្រើនបំផុតសម្រាប់សមាគមគឺមានប្រភពមកពីបរទេសដែលការអនុវត្តនេះអាចបង្កជាឧបសគ្គក្នុងការទទួលមូលនិធិពីបរទេសជាពិសេសសម្រាប់អង្គការតូចៗ។ ម្យ៉ាងទៀតបទប្បញ្ញត្តិទាំងនេះ អាចត្រូវបានរំលោភបំពានដើម្បីយាយីដល់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលទទួលការគាំទ្រពីបរទេស។ |

[173] អត្ថបទស្តីពីសេរីភាពខាងសមាគមរបស់អង្គការពលកម្មអន្តរជាតិឆ្នាំ២០១៦ កថាខ័ណ្ឌ៦៨៣ <http://www.ilo.org/wcmsp5/groups/public/@ed_norm/@normes/documents/publication/wcms_090632.pdf>។

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១.១៥ សមាគមមិនប្រឈមនឹងការរឹតត្បិតមិនសមហេតុផល ពីការទទួល មូលនិធិឯកជន (ក្នុងស្រុក) | កម្រិតនៃ ច្បាប់ ឬគោលនយោបាយអនុញ្ញាតឱ្យសមាគមទទួលមូលនិធិពីប្រភពឯកជនដោយគ្មានការរឹតត្បិតមិនសមហេតុផល | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៤ | ៤ | ៤ | ៤ | កម្ពុជាបានបំពេញចំណុចនេះ។ កម្ពុជាពុំមានច្បាប់ហាមប្រាមក្នុងការទទួលមូលនិធិពីប្រភពឯកជនក្នុងស្រុកឡើយ។ ប៉ុន្តែការទទួលការគាំទ្រពីម្ចាស់ជំនួយ ទោះក្រៅប្រទេស ឬ ក្នុងប្រទេសនឹងនាំឱ្យមានលក្ខខណ្ឌធ្វើរបាយការណ៍ដែលតាមការអនុវត្តជាក់ស្តែង អាចបង្កជាឧបសគ្គមួយ ជាពិសេសចំពោះអង្គការតូចៗ។ ជាងនេះទៅទៀតមាត្រា ២៥ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល តម្រូវថាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសដែលទទួលការគាំទ្រពីម្ចាស់ជំនួយត្រូវបញ្ជូនច្បាប់ចំលងនៃឯកសារដើមដែលបានបញ្ជូនទៅម្ចាស់ជំនួយមកក្រសួងមហាផ្ទៃ ឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការបរទេសឱ្យបានក្នុងអំឡុងពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ ព្រមទាំងឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន។ |
| ១.១៦ កាតព្វកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុ មិនមានលក្ខណៈស្មុគស្មាញ | កម្រិតនៃ លក្ខខណ្ឌតម្រូវសម្រាប់ការធ្វើរបាយការណ៍ហិរញ្ញវត្ថុ ស្របទៅតាមបទអន្តរជាតិ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ២ | ២ | ២ | ២ | កម្ពុជាពុំបានបំពេញចំណុចនេះឱ្យបានពេញលេញទេ។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលកំណត់កាតព្វកិច្ចក្នុងការធ្វើរបាយការណ៍ហិរញ្ញវត្ថុ ក្នុងនោះរួមទាំងបទប្បញ្ញត្តិទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងព័ត៌មានលម្អិតអំពីការទទួលមូលនិធិផងដែរ។ ការកំណត់លក្ខខណ្ឌតម្រូវក្នុងការធ្វើរបាយការណ៍ផ្នែកហិរញ្ញវត្ថុនេះក៏មានចែងក្នុងច្បាប់ស្តីពីសហជីពផងដែរ និងជាកម្មវត្ថុអាចត្រូវកែប្រែពីក្រសួងការងារនៅពេលណាមួយក៏បាន។ មាត្រា១៧ នៃវិសោធនកម្មច្បាប់ស្តីពីសហជីពត្រូវបានកែសម្រួលឡើងវិញពីប្រើពាក្យថា "រៀបចំ" ជំនួសឱ្យ "ដាក់ជូន" នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងរបាយការណ៍សកម្មភាពសម្រាប់សវនករតាមសំណើររបស់ម្ចាស់ជំនួយឬសំណើររបស់សមាជិកសរុបយ៉ាងតិច១០%សម្រាប់សហជីពមូលដ្ឋាន ឬ៥% នៃសមាជិកសរុបសម្រាប់សហព័ន្ធឬសហភាព។ មាត្រា១៧ ដដែលនេះក៏នៅតែបន្តរឹតត្បិតនៃដល់កិច្ចការផ្ទៃក្នុងរបស់សមាគមដដែល។[174]<br>ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយក៏ចែងពីកាតព្វកិច្ចថ្មីមួយក្នុងការប្រកាសទ្រព្យសម្បត្តិ និងទំនួលខុសត្រូវចំពោះអង្គភាពប្រឆាំងអំពើពុករលួយ។ ជាចុងក្រោយ លក្ខខណ្ឌតម្រូវឱ្យធ្វើរបាយការណ៍ក៏មានចែងក្នុងសេចក្តីប្រកាសស្តីពីគោលការណ៍ណែនាំអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលចាត់ទុកជាបន្ទុកការងារបន្ថែមទៀតលើលក្ខខណ្ឌតម្រូវធ្វើរបាយការណ៍ដែលអាចរឹតត្បិតលើសេរីភាពខាងសមាគមដែលពុំអនុលោមតាមច្បាប់។ |
| ១.១៧ យន្តការសម្រាប់ការដោះស្រាយការរំលោភទៅលើសេរីភាពខាងការបង្កើតសមាគម ត្រូវ អនុវត្ត | កម្រិតនៃប្រព័ន្ធដោះស្រាយសម្រាប់ការរំលោភលើសេរីភាពខាងការបង្កើតសមាគម ត្រូវបានធានាដោយច្បាប់ និងគោលនយោបាយ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៣ | ២,៥ | ២,៥ | ២,៥ | កម្ពុជាពុំបានបំពេញចំណុចនេះឱ្យបានពេញលេញនៅឡើយទេ។ រដ្ឋធម្មនុញ្ញផ្តល់សិទ្ធិអំណាចដល់ពលរដ្ឋអោយតតាំងនឹងការរំលោភបំពានណាមួយលើសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ ប៉ុន្តែនីតិវិធីត្រួតពិនិត្យផ្នែកតុលាការពុំត្រូវបានពន្យល់ឱ្យបានច្បាស់លាស់ ដែលធ្វើឱ្យការធានានេះមានប្រសិទ្ធភាពតិចតួច។ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញអនុញ្ញាតឱ្យពលរដ្ឋតតាំងចំពោះច្បាប់ឬសេចក្តីសម្រេចដែលបង្កឱ្យមានការរំលោភលើសិទ្ធិក្នុងរដ្ឋធម្មនុញ្ញ។ ប៉ុន្តែច្បាប់នេះត្រូវបានធ្វើវិសោធនកម្មក្នុងខែកុម្ភៈ ឆ្នាំ២០១៨ លុបចេញបញ្ញត្តិដែលអនុញ្ញាតអោយគណបក្សនយោបាយអាចប្តឹងទាស់ទៅនឹងសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃដែលបដិសេធលើសំណើសុំចុះបញ្ជី។ ក្រោមច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលមិនមានយន្តការជាក់ទោសរដ្ឋបាលមកលើការបដិសេធការចុះបញ្ជីសមាគមនោះទេ។ សម្រាប់សមាគមក្នុងស្រុកមានវិធានការមួយប៉ុណ្ណោះសម្រាប់តវ៉ាមកលើការបដិសេធការចុះបញ្ជីរបស់ពួកគេដែលត្រូវតវ៉ាចំពោះការបដិសេធនោះតាមប្រព័ន្ធតុលាការ។ សម្រាប់សមាគមបរទេសឬអង្គការអន្តរជាតិពួកគេអាចតវ៉ាពីការសម្រេចនេះទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។ ប្រកាសលេខ២៥០ និង២៥១ ពង្រីកវិសាលភាពដល់ច្បាប់ស្តីពីសហជីព ដែលកម្រិតការតវ៉ាត្រឹមតែក្រសួងបណ្តុះបណ្តាលការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ប៉ុន្តែមិនបានផ្តល់សិទ្ធិឱ្យពួកគេតវ៉ាពីការសម្រេចនេះដល់តុលាការនោះទេ។ ហើយទាំងនេះគឺមិនស្របតាមការអនុវត្តល្អបំផុតជាអន្តរជាតិដែលអនុញ្ញាតឱ្យ "សមាគមអាចតវ៉ាអំពីការបដិសេធមិនចុះបញ្ជីដោយមិនលំអៀង និងឯករាជ្យ"។[175] |
| សេរីភាពខាងការជួបប្រជុំ | | | | | | | |

[174] សូមមើលចំណុចគន្លឹះទី១។

[175] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម ,Maina Kiai,' UN Doc. A/HRC/២០/២៧, (ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២(, កថាខណ្ឌ៩៥ <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session20/A-HRC-20-27_en.pdf>

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១.១៨ ការសន្មតមុនដែលគាំទ្រដល់ការរៀបចំការប្រមូលផ្តុំដោយសន្តិវិធី គឺត្រូវបានកំណត់យ៉ាងច្បាស់លាស់ | កម្រិតនៃ ក្របខ័ណ្ឌច្បាប់កំណត់នូវការសន្មតមុនដែលគាំទ្រ ចំពោះការប្រមូលផ្តុំដោយសន្តិវិធីដែលត្រូវបានអនុញ្ញាត | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៣ | ៣ | ៣ | កម្ពុជាខកខានក្នុងការគោរពចំណុចនេះឱ្យបានពេញលេញច្បាប់កម្ពុជាចែងពុំច្បាស់លាស់ពីការសន្មត់ជាមុនក្នុងការគាំទ្រដល់ការរៀបចំបាតុកម្មដោយសន្តិវិធី។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីចែងពីការសន្មត់ទុកជាមុនក្នុងការគាំទ្រដល់ការរៀបចំបាតុកម្មដោយសន្តិវិធីដែលចែងថា អាជ្ញាធរមានសមត្ថកិច្ច "ត្រូវឆ្លើយតបជាវិជ្ជមានជាលាយលក្ខណ៍អក្សរ"។[176] ប៉ុន្តែការសន្មត់ទុកជាមុននេះមិនអនុវត្តទោះការប្រមូលផ្តុំដោយសន្តិវិធីធ្វើឡើងនៅក្នុងអំឡុងពេលថ្ងៃឈប់សម្រាក (ពិធីបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ ពិធីឡើងគ្រងរាជ បុណ្យឯករាជ្យជាតិ បុណ្យចូលឆ្នាំខ្មែរ និងបុណ្យភ្ជុំបិណ្ឌ)។ ម្យ៉ាងទៀត ប្រសិនបើមាន "ព័ត៌មានច្បាស់លាស់" បញ្ជាក់ថាបាតុកម្ម "អាចបង្កគ្រោះថ្នាក់" ឬ " អាចធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ" ការសន្មត់ទុកជាមុននោះក៏នឹងត្រូវមោឃៈភាពផងដែរ។[177] ម្យ៉ាងទៀតច្បាប់នេះ មានវិសាលភាពតូចចង្អៀតពេក ដែលមិនរាប់បញ្ចូលការជួបប្រជុំក្នុងយុទ្ធនាការបោះឆ្នោត ឬការជួបប្រជុំទាក់ទងនឹងវិវាទការងារជាដើម ដែលផ្ទុយទៅនឹងគោលការណ៍សន្មត់ទុកជាមុនដែលបានលើកឡើងខាងលើ។[178] ស្រដៀងគ្នានេះច្បាប់ការងារក៏មិនរាប់បញ្ចូលនូវសកម្មភាពមួយចំនួនក្រៅពីវិសាលភាពនៃកិច្ចការពារដែលមានចែងក្នុងច្បាប់នេះដែរ។[179] ជាចុងក្រោយ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនិងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ ក៏ពុំបានបញ្ចូលបទប្បញ្ញត្តិជាក់លាក់ដែលត្រូវតែអនុញ្ញាតដល់ការប្រមូលផ្តុំនោះដែរ។[180] |
| ១.១៩ ការប្រមូលផ្តុំមិនចាំបាច់ត្រូវការការអនុញ្ញាត ពី រដ្ឋាភិបាល ឬអាជ្ញាធរ | កម្រិតនៃក្របខ័ណ្ឌច្បាប់ការពារសិទ្ធិខាងការជួបប្រជុំដោយមិនចាំបាច់សុំការអនុញ្ញាត | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៣,៥ | ៤ | ៤ | កម្ពុជាបានបំពេញចំណុចនេះបានខ្លះ។ មាត្រា ៥ និងមាត្រា៧ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីកំណត់ពីប្រព័ន្ធនៃការជូនដំណឹងជាមុន ជាជាងការសុំអនុញ្ញាត។ ម្យ៉ាងទៀតមាត្រា ២០ នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធីពុំតម្រូវឱ្យមានការជូនដំណឹងជាមុនឡើយចំពោះ"ការជួបប្រជុំផ្សេងៗ ទាំងផ្នែកសាសនា សិល្បៈ វប្បធម៌ ពិធីបុណ្យតាមទំនៀមទម្លាប់ប្រពៃណី" ឬសកម្មភាពផ្សព្វផ្សាយពីការអប់រំសម្រាប់ផលប្រយោជន៍សង្គម"។ ប៉ុន្តែ ការប្រមូលផ្តុំដោយសន្តិវិធីអាចត្រូវបានអាជ្ញាធរមានសមត្ថកិច្ចបញ្ឈប់ ប្រសិនបើពុំមានការជូនដំណឹងឱ្យបានត្រឹមត្រូវជាមុននោះទេ ដែលនេះពុំស្របតាមច្បាប់និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។[181] |

176 មាត្រា៩ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

177 ក្នុងករណីនេះ ក្រោមមាត្រា ១១ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីចែងថាអាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរដែនដីរាជធានី ឬខេត្ត ត្រូវធ្វើការឆ្លើយតបដោយជូនដំណឹង "ជាបន្ទាន់" ទៅអ្នកដែលបានដាក់លិខិតជូនដំណឹង "ដើម្បីឱ្យពួកគេអាចមានពេលជួបជាមួយអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត ធ្វើការពិចារណាដើម្បីពិភាក្សាគ្នាដោះស្រាយ" ។ ប្រសិនបើពុំមានការឯកភាពគ្នាទេ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវផ្តល់សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលយ៉ាងយូរត្រឹមម្ភៃបួន (២៤) ម៉ោងមុនពេលកំណត់នៃការធ្វើបាតុកម្មដោយសន្តិវិធី (មាត្រា១២)។

178 មាត្រា ៣ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

179 ទន្ទឹមនេះ ច្បាប់ការងារចែងក្នុងមាត្រា៣២០ ថា សិទ្ធិធ្វើកូដកម្ម ត្រូវបាន "ធានា" សិទ្ធិនេះក៏ត្រូវបានអនុវត្តដែរ នៅពេលដែលសហជីពជាតំណាងកម្មករនិយោជិតយល់ឃើញថាត្រូវយកសិទ្ធិនេះ មកប្រើ ដើម្បីបង្ខំឱ្យមានការគោរពតាមអនុសញ្ញារួម ឬតាមច្បាប់។ ជាពិសេស សិទ្ធិធ្វើកូដកម្មអាចអនុវត្តទៅបាន លុះត្រាតែបានប្រើប្រាស់អស់លទ្ធភាពក្នុងការដោះស្រាយជំលោះដោយ មធ្យោបាយសន្តិវិធីជាមួយនិយោជក។

180 មាត្រា ៧៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកគ្រប់គ្រងមហោស្រព មណ្ឌលកីឡា ឧទ្យានសាធារណៈ សាលសាធារណៈត្រូវផ្តល់ទីកន្លែងរបស់ខ្លួនដល់បេក្ខជន ឬគណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោត ដែលសុំជួលប្រើប្រាស់សម្រាប់បម្រើការឃោសនាបោះឆ្នោត។

181 មាត្រា ២០ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ។

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១.២០ ការហាមឃាត់ការប្រមូលផ្តុំត្រូវបានកំណត់ថាជាវិធានការចុងក្រោយ ចាំបាច់ និងសមាមាត្រទៅនឹងគោលបំណង | កម្រិតនៃក្របខ័ណ្ឌច្បាប់ដែលហាមឃាត់ការជួបប្រជុំ ដែលបានកំណត់ថាជាវិធានចុងក្រោយសមាមាត្រ ទៅនឹងគោលបំណង | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ២,៥ | ៣ | ៣ | កម្ពុជាពុំបានគោរពចំណុចនេះឱ្យបានពេញលេញ។ មាត្រា៩ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីចែងនូវលក្ខខណ្ឌចំនួនពីរដែលការជូនដំណឹងពីការប្រមូលផ្តុំអាចត្រូវបានបដិសេធ ដែលលក្ខខណ្ឌទាំងពីរនោះមានខ្លឹមសារស្រពិចស្រពិល។[182] សៀវភៅណែនាំការអនុវត្តច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីកំណត់ពីស្តង់ដារអនុវត្តលើប្រភេទព័ត៌មានដែលអាចនាំទៅរកការហាមប្រាម ហើយបើមានសំណើរដែលមិនស្ថិតក្នុងការហាមប្រាមត្រូវពិភាក្សាជាមុន។[183] នៅក្នុងផ្នែកទាក់ទងនឹងការណែនាំការអនុវត្តនេះក៏គូសបញ្ជាក់ផងដែរថា ប្រសិនបើអាជ្ញាធរជឿថាមានព័ត៌មានដូចបានបញ្ជាក់ក្នុងមាត្រា៩ (២) អាជ្ញាធរត្រូវ "ពិចារណានិងវាយតម្លៃលើព័ត៌មាននោះដើម្បីកំណត់ថាតើព័ត៌មាននោះមានភស្តុតាងដែរឬយ៉ាងណា" ហើយអាជ្ញាធរត្រូវជូនដំណឹងនិងផ្តល់កិច្ចសហប្រតិបត្តិការតាមការបង្កើត "ដំណោះស្រាយដែលលុបបំបាត់គ្រោះថ្នាក់ដែលអាចកើតឡើង ធ្វើយ៉ាងណាឱ្យបាតុកម្មនោះអាចដំណើរការទៅបាន"។[184] ផ្ទុយទៅវិញ ប្រសិនបើមានការអនុវត្តតាមមាត្រា៩(២) នេះក៏ពុំមានបទប្បញ្ញត្តិដើម្បីអាចអោយអាជ្ញាធរឆ្លើយតបវិញឡើយ។ |
| ១.២១ ការរឹតត្បិតតម្រូវឱ្យមានហេតុផលច្បាស់លាស់និងទាន់ពេលវេលា | កម្រិតនៃ ក្របខ័ណ្ឌច្បាប់តម្រូវឱ្យមានហេតុផលច្បាស់លាស់ទាន់ពេលវេលាចំពោះការរឹតត្បិត លើការប្រជុំ | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៣,៥ | ៤ | ៤ | កម្ពុជាបានបំពេញតាមចំណុចនេះបានខ្លះ។ ក្របខ័ណ្ឌច្បាប់ដែលមានស្រាប់តម្រូវឱ្យមានការឆ្លើយតបពីអាជ្ញាធរមកលើការជូនដំណឹងអំពីការជួបប្រជុំ។ ការឆ្លើយតបចាំបាច់ត្រូវប្រាប់ពីមូលហេតុដែលអាជ្ញាធររឹតត្បិតទោះជាបែបនេះក្តីក៏នៅតែមិនមានចែងជាក់លាក់នោះទេ។ ច្បាប់ជាតិបានសន្មត់ថាបានផ្តល់សិទ្ធិប្រសិនបើមិនទទួលបានការឆ្លើយតបពីការជូនដំណឹងនោះទេ។[185] នៅក្នុងមាត្រា៩ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីអាជ្ញាធរដែនដីរាជធានីឬខេត្ត មានសមត្ថកិច្ចត្រូវតែឆ្លើយតបជូនលិខិត ជូនដំណឹងយ៉ាងយូរត្រឹម៣ថ្ងៃនៃការងារដោយគិតចាប់ពីថ្ងៃដែលលិខិតជូនដំណឹងត្រូវបានដាក់ជូន។ ប្រសិនបើអាជ្ញាធរដែនដីរាជធានី ឬខេត្តមានសមត្ថកិច្ចខកខានក្នុងការឆ្លើយតបរហូតដល់ពេលកំណត់ដែលនឹងត្រូវធ្វើបាតុកម្មដោយសន្តិវិធី "មានន័យថាអាជ្ញាធរដែនដីរាជធានី ឬខេត្តមានសមត្ថកិច្ចបានព្រមព្រៀងហើយ"។[186] លើសពីនេះទៀត ក្នុងករណីដែលចែងនៅក្នុងមាត្រា៩(២) ប្រសិនបើមិនមានការព្រមព្រៀងគ្នា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនឹងជាបុគ្គលម្នាក់គត់ដែលជាអ្នកធ្វើសេចក្តីសម្រេចចុងក្រោយជាលាយលក្ខណ៍អក្សរនិងយ៉ាងយូរបំផុតម្ភៃបួន(២៤)ម៉ោងមុនពេលកំណត់នៃការធ្វើបាតុកម្មដោយសន្តិវិធី។[187] សេចក្តីសម្រេចនេះមិនបានអនុញ្ញាតឱ្យមានការតវ៉ានៅមុខតុលាការមិនលំអៀងដូចមានចែងក្នុងច្បាប់អន្តរជាតិនោះទេ។[188] |
| ១.២២ ការរឹតត្បិតលើពេលវេលា និង ទីកន្លែង មិនមែនជាកាតព្វកិច្ចនោះទេ | កម្រិតនៃក្របខ័ណ្ឌច្បាប់ដែលរឹតត្បិតតែលើពេលវេលា និង/ឬទីកន្លែង ត្រូវបានចែងនៅក្នុងក្របខ័ណ្ឌច្បាប់ | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៤ | ៤ | ៤ | កម្ពុជាមិនបានបំពេញតាមចំណុចនេះ។ មាត្រា៩(១) នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីបង្ហាញពីការហាមឃាត់ទៅលើការធ្វើបាតុកម្មដោយសន្តិវិធីនៅថ្ងៃបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ ព្រះរាជពិធីរាជាភិសេកព្រះមហាក្សត្រ ព្រះរាជពិធីបុណ្យអុំទូក បុណ្យឯករាជ្យជាតិ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងពិធីបុណ្យភ្ជុំបិណ្ឌ។ ការហាមឃាត់ទាំងអស់នេះ មិនមាននៅក្នុងគោលបំណងណាមួយដែលមាននៅក្នុងមាត្រា២១ ក.អ.ស.ព.ន ប៉ុន្តែនៅតែអាចធ្វើបាន។ ករណីខ្លះទៀត ការហាមឃាត់ទៅលើការធ្វើបាតុកម្មដោយសន្តិវិធីទាំងអស់នៃថ្ងៃទាំងនោះ មិនបំពេញតាមតម្រូវការចាំបាច់និងសមាមាត្រនៃផ្នែកទី៣នៃលក្ខខណ្ឌទាំងបីចំណុច វាអាចមានការជំទាស់គំនិតគ្នាក្នុងការពិចារណាអំពីកាលៈទេសៈជាក់លាក់នៃការប្រមូលផ្តុំនីមួយៗហើយដូច្នេះនឹងមានវិសមភាពនិងការរើសអើង (វាប៉ះពាល់ដល់ពលរដ្ឋដែលមានបំណងអនុវត្តសិទ្ធិសេរីភាពខាងការជួបប្រជុំ)។[189] |

182 មាត្រា ៩ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ចែងថាអាជ្ញាធរដែនដីរាជធានី ឬខេត្ត មានសមត្ថកិច្ចត្រូវឆ្លើយតបជាវិជ្ជមាន ចំពោះលិខិតជូនដំណឹងនោះជាលាយលក្ខណ៍អក្សរ លើកលែងតែ៖ ១) ការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវចំលើថ្ងៃប្រារព្ធព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ ព្រះរាជពិធីរាជាភិសេកព្រះមហាក្សត្រ ព្រះរាជពិធីបុណ្យអុំទូក ពិធីបុណ្យឯករាជ្យជាតិ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងពិធីបុណ្យភ្ជុំបិណ្ឌ។ ២) មានព័ត៌មានច្បាស់ថា ការធ្វើបាតុកម្មនេះនឹងអាចបង្កគ្រោះថ្នាក់ណាមួយ ឬនឹងអាចប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។

183 ផ្នែក៣ មាត្រា ២ មាត្រា៤ មាត្រា៧ នៃសៀវភៅណែនាំការអនុវត្តច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

184 ផ្នែក៣ មាត្រា ២ មាត្រា៤ មាត្រា៧ នៃសៀវភៅណែនាំការអនុវត្តច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

185 សូមមើលមាត្រា៩ នៃច្បាប់ស្តីពីការធ្វើបាតុម្មដោយសន្តិវិធី។

186 មាត្រា១០ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

187 មាត្រា១២ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

188 គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម ,Maina Kiai,' UN Doc. A/HRC/២០/២៧, (ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២(, កថាខណ្ឌ៤២ <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session20/A-HRC-20-27_en.pdf>

189 គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍រួមគ្នារបស់អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម និងការដោះស្រាយក្រៅប្រព័ន្ធច្បាប់ ដោយសង្ខេប ឬតាមទំនើងចិត្តដើម្បីគ្រប់គ្រងការប្រមូលផ្តុំ, (ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦(, UN Doc. A/HRC/៣១/៦៦ កថាខណ្ឌ៣០។ សូមអានគណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ, 'របាយការណ៍ជុំទី២របស់អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម Maina Kiai,' UN Doc. A/HRC/២៣/៣៩, (ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣, កថាខណ្ឌ៦៣ <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session23/A.HRC.23.39_EN.pdf>

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១.២៣ ការប្រមូលផ្តុំស្របពេលគ្នានៅទីតាំង និងពេលវេលាតែមួយត្រូវបានអនុញ្ញាត | កម្រិតនៃ ក្របខណ្ឌច្បាប់ដែលអនុញ្ញាតឱ្យមានការប្រមូលផ្តុំស្របពេលគ្នា | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៥ | ៥ | ៥ | កម្ពុជាបានបំពេញតាមចំណុចនេះ។ គ្មានច្បាប់ការហាមឃាត់ទៅលើការជួបប្រជុំដែលបានធ្វើក្នុងពេលជាមួយគ្នានោះទេ។ មាត្រា១៤ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីបានចែងថា ការធ្វើបាតុកម្មដោយសន្តិវិធីមានពីក្រុមផ្សេងគ្នាហើយធ្វើនៅកន្លែងតែមួយនិងពេលវេលាតែមួយ អាជ្ញាធរដែនដីរាជធានីឬខេត្ត មានសមត្ថកិច្ចត្រូវសម្រេចឱ្យក្រុមអ្នកដែលបានដាក់សេចក្តីជូនដំណឹងមុនទទួលបានសិទ្ធិធ្វើមុន ឬអាចអនុញ្ញាតឱ្យធ្វើនៅកន្លែងមួយផ្សេងទៀតដែលមានចម្ងាយយ៉ាងតិចប្រាំរយ(៥០០) ម៉ែត្រពីគ្នា។ ការផ្តល់ជូននេះគឺជាផ្នែកមួយនៃមាត្រា១៤ ដែលទាក់ទងនឹងករណីបាតុកម្មជាក់ស្តែងនៅ "កន្លែងមញ្ញមតិជាសាធារណៈ" ឬនៅកន្លែងឯកជន។ ប៉ុន្តែនៅក្នុងផ្នែកទី២ នៃមាត្រា២.៤.៥ នៃការណែនាំការអនុវត្តបានបង្ហាញច្បាស់លាស់ថាអាជ្ញាធរគួរតែ "ប្រើប្រាស់កិច្ចខិតខំប្រឹងប្រែងដ៏ល្អបំផុតរបស់ពួកគេ" ដើម្បីធានាថាក្រុមដែលចង់ធ្វើបាតុកម្មទាំងអស់អាចធ្វើបាតុកម្មបាន "ក្នុងកម្រិតដែលអាចធ្វើទៅបាន" ដែលពួកគេអាចធ្វើដូច្នោះក្នុងលក្ខណៈ ពេលវេលា និងទីតាំងដែលពួកគេបានស្នើសុំ។ |
| ១.២៤ នីតិវិធីប្តឹងជំទាស់មុនពេលមានស្ថាប័នឯករាជ្យ និងមិនលម្អៀងត្រូវបានបង្កើតឡើងសម្រាប់ការដាក់កំហិតលើការប្រមូលផ្តុំ | កម្រិតនៃនីតិវិធីជំទាស់ដែលត្រូវបានកំណត់នៅក្នុងក្របខណ្ឌច្បាប់ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៣ | ៣ | ៣ | កម្ពុជាមិនបានបំពេញតាមចំណុចនេះ។ នៅក្នុងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី អាជ្ញាធរដែនដីរាជធានីឬខេត្តមានសមត្ថកិច្ចត្រូវតែឆ្លើយតបទៅនឹងលិខិតជូនដំណឹងយ៉ាងយូរត្រឹមបី(៣) ថ្ងៃនៃថ្ងៃការងារដោយគិតចាប់ពីថ្ងៃដែលលិខិតជូនដំណឹងត្រូវបានគេដាក់ជូន។[190] អាជ្ញាធរដែនដី រាជធានីឬខេត្តមានសមត្ថកិច្ចខកខានក្នុងការឆ្លើយតបរហូតដល់ពេលកំណត់ដែលនឹងត្រូវធ្វើបាតុកម្មដោយសន្តិវិធី "មានន័យថាអាជ្ញាធរដែនដីរាជធានីឬខេត្តមានសមត្ថកិច្ចបានព្រមព្រៀងហើយ"។[191] បើកន្លែងណាមានព័ត៌មានច្បាស់ថាការធ្វើបាតុកម្មនេះនឹងអាចបង្កគ្រោះថ្នាក់ណាមួយ ឬនឹងអាចប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។ អាជ្ញាធរ ដែនដីរាជធានីឬខេត្តត្រូវតែជូនដំណឹងទៅអ្នករៀបចំកម្មវិធី "ភ្លាមៗ" ហើយមានរយៈពេលបីថ្ងៃដើម្បីជួបជាមួយអ្នកដឹកនាំបាតុកម្មដើម្បីឈានទៅរកកិច្ចព្រមព្រៀងមួយ។ បើសិនមិនមានការព្រមព្រៀងគ្នាទេ មាត្រា១២ បានចែងថា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនឹងជាបុគ្គលម្នាក់ដែលជាអ្នកសម្រេចចុងក្រោយជាលាយលក្ខណ៍អក្សរ និងយ៉ាងយូរបំផុតម្ភៃបួន(២៤)ម៉ោង មុនពេលកំណត់នៃការធ្វើបាតុកម្មដោយសន្តិវិធី។ ប៉ុន្តែមិនអាចត្រូវបានចាត់ទុកថាជា "ស្ថាប័នឯករាជ្យនិងមិនលំអៀងឡើយ"។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គឺជាសមាជិកនៃអង្គនីតិប្រតិបត្តិមិនមែនជា"ស្ថាប័នឯករាជ្យ"។ មិនអាចប្តឹងទៅស្ថាប័នតុលាការបន្ថែមទៀតបានទេ។ |
| ១.២៥ នីតិវិធីនៃការជូនដំណឹងមុនចំពោះការប្រមូលផ្តុំអនុលោមតាមការអនុវត្តល្អបំផុតនៃអន្តរជាតិ | កម្រិតនៃ នីតិវិធីនៃការជូនដំណឹងមុនលើការប្រមូលផ្តុំ អនុលោមតាមការអនុវត្តល្អបំផុតនៃអន្តរជាតិ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៣,៥ | ៤ | ៤ | កម្ពុជាខកខានក្នុងការបំពេញតាមចំណុចនេះ។ ច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី[192] ច្បាប់ស្តីពីការងារ[193] និងច្បាប់ស្តីពីការបោះឆ្នោតបង្ហាញពីនីតិវិធីនៃការជូនដំណឹងមុនសម្រាប់ការជួបប្រជុំ[194] ដែលស្របតាមច្បាប់អន្តរជាតិអំពីនីតិវិធីនៃការជូនដំណឹងមុន។ ទោះជាបែបនេះក្តីការអនុវត្តល្អជាអន្តរជាតិបានផ្តល់អនុសាសន៍ អំពីការជូនដំណឹងមុនចំពោះការជួបប្រជុំដែលមានចំនួនអ្នកចូលរួមច្រើន ឬការជួបប្រជុំដែលអ្នករៀបចំរំពឹងថាមានការខាតខាតតែប៉ុណ្ណោះ។[195] ច្បាប់ស្តីពីការបោះឆ្នោតរឹតត្បិតមកលើការជួបប្រជុំដោយមិនសមាមាត្រដូចជាតម្រូវឱ្យជូនដំណឹងមុនដែលនេះមិនមែនជាការតម្រូវផ្លូវការដែលទាមទារឱ្យមានការជូនដំណឹងគ្រប់ការជួបប្រជុំ ដូចជាការជួបប្រជុំដែលមានអ្នកចូលរួមតិចតួចដោយមិនមានការវិនិច្ឆ័យត្រឹមត្រូវ។[196] ភាគច្រើននៃព័ត៌មានដែលត្រូវការនៅក្នុងការជូនដំណឹងមុនមានលក្ខណៈសមាមាត្រនិងមិនមែនជាបន្ទុក ដូចជាត្រូវប្រាប់គោលបំណងសំរាប់ការជួបប្រជុំ។ កាលបរិច្ឆេទ ពេលវេលា រយៈពេល ចំនួនអ្នកចូលរួមនិងយានជំនិះដែលត្រូវប្រើ។ ទោះយ៉ាងណា ច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធីក៏តម្រូវឱ្យមានព័ត៌មានលំអិតនៃអត្តសញ្ញាណរបស់ថ្នាក់ដឹកនាំទាំងបីដែលជាតម្រូវការមួយដែលហាក់ដូចជាមិនសមាមាត្រនិងមិនចាំបាច់។[197] នេះដូចមិនច្បាស់ថាហេតុអ្វីបានជាព័ត៌មានលម្អិតអំពីបុគ្គលចំនួន ៣ នាក់ចាំបាច់ត្រូវទាមទារសំរាប់ការជួបប្រជុំតូចៗ វាអាចមិនពាក់ព័ន្ធឬជាបន្ទុកដូច្នេះវាជាឧបសគ្គដល់សេរីភាពខាងការជួបប្រជុំ។ លើសពីនេះទៀត ច្បាប់តម្រូវឱ្យមានការជូនដំណឹងជាមុនត្រូវធ្វើយ៉ាងហោចណាស់ប្រាំថ្ងៃនៃថ្ងៃធ្វើការមុនពេលព្រឹត្តិការណ៍កើតឡើង។[198] ការកំណត់រយៈពេលបែបនេះគឺជាសកម្មភាពនៃការរឹតត្បិតសេរីភាពខាងការជួបប្រជុំដែលរាំងអ្នករៀបចំក្នុងការទទួលបានការឆ្លើយតបមកលើព្រឹត្តិការណ៍ដែលពួកគេបានរៀបចំ។ |

190 មាត្រា១២ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

191 មាត្រា១០ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

192 មាត្រា៦,៧,១០,១៤,២០ និង២៨ នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី។

193 មាត្រា៣២៤ និង៣២៧ នៃច្បាប់ស្តីពីសហជីព។

194 មាត្រា៧៨,៧៩ និង៨១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា។ មាត្រា៧៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

195 OSCE-ODIHR and Venice Commission, 'គោលការណ៍ណែនាំអំពីសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី', (បោះពុម្ពលើកទី២ ២០១០), កថាខណ្ឌ១១៥។

196 មាត្រា៦,៧,១០,១៤,២០ និង២៨ នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី។

197 មាត្រា៦ នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី។

198 មាត្រា៧ នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី។

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១.២៦ អ្នករៀបចំមិនប្រឈមនឹងទោសព្រហ្មទណ្ឌ ឬ ទណ្ឌកម្មរដ្ឋបាល ការខកខានមិនបានជូនដំណឹងដល់អាជ្ញាធរ | កម្រិតនៃ ក្របខ័ណ្ឌច្បាប់ដែលកំណត់អំពីការដាក់ទោស ព្រហ្មទណ្ឌនិង/ឬ រដ្ឋបាលចំពោះអ្នករៀបចំដែល ខកខានមិនបានជូនដំណឹងអាជ្ញាធរ | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៣ | ៣ | ៣ | កម្ពុជាមិនបានបំពេញតាមចំណុចនេះ។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ផ្តល់នូវការព្រមានដល់អ្នករៀបចំបាតុកម្មដែលមិនផ្តល់នូវការជូនដំណឹង។[199] ច្បាប់ស្តីពីសហជីពនិងច្បាប់ស្តីពីការងារបានចែងថាការធ្វើកូដកម្មដែលមិនស្របតាមបទប្បញ្ញត្តិរបស់ខ្លួនរួមទាំងតម្រូវឱ្យជូនដំណឹងជាមុនត្រូវចាត់ទុកថាខុសច្បាប់។[200] ប៉ុន្តែមានតែស្ថាប័នតុលាការតែមួយគត់អាចកំណត់ពីភាពស្របច្បាប់និងមិនស្របច្បាប់នៃការធ្វើកូដកម្ម។[201] យ៉ាងណាក៏ដោយ ច្បាប់ស្តីពីសហជីពចែងថា ប្រសិនបើអ្នកធ្វើកូដកបន្តធ្វើកូដកម្ម ត្រូវបានតុលាការការងារប្រកាសថាខុសច្បាប់និងមិនបានអនុវត្តតាមការព្រមាន ពួកគេនឹងត្រូវទទួលរងការផាកពិន័យជាអន្តរការណ៍ ជាទឹកប្រាក់មិនលើសពី៥លានរៀល (ប្រមាណ ១២០០ ដុល្លាសហរដ្ឋអាមេរិក)។[202] នៅពេលដែលការពិន័យគឺជាជម្រើសចុងក្រោយទៅតាមការព្រមានពីរបីដង ចំនួនការផាកពិន័យបង្កើតឱ្យមានការដាក់កំហិតដោយមិនសមហេតុផលទៅលើសិទ្ធិសេរីភាពកម្មករក្នុងការប្រើប្រាស់សេរីភាពខាងសមាគម។ |
| ១.២៧ នគរបាលមានកាតព្វកិច្ចសម្របសម្រួលដល់ការប្រមូលផ្តុំដោយសន្តិវិធី | កម្រិតនៃអ្នកអនុវត្តច្បាប់និងគោល នយោបាយ គាំទ្រដល់ ការប្រមូលផ្តុំដោយសន្តិវិធី | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៥ | ៥ | ៥ | កម្ពុជាបានបំពេញតាមចំណុចនេះ។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីចែងថា អាជ្ញាធរដែនដីរាជធានី ឬខេត្ត មានសមត្ថកិច្ចគួតែទទួលខុសត្រូវក្នុងការការពារនៅបាតុកម្មដោយសន្តិវិធី និងមិនជ្រៀតជ្រែកនៅការធ្វើបាតុកម្មដោយសន្តិវិធីនេះ។[203] អាជ្ញាធរមានសមត្ថកិច្ចឆ្លើយតបទៅនឹងសំណើសម្រាប់ជំនួយដល់អ្នករៀបចំបាតុកម្មដើម្បីធានាថា "សិទ្ធិសេរីភាពក្នុងការធ្វើបាតុកម្មដោយសន្តិវិធីនិងការអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិជាសាធារណៈរបស់ពួកគេដោយមានសេចក្តីថ្លៃថ្នូរ"។[204] ក្នុងករណីមានអំពើហិង្សា សេចក្តីណែនាំឱ្យមានការអនុវត្តចែងយ៉ាងច្បាស់ថា បាតុកម្មអាចត្រូវបានបំបែកនៅពេលដែលគ្មានជម្រើសផ្សេងទៀត[205] បន្ថែមទៀតថារាល់សកម្មភាពរបស់នគរបាលត្រូវតែមានសមាមាត្រទៅនឹងស្ថានភាព ហើយត្រូវបានប្រើក្នុងករណីចាំបាច់។[206] |
| ១.២៨ អ្នករៀបចំ ការប្រមូលផ្តុំមិនទទួលខុសត្រូវលើបន្ទុកហិរញ្ញវត្ថុសម្រាប់ការផ្តល់សេវាសាធារណៈ | កម្រិតនៃក្របខ័ណ្ឌច្បាប់ដែលការពារ អ្នករៀបចំ មិនឱ្យទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ ចំពោះការផ្តល់សេវាសាធារណៈ | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៥ | ៥ | ៥ | កម្ពុជាបានបំពេញតាមចំណុចនេះ។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីមិនបានចែងថា អ្នករៀបចំបាតុកម្មគឺទទួលខុសត្រូវចំពោះការគិតថ្លៃផ្នែកហិរញ្ញវត្ថុសម្រាប់ការផ្តល់សេវាសាធារណៈនោះទេ។ |
| ១.២៩ អ្នករៀបចំការប្រមូលផ្តុំ និងអ្នកចូលរួមមិនទទួលខុសត្រូវ ចំពោះទង្វើខុសច្បាប់របស់អ្នកដទៃ ឬចំពោះការថែរក្សាសណ្តាប់ធ្នាប់ សាធារណៈ ឡើយ | កម្រិតនៃក្របខ័ណ្ឌច្បាប់ដែលអ្នករៀបចំ និងអ្នកចូលរួមមាន ទំនួលខុសត្រូវផ្នែកច្បាប់ចំពោះការធ្វើខុសច្បាប់របស់អ្នកដទៃ និង/ឬ ចំពោះការថែរក្សាសណ្តាប់ធ្នាប់សាធារណៈ | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៤ | ៤ | ៤ | កម្ពុជាបានបំពេញតាមចំណុចនេះ។ អ្នករៀបចំការជួបជុំមិនត្រូវទំនួលខុសត្រូវ ឬទទួលខុសត្រូវចំពោះការខូចខាតទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍មួយដែលបានប្រែជាអំពើហិង្សានោះឡើយ។ ក្នុងករណីមានការប្រជុំដោយសន្តិវិធីប្រែជាហិង្សាដូចដែលមានចែងក្នុងមាត្រា ២០ (២) នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី អ្នករៀបបាតុកម្មត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ។ មាត្រា ២៣ ដល់ ២៧ ដំណោះស្រាយទាក់ទងនឹងការកាន់អាវុធ ឬសារធាតុគ្រោះថ្នាក់ ការខូចខាតទ្រព្យសម្បត្តិឯកជនឬសាធាណៈអំពើហិង្សាដែលបណ្តាលឱ្យមានរបួសបុស្លាប់។ ក្នុងករណីទាំងអស់នេះច្បាប់ចែងយ៉ាងច្បាស់ថាបុគ្គលដែលជាអ្នកធ្វើសកម្មភាពនោះជាអ្នកត្រូវទទួលខុសត្រូវ។ នេះមិនអាចចាត់ទុកថាជាការទទួលខុសត្រូវរបស់អ្នករៀបចំនិងអ្នកចូលរួមដទៃទៀតនោះទេ។ |

[199] មាត្រា២១ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី, សូមមើលផ្នែកទី៣ មាត្រា៤-៤-១ នៃសេចក្តីណែនាំឱ្យអនុវត្ត។

[200] មាត្រា៩២ នៃច្បាប់ស្តីពីសហជីព។

[201] មាត្រា៣៣៧ នៃច្បាប់ស្តីពីការងារ។

[202] មាត្រា៩២ នៃច្បាប់ស្តីពីសហជីព។

[203] មាត្រា១៧ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[204] មាត្រា១៨ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[205] ផ្នែកទី២ នៃចំនុច ៣.៦.៤ នៃសៀវភៅណែនាំការអនុវត្ត។

[206] ផ្នែកទី២ នៃចំនុច ៣.៦.៥ នៃសៀវភៅណែនាំការអនុវត្ត។

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១.៣០ ការប្រើប្រាស់កម្លាំងរបស់រដ្ឋអាចធ្វើទៅបានលុះត្រាតែចាំបាច់ដើម្បីគ្រប់គ្រង ស្ថានភាពក្នុងលក្ខណៈសមហេតុផល និងសមាមាត្រ | កម្រិតនៃក្របខណ្ឌច្បាប់កំណត់ពីការប្រើប្រាស់កម្លាំងរបស់រដ្ឋនៅក្នុងស្ថានភាព ដែលចាំបាច់ដើម្បីគ្រប់គ្រងស្ថានភាព ក្នុងលក្ខណៈសមហេតុផល និងសមាមាត្រ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៤ | ៤ | ៤ | កម្ពុជាបានបំពេញតាមចំណុចនេះ។ ប្រសិនបើការជួបប្រជុំដោយសន្តិវិធីប្រែជាហិង្សាអាជ្ញាធរត្រូវចាត់វិធានការសមស្របដើម្បីទប់ស្កាត់និងបញ្ឈប់ការធ្វើបាតុកម្មភ្លាមៗ។[207] មាត្រា ២៣-២៧ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីបង្ហាញពីរបៀបដែលអាជ្ញាធរគួរតែឆ្លើយតបប្រសិនបើបាតុកម្មប្រែទៅជាអំពើហិង្សាឬបាតុករប្រព្រឹត្តិបទឧក្រិដ្ឋ។ ការឆ្លើយតបរួមមានការរឹបអូសយកអាវុធ ផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌ។ ការអន្តរាគមន៍ណាមួយរបស់ប៉ូលីសត្រូវតែសមាមាត្រទៅនឹងស្ថានភាព ហើយត្រូវបានប្រើតែក្នុងកម្រិតចាំបាច់ដើម្បីស្តារសណ្តាប់ធ្នាប់ភ្លាមៗ។[208] លើសពីនេះទៅទៀតច្បាប់មិនបានចែងពីការប្រើប្រាស់កម្លាំងដោយអាជ្ញាធរទេទោះបីជាមិនបានហាមឃាត់យ៉ាងច្បាស់ក៏ដោយ។ |
| ១.៣១ ប្រព័ន្ធកត់ត្រាការប្រាស្រ័យទាក់ទងដើម្បីឃ្លាំមើលបញ្ហា អ្នកទទួលខុសត្រូវលើការបញ្ជា និងអ្នកអនុវត្តបញ្ជាជាកាតព្វកិច្ច | កម្រិតនៃ ប្រព័ន្ធកត់ត្រាការប្រាស្រ័យទាក់ទងត្រូវបានបង្កើតឡើងដោយក្របខណ្ឌច្បាប់ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ២ | ២ | ២ | កម្ពុជាបានខកខានក្នុងការបំពេញតាមចំណុចនេះ។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីមិនចែងពីប្រព័ន្ធកំណត់ត្រាការប្រាស្រ័យទាក់ទងនោះទេ តែមាត្រា ១៩ ចែងថា "អាជ្ញាធរដែលត្រូវបានចាត់ឱ្យរក្សាសន្តិសុខសុវត្ថិភាពនិងសណ្តាប់ធ្នាប់សាធារណៈនៅកន្លែងបាតុកម្មប្រជុំដោយសន្តិវិធីត្រូវពាក់ឯកសណ្ឋានឱ្យបានត្រឹមត្រូវព្រមទាំងមានស្លាកឈ្មោះនិងអត្តលេខសម្គាល់ខ្លួននៅផ្នែកខាងមុខដែលលើកកម្ពស់តណាវនេយ្យភាពនិងសម្របសម្រួលការកំណត់អត្តសញ្ញាណអ្នកធ្វើខុស។ |

207 មាត្រា២០(២) ២៣ ដល់២៧ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី

208 ចំនុច ៣.៦.៥ នៃសៀវភៅណែនាំការអនុវត្ត

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១.៣២ ការរឹតត្បិតសេរីភាពខាងការបញ្ចេញមតិ ផ្អែកតាមលក្ខខណ្ឌ ៣ ចំណុចយោងតាមមាត្រា ១៩ នៃ ក.អ.ស.ព.ន | កម្រិតនៃ ច្បាប់ដែលប៉ះពាល់សេរីភាពខាងការបញ្ចេញមតិ ផ្អែកតាមលក្ខខណ្ឌ ៣ ចំណុចពី មាត្រាទី ១៩ នៃ ក.អ.ស.ព.ន | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ១ | ១ | ១ | ច្បាប់សំខាន់ៗរបស់កម្ពុជាបានរឹតត្បិតលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិដែលមិនអនុលោមទៅតាមលក្ខខណ្ឌបីចំនុចនៃមាត្រា១៩ នៃក.អ.ស.ព.ន។ ដូច្នេះកម្ពុជាពុំបានបំពេញសូចនាករមួយនេះឡើយ។[209] ជាពិសេសក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ចាត់ទុកជាបទល្មើសព្រហ្មទណ្ឌចំពោះការបរិហារកេរ្តិ៍ ការប្រមាថ ញុះញង់ និងកាលពីខែកុម្ភៈ ឆ្នាំ២០១៨ នៅបទល្មើសប្រមាថអង្គព្រះមហាក្សត្រ) ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ច្បាប់ស្តីពីទូរគមនាគមន៍ ច្បាប់ស្តីពីការអប់រំ ក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ច្បាប់ស្តីពីរបបសារព័ត៌មាន និងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៅឆ្នាំ២០១៨ ដែលមិនអនុលោមតាមលក្ខខណ្ឌបីចំនុចនៃមាត្រា ១៩ (៣) នៃក.អ.ស.ព.ន ។[210] លើសពីនេះទៀតប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលដំណើរការតាមប្រព័ន្ធអិនធឺណិតរឹតត្បិតលើសិទ្ធិសេរីភាពបញ្ចេញមតិ។ ការហាមឃាត់នៅក្នុងប្រកាសអន្តរក្រសួងគឺមានលក្ខណៈទូលំទូលាយពេកនិងមិនច្បាស់លាស់សម្រាប់ប្រជាពលរដ្ឋដើម្បីកំណត់ថាតើខ្លឹមសារណាមួយដែលអនុញ្ញាតឬមិនអនុញ្ញាត។ លើសពីនេះទៅទៀតគោលបំណងនៃប្រកាសនេះមិនបានការពារសិទ្ធិនិងកេរ្តិ៍ឈ្មោះរបស់នរណាម្នាក់ឡើយឬដើម្បីការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈឬសុខភាពសាធារណៈនិងសីលធម៌។ ចុងក្រោយមានការផ្តន្ទាទោសសម្រាប់ការផ្សព្វផ្សាយ រួមមានបិទគេហទំព័រនិងចំណាត់ការផ្លូវច្បាប់ចំពោះបុគ្គលនិងនីតិបុគ្គល។[211] ការផ្តន្ទាទោសទាំងនេះមិនមែនជាមធ្យោបាយរឹតត្បិតដែលចាំបាច់ដើម្បីសម្រេចបាននូវគោលបំណងនៃប្រកាសនេះ។[212] |

209 មាត្រា២(១) នៃក.អ.ស.ព.ន តម្រូវឱ្យរដ្ឋភាគី ការគោរពនិងដើម្បីធានាដល់បុគ្គលទាំងអស់នៅក្នុងទឹកដីនិងក្រោមយុត្តាធិការរបស់ខ្លួននូវសិទ្ធិដែលបានទទួលស្គាល់នៅក្នុងកតិកាសញ្ញានេះ។ លើសពីនេះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាថ្ងៃទី១០ខែកក្កដាឆ្នាំ ២០០៧ បានបកស្រាយមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញថាសន្ធិសញ្ញាអន្តរជាតិដែលបានផ្តល់សច្ចាប័នដោយកម្ពុជារួមមានអ.ស.ព.ន ត្រូវបានអនុវត្តនៅក្នុងច្បាប់ជាតិ។ សូមមើលសេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញលេខ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧)

210 សូមអានសូមមើល "របាយការណ៍ប្រចាំឆ្នាំលើកទី១ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និងអាយ. ស៊ី .អិន.អិល (ខែសីហា ឆ្នាំ២០១៧) ទំព័រ ៧-៨ ដែលអាចរកបាន៖ https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf និងសូមអានសូមមើល "របាយការណ៍ប្រចាំឆ្នាំលើកទី២ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និងអាយ. ស៊ី .អិន.អិល (ខែកញ្ញា ឆ្នាំ២០១៨) ទំព័រ ៤ ដែលអាចរកបាន៖ https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=128&id=5

211 សូមអាន "របាយការណ៍ប្រចាំឆ្នាំលើកទី២ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និងអាយ. ស៊ី .អិន.អិល (ខែកញ្ញា ឆ្នាំ២០១៨) ទំព័រ ៣ ដែលអាចរកបាន៖ https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf

212 សូមអាន អាយ. ស៊ី .អិន.អិល "ការវិភាគប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលដំណើរការតាមប្រព័ន្ធអិនធឺណិត" ខែកក្កដា ឆ្នាំ២០១៨ ទំព័រ ៥ ដល់៨ ដែលអាចរកបាន៖ http://sithi.org/judicial/docs/ICNL-Analysis-Prakas-on-Websites-and-Social-Media_July-2018.pdf

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១.៣៣ ការនិយាយបង្ខូចកេរ្តិ៍មិនត្រូវមានទោសព្រហ្មទណ្ឌទេ | កម្រិតនៃការបង្ខូចកេរ្តិ៍មិនត្រូវជាប់ទោសព្រហ្មទណ្ឌទេ | ការពិនិត្យ និងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ២ | ២ | ២ | កម្ពុជាបានខកខានក្នុងការបំពេញតាមចំណុចនេះ ដូចមាត្រា៣០៥ និង៣០៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមានបទបរិហារកេរ្តិ៍និងការប្រមាថ។ ការបរិហារកេរ្តិ៍ត្រូវបានកំណត់ថា " គ្រប់ការអះអាងបំផ្លើសឬទំលាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសឬកិត្តិស័ព្ទនៃបុគ្គលឬស្ថាប័ន។ ការប្រមាថមានន័យថាពាក្យមើលងាយឬគ្រប់ពាក្យត្រគោះដែលគ្មានការទំលាក់កំហុសទៅលើអំពើណាមួយគឺជាការប្រមាថ។ ការដាក់ទោសនៃការបរិហារកេរ្តិ៍នៅក្នុងច្បាប់ជាតិគឺមានបញ្ហាពីព្រោះនិយមន័យមិនច្បាស់លាស់ដោយមិនតម្រូវចាំឱ្យមានគ្រោះថ្នាក់ណាមួយកើតឡើងឡើយ។ ការដាក់ទោសនេះមិនបានការពារអំពីការពិតឬផលប្រយោជន៍សាធារណៈតម្រូវដោយច្បាប់និងបទដ្ឋានអន្តរជាតិនោះដែរ។ លើសពីនេះទៀតក្នុងការអនុវត្ត ការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ព្រហ្មទណ្ឌអាចប្រើលើបុគ្គល "ស្ថាប័ន" ដែលមិនបានគោរពតាមច្បាប់អន្តរជាតិ។ ខណៈដែលការពិន័យចំពោះការបរិហារកេរ្តិ៍ឬការជេរប្រមាថមិនបានបញ្ចូលទោសជាប់ពន្ធនាគារ ប៉ុន្តែបទល្មើសទាំងនេះត្រូវផ្តន្ទាទោសដោយការផាកពិន័យក្នុងក្រមព្រហ្មទណ្ឌ។[213] លើសពីនេះនៅខែកុម្ភៈ ឆ្នាំ២០១៨ ការធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌរួមទាំងមាត្រា ៤៣៧ស្ទួន "បទប្រមាថអង្គព្រះមហាក្សត្រ" ។ បទល្មើសនេះផ្ទុយនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលចែងច្បាស់ថាបុគ្គលសាធារណៈត្រូវតែប្រឈមនឹងការរិះគន់កម្រិតខ្ពស់ ដោយគ្រាន់តែថាទម្រង់នៃការបញ្ចេញមតិបែបនេះត្រូវបានគេចាត់ទុកថាជាការប្រមាថដល់បុគ្គលសាធារណៈដែលគួរនឹងមានការដាក់ទណ្ឌកម្មនោះទេ។[214] ការបំពានមាត្រានេះនាំឱ្យមានការពិន័យមិនស្មើគ្នាពោលគឺត្រូវជាប់ពន្ធនាគារពី ១ ឆ្នាំទៅ ៥ ឆ្នាំនិងពិន័យជាប្រាក់ពី ២ ទៅ ១០ លានរៀល។ មាត្រា ៧១ នៃ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា និងមាត្រា ៧១ នៃ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ក៏មានទោសព្រហ្មទណ្ឌចំពោះការបរិហារកេរ្តិ៍ដោយការរឹតត្បិតលើគណបក្សនយោបាយនិងបេក្ខជនឬអ្នកគាំទ្រនៅពេលថ្លែងដោយផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរថាបានប្រើពាក្យ "អសីលធម៌" ឬ "ប្រមាថ" ក្នុងអំឡុងពេលឃោសនាបោះឆ្នោត។[215] ខណៈដែលច្បាប់អន្តរជាតិអនុញ្ញាតឱ្យមានការរឹតត្បិតក្នុងការប្រើប្រាស់ពាក្យពេចន៍ក្នុងពេលបោះឆ្នោត លក្ខណៈមិនច្បាស់នៃបទប្បញ្ញត្តិនេះមិនត្រូវបានគោរពតាមស្តង់ដារអន្តរជាតិនោះទេពីព្រោះច្បាប់នេះផ្តល់ឱកាសឱ្យមានការរំលោភបំពាន- ការមិនយល់ស្របជាមួយគណបក្សនយោបាយអាចត្រូវបានកំណត់ថាជា "អំពើអសីលធម៌ឬប្រមាថ"។[216] មាត្រា ៧១ បានចែងទាំងការពិន័យជាប្រាក់និងការលុបបេក្ខភាព។ |

213 សូមអាន "របាយការណ៍ប្រចាំឆ្នាំលើកទី២ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និងអាយ. ស៊ី .អិន.អិល (ខែកញ្ញា ឆ្នាំ២០១៨) ទំព័រ ៨ ដែលអាចរកបាន៖ https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf

214 គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'អនុសាសន៍ទូទៅលេខ៣៤' , UN Doc. CCPR/C/GC/៣៤, (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១), កថាខណ្ឌ៣៨ <https://www2.ohchr.org/english/bodies/hrc/docs/gc34.pdfhttps://bit.ly/1xmySgV>

215 យុទ្ធនាការឃោសនាបោះឆ្នោតមានរយៈពេល២១ថ្ងៃ (មាត្រា៧២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា) និងរយៈពេល១៤ថ្ងៃសំរាប់ការបោះឆ្នោតឃុំ-សង្កាត់ (មាត្រា៧០នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់)។

216 សហភាពអឺរ៉ុប, របាយការណ៍បញ្ចប់បេសកកម្មការត្រួតពិនិត្យនៅកម្ពុជា ឆ្នាំ២០១៥ <https://eeas.europa.eu/sites/eeas/files/efm_cambodia_2015_final_report_publ.pdf>

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១.៣៤ ការតាមដានមកលើការប្រាស្រ័យទាក់ទងអាចធ្វើបានក្រោយពេលមានការត្រួតពិនិត្យពីតុលាការតែប៉ុណ្ណោះ | កម្រិតនៃក្របខ័ណ្ឌច្បាប់ធានាថាការតាមដានមកលើការប្រាស្រ័យទាក់ទងអាចធ្វើបានក្រោយពេលមានការត្រួតពិនិត្យពីតុលាការតែប៉ុណ្ណោះ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ១ | ១ | ១ | ច្បាប់កម្ពុជាពុំបានបំពេញតាមចំណុចនេះទេ។ ច្បាប់ស្តីពីទូរគមនាគមន៍ដែលបានប្រកាសឱ្យប្រើនៅឆ្នាំ ២០១៦ បានផ្តល់អំណាចទូលាយឱ្យរដ្ឋាភិបាលនូវក្នុងការតាមដានទូរគមនាគមន៍ដោយគ្មានការត្រួតពិនិត្យពីប្រព័ន្ធតុលាការឬស្ថាប័នឯករាជ្យផ្សេងទៀត។ មាត្រា៦ ចែងថា "ប្រតិបត្តិករទូរគមនាគមន៍និងអ្នកដែលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ត្រូវផ្តល់ឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នូវទិន្នន័យសេវាកម្មបច្ចេកវិជ្ជាទូរគមនាគមន៍ព័ត៌មាននិងទិន្ន័យសេវាទូរគមនាគមន៍"។ យោងតាមបទបញ្ញត្តិនេះប្រតិបត្តិករទូរគមនាគមន៍ចាំបាច់ត្រូវឆ្លងការពិនិត្យពីតុលាការឬស្ថាប័នឯករាជ្យឡើយ។ ពាក្យថា "ទិន្នន័យសេវា" មិនត្រូវបានកំណត់នៅក្នុងច្បាប់ទេហើយអាចត្រូវបានបកស្រាយគ្រប់ប្រព័ន្ធបញ្ចូលការកំណត់ត្រាទំនាក់ទំនងអ្នកប្រើទាំងអស់ ប្រវត្តិស្វែងរក និងព័ត៌មានសម្ងាត់ផ្សេងទៀត។ ហើយនេះរំលោភលើមាត្រា៤០ នៃរដ្ឋធម្មនុញ្ញដែលធានានូវសិទ្ធិរក្សាការសម្ងាត់។ មាត្រា៩៧ ច្បាប់ស្តីពីទូរគមនាគមន៍ចែងអំពីការលួចស្តាប់ ថតសម្លេងការសន្ទនាបានលុះត្រាតែមានការអនុញ្ញាតពី"អាជ្ញាធរជម្មានុរូប" ហើយការផ្សព្វផ្សាយពីកិច្ចសន្ទនាទាំងនោះក៏ចាំបាច់មានត្រូវមានការអនុញ្ញាតពី"អាជ្ញាធរជម្មានុរូប"។ បទបញ្ញត្តិទាំងនេះមានលក្ខណៈទូលាយងាយស្រួលក្នុងការបំពានព្រោះពួកគេអនុញ្ញាតឱ្យមានការឃ្លាំមើលដោយគ្មានគណនេយ្យភាពសាធារណៈឬការការពារសុវត្ថិភាព។ ស្រដៀងគ្នានេះច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយឆ្នាំ២០១០ បានផ្តល់អំណាចដល់អង្គភាពដោយមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់តុលាការ។[217] មាត្រាទី២៧ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយត្រូវបានអនុញ្ញាតឱ្យ "ឃ្លាំមើល ត្រួតត្រា ស្តាប់សម្លេង ថតចម្លងនិងថតរូបនិងថតសម្លេងទូរស័ព្ទ" ដែលមានព័ត៌មានច្បាស់លាស់នៃអំពើពុករលួយ។ ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សាយតាមគេហទំព័រនិងបណ្តាញសង្គមបានបរាជ័យនៅក្នុងសូចនាករនេះដោយសារការបង្កើត" ក្រុមការងារតាមដាន" រួមគ្នាជាមួយតំណាងក្រសួងដើម្បី "ត្រួតពិនិត្យ" និងចាត់វិធានការតាមផ្លូវច្បាប់ប្រឆាំងនឹងការផ្សព្វផ្សាយខុសច្បាប់នៅលើគេហទំព័រនិងប្រព័ន្ធផ្សព្វផ្សាយសង្គម។ មិនមានការនិយាយពីការត្រួតពិនិត្យតាមនីតិវិធីតុលាការឡើយ។[218] |
| ១.៣៥ សិទ្ធិទទួលព័ត៌មានត្រូវបានការពារ និងលើកកម្ពស់ | កម្រិតនៃក្របខណ្ឌច្បាប់ ការពារ និងលើកកម្ពស់សិទ្ធិទទួលបានព័ត៌មាន | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ១ | ១ | ១ | កម្ពុជាបានខកខានក្នុងការបំពេញតាមចំណុចនេះ ពីព្រោះសិទ្ធិទទួលបានព័ត៌មានមិនត្រូវបានការពារដោយច្បាប់ឡើយ។[219] ទោះយ៉ាងណា រដ្ឋាភិបាលត្រូវបានគេរាយការណ៍ថាកំពុងធ្វើការលើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន។ ច្បាប់ជាច្រើនមានឥទ្ធិពលទៅលើសិទ្ធិទទួលបានព័ត៌មានរួមមានច្បាប់ស្តីពីរបបសារព័ត៌មាននិងក្រមព្រហ្មទណ្ឌ។ ច្បាប់ស្តីពីរបបសារព័ត៌មានហាមឃាត់និងផ្តន្ទាទោសការបោះពុម្ពផ្សាយនូវការបញ្ចេញមតិជាច្រើន។ មាត្រា ១២ នៃច្បាប់នេះបង្កើតឱ្យមានការរឹតត្បិតលើរាល់ព័ត៌មានដែលអាចប៉ះពាល់ដល់សន្តិសុខជាតិនិងស្ថេរភាពនយោបាយ តែមិនតម្រូវថាទាល់តែមានទំនាក់ទំនងរវាងការបោះពុម្ពផ្សាយនិងហានិភ័យនៃគ្រោះថ្នាក់ឡើយ។ នេះបង្ហាញពីបរាជ័យក្នុងការការពារសិទ្ធិទទួលព័ត៌មាន។ បទល្មើសនៃការ" ក្លែងព័ត៌មាន" ក្រោមមាត្រា ៤២៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាបានដាក់ជាបទល្មើសព្រហ្មទណ្ឌនូវអំពើដែលផ្តល់ឬបើកកកាយព័ត៌មានក្លែងដើម្បីធ្វើឱ្យជឿថា នឹងកើតមានឡើងនូវការបំផ្លិចបំផ្លាញ ការធ្វើឱ្យខូចខាត ប្រកបដោយគ្រោះថ្នាក់ចំពោះមនុស្ស។ ការប្រើប្រាស់ពាក្យដែលមានន័យទូលំទូលាយមិនច្បាស់លាស់ នៃបទល្មើសបែបនេះបណ្តាលឱ្យមានការអនុវត្តច្របូកច្របល់ ដល់ការបញ្ចេញមតិដែលមិនមែនក្លែងក្លាយ ឬ ព័ត៌មានដែលជាមតិយោបល់។ នេះនឹងបង្កើនវិសាលភាពច្បាប់លើសពីកម្រិតនៃការរឹតត្បិតលើសេរីភាពនៃការបញ្ចេញមតិដែលត្រូវបានអនុញ្ញាត។ បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ ឆ្នាំទៅ ២ ឆ្នាំនិងពិន័យជាប្រាក់ពី ២ ទៅ ៤ លានរៀល។ ការពិន័យនេះមើលទៅដូចជាមិនសមាមាត្រចំពោះសកម្មភាពព្រហ្មទណ្ឌទាល់តែសោះ។ |

217 សូមអាន "របាយការណ៍ប្រចាំឆ្នាំលើកទី២ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាពនិងអាយ. ស៊ី .អិន.អិល (ខែកញ្ញា ឆ្នាំ២០១៨) ទំព័រ ៤ ដែលអាចរកបាន៖ https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=128&id=5

218 ប្រកាសអន្តរ ចំណុចទី៤ សូមមើល កាន់ វិច្ឆិកា, 'កម្ពុជាបង្កើតក្រុមការងារតាមដានការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយតាមប្រព័ន្ធផ្សព្វផ្សាយនិងបណ្តាញសង្គម' (វីអូអេ, ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៨), <https://www.voacambodia.com/a/cambodia-forms-task-force-to-monitor-fake-news-on-social-media/4425534.html>

219 ខែមីនា ឆ្នាំ២០១៨ រដ្ឋមន្ត្រីក្រសួងព័ត៌មានបានបញ្ជាក់ថាសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានត្រូវបានដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល។ សូមមើល ខ្មែរថាមស៍ 'ការត្រៀមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន', (ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩) ដោយ តាំងវីដា https://www.khmertimeskh.com/50577422/access-to-information-draft-law-ready/ ។ សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន អាចរកបាននៅ https://www.phnompenhpost.com/Assets/doc/Doc-Jan-31-2018-15-30-en.pdf

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១.៣៦ សិទ្ធិប្រើប្រាស់ អ៊ិនធឺណិតមិនអាចត្រូវបានកាត់ផ្ដាច់តាមអំពើចិត្តនោះទេ | កម្រិតនៃសិទ្ធិប្រើប្រាស់អ៊ីនធើណិត ត្រូវបានធានាដោយច្បាប់ និង ការពារពីការផ្ដាច់តាមអំពើចិត្ត | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៣ | ៣ | ៣ | កម្ពុជាបានខកខានក្នុងការបំពេញតាមចំណុចនេះ។ ខណៈដែលគ្មានបទប្បញ្ញត្តិផ្ដល់អំណាចដល់រដ្ឋាភិបាលអាចបិទប្រព័ន្ធអ៊ិនធើណិត មាត្រា ៧នៃច្បាប់ស្ដីពីទូរគមនាគមន៍អាចនាំឱ្យមានការប្រើប្រាស់អ៊ិនធើណិតតាមអំពើចិត្ត។ មាត្រា៧ នៃច្បាប់ស្ដីពីទូរគមនាគមន៍ចែងថា "ក្នុងករណីដែលមានភាពមិនប្រក្រតីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ឬក្រសួងឬស្ថាប័នដែលមានសមត្ថកិច្ចអាចបញ្ជាឱ្យប្រតិបត្តិករទូរគមនាគមន៍ពាក់ព័ន្ធចាត់វិធានការចាំបាច់ដោយផ្អែកលើការសម្រេចរបស់រាជរដ្ឋាភិបាល" ។ បន្ថែមពីនេះក៏បានផ្ដល់ឱ្យក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ក្រោមមាត្រា២៤ ដែលចែងថា "រចនាសម្ព័ន្ធទូរគមនាគមន៍និងបណ្ដាញទូរគមនាគមន៍និងរចនាសម្ព័ន្ធគាំទ្រដល់ទូរគមនាគមន៍នឹងស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍" ។ ក្រោមបទប្បញ្ញត្តិទាំងនេះរដ្ឋាភិបាលទំនងជាទទួលបានការត្រួតពិនិត្យគ្រប់ឧស្សាហកម្មទូរគមនាគមន៍រួមមានសកម្មភាពនិងហេដ្ឋារចនាសម្ព័ន្ធ។ ក្រុមការងារពិសេសដែលបង្កើតឡើងដោយប្រកាសអន្តរក្រសួងក៏មានអំណាចផ្ដាច់សេវាប្រព័ន្ធអ៊ិនធឺណេតដោយមិនចាំបាច់មានការត្រួតពិនិត្យពីតុលាការដើម្បីទប់ស្កាត់ការអនុវត្តន៍តាមអំពើចិត្តឡើយ។[220] |
| ចំណុចគន្លឹះទី២៖ ក្របខណ្ឌច្បាប់ជាតិពាក់ព័ន្ធនឹងសេរីភាពខាងសមាគម សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិត្រូវបានអនុវត្តនិងប្រត្តិបត្តិតាមត្រឹមត្រូវឬទេ? | | | | | | | |
| ធាតុផ្សំ | សូចនាករ | ប្រភពទិន្នន័យ | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | កំណត់សម្គាល់ |
| ២.១ រដ្ឋាភិបាល យល់ពីសិទ្ធិ និងកាតព្វកិច្ចទាក់ទិននឹងសេរីភាពខាងការបង្កើតសមាគម ជួបប្រជុំ និង បញ្ចេញមតិ | % នៃការថ្លែងតាមប្រព័ន្ធផ្សព្វផ្សាយបង្ហាញឱ្យឃើញពី ការយល់ដឹងត្រឹមត្រូវអំពីសេរីភាពខាងការបង្កើតសមាគម ជួបប្រជុំ និងបញ្ចេញមតិរបស់តំណាងរដ្ឋាភិបាល | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ៤៨% | ២៣% | ១៥% | ១៤% | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយកត់ត្រា២២ ក្នុងចំណោម១៥៩ នៃការលើកឡើងរបស់មន្ត្រីរដ្ឋាភិបាលបង្ហាញពីការយល់ដឹងលើសេរីភាពមូលដ្ឋាន។ |
| ២.២ រដ្ឋាភិបាល គោរពសិទ្ធិកាតព្វកិច្ច និងការប្រើប្រាស់ សេរីភាពខាងការបង្កើតសមាគម | # ពេលការណ៍នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ដែល បង្ហាញថា រដ្ឋាភិបាល គោរពសិទ្ធិ កាតព្វកិច្ច និងការប្រើប្រាស់ សេរីភាពខាងការបង្កើតសមាគម | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ២០២ | ៣៣ | ៣៣ | ៣ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយកត់ត្រា ៣ ករណីនៃការលើកឡើងរបស់មន្ត្រីរដ្ឋាភិបាលបង្ហាញពីការយល់ដឹងមិនត្រឹមត្រូវមកលើសេរីភាពខាងសមាគម។ |
| | # ចំនួនហេតុការណ៍ ដែល រដ្ឋាភិបាល រំលោភលើសេរីភាព ខាងការបង្កើតសមាគម | ការរាយការណ៍ពីហេតុការណ៍ | ១១៤ | ២២០ | ១០១ | ៤៨ | ការរាយការណ៍ពីហេតុការណ៍កត់ត្រាចំនួន៤៨ ករណីដែលរដ្ឋាភិបាលរំលោភបំពានសេរីភាពខាងសមាគម។ |

220 ប្រកាសអន្តរក្រសួងស្ដីពីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្ដាញទំនាក់ទំនងសង្គម ប្រការ ៤

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២.៣ ការចុះបញ្ជីសមាគមត្រូវបានអនុវត្តដោយយុត្តិធម៌ និងតម្លាភាព | កម្រិតនៃ ដំណើរការចុះបញ្ជីសមាគម ត្រូវបានអនុវត្តដោយយុត្តិធម៌ និងតម្លាភាព | ការវាយតម្លៃពីនីតិវិធីចុះបញ្ជីអង្គការសមាគម | មិនមានចម្លើយ | ១ | ១ | មិនមានចម្លើយ | មិនមានព័ត៌មានពាក់ព័ន្ធដែលគម្រោងទទួលបាន។ |
| ២.៤ មានសមាគមច្រើនដែល គោលបំណងស្រដៀងគ្នា | # ពាក្យស្នើសុំចុះបញ្ជីត្រូវបានបដិសេធ ដោយសារតែមានសមាគមច្រើន ដែលមានគោលបំណងស្រដៀងគ្នា | ការរាយការណ៍ពីហេតុការណ៍ | ០ | ១ | ០ | ០ | ការរាយការណ៍ពីហេតុការណ៍គ្មានករណីការបដិសេធពីការចុះបញ្ជីដោយសារតែមានសមាគមច្រើនមានគោលបំណងស្រដៀងគ្នា។ |
| | | ការវាយតម្លៃពីនីតិវិធីចុះបញ្ជីអង្គការសមាគម | មិនមានចម្លើយ | ០ | ០ | | ការវាយតម្លៃពីនីតិវិធីចុះបញ្ជីអង្គការសមាគមមិនបានកត់ត្រាការបដិសេធការចុះបញ្ជីដោយសារមូលហេតុបែបនេះ។ |
| ២.៥ សមាគមអាចបង្កើតបណ្តាញ សម្ព័ន្ធ សហព័ន្ធ ឬប្រភេទផ្សេងទៀតនៃសហជីព ដោយសេរី | %នៃថ្នាក់ដឹកនាំសមាគមដែលរាយការណ៍ អំពីការជ្រៀតជ្រែក មកលើគោលបំណង បង្កើតបណ្តាញ សម្ព័ន្ធ សហព័ន្ធ ឬប្រភេទផ្សេងទៀតនៃសហជីព | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | មិនមានចម្លើយ | ៣៨% | ៤៤% | ៤១% | សូមមើលសំណួរ៤.១ នៃការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល។ |
| | # ហេតុការណ៍ ដែលមានការ ជ្រៀតជ្រែកមកលើ គោល បំណង សមាគមក្នុងការបង្កើតបណ្តាញ សម្ព័ន្ធ សហព័ន្ធ ឬប្រភេទផ្សេងទៀតនៃសហជីព | ការរាយការណ៍ពីហេតុការណ៍ | ០ | ១៤ | ០ | ៣ | ការរាយការណ៍ពីហេតុការណ៍កត់ត្រាចំនួន៣ ករណី ដែលមានការជ្រៀតជ្រែកមកលើគោលបំណងសមាគមក្នុងការបង្កើតបណ្តាញសម្ព័ន្ធ សហព័ន្ធ ឬប្រភេទផ្សេងទៀតនៃសហជីព។ |
| ២.៦ សមាគមដំណើរការដោយពុំមានការជ្រៀតជ្រែក ពីរដ្ឋាភិបាល | % នៃថ្នាក់ដឹកនាំសមាគមដែលរាយការណ៍ អំពីការជ្រៀតជ្រែកពីរដ្ឋាភិបាល | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | មិនមានចម្លើយ | ៧៦% | ៧៤% | ៧៤% | សូមមើលសំណួរ៤.៥ នៃការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល។ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | # ហេតុការណ៍ដែលរដ្ឋាភិបាលជ្រៀតជ្រែក មកលើសមាគម រំលោភលើបទដ្ឋានអន្តរជាតិ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ១៨៨ | ១៨៤ | ៤៣ | ១០៤ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយកត់ត្រា ១០៤ករណីដែលរដ្ឋាភិបាលជ្រៀតជ្រែកមកលើសមាគមរំលោភលើបទដ្ឋានអន្តរជាតិ។ |
| ២.៧ បុគ្គលពុំបានក្លាយជាគោលដៅដោយសារតែការចូលរួមជាមួយសមាគមនោះទេ | %នៃថ្នាក់ដឹកនាំសមាគមដែលរាយការណ៍អំពីការក្លាយជាជនរងគ្រោះ ដោយសារតែការចូលរួមជាមួយសមាគម | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ៣% | ៣៥% | ៣៦% | ៣០% | សូមមើលសំណួរ៥.៦ នៃការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល។ |
| | %នៃបុគ្គលដែលរាយការណ៍អំពីការក្លាយជាជនរងគ្រោះដោយសារតែការចូលរួមជាមួយសមាគម | ការស្ទង់មតិជាសាធារណៈ | មិនមានចម្លើយ | ១៤% | ១៩% | ២៥% | សូមមើលសំណួរ៣.៣ នៃការស្ទង់មតិជាសាធារណៈ។ |
| ២.៨ សមាគមត្រូវបានការពារពីការជ្រៀតជ្រែករបស់ភាគីទីបី | %នៃថ្នាក់ដឹកនាំសមាគមដែលរាយការណ៍អំពីការជ្រៀតជ្រែកពីភាគីទីបី | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ២៣% | ២៥% | ១៧% | ១៤% | សូមមើលសំណួរ៤.៧ នៃការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល។ |
| | ចំនួនហេតុការណ៍នៃការជ្រៀតជ្រែកពីភាគីទីបី | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ២៤ | ៣៥ | ១០ | ១៥ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយកត់ត្រា ១២ ករណីដែលថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលរាយការណ៍ថាមានការជ្រៀតជ្រែកមកលើសមាគមរបស់ពួកគេដោយជនទី៣។ |
| | | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ៨ | ១៤ | ១២ | ការរាយការណ៍ពីហេតុការណ៍កត់ត្រាចំនួន ១៥ ករណីដែលថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលរាយការណ៍ថាមានការជ្រៀតជ្រែកមកលើសមាគមរបស់ពួកគេដោយជនទី៣។ |
| ២.៩ សមាគមមិនប្រឈមនឹងលក្ខខណ្ឌតម្រូវធ្វើរបាយការណ៍ដែលជាបន្ទុក និងស្មុគស្មាញ | %នៃថ្នាក់ដឹកនាំសមាគមដែលរាយការណ៍ថាត្រូវប្រឈមនឹងការធ្វើរបាយការណ៍ច្រើនលើសលុប | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | មិនមានចម្លើយ | ៦០% | ៥៨% | ៦០% | សូមមើលសំណួរ៤.១២ នៃការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល។ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២.១០ ការដាក់ទណ្ឌកម្មលើសមាគមត្រូវបានអនុវត្តស្របតាមច្បាប់របស់កម្ពុជា | %នៃថ្នាក់ដឹកនាំសមាគម ដឹងអំពីសិទ្ធិ របស់ពួកគេ ហើយរាយការណ៍ថា ការ ដាក់ទោសមិនគោរពតាម ច្បាប់ | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ១០០% | ១០០% | ១០០% | ១០០% | សូមមើលសំណួរ៤.១៨ នៃការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល។ |
| | # ហេតុការណ៍ ដែលការដាក់ ទោសដោយពុំបានអនុវត្ត ស្របទៅតាមច្បាប់ | ការតាមដានប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | ១២ | ១ | ០ | មិនមានហេតុការណ៍ត្រូវបានកត់ត្រាក្នុងការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយដែលការដាក់ទោសដោយពុំបានអនុវត្តស្របទៅតាមច្បាប់។ |
| | | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ៣ | ០ | ០ | មិនមានហេតុការណ៍ត្រូវបានកត់ត្រាក្នុងការរាយការណ៍ពីហេតុការណ៍ដែលការដាក់ទោសដោយពុំបានអនុវត្តស្របទៅតាមច្បាប់។ |
| ២.១១ សមាគមបានឧបាស្រ័យ ប្រសិនបើពួកគេត្រូវបានដាក់ទោស | %នៃថ្នាក់ដឹកនាំសមាគមដែល រាយការណ៍ ថាបានឧបាស្រ័យ ករណីមានការដាក់ទោស | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ៥០% | ៤២% | ៩% | ៣២% | សូមមើលសំណួរ៤.១៩ នៃការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល។ ចំនួនឆ្លើយតបតិចតួចបង្ហាញពីភាពប្រសើរឡើងពីមួយឆ្នាំទីមួយឆ្នាំ។ |
| | #ថ្នាក់ដឹកនាំសមាគមដែល រាយការណ៍ថាបានឧបាស្រ័យ ករណីមានការដាក់ទោស | ការរាយការណ៍ពីហេតុការណ៍ | ០ | ០ | ១ | ០ | មិនមានហេតុការណ៍ត្រូវបានកត់ត្រាក្នុងការរាយការណ៍ពីហេតុការណ៍ដែលថ្នាក់ដឹកនាំសមាគមដែលរាយការណ៍ថាបានឧបាស្រ័យករណីមានការដាក់ទោស។ |
| ២.១២ ការរំលាយសមាគមធ្វើបានក្រោយពេលមធ្យោបាយផ្លូវច្បាប់ត្រូវបានប្រើប្រាស់និងបង្ហាញថាអាចនឹងមានគ្រោះថ្នាក់ | ចំនួននៃការរំលាយសមាគម ដោយបង្ខំ | ការរាយការណ៍ពីហេតុការណ៍ | ០ | ០ | ០ | ០ | មិនមានហេតុការណ៍ត្រូវបានកត់ត្រាក្នុងការរាយការណ៍ពីហេតុការណ៍ដែលមានការរំលាយសមាគមដោយបង្ខំ។ |
| | # រំលាយកើត មុនពេលដែល មធ្យោបាយច្បាប់បានប្រើអស់ លទ្ធភាព& ពុំមានគ្រោះថ្នាក់ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ០ | ០ | ០ | មិនមានហេតុការណ៍ត្រូវបានកត់ត្រាក្នុងការរាយការណ៍ពីហេតុការណ៍ដែលការរំលាយកើតឡើងមុនពេលដែល មធ្យោបាយច្បាប់បានប្រើអស់លទ្ធភាព& ពុំមានគ្រោះថ្នាក់។ |
| ២.១៣ សមាគមមិនត្រូវបានរឹតត្បិតមិនឱ្យធ្វើសកម្មភាពសេដ្ឋកិច្ចឡើយ | %នៃថ្នាក់ដឹកនាំសមាគមរាយការណ៍ ថាសមាគមត្រូវបានរឹតត្បិតក្នុងការ សកម្មភាពសេដ្ឋកិច្ច | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ៤% | ៧% | ៣% | ៤% | សូមមើលសំណួរ៤.២២ នៃការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល។ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២.១៤ សមាគមមិនត្រូវបានរឹតត្បិតក្នុងការទទួលបានមូលនិធិ | %នៃថ្នាក់ដឹកនាំសមាគមដែលរាយការណ៍ថាសមាគមមិនត្រូវបានរឹតត្បិតក្នុងការទទួលបានមូលនិធិ | | មិនមានចម្លើយ | ៨៣% | ៧២% | ៧៩% | សូមមើលសំណួរ៤.២៤ និង ៤.២៦ នៃការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល។ មូលនិធិក្នុងស្រុក ៧៧%,មូលនិធិបរទេស ៨១%។ |
| ២.១៥ សមាគមពុំប្រឈមនឹងនីតិវិធីស្មុគស្មាញក្នុងការទទួលបានមូលនិធិ | %នៃថ្នាក់ដឹកនាំសមាគមពុំប្រឈម នឹងនីតិវិធីស្មុគស្មាញដើម្បីទទួលបានមូលនិធិ | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | 0% | 0% | 0% | 0% | សូមមើលសំណួរ៤.២៥ និង ៤.២៧ នៃការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល។ |
| ២.១៦ សមាគមពុំតម្រូវឱ្យ បំពេញតាមលក្ខខណ្ឌរបាយការណ៍ហិរញ្ញវត្ថុដ៏ច្រើនលើសលុបនោះទេ | %នៃថ្នាក់ដឹកនាំសមាគមដែលរាយការណ៍សមាគមត្រូវផ្ញើរបាយការណ៍ហិរញ្ញវត្ថុលើសលុប | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | មិនមានចម្លើយ | ៦០% | ៥៨% | ៦០% | សូមមើលសំណួរ៤.១២ នៃការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល។ |
| | %នៃថ្នាក់ដឹកនាំសមាគម ដែល មិនអាចបំពេញ របាយការណ៍ហិរញ្ញវត្ថុ | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ៦២% | ៣៦% | ១៦% | ១៩% | សូមមើលសំណួរ៤.១០ នៃការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល។ |
| ២.១៧ អាជ្ញាធរដែលរំលោភ លើសេរីភាពខាងការបង្កើតសមាគម និងសិទ្ធិពាក់ព័ន្ធទទួលខុសត្រូវចំពោះមុខស្ថាប័នឯករាជ្យ និង/ឬតុលាការ | #ករណីដែល ការរំលោភលើសេរីភាពខាងការបង្កើតសមាគមត្រូវបានដោះស្រាយដោយស្ថាប័នឯករាជ្យ និង/ឬតុលាការ | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ៧០% | ១៨% | 0% | ១៥% | សូមមើលសំណួរ៤.២១ នៃការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល។ ចំនួនឆ្លើយតបតិចតួចចំពោះសំណួរនេះមានន័យថាមានភាពប្រសើរឡើងពី១ឆ្នាំទៅ១ឆ្នាំ។ |
| | | ការរាយការណ៍ពីហេតុការណ៍ | 0 | 0 | 0 | 0 | មិនមានហេតុការណ៍ត្រូវបានកត់ត្រាក្នុងការរាយការណ៍ពីហេតុការណ៍ដែលមានការរំលោភបំពានសេរីភាពខាងសមាគមត្រូវបានដោះស្រាយដោយស្ថាប័នឯករាជ្យនិងឬតុលាការ។ |
| ២.១៨ រដ្ឋាភិបាល ចាត់វិធានការ គោរព និងលើកកម្ពស់សេរីភាពខាងការបង្កើតសមាគមរបស់ក្រុមងាយរងគ្រោះ | #ករណីផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ អំពីសេរីភាពខាងការបង្កើតនៃក្រុមងាយរងគ្រោះ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | ២ | ២ | ៨ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយកត់ត្រា ៨ ករណីដែលរដ្ឋាភិបាលបានលើកកម្ពស់សេរីភាពខាងសមាគមរបស់ក្រុមងាយរងគ្រោះ។ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | #ករណីដែលរដ្ឋាភិបាលមានការរើសអើងមកលើក្រុមងាយរងគ្រោះ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ២០ | ១០ | ៣ | ០ | មិនមានហេតុការណ៍ក្នុងការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រាករណីដែលរដ្ឋាភិបាលរើសអើងមកលើក្រុមងាយរងគ្រោះ។ |
| | | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ៤ | ០ | ១ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា ១ ករណីដែលរដ្ឋាភិបាលរើសអើងមកលើក្រុមងាយរងគ្រោះ។ |
| ២.១៩ ច្បាប់ និងបទប្បញ្ញត្តិដែលប៉ះពាល់លើ សេរីភាពខាងការបង្កើតសមាគម ត្រូវបានបង្ហាញដល់សាធារណជន | %នៃច្បាប់ និងបទប្បញ្ញត្តិ ដែលប៉ះពាល់សេរីភាពខាងការបង្កើតសមាគមត្រូវបានបោះពុម្ពផ្សាយនៅលើសៀវភៅរាជកិច្ច | ការពិនិត្យនិងសិក្សាឡើងវិញសៀវភៅរាជកិច្ច | មិនមានចម្លើយ | ០ | ០ | ១០០% | វិសោធនកម្មច្បាប់ស្តីពីសហជីពប្រកាសឱ្យប្រើក្នុងឆ្នាំទី៤នេះបានផ្សព្វផ្សាយនៅក្នុងសៀវភៅរាជកិច្ច។ អាចរកបានតាមរយៈ https://www.ocm.gov.kh/wp-content/uploads/2020/03/11-2020.pdf |
| សេរីភាពខាងការជួបប្រជុំ | | | | | | | |
| ២.២០ តំណាងសមាគមបុគ្គល ឬតាមរយៈស្ថាប័នរបស់ខ្លួននោះ អាចប្រើប្រាស់សេរីភាពខាងការជួបប្រជុំដោយសន្តិវិធីបាន | %នៃថ្នាក់ដឹកនាំសមាគមដែលអាចប្រើប្រាស់ដោយសេរីនូវសេរីភាពខាងការប្រមូលផ្តុំដោយសន្តិវិធី | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ១៩% | ១០% | ៤% | ៧% | សូមមើលសំណួរ៤.១០ នៃការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល។ |
| | #ហេតុការណ៍ដែលរឹតត្បិតលើសេរីភាពខាងការជួបប្រជុំ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ៤៥ | ៧៥ | ៥ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា ៥ ករណីដែលរដ្ឋាភិបាលរឹតត្បិតមកលើសេរីភាពខាងការជួបប្រជុំ។ |
| | %នៃការប្រមូលផ្តុំដែលប្រឈមនឹងការជៀតជ្រែក ត្រូវបានរាយការណ៍នៅក្នុងបណ្តាញផ្សព្វផ្សាយ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | ៦% | ៩% | ១០% | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយកត់ត្រា ១៨ ករណីក្នុងចំណោមការជួបប្រជុំសរុប ១៧៩ ករណីមានការជៀតជ្រែកពីរដ្ឋាភិបាល។ |
| ២.២១ ក្រុមនានាអាចប្រមូលផ្តុំដោយពុំចាំបាច់សុំ ឬទទួលការអនុញ្ញាតពីអាជ្ញាធរជាមុនឡើយ | #នៃការប្រមូលផ្តុំដែលត្រូវបានរឹតត្បិត ឬហាមឃាត់ ដោយសារតែពុំមានការអនុញ្ញាតមុន | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | ៧ | ៦ | ០ | មិនមានហេតុការណ៍ក្នុងការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រាករណីការប្រមូលផ្តុំដែលត្រូវបានរឹតត្បិត ឬហាមឃាត់ ដោយសារតែពុំមានការអនុញ្ញាតមុន។ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ២ | ១០ | ០ | មិនមានហេតុការណ៍ត្រូវបានកត់ត្រាក្នុងការរាយការណ៍ពីហេតុការណ៍ករណីការប្រមូលផ្តុំដែលត្រូវបានរឹតត្បិត ឬហាមឃាត់ ដោយសារតែពុំមានការអនុញ្ញាតមុន។ |
| | #ការប្រមូលផ្តុំដែលត្រូវបានជ្រៀតជ្រែកដោយសារតែពុំមានការអនុញ្ញាតមុន | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | ៦ | ១៦ | ០ | មិនមានហេតុការណ៍ក្នុងការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រាករណីការប្រមូលផ្តុំដែលត្រូវបានជ្រៀតជ្រែកដោយសារតែពុំមានការអនុញ្ញាតជាមុន។ |
| | | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ៩ | ៥ | ០ | មិនមានហេតុការណ៍ក្នុងការរាយការណ៍ពីហេតុការណ៍បានកត់ត្រាករណីការប្រមូលផ្តុំដែលត្រូវបានជ្រៀតជ្រែកដោយសារតែពុំមានការអនុញ្ញាតជាមុន។ |
| ២.២២ ការហាមឃាត់ការប្រមូលផ្តុំ គឺជាវិធានការជម្រើសចុងក្រោយក្នុងករណីចាំបាច់ និងសមស្របទៅតាមគោលបំណងដែលចង់បាន | %នៃគម្រោងប្រមូលផ្តុំត្រូវបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយដែលត្រូវបានហាមឃាត់ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | ៣% | ៣% | ២% | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយកត់ត្រា ៤ ករណីនៃគម្រោងការជួបប្រជុំក្នុងចំណោមការជួបប្រជុំសរុប ១៧៧ ករណីត្រូវបានហាមឃាត់។ |
